គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

ក្រមក្រមសេចក្តីសម្រេច មានលក្ខណៈបទបញ្ជារបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

រួមគ្នាដើម្បីឧត្តមភាពនិងឥតខ្ចោះនៃវិជ្ជាជីវៈមេធាវី
អាសយដ្ឋាន៖ អគារកៅច់ជ្រុងផ្លូវ១១២៩ និងផ្លូវ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ ០២៣ ៦២២ ៧០ ៧០
អ៊ីមែល info@bakc.org.kh

កម្រងសេចក្តីសម្រេច
មានលក្ខណៈបច្ចេក
របស់គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា

អារម្ភកថា

សៀវភៅ **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ ចងក្រងសេចក្តីសម្រេចនិងសេចក្តីណែនាំរបស់គណៈមេធាវីនៅជាធរមានទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងវិជ្ជាជីវៈមេធាវីនិងវិធានដែលមានលក្ខណៈបទបញ្ជាសម្រាប់មេធាវីអនុវត្ត យកមកបោះពុម្ពផ្សាយក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលដល់សហភាគានិងអ្នកស្រាវជ្រាវ ក្នុងការស្វែងរកសេចក្តីសម្រេចនិងសេចក្តីណែនាំដែលមានលក្ខណៈជាបទបញ្ជារបស់គណៈមេធាវី និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចនិងសេចក្តីណែនាំរបស់គណៈមេធាវី។ នេះជាលើកទី១ដែលគណៈមេធាវីធ្វើការចងក្រងនូវសេចក្តីសម្រេចនិងសេចក្តីណែនាំរបស់គណៈមេធាវីនិងបានយកមកបោះពុម្ពផ្សាយជាផ្លូវការ។

សៀវភៅ **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ បែងចែកជា៤ផ្នែកគឺ ផ្នែកទី១ ចងក្រងនូវសេចក្តីសម្រេចរបស់គណៈមេធាវីពាក់ព័ន្ធនឹងការគ្រប់គ្រងវិជ្ជាជីវៈមេធាវី ផ្នែកទី២ ចងក្រងនូវសេចក្តីសម្រេចនិងសេចក្តីណែនាំពាក់ព័ន្ធនឹងវិធានសម្រាប់មេធាវីអនុវត្ត ផ្នែកទី៣ ចងក្រងនូវសេចក្តីសម្រេចពាក់ព័ន្ធនឹងការលើកទឹកចិត្តមេធាវី និងផ្នែកទី៤ ចងក្រងនូវសេចក្តីសម្រេចសម្រាប់សិស្សមេធាវីអនុវត្ត។ ដើម្បីសម្រួលដល់ការរក្សាទុកក្នុងទម្រង់ជា PDF ឬផលិតចេញ សហភាគាអាចទាញយកសៀវភៅ **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ ចេញពីគេហទំព័ររបស់គណៈមេធាវី www.bakc.org.kh។

ចាប់តាំងពីវិជ្ជាជីវៈមេធាវីនិងគណៈមេធាវីបានបង្កើតឡើងនៅឆ្នាំ១៩៩៥ រហូតមកដល់បច្ចុប្បន្ន ដើម្បីគ្រប់គ្រងវិជ្ជាជីវៈមេធាវីនេះឱ្យមានការរីកចម្រើន ប្រសិទ្ធភាព និងមានកិត្យានុភាព គណៈមេធាវីបានចេញសេចក្តីសម្រេចជាច្រើនអនេក ទាំងសេចក្តីសម្រេចដែលមានលក្ខណៈបទបញ្ជា ទាំងសេចក្តីសម្រេចជាឯកត្តភូត ហើយមានសេចក្តីសម្រេចមួយចំនួនបានធ្វើការកែសម្រួលខ្លះៗឬទាំងស្រុង។ ដោយឡែក **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ មិនបានចងក្រងសេចក្តីសម្រេចដែលបាននិរាករណ៍រួចហើយនិងសេចក្តីសម្រេចជាឯកត្តភូតឡើយ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះការខិតខំលះបង់កម្លាំងកាយកម្លាំងចិត្ត និងប្រាជ្ញាស្មារតីរបស់អតីតប្រធានគណៈមេធាវីគ្រប់ៗរូបនិងសមាជិកក្រុមប្រឹក្សាគណៈមេធាវីគ្រប់អាណត្តិដែលបានលះបង់ដើម្បីធ្វើឱ្យវិជ្ជាជីវៈមេធាវីមានវឌ្ឍនភាពនិងកិត្យានុភាពដល់បច្ចុប្បន្ន។ ទន្ទឹមនឹងនេះខ្ញុំក៏សូមថ្លែងអំណរគុណដល់សហភាគាទាំងអស់ដែលបានចូលរួមលើកស្ទួយតម្លៃវិជ្ជាជីវៈមេធាវី តាមរយៈការចូលរួមអនុវត្តវិធានវិជ្ជាជីវៈមេធាវីដែលក្នុងនោះរួមមានទាំងសេចក្តីសម្រេចនានារបស់គណៈមេធាវីឱ្យមានប្រសិទ្ធភាព។ ការគោរពអនុវត្តសេចក្តីសម្រេចរបស់គណៈមេធាវីឱ្យមានប្រសិទ្ធភាព គឺជាសរសេរស្តម្ភមួយសម្រាប់លើកកម្ពស់ឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី។

ខ្ញុំសូមជម្រាបជូនសហភាគាជ្រាបថា ក្រៅពីសៀវភៅ **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ គណៈមេធាវីក៏បានចងក្រងនិងបោះពុម្ពនូវសៀវភៅ **"កម្រងវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា"** ដែលក្នុងនោះមានច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងប្រការមួយចំនួនដែលបានធ្វើការកែសម្រួលកន្លងមក និងក្រមសីលធម៌មេធាវី ហើយក៏មានបញ្ចូលនូវព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃ៣ ខែម៉ារ្ស ឆ្នាំ១៩៣២ ស្តីពីថណាយកែសេចក្តីក្នុងតុលាការខ្មែរ ព្រះរាជប្រកាសលេខ១៤ ចុះថ្ងៃ១ ខែហ្វេវរីយេរ ឆ្នាំ១៩៣៣ ស្តីពីអ្នកថណាយក្តីត្រូវឱ្យមានសំលៀកបំពាក់ និងព្រះរាជក្រមលេខ៦៤៨ ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៥១ ស្តីពីវិជ្ជាជីវៈស្មាក្តី បានធ្វើការកែសម្រួលព្រះរាជប្រកាសលេខ៣២ ស្តីពីថណាយកែសេចក្តីក្នុងតុលាការខ្មែរ ដើម្បីទុកជាមូលដ្ឋាននៃការស្រាវជ្រាវនិងស្វែងយល់អំពីការកកើតវិជ្ជាជីវៈមេធាវីនៅព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសង្ឃឹមថា ក្រោយទទួលបានសៀវភៅ **"កម្រងសេចក្តីសម្រេចមានលក្ខណៈបទបញ្ជារបស់គណៈមេធាវី"** នេះ សហភាគានឹងអានហើយចូលរួមគោរពអនុវត្តតាមសេចក្តីសម្រេចទាំងនេះ ដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវីយើង ព្រមទាំងចូលរួមជាមតិយោបល់សម្រាប់ធ្វើការកែសម្រួលលើវិធាននៃវិជ្ជាជីវៈមេធាវី ដើម្បីវឌ្ឍនភាពនៃវិជ្ជាជីវៈមេធាវីនិងប្រសិទ្ធភាពក្នុងការគ្រប់គ្រងវិជ្ជាជីវៈមេធាវីនិងការដឹកនាំគណៈមេធាវី។

ជាចុងបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនសហភាគាទាំងអស់ សូមទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើននិងជោគជ័យគ្រប់ភារកិច្ច៕

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

លី ច័ន្ទតុលា
ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

មាតិកា

ក. សេចក្តីសម្រេចពាក់ព័ន្ធនឹងការត្រួតត្រាវិជ្ជាជីវៈមេធាវី

1. សេចក្តីសម្រេចលេខ ១០១៣/សសគម/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
2. សេចក្តីសម្រេចលេខ ៦៨៣/គមប្រយ/១៨ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីគោលនយោបាយហិរញ្ញវត្ថុក្នុងគណៈមេធាវី
3. សេចក្តីសម្រេចលេខ ១៥៧/សសគម/១៩ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងនិងសម្របសម្រួលថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្តសម្រាប់អនុវត្តគម្រោងការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សានិងផ្តល់ការអប់រំផ្នែកច្បាប់
4. សេចក្តីសម្រេចលេខ ២៣៧/សសគម/២០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ស្តីពីគោលនយោបាយបុគ្គលិកគណៈមេធាវី
5. សេចក្តីសម្រេចលេខ ០៩៨/សសគម/២១ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីគោលនយោបាយស្តីពីការពិគ្រោះយោបល់ និងការការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ
6. សេចក្តីសម្រេចលេខ ១០៤/សសគម/២១ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន
7. សេចក្តីសម្រេចលេខ ២៣៦/សសគម/២០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការប្រើត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី
8. សេចក្តីសម្រេចលេខ ២៨៥/សសគម/២១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការរបស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
9. សេចក្តីសម្រេចលេខ ៤២៨/សសគម/២៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចម្ងល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)"
10. សេចក្តីសម្រេចលេខ ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចុលប្រកបវិជ្ជាជីវៈមេធាវី
11. សេចក្តីសម្រេចលេខ ៣៤៤/សសគម/២១ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ស្តីពីបែបបទនៃការប្រឡងវិញ្ញាសារសេរសម្រាប់បេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

12. សេចក្តីសម្រេចលេខ ៤៥២/សសគម/២១ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងគណៈមេប្រយោគសម្រាប់ការប្រឡងវិញ្ញាសាសរសេរសម្រាប់បេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
13. សេចក្តីសម្រេចលេខ ៦២៤/សសគម/២១ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការកំណត់ថ្លៃពាក្យសុំ និងថ្លៃដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី
14. សេចក្តីសម្រេចលេខ ៨០៨/សសគម/២១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារកែសម្រួលវិធានស្តីពីគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី
15. សេចក្តីសម្រេចលេខ ៨០៩/សសគម/២១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី
16. សេចក្តីសម្រេចលេខ ៤៦៨/សសគម/២០ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១១ ប្រការ២២ និងប្រការ២៣ នៃសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី
17. សេចក្តីសម្រេចលេខ ៥៥៣/សសគម/២១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
18. សេចក្តីសម្រេចលេខ ៨១១/សសគម/២១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
19. សេចក្តីសម្រេចលេខ ៥៥៤/សសគម/២១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារសិក្សានិងស្រាវជ្រាវអំពីផ្លូវច្បាប់ពាក់ព័ន្ធនឹងសិទ្ធិរបស់មេធាវីនៅដំណាក់កាលនគរបាលយុត្តិធម៌
20. សេចក្តីសម្រេចលេខ ១០៥០/សសគម/២១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការចាត់តាំងអ្នកសម្រុះសម្រួល
21. សេចក្តីសម្រេចលេខ ១២៦/សសគម/២០ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកំណត់ថ្លៃសេវាបណ្តឹង
22. សេចក្តីសម្រេចលេខ ៤២៣/សសគម/២២ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការជំនាញរបស់គណៈមេធាវី
23. សេចក្តីសម្រេចលេខ ៤២៧/សសគម/២២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបន្ថែមសមាសភាពគណៈកម្មការជំនាញរបស់គណៈមេធាវី
24. សេចក្តីសម្រេចលេខលេខ ៤៦០/សសគម/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការបន្ថែមសមាសភាពគណៈកម្មការជំនាញរបស់គណៈមេធាវី

25. សេចក្តីសម្រេចលេខ ៥០៣/សសគម/១៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
26. សេចក្តីសម្រេចលេខ ៣៨៣/សសគម/២២ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
27. សេចក្តីសម្រេចលេខ ៥៦៧/សសគម/២២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ស្តីពីការបង្កើតអនុគណៈកម្មការកីឡាវាយសីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
28. សេចក្តីសម្រេចលេខ ៦០៩/សសគម/២២ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារចំណុះឱ្យអនុគណៈកម្មការកីឡាវាយសីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

១. សេចក្តីសម្រេចនិងសេចក្តីណែនាំពាក់ព័ន្ធនឹងវិជ្ជាជីវៈសម្រាប់មេធាវីអនុវត្ត

1. សេចក្តីសម្រេចលេខ ៤៣/សសគម/០៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៣ ស្តីពីការដាក់ទណ្ឌកម្មវិន័យលើមេធាវីដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទាន
2. សេចក្តីសម្រេចលេខ ២០/សសគម/០៧ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបញ្ចុះភាគទានប្រចាំត្រីមាស សម្រាប់សមាជិក-សមាជិកាមេធាវី
3. សេចក្តីសម្រេចលេខ ០៣៩/សសគម/០៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ ស្តីពីលក្ខខណ្ឌផ្សព្វផ្សាយព័ត៌មានវិជ្ជាជីវៈមេធាវី និងការប្រើប្រាស់នាមប័ណ្ណមេធាវី
4. សេចក្តីសម្រេចលេខ ០៩២/សសគម/០៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការកំណត់ឱ្យបង់ប្រាក់ចូលមូលនិធិទ្រទ្រង់រដ្ឋបាលគណៈមេធាវីចំពោះមេធាវីសុំនៅក្រៅបញ្ជី
5. សេចក្តីសម្រេចលេខ ០០២/សសគម/១១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ ស្តីពីការលុបឈ្មោះចេញពីបញ្ជីដំពាក់ប្រាក់ភាគទានចំពោះសមាជិក-សមាជិកាគណៈមេធាវីដែលទទួលមរណភាព
6. សេចក្តីសម្រេចលេខ ០៤២/សសគម/១១ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់គ្រូកម្មសិក្សា ក្នុងអំឡុងពេលអន្តរកាលក្រោយការបញ្ចប់កម្មសិក្សារយៈពេល ១២ ខែរបស់កម្មសិក្សាការី
7. សេចក្តីសម្រេចលេខ ០០៦/សសគម/១៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង់ថវិកាសម្រាប់ឧបត្ថម្ភដល់ប្រតិបត្តិការការពារក្តីជូនក្រីក្រ
8. សេចក្តីសម្រេចលេខ ១១៦/សសគម/១៤ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការសម្រេចផ្តល់សិទ្ធិជូនប្រធានគណៈមេធាវី

9. សេចក្តីសម្រេចលេខ ០៣៩/សសគម/១៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី
10. សេចក្តីសម្រេចលេខ ០៤៣/សសគម/១៥ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកំណត់អត្តលេខមេធាវីកម្មសិក្សា
11. សេចក្តីសម្រេចលេខ ០០៤/សសគម/១៦ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស
12. សេចក្តីសម្រេចលេខ ១៥៨/សសគម/១៩ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតម្រូវឱ្យមេធាវីដែលមានបំណងបន្តសុំនៅក្រៅបញ្ជីដាក់ពាក្យសុំនៅក្រៅបញ្ជីបន្តជាថ្មីឡើងវិញ
13. សេចក្តីសម្រេចលេខ ៤៦៧/សសគម/២០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារសិក្សាអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈ
14. សេចក្តីសម្រេចលេខ ៩១៦/សសគម/២០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចបង់ប្រាក់របស់បេក្ខជនដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
15. សេចក្តីសម្រេចលេខ ១០១៤/សសគម/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីនិងការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសម្រាប់មេធាវីបរទេសដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
16. សេចក្តីណែនាំលេខ ១៥៥៥/គ.ម/១៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការប្រកបវិជ្ជាជីវៈមេធាវី
17. សេចក្តីណែនាំលេខ ០៩៧៩/គម/២០ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការបំពេញបេសកកម្មជាអនុតំណាង
18. សេចក្តីណែនាំលេខ ១២៦/គម/២៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ស្តីពីការធ្វើកម្មសិក្សានិងការដាក់របាយការណ៍បញ្ចប់កម្មសិក្សា
19. សេចក្តីណែនាំលេខ ៩៣៩/គម/២៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ស្តីពីជំនួយការមេធាវី
20. សេចក្តីណែនាំលេខ ២៣២៦/គម/២៣ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ស្តីពីកាតព្វកិច្ចផ្តល់ព្រឹត្តបត្រប្តោលទោសដែលមានសុពលភាពនៅពេលដាក់ពាក្យសុំធ្វើកម្មសិក្សា ពាក្យសុំរួចផុតពីកម្មសិក្សា និងរបាយការណ៍បញ្ចប់កម្មសិក្សា

ក. សេចក្តីសម្រេចពាក់ព័ន្ធនឹងការលើកឧត្តមចិត្តមេធាវី

1. សេចក្តីសម្រេចលេខ ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ស្តីពីការកំណត់ប្រភេទអាវវិជ្ជាជីវៈមេធាវី និងអាវសម្រាប់មេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យរបស់គណៈមេធាវី
2. សេចក្តីសម្រេចលេខ ៧២៦/សសគម/២០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីអាវកិត្តិយសរបស់គណៈមេធាវី
3. សេចក្តីសម្រេចលេខ ៥៥៧/សសគម/២២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ ស្តីពីសុខុមាលភាពមេធាវី
4. សេចក្តីសម្រេចលេខ ៨៦១/សសគម/២២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ស្តីពីគ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ឃ. សេចក្តីសម្រេចសម្រាប់សិស្សមេធាវីអនុវត្ត

1. សេចក្តីសម្រេចលេខ ២៣៦/សសគម/១៤ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
2. សេចក្តីសម្រេចលេខ ២៦២/សសគម/១៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តបទវិន័យរបស់សិស្សមេធាវី

សេចក្តីសម្រែចពាក់ព័ន្ធនឹង
ការត្រៀបត្រងវិជ្ជាជីវៈមេធាវី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ធាម
២-មេធាវី ឆេង បុថល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ជ័រ ឡូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ាគន់
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ចំន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំក្រ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ឌួន ជានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ១០១៧ /សសគម/២០

សេចក្តីសម្រេច

ស្តីពី

រចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ ..

សេចក្តីសម្រេចនេះមានគោលបំណងពង្រឹងការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការងាររបស់គណៈមេធាវី តាមរយៈការកំណត់អំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

ប្រការ២ ..

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពចំណុះឱ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី២
រចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវី

ប្រការ៣ ..

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយប្រធានមួយរូបនិងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដឹកនាំដោយនាយកមួយរូបនិងមានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការ ។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូបនិងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

ទីប្រឹក្សានិងជំនួយការប្រធានគណៈមេធាវីមានភារកិច្ចជួយផ្តល់យោបល់និងបំពេញរាល់ភារកិច្ចដែលប្រធានប្រគល់ឱ្យ ។

អង្គការលេខរបស់គណៈមេធាវីជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

ជំពូកទី៣
តួនាទីនិងភារកិច្ច
ផ្នែកទី១
តួនាទីនិងភារកិច្ចរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ប្រការ៤ ..

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីមានតួនាទីនិងភារកិច្ចទាំងឡាយ តាមការកំណត់ក្នុងអនុក្រឹត្យលេខ១៣០អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។

ផ្នែកទី២
តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន

ប្រការ៥ ..

អគ្គលេខាធិការដ្ឋានមានតួនាទីជាសេនាធិការឱ្យប្រធានគណៈមេធាវី លើការងារសម្របសម្រួលនិងគ្រប់គ្រងលើកិច្ចការរដ្ឋបាល បុគ្គលិក ផែនការ ស្ថិតិ ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា ។

អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានក្រោមឱវាទចំនួន៦៖

-នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល

-នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

-នាយកដ្ឋានការពារក្តីជូនជនក្រីក្រ

-នាយកដ្ឋានអធិការកិច្ច

-នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

-នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ។

ប្រការ៦ ..

នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ នាយកដ្ឋាននេះមានការិយាល័យចំណុះចំនួន២ គឺការិយាល័យបុគ្គលិកនិងរដ្ឋបាល និងការិយាល័យចុះបញ្ជីនិងចេញវិញ្ញាបនបត្រ។

នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងនិងសម្របសម្រួលរាល់សកម្មភាពការងារផ្នែករដ្ឋបាល បញ្ជីកា ពិធីការ និងពិធីផ្សេងៗ

-រៀបចំចាត់ចែងនិងគ្រប់គ្រងលិខិតរដ្ឋបាលនានា និងផ្តត់ផ្គង់ក្នុងកិច្ចប្រជុំនិងពិធីផ្សេងៗ

-ពិនិត្យនិងផ្តល់យោបល់លើឯកសារចេញ-ចូល

-ចុះលេខលិខិតចូល លិខិតចេញ និងបញ្ជូនលិខិត

-ចេញវិញ្ញាបនបត្រសមាជិកគណៈមេធាវី

-ចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី

-ចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី

-គ្រប់គ្រងសំណុំឯកសារបុគ្គលិកនិងសំណុំឯកសារមេធាវី

-រៀបចំនិងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស

-រៀបចំផែនការ ចាត់ចែងរាល់ការងារអភិវឌ្ឍន៍ធនធានមនុស្ស និងការងារផ្សព្វផ្សាយ ពាក់ព័ន្ធនឹងការងារពង្រឹងសមត្ថភាព

-គ្រប់គ្រងបុគ្គលិក វាយតម្លៃលទ្ធផលការងារ និងលើកសំណើតែងតាំង លើកសរសើរ ឬរំសាយឋានៈតួនាទី

-រៀបចំ ចាត់ចែង និងគ្រប់គ្រងការងារប្បវត្តិពលកម្ម និងរបបឧបត្ថម្ភផ្សេងៗ

-រៀបចំសណ្តាប់ធ្នាប់ ការពារសន្តិសុខក្នុងបរិវេណគណៈមេធាវី ឬក្នុងពិធីពាក់ព័ន្ធនានា

-គ្រប់គ្រង ជួសជុលអគារ យានយន្ត និងសម្ភារប្រើប្រាស់

-រៀបចំជំនួបនានារវាងភ្ញៀវជាតិនិងអន្តរជាតិជាមួយគណៈមេធាវី

-សម្របសម្រួលក្នុងការរៀបចំសិក្ខាសាលារបស់គណៈមេធាវី

-បំពេញភារកិច្ចជាពិធីការក្នុងកម្មវិធីផ្សេងៗរបស់គណៈមេធាវី

-សម្របសម្រួលនិងរៀបចំកម្មវិធីការងារជូនថ្នាក់ដឹកនាំ

-រៀបចំតាក់តែងលំអសោភ័ណភាពក្នុងពិធីបុណ្យជាតិឬអន្តរជាតិ

-ថែរក្សានិងតុបតែងសាលប្រជុំនិងបន្ទប់ថ្នាក់ដឹកនាំ

-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ។

ប្រការ៧ ..

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុត្រូវដឹកនាំដោយប្រធានមួយរូបនិងមានជំនួយការមួយចំនួនតាមការចាំបាច់ ។

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-រៀបចំនិងបើកគណនីចរន្ត គណនីសន្សំសម្រាប់រក្សាមូលនិធិគណៈមេធាវី

-កាន់កាប់បញ្ជីគណនេយ្យរួមរបស់គណៈមេធាវី

-ប្រមូលប្រាក់ភាគទានសមាជិកគណៈមេធាវីនិងមូលនិធិផ្សេងទៀតរបស់គណៈមេធាវី

-បើកប្រាក់បៀវត្សជូនបុគ្គលិកនានារបស់គណៈមេធាវី

-ចេញលិខិតជូនដំណឹងនិងប្រមូលភាគទានដែលសមាជិកមេធាវីពុំទាន់បានបង់

-សម្របសម្រួលការងារពាក់ព័ន្ធហិរញ្ញវត្ថុក្នុងគណៈមេធាវី

-គ្រប់គ្រងចំណូល-ចំណាយសម្រាប់ប្រតិបត្តិការរបស់គណៈមេធាវី

-គ្រប់គ្រងបញ្ជីសារពើភណ្ឌរបស់គណៈមេធាវី

-ត្រួតពិនិត្យរាល់ចំណូល-ចំណាយឱ្យមានតម្លាភាពនិងត្រឹមត្រូវតាមគោលការណ៍របស់គណៈ-មេធាវី

-រៀបចំគម្រោងថវិកា

-លើកគម្រោងចំណាយដាក់ជូនក្រុមប្រឹក្សាគណៈមេធាវី ចំពោះចំណាយដែលមានទឹកប្រាក់លើសពី ៣ ០០០(បីពាន់)ដុល្លារសហរដ្ឋអាមេរិក ដើម្បីពិនិត្យនិងសម្រេច

-លើកគម្រោងចំណាយដាក់ជូនប្រធានគណៈមេធាវី ចំពោះទឹកប្រាក់តិចជាងឬស្មើនឹង ៣ ០០០ (បីពាន់)ដុល្លារសហរដ្ឋអាមេរិក ដើម្បីពិនិត្យនិងសម្រេច

-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ប្រការ៨ ..

នាយកដ្ឋានការពារក្តីជូនជនក្រីក្រត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋាននេះមានការិយាល័យចំណុះចំនួន ៣០ គឺ ការិយាល័យចុះបញ្ជីនិងសរុប ការិយាល័យការពារសិទ្ធិស្ត្រីនិងកុមារ និងការិយាល័យប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្តនិងសាលាឧទ្ធរណ៍ ។

នាយកដ្ឋានការពារក្តីជូនជនក្រីក្រមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-ទទួលបន្ទុករៀបចំផែនការ ការគ្រប់គ្រងសំណុំរឿងក្តីការពារជនក្រីក្រតាមការស្នើសុំរបស់តុលាការនានាឬប្រជាពលរដ្ឋ

-រៀបចំយុទ្ធសាស្ត្រក្នុងការការពារសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី និងសិទ្ធិផ្សេងៗទៀតតាមច្បាប់កំណត់

-សម្របសម្រួលការចាត់តាំងមេធាវីការពារក្តីជូនជនក្រីក្រនៅសាលាដំបូងរាជធានី-ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល

-ប្រមូលនិងគ្រប់គ្រងទិន្នន័យការពារក្តីជូនជនក្រីក្រទូទាំងប្រទេស

-រៀបចំគម្រោងថវិកាសម្រាប់ការពារក្តីជូនជនក្រីក្រនិងស្វែងរកមូលនិធិសម្រាប់ការពារក្តីជូនជនក្រីក្រ

-ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដោយមិនគិតកម្រៃជូនជនក្រីក្រ

-សហការជាមួយនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ដើម្បីរៀបចំគម្រោងស្នើសុំថវិកាពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ សម្រាប់ប្រតិបត្តិការការពារក្តីជូនជនក្រីក្រ

-កត់ត្រារឿងក្តីជនក្រីក្រ ការពិគ្រោះយោបល់ផ្នែកច្បាប់ទាំងអស់ និងការការពារសិទ្ធិមនុស្សនិងសិទ្ធិរបស់អ្នកទន់ខ្សោយ ដើម្បីជូនប្រធានគណៈមេធាវីជ្រាបនិងដាក់ចេញជាយុទ្ធសាស្ត្រ

-រៀបចំសេចក្តីព្រាងលិខិតបេសកកម្មការពារក្តីជូនជនក្រីក្រ ទៅតាមបណ្តារាជធានី-ខេត្ត ជូនប្រធានគណៈមេធាវីចុះហត្ថលេខា

-រៀបចំលិខិតស្នើសុំចំណាយលើរឿងក្តីនីមួយៗ រួមទាំងការចំណាយលើបេសកកម្ម ដោយសហការជាមួយនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ដាក់ជូនប្រធានគណៈមេធាវីពិនិត្យនិងសម្រេច

-ត្រួតពិនិត្យ តាមដាន និងសម្របសម្រួលនូវដំណើរការការងាររបស់ប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត និងសាលាឧទ្ធរណ៍ទាំងអស់

-ពិនិត្យតម្លាភាពក្នុងការបែងចែកសំណុំរឿងក្តីការពារជនក្រីក្រ

-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ប្រការ៩ ..

នាយកដ្ឋានអធិការកិច្ចត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋាននេះមានការិយាល័យចំណុះចំនួន៣ គឺការិយាល័យអង្កេតការសុំចូលប្រកបវិជ្ជាជីវៈមេធាវី ការិយាល័យទទួលពាក្យបណ្តឹងនិងអង្កេតទូទៅ និងការិយាល័យនីតិកម្ម ។

នាយកដ្ឋានអធិការកិច្ចមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងអធិការ

-បញ្ជូលនិងគ្រប់គ្រងទិន្នន័យសមាជិកគណៈមេធាវី

-បញ្ជូលនិងគ្រប់គ្រងទិន្នន័យរបស់បេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវី

-ទទួលនិងចុះបញ្ជីបណ្តឹង ដែលមេធាវីប្តឹងមេធាវី ប្រជាពលរដ្ឋប្តឹងមេធាវី ឬនីតិបុគ្គលសាធារណៈនិងឯកជនប្តឹងមេធាវី

-ទទួលពាក្យស្នើសុំចូលប្រកបវិជ្ជាជីវៈ

- សម្របសម្រួលនិងចាត់តាំងអធិការឱ្យធ្វើការអង្កេតលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីនិងពាក្យបណ្តឹងដែលបានប្តឹងមេធាវី
-លើកយោបល់ជូនប្រធានគណៈមេធាវីនូវលទ្ធផលអធិការកិច្ចគ្រប់ករណី
-សម្របសម្រួលលើការផ្សះផ្សាភាគីបណ្តឹងតាមការកំណត់របស់ប្រធានគណៈមេធាវី
-សម្របសម្រួលលើកិច្ចការរបស់គណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី
-ប្រមូលចងក្រងឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី
-សិក្សានិងរៀបចំគោលនយោបាយ ពិធីសារ អនុស្សារណៈ កិច្ចព្រមព្រៀង ឬសេចក្តីសម្រេចចាំបាច់នានាសម្រាប់ដំណើរការការងាររបស់គណៈមេធាវីនិងវិជ្ជាជីវៈមេធាវី
-រៀបចំសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាគណៈមេធាវី
- ចូលរួមផ្តល់មតិយោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី
-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី
-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ប្រការ១០ ..

នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋាននេះមានការិយាល័យចំណុះចំនួន៣និងគណៈកម្មការជំនាញចំនួន៥ គឺការិយាល័យស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យព្រឹត្តិបត្រនិងបោះពុម្ព គណៈកម្មការកិច្ចការរដ្ឋប្បវេណី គណៈកម្មការកិច្ចការព្រហ្មទណ្ឌ គណៈកម្មការកិច្ចការការងារ គណៈកម្មការកិច្ចការពាណិជ្ជកម្ម និងគណៈកម្មការកិច្ចការសិទ្ធិមនុស្សនិងច្បាប់អន្តរជាតិ ។

នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-រៀបចំនិងបោះពុម្ពព្រឹត្តិបត្រមេធាវី និងការផ្សព្វផ្សាយតាមអ៊ីនធើណែត
-សិក្សានិងត្រួតពិនិត្យអំពីតម្រូវការនិងប្រសិទ្ធភាពនៃសកម្មភាពផ្សព្វផ្សាយ និងបោះពុម្ព
-ស្វែងរកមូលនិធិពីប្រភពខាងក្រៅគណៈមេធាវីដើម្បីគាំទ្រគម្រោងនានារបស់នាយកដ្ឋាន
-សម្របសម្រួលការងាររបស់គណៈកម្មការជំនាញទាំងប្រាំរបស់គណៈមេធាវី
-ធ្វើកំណត់ហេតុអំពីកិច្ចប្រជុំរបស់គណៈកម្មការជំនាញ
-ធ្វើទំនាក់ទំនងជាមួយមេធាវី ចៅក្រម និងសាស្ត្រាចារ្យច្បាប់នានា ដើម្បីឱ្យចូលរួមក្នុងការធ្វើវិភាគទាន សំណើផ្សេងៗ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី
-ថតរូបភាពសកម្មភាពថ្នាក់ដឹកនាំគណៈមេធាវីនិងកម្មវិធីផ្លូវការផ្សេងៗ ដើម្បីធ្វើការផ្សព្វផ្សាយតាមគេហទំព័ររបស់គណៈមេធាវីនិងបណ្តាញសង្គម

- ផ្សព្វផ្សាយនូវសកម្មភាពគណៈមេធាវីនិងធ្វើការផ្សាយផ្ដាល់នូវសកម្មភាពសំខាន់ៗ តាមរយៈ គេហទំព័ររបស់គណៈមេធាវី បណ្ដាញសង្គមហ្វេសបុកផ្លូវការរបស់គណៈមេធាវី និងបណ្ដាញសង្គមផ្សេងទៀត
-ធ្វើបណ្ណមេធាវីនិងជំនួយការមេធាវី
-ធ្វើបច្ចុប្បន្នភាពឈ្មោះមេធាវីនៅលើបណ្ដាញអ៊ីនធើណែត
-រៀបចំបណ្ដាញសើរើរបស់គណៈមេធាវី
-ផ្ដល់ជំនួយបច្ចេកទេសផ្នែកប្រព័ន្ធបច្ចេកវិទ្យាដល់គណៈមេធាវីទាំងមូល
- ធ្វើការទំនាក់ទំនងជាមួយស្ថានីយវិទ្យុនិងទូរទស្សន៍ក្នុងស្រុក ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់និងតួនាទីរបស់មេធាវីដល់សាធារណជន
-ធ្វើការពិនិត្យនិងសម្រួលអត្ថបទផ្សេងៗមុននឹងបោះពុម្ពផ្សាយ
-ធ្វើផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ដាក់ជូនប្រធានគណៈមេធាវី
-រៀបចំបង្កើតនិងគ្រប់គ្រងគណៈកម្មការជំនាញតាមវិស័យច្បាប់នានា
-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី
-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ប្រការ១១ ..

គណៈកម្មការជំនាញទាំង៥ត្រូវដឹកនាំដោយប្រធានគណៈកម្មការមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការ។ មេធាវីទាំងអស់អាចចូលជាសមាជិក-សមាជិកានៃគណៈកម្មការជំនាញដោយស្ម័គ្រចិត្ត ដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យច្បាប់និងយុត្តិធម៌ តាមរយៈការពិភាក្សា ស្រាវជ្រាវ និងធ្វើបទវិភាគពាក់ព័ន្ធនឹងវិស័យច្បាប់ណាមួយ ។

គណៈកម្មការជំនាញទាំងនេះមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-សិក្សាស្រាវជ្រាវច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ធ្វើការវិភាគបកស្រាយនូវខ្លឹមសារច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ការបោះពុម្ពនិងផ្សព្វផ្សាយលើព្រឹត្តិបត្រមេធាវី គេហទំព័រគណៈមេធាវី និងបណ្ដាញសង្គម
- ពិភាក្សារកចម្លើយ ដើម្បីឆ្លើយតបនឹងចម្ងល់នានារបស់មេធាវីនិងសាធារណជន ពាក់ព័ន្ធនឹងខ្លឹមសារច្បាប់
- ពិភាក្សាលើប្រធានបទនិងសំណួរចម្លើយ ដើម្បីចូលរួមការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនៅតាមកម្មវិធីនិងតាមបណ្ដាញផ្សព្វផ្សាយនានា
-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ប្រការ១២ ..

នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

-សម្របសម្រួលរាល់ទំនាក់ទំនងជាមួយសាធារណជន ស្ថាប័នជាតិ អង្គការនានា និងស្ថាប័នអន្តរជាតិ

-ទទួលបន្ទុកលើអ៊ីម៉ែលរបស់គណៈមេធាវី

-ទទួលបន្ទុកឆ្លើយឆ្លងតាមអ៊ីម៉ែលរបស់គណៈមេធាវី

-ភ្ជាប់ទំនាក់ទំនងរវាងគណៈមេធាវីជាមួយគណៈមេធាវីតាមបណ្តាប្រទេសផ្សេងៗនិង ស្ថាប័នអន្តរជាតិនានា

-ស្វែងរកព័ត៌មានទាក់ទងនឹងសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងអាហារូបករណ៍នៅបរទេស សម្រាប់ផ្តល់ជូនសមាជិកគណៈមេធាវី

-ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រធានគណៈមេធាវី

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានគណៈមេធាវីប្រគល់ឱ្យ ។

ជំពូកទី៤
អវសានប្បញ្ញត្តិ

ប្រការ១៣ ..

សេចក្តីសម្រេចលេខ៦៧៥/សសមគ/១៨ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីរចនាសម្ព័ន្ធដឹកនាំរបស់គណៈមេធាវីនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ១៤ ..

នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី អគ្គលេខាធិការ និងប្រធាននាយកដ្ឋានទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ៥ក្រៃ ៤ទៀត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២០

ប្រ ធា ន




មេធាវី លី_ច័ន្ទតុលា

ចម្លងជូន:

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ ១៤
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ.....១០១៧.../សសគម/...៤០... ចុះថ្ងៃទី ១៧ ខែ ក្ក ឆ្នាំ ៣០៤០

អង្គការលេខនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ឡូតា
៦-មេធាវី ចេង ប៊េងហាប់
៧-មេធាវី ឃុន ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី សៅ ឆុនិន្ន:
១០-មេធាវី តែ ច័ណាន
១១-មេធាវី ខូវ បន្លា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ខុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន ចន្ណ:
១៧-មេធាវី ចំន្ទ ឥចិត្រ
១៨-មេធាវី ព្រហ្ម ឥចិត្រសុភា
១៩-មេធាវី ឈុប គុណឌុប
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំអាស់
៣២-មេធាវី ឡូន ផានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ៦៨៩ /សសគម/១៨

ថ្ងៃសុក្រ ៧កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨

សេចក្តីសម្រេច
ស្តីពី
គោលនយោបាយហិរញ្ញវត្ថុគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី១៤ ខែតុលា ឆ្នាំ ២០១៦បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវី អាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៨ ។

អាគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh/ Website: www.bakc.org.kh

សម្រេច

ដាក់ឱ្យអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុ និងនីតិវិធីនៃការចំណាយសំរាប់ប្រតិបត្តិការការងារ របស់គណៈមេធាវី ដោយបានទទួលការអនុម័តពីក្រុមប្រឹក្សាគណៈមេធាវី ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.- គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងគ្រប់គ្រង ចាត់ចែងចំណូលនិងចំណាយរបស់គណៈមេធាវីឱ្យមានប្រសិទ្ធភាព តម្លាភាព និងផ្តល់ទំនុកចិត្តដល់សមាជិករបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (“គណៈមេធាវី”) ។

ប្រការ ២.- គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅបង្កើតយន្តការ និងនីតិវិធីសំរាប់ប្រតិបត្តិការហិរញ្ញវត្ថុ នៅក្នុងស្ថាប័នគណៈមេធាវីទាំងមូល ។

ប្រការ ៣.- វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្ត ចំពោះប្រតិបត្តិការហិរញ្ញវត្ថុ ដែលកើតឡើងនៅក្នុងរង្វង់គណៈមេធាវីទាំងមូល ដោយរួមបញ្ចូលប្រតិបត្តិការនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីផងដែរ ។ ចំពោះគោលការណ៍លំអិត សម្រាប់អនុវត្តនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវកំណត់ក្នុងសេចក្តីសម្រេចដោយឡែករបស់គណៈមេធាវី ។

ផ្នែកទី ២

ការគ្រប់គ្រងហិរញ្ញវត្ថុ

ប្រការ ៤.- ប្រភពចំណូល

ចំណូលរបស់គណៈមេធាវីគឺបានមកពី៖

- ភាគទានប្រចាំឆ្នាំរបស់សមាជិកពេញសិទ្ធិ

- ថ្លៃបង់ករណីយកិច្ចទាំងឡាយរបស់បេក្ខជន ដែលសុំចូលប្រកបវិជ្ជាជីវៈមេធាវី
- ថ្លៃបង់ករណីយកិច្ចនៃបេក្ខជន ដែលប្រឡងជាប់ចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
- ថ្លៃបង់ករណីយកិច្ចនៃមេធាវីម្នាក់ៗ សម្រាប់ការបើកការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី
- ថ្លៃបង់ករណីយកិច្ចសម្រាប់ការប្រកបវិជ្ជាជីវៈមេធាវី
- ថ្លៃបង់ករណីយកិច្ចផ្សេងៗដែលតម្រូវដោយគណៈមេធាវីមានជាអាទិ៍ ថ្លៃករណីយកិច្ចនៃការដាក់ពាក្យនានា
- អំណោយរបស់សប្បុរសជន ឬរាជរដ្ឋាភិបាល
- រាល់ចំណូលដទៃទៀតដែលកំណត់ដោយគណៈមេធាវី។

ប្រការ ៥.- ឆ្នាំសារពើពន្ធរបស់គណៈមេធាវី

ឆ្នាំសារពើពន្ធរបស់គណៈមេធាវីគឺគិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែតុលា នៃឆ្នាំបន្ទាប់។

ប្រការ ៦.- ការរក្សាទុកចំណូល

រាល់ចំណូលរបស់គណៈមេធាវីត្រូវរក្សាទុកក្នុងគណនី នៃធនាគារណាមួយ ដែលបង្កើតដោយគណៈមេធាវី។

ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុអាចតម្កល់ប្រាក់នៅក្នុងទូរដៃកសុវត្ថិភាពរបស់គណៈមេធាវីសំរាប់ចំណាយប្រចាំថ្ងៃ ដែលមានចំនួន ៣000 (បីពាន់)ដុល្លារអាមេរិក។ ក្នុងករណីមានចំនួនទឹកប្រាក់នៅក្នុងទូរដៃកសុវត្ថិភាពតិចជាងនេះ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុត្រូវស្នើសុំដកប្រាក់ពីធនាគារមកបង្គ្រប់វិញ។

គ្មានបុគ្គលិកណាម្នាក់អាចយកប្រាក់របស់គណៈមេធាវីរក្សាទុក ឬរកផលចំណេញផ្ទាល់ខ្លួនបានឡើយ។

ប្រការ ៧.- ឈ្មោះគណនី

គណនីទាំងអស់របស់គណៈមេធាវីត្រូវដាក់ឈ្មោះគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ប្រធានគណៈមេធាវីមានសិទ្ធិបង្កើត បិទ ឬប្តូរគណនីសម្រាប់ប្រតិបត្តិការរួមក្នុងស្ថាប័នរបស់ខ្លួន។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី អាចបើកគណនីសម្រាប់ប្រតិបត្តិការរបស់ខ្លួនបាន តែត្រូវប្រើឈ្មោះនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី។

ប្រការ ៨.- ការត្រួតពិនិត្យ

ប្រធានគណៈមេធាវីមានសិទ្ធិចាត់ចែង និងទទួលខុសត្រូវក្នុងការត្រួតពិនិត្យរួមលើការចាត់ចែងរាល់ចំណូលនិងចំណាយរបស់គណៈមេធាវី។ បុគ្គលិកម្នាក់ៗរបស់គណៈមេធាវីដែលទទួលភារកិច្ចក្នុងការចំណាយ ចាត់ចែង ឬគ្រប់គ្រងថវិការបស់គណៈមេធាវីត្រូវទទួលខុសត្រូវដោយផ្ទាល់ ចំពោះថវិកាដែលទទួលទៅតាមទំហំនៃការងារ ឬការខូចខាតនោះ។

ប្រការ ៩.- ការដកប្រាក់

មានតែប្រធានគណៈមេធាវីទេ ដែលមានអំណាចសម្រេចលើការដកប្រាក់ពីធនាគារ។ ប្រធានគណៈមេធាវីអាចប្រគល់អំណាចសម្រេចដកប្រាក់នេះ ជាលាយលក្ខណ៍អក្សរជូនបុគ្គលិកណាម្នាក់របស់គណៈមេធាវី ក្នុងករណីអវត្តមានឬជាប់រវល់ក្នុងកិច្ចការណាមួយ។ ប្រធានគណៈមេធាវីត្រូវផ្តល់គំរូហត្ថលេខារបស់បុគ្គលិកនោះដល់ធនាគារ។

ការសម្រេចលើការដកប្រាក់នេះត្រូវតែមានឯកសារគាំទ្រ ដែលបង្ហាញពីចំនួនទឹកប្រាក់ជាក់លាក់ និងគោលបំណងនៃការដកប្រាក់នេះ។

ផ្នែកទី ៣
ការចំណាយ

ប្រការ ១០.- ការបញ្ជាចំណាយ

រាល់ការចំណាយទាំងអស់ត្រូវសម្រេចដោយប្រធានគណៈមេធាវី លើកលែងតែការចំណាយបន្ទាប់បន្សំ ដែលត្រូវសម្រេចដោយអគ្គលេខាធិការគណៈមេធាវី។

ចំណាយបន្ទាប់បន្សំគឺជាចំណាយ ដែលមានចំនួនទឹកប្រាក់មិនលើសពី ១00 (មួយរយ) ដុល្លារអាមេរិក ឬមិនលើសពី ៤00 000 (បួនសែន) រៀល។

ការចំណាយអាចធ្វើបាន លុះត្រាតែមុខចំណាយនោះត្រូវគ្នានឹងខ្លឹងដែលកំណត់នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដែលសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

ក្នុងករណីការចំណាយនោះលើសពី ៣000 (បីពាន់) ដុល្លារអាមេរិក ហើយមិនមានចែងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ការចំណាយនោះត្រូវសុំការសម្រេចពីក្រុមប្រឹក្សាគណៈមេធាវីមុននឹងធ្វើការបញ្ជាចំណាយ។

ប្រធានគណៈមេធាវីអាចសម្រេចលើការដកពីខ្ទង់ចំណាយមួយ ទៅខ្ទង់មួយទៀតបានដែលមិនលើសពី១0%(ដប់ភាគរយ)នៃខ្ទង់ចំណាយចំបង។ ការផ្លាស់ប្តូរខ្ទង់ចំណាយណាមួយដែលលើសពី១0%(ដប់ភាគរយ)នៃខ្ទង់ចំណាយចំបងត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ ១១.- ទម្រង់នៃការចំណាយ

ការចំណាយអាចធ្វើជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ។ ការចំណាយលើសពី ៣00 (បីរយ) ដុល្លារអាមេរិកត្រូវធ្វើឡើងជាមូលប្បទានបត្រ។

ប្រការ ១២.- ការចំណាយលើប្រាក់ប្បៀវត្ស

ប្រាក់ប្បៀវត្សរ៍ត្រូវបើកជូនបុគ្គលិកនៅរៀងរាល់បំណាច់ខែនីមួយៗ ដោយបញ្ចូលទៅក្នុងគណនីធនាគាររបស់បុគ្គលិកម្នាក់ៗ។ បុគ្គលិកទាំងអស់ត្រូវមានគណនីធនាគាររបស់ខ្លួនលើកលែងតែករណីមិនអាចបើកគណនីបាន។

ចំពោះបុគ្គលិក ដែលស្ម័គ្រចិត្តធ្វើការថែមម៉ោងលើសពីម៉ោងការងារក្នុងថ្ងៃធ្វើការ ឬធ្វើការថែមម៉ោងក្នុងថ្ងៃឈប់សម្រាកដែលមានប្រាក់ឈ្នួល តាមការកំណត់របស់ប្រធានគណៈមេធាវីត្រូវទទួលបានប្រាក់ថែមម៉ោងក្នុងអត្រា១៥0% (មួយរយហាសិបភាគរយ)នៃប្រាក់ប្បៀវត្សរ៍ក្នុងមួយម៉ោង។

ប្រការ ១៣.- ការខ្ចីប្រាក់ប្បៀវត្ស

បុគ្គលិកម្នាក់ៗអាចស្នើសុំខ្ចីប្រាក់ប្បៀវត្សរបស់ខ្លួនបាន ក្នុងករណីយកទៅព្យាបាលជំងឺគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬករណីចាំបាច់ណាមួយ តែចំនួននៃប្រាក់កម្ចីនោះមិនត្រូវលើសពីប្រាក់ប្បៀវត្សប្រចាំខែចំនួន ៣ (បី)ខែឡើយ។

បុគ្គលិកដែលខ្ចីប្រាក់នោះត្រូវសងមកគណៈមេធាវីវិញ ក្នុង១ខែចំនួន ២៥% (ម្ភៃប្រាំភាគរយ)នៃប្រាក់ប្បៀវត្សប្រចាំខែរបស់ខ្លួន ក្រោយពីខ្លួនខ្ចី ដោយកាត់ផ្ទាល់ចេញពីប្រាក់ខែបន្ទាប់ៗ រហូតដល់គ្រប់ចំនួនទឹកប្រាក់ដែលបានខ្ចី។

ប្រការ ១៤.- ការតម្លើងប្រាក់ប្សែវត្ស

បុគ្គលិករបស់គណៈមេធាវីម្នាក់អាចត្រូវបានស្នើសុំឱ្យតម្លើងប្រាក់ប្សែវត្ស ទៅតាមស្នាដៃនៃការបំពេញការងារ និងចំណូលរបស់គណៈមេធាវីនៅបំណាច់ឆ្នាំនីមួយៗ។ ការតម្លើងប្រាក់ប្សែវត្សរ៍នេះមិនអាចលើសពី ១0%(ដប់ភាគរយ)នៃប្រាក់ប្សែវត្ស ក្នុងមួយឆ្នាំឡើយ។

ការវាយតម្លៃស្នាដៃការងារនៃបុគ្គលិកត្រូវធ្វើស្របតាមគោលនយោបាយបុគ្គលិករបស់គណៈមេធាវី។

ប្រការ ១៥.- ការចំណាយលើការបណ្តុះបណ្តាលបុគ្គលិក

បុគ្គលិករបស់គណៈមេធាវីអាចទទួលបានការគាំទ្រពីគណៈមេធាវី ដើម្បី បណ្តុះបណ្តាលបន្ថែមលើមុខវិជ្ជាណាមួយដែលចាំបាច់ សម្រាប់បំរើការងាររបស់គណៈមេធាវី ដោយមានការឆ្លងយោបល់ពីប្រធានផ្នាល់នីមួយៗ និងសម្រេចដោយប្រធានគណៈមេធាវី។ ការចំណាយនេះមិនអាចលើសពី ៣00 (បីរយ)ដុល្លារអាមេរិកសម្រាប់បុគ្គលិកម្នាក់ ហើយមិនលើសពី៣នាក់ក្នុង១ឆ្នាំ។

ប្រការ ១៦.- ប្រាក់រង្វាន់ប្រចាំឆ្នាំ

នៅបំណាច់ឆ្នាំនីមួយៗ បុគ្គលិកគណៈមេធាវីអាចទទួលបានប្រាក់រង្វាន់លើកទឹកចិត្តស្មើនឹងចំនួនប្រាក់ប្សែវត្សរ៍របស់ខ្លួន១ខែ ទៅតាមគម្រោងថវិកាប្រចាំឆ្នាំ។ ប្រាក់នេះត្រូវបើកនៅពេលបុណ្យភ្ជុំបិណ្ឌចំនួនកន្លះខែ និងបុណ្យចូលឆ្នាំប្រពៃណីជាតិចំនួនកន្លះខែ។

ប្រការ ១៧.- ការចំណាយលើបុគ្គលិកស្ម័គ្រចិត្ត

បុគ្គលិកស្ម័គ្រចិត្តដែលបំរើការងារនៅក្នុងគណៈមេធាវីអាចទទួលបានត្រឹមតែប្រាក់ឧបត្ថម្ភប្រចាំខែ ទៅតាមការសម្រេចរបស់ប្រធានគណៈមេធាវី និងគម្រោងថវិកាប្រចាំឆ្នាំ។

ប្រការ ១៨.- ការចំណាយបេសកកម្មក្នុងប្រទេស

ថ្នាក់ដឹកនាំ ឬបុគ្គលិករបស់គណៈមេធាវី ដែលទទួលបានការចាត់តាំងទៅបំពេញភារកិច្ចនៅតាមខេត្តនានា នៅក្នុងប្រទេសត្រូវបានឧបត្ថម្ភសម្រាប់បេសកកម្មចំនួន៤0(សែសិប)ដុល្លារអាមេរិកក្នុង១ថ្ងៃសម្រាប់អាហារ (ពេលព្រឹក១0ដុល្លារ ពេលថ្ងៃត្រង់១0ដុល្លារ និងពេលល្ងាច១0ដុល្លារ និងចំណាយផ្សេងៗ១0ដុល្លារ) បន្ថែមលើថ្លៃស្នាក់នៅ និងការធ្វើដំណើរ។ ចំពោះថ្លៃស្នាក់នៅ និងការធ្វើដំណើរត្រូវទូទាត់តាមវិក័យប័ត្រជាក់ស្តែង និងសមរម្យ ដោយ

ផ្អែកលើគោលការណ៍ដែលកំណត់ដោយគណៈមេធាវី។ ក្នុងករណីដែលទទួលបានអាហារ ឬការឧបត្ថម្ភពីកម្មវិធីណាមួយ នោះប្រាក់ឧបត្ថម្ភត្រូវកាត់ចេញតាមជាក់ស្តែង។

ក្រោយពីត្រឡប់មកពីបំពេញភារកិច្ចវិញ សាមីខ្លួនត្រូវធ្វើរបាយការណ៍ជូនគណៈមេធាវីពីសកម្មភាពដែលខ្លួនបានបំពេញ។ ក្នុងករណីមិនបានធ្វើរបាយការណ៍ជូនគណៈមេធាវីទេ នោះសាមីខ្លួននឹងមិនអាចទទួលបានប្រាក់បៀសកកម្មពីគណៈមេធាវីបានទេ ឬត្រូវសងគណៈមេធាវីវិញនូវប្រាក់ដែលបានធ្វើបុរេប្រទានរួចហើយ។ ការទូទាត់លើប្រាក់បៀសកកម្មមិនឱ្យលើសពី ២សប្តាហ៍បន្ទាប់ពីបញ្ចប់បៀសកកម្ម។

ប្រការ ១៩.- ការចំណាយបៀសកកម្មនៅក្រៅប្រទេស

ថ្នាក់ដឹកនាំ ឬបុគ្គលិករបស់គណៈមេធាវីដែលទទួលបានការចាត់តាំងទៅបំពេញភារកិច្ចនៅក្រៅប្រទេស នឹងទទួលប្រាក់ឧបត្ថម្ភសម្រាប់បៀសកកម្មចំនួន ២០០ (ពីររយ) ដុល្លារអាមេរិកក្នុង១ថ្ងៃសំរាប់អាហារ និងចាយវាយផ្សេងៗ (ពេលព្រឹក៣០ដុល្លារ ពេលថ្ងៃត្រង់៦០ដុល្លារ ពេលល្ងាច៦០ដុល្លារ និងចំណាយផ្សេងៗ៥០ដុល្លារ) បន្ថែមលើថ្លៃស្នាក់នៅ និងសំបុត្រយន្តហោះ។

ថ្លៃស្នាក់នៅ និងសំបុត្រយន្តហោះត្រូវទូទាត់តាមវិក័យប័ត្រជាក់ស្តែង ដោយផ្អែកលើគោលការណ៍ចំណាយដែលសមស្រប។ ក្នុងករណីដែលទទួលបានអាហារ ឬការឧបត្ថម្ភពីកម្មវិធីណាមួយ នោះប្រាក់ឧបត្ថម្ភត្រូវកាត់ចេញតាមជាក់ស្តែង។

ពេលត្រឡប់ពីបំពេញភារកិច្ចវិញ សាមីខ្លួនត្រូវធ្វើរបាយការណ៍ជូនគណៈមេធាវីពីសកម្មភាពដែលខ្លួនបានបំពេញ។ ក្នុងករណីមិនបានធ្វើរបាយការណ៍ជូនគណៈមេធាវីទេ នោះសាមីខ្លួនមិនត្រូវទទួលបានប្រាក់បៀសកកម្មពីគណៈមេធាវីទេ ឬត្រូវសងគណៈមេធាវីវិញនូវប្រាក់ដែលបានធ្វើបុរេប្រទានរួចហើយ។ ការទូទាត់លើប្រាក់បៀសកកម្មមិនឱ្យលើសពី ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបញ្ចប់បៀសកកម្មឡើយ។

ប្រការ ២០.- ការចំណាយលើគម្រោង

បៃបបទ និងការចំណាយផ្សេងៗដែលផ្តត់ផ្តង់ដោយម្ចាស់ជំនួយ ឬរាជរដ្ឋាភិបាលត្រូវអនុវត្តតាមការព្រមព្រៀង ឬគោលការណ៍ផ្ទៃក្នុងរបស់គណៈមេធាវី និងគោលការណ៍ដែលកំណត់ដោយម្ចាស់ជំនួយផងដែរ។

ផ្នែកទី ៤

នីតិវិធីនៃការចំណាយ

ប្រការ ២១.- ការស្នើសុំចំណាយ

រាល់ការចំណាយត្រូវមានការស្នើសុំជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៣ថ្ងៃយ៉ាងតិច មុនការចំណាយ ដោយមានហត្ថលេខាអ្នកស្នើសុំ រួមទាំងបញ្ជាក់ពីគោលបំណង និងចំនួនទឹកប្រាក់ជាក់លាក់ (ទំរង់សំណើមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ១) នៃសេចក្តីសម្រេចនេះ។

ប្រធាននាយកដ្ឋាននីមួយៗត្រូវត្រួតពិនិត្យ និងធ្វើមូលវិចារលើសំណើ រួចបញ្ជូនទៅនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ដើម្បីផ្តល់យោបល់ថាតើសំណើនេះសមស្រប និងមានថវិកាចំណាយឬទេ។ ដោយផ្អែកលើយោបល់នេះ អគ្គលេខាធិការត្រូវធ្វើមូលវិចារ មុននឹងបញ្ជូនសំណើនេះឱ្យប្រធានគណៈមេធាវី សម្រេច។ ការចាយមុនក៏ត្រូវអនុវត្តបែបនេះដែរ។

ការស្នើសុំប្រាក់ប្បៀវត្សរ៍សំរាប់បុគ្គលិកត្រូវមានបញ្ជីប្រាក់ខែ។ បុគ្គលិកម្នាក់ៗត្រូវទទួលបានប័ណ្ណចំណាយ ដោយបញ្ជាក់ពីចំនួនប្រាក់ប្បៀវត្សរ៍ អត្ថប្រយោជន៏ និងបំណុលប្រសិនបើមាន។ ប័ណ្ណចំណាយនេះត្រូវប្រគល់ជូនបុគ្គលិក ក្រោយពីបញ្ជូនប្រាក់ប្បៀវត្សរ៍ ចូលទៅក្នុងគណនីធនាគាររបស់បុគ្គលិកម្នាក់ៗ។

ប្រការ ២២.- ឯកសារភ្ជាប់ជាមួយការស្នើសុំចំណាយ

រាល់សំណើចំណាយត្រូវភ្ជាប់ជាមួយនូវឯកសារសម្រង់តម្លៃយ៉ាងតិច ៣(បី)កន្លែង បើចំណាយនោះទាក់ទងនឹងការទិញសម្ភារៈ សេវាកម្ម ឬការជួលដែលមានទឹកប្រាក់៖

- ក្រោម ៥០០(ប្រាំរយ) ដុល្លារ ត្រូវមានសម្រង់តម្លៃតាមទូរស័ព្ទ
- ចាប់ពី ៥០០(ប្រាំរយ) ដុល្លារ ទៅដល់ ២០០០ (ពីរពាន់) ដុល្លារត្រូវមាន សម្រង់តម្លៃជាលាយលក្ខណ៍អក្សរពីអ្នកផ្គត់ផ្គង់
- ចាប់ពី ២០០១(ពីរពាន់មួយ) ដុល្លារឡើងទៅតម្រូវឱ្យមានសម្រង់តម្លៃ ព្រមទាំងធ្វើការវាយតម្លៃនិងជ្រើសរើស ដោយគណៈកម្មការលទ្ធកម្មដែលមានសមាសភាពបីរូបគឺ ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ អគ្គលេខាធិការគណៈមេធាវី និងប្រធានគណៈមេធាវី។

ក្នុងករណីដែលមិនអាចរកសម្រង់តម្លៃចំពោះទំនិញ ឬសេវាកម្មនោះបានទេ នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលត្រូវសុំការអនុញ្ញាតពីប្រធានគណៈមេធាវីជាមុនសិន។ ការទិញសម្ភារៈការិយាល័យបន្ថែមត្រូវមានភ្ជាប់មកជាមួយនូវបញ្ជីសម្ភារៈដែលបានប្រើកន្លងមក។

វិក័យប័ត្រត្រូវមានរាយនាមមុខទំនិញ ឬប្រភេទសេវា និងតម្លៃ ដោយមានកាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះក្រុមហ៊ុន ឬអ្នកផ្តល់សេវា និងអ្នកទទួល សេវាឱ្យបានច្បាស់លាស់។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុត្រូវត្រួតពិនិត្យលើឯកសារទាំងអស់នេះ រួចហើយរៀបចំប័ណ្ណចំណាយ និងបញ្ជូនទៅអគ្គលេខាធិការត្រួតពិនិត្យ និងសុំការសម្រេចពីប្រធានគណៈមេធាវី។ គណនេយ្យករអាចទូទាត់ចេញប្រាក់ចំណាយបានលុះត្រាតែប័ណ្ណចំណាយនេះមានចុះហត្ថលេខាត្រួតពិនិត្យពីប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ អគ្គលេខាធិការ និងសម្រេចពីប្រធានគណៈមេធាវីរួចរាល់សិន។

ប្រការ ២៣.- ការទិញសម្ភារៈ

នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ជាអ្នកទទួលខុសត្រូវលើរាល់ការទិញ សម្ភារៈ និងទំនិញ ឬទូទាត់ចំណាយផ្សេងៗ ក្រោយពីមានការបញ្ជាចំណាយ។ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក៏ដូចជានាយកដ្ឋានផ្សេងៗមិនអាចបំពេញតួនាទីនេះបានទេ។ រាល់ការទិញទំនិញ ឬសេវាកម្មទាំងអស់ត្រូវផ្អែកលើគោលការណ៍លទ្ធកម្មរបស់គណៈមេធាវីដែលបានចែង។

ប្រការ ២៤.- ការទូទាត់ការចំណាយ

ការចំណាយដែលតម្រូវឱ្យមានវិក័យប័ត្រ ឬប្រាក់កម្ចីសំរាប់ប្រតិបត្តិការ ត្រូវធ្វើការទូទាត់ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់បេសកកម្ម។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុត្រូវរំលឹកបុគ្គលិក អំពីការទូទាត់នេះ។ ក្នុងករណីបុគ្គលិកមិនព្រមអនុវត្តកាតព្វកិច្ចនេះទេ ប្រាក់ដែលបានចំណាយរួចត្រូវចាត់ទុកថាមិនបានចំណាយ ហើយត្រូវទូទាត់សងគណៈមេធាវីវិញ។ រាល់ការទូទាត់លើចំណាយទាំងអស់ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុត្រូវធ្វើការទូទាត់ដោយផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកផ្តល់សេវា។

ផ្នែកទី ៥

ការធ្វើសវនកម្ម

ប្រការ ២៥.- របាយការណ៍ចំណាយ

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុត្រូវកត់ត្រារាល់ចំណូលនិងចំណាយ តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដែលបានកំណត់តាមគោលការណ៍របស់គណៈមេធាវី។

របាយការណ៍ត្រូវធ្វើប្រចាំឆមាស និងប្រចាំឆ្នាំ។ នៅក្នុងរបាយការណ៍ត្រូវបញ្ជាក់លំអិតពីប្រភេទចំណូលនិងចំណាយ រួមទាំងសមតុល្យ ដោយមានហត្ថលេខា ប្រធាននាយកដ្ឋាន អគ្គលេខាធិការ និងប្រធានឬតំណាងប្រធានគណៈមេធាវី។

បណ្ណ័ចំណាយ និងឯកសារយោងត្រូវរក្សាទុកនៅក្នុងការិយាល័យធ្វើការនៃនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ តាមលំដាប់លំដោយនៃប្រភេទចំណូល និងចំណាយជាឯកសារដើមនិងអេឡិចត្រូនិក។

ប្រការ ២៦.- បញ្ជីសារពើភណ្ឌ

ទ្រព្យសម្បត្តិរបស់គណៈមេធាវីត្រូវស្ថិតក្នុងបញ្ជីសារពើភណ្ឌរបស់គណៈមេធាវី។ ទ្រព្យសម្បត្តិនីមួយៗត្រូវមានលេខសំគាល់។ បញ្ជីសារពើភណ្ឌត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់៦ខែម្តង និងប្រចាំឆ្នាំ ដោយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ។ របាយការណ៍នេះត្រូវបញ្ជាក់ពីគុណភាពនៃវត្ថុនីមួយៗ។ ការដកទ្រព្យសម្បត្តិណាមួយចេញពីបញ្ជីសារពើភណ្ឌត្រូវសម្រេចដោយ គណៈកម្មការវាយតម្លៃ ដែលបង្កើតឡើងដោយប្រធានគណៈមេធាវី។

ប្រការ ២៧.- ការធ្វើសវនកម្ម

សវនកម្មផ្ទៃក្នុងនៃសកម្មភាពការងារ និងស្ថានភាពហិរញ្ញវត្ថុរបស់គណៈមេធាវីត្រូវប្រព្រឹត្តឡើងជារៀងរាល់ឆ្នាំ ដើម្បីបង្ហាញពីតម្លាភាពនៃការគ្រប់គ្រងនិងដឹកនាំរបស់គណៈមេធាវី។ គណៈកម្មការសវនកម្មផ្ទៃក្នុងត្រូវបង្កើតឡើងដោយក្រុមប្រឹក្សាគណៈមេធាវី ដែលមានសមាសភាពចំនួន៣រូបយ៉ាងតិច។

សវនកម្មខាងក្រៅត្រូវបានអនុវត្តនៅរៀងរាល់២(ពីរ)ឆ្នាំម្តង ដែលនឹងធ្វើឡើងដោយក្រុមសវនកម្មឯករាជ្យ។ ការចំណាយសវនកម្មជាបន្ទុករបស់គណៈមេធាវី ឬសប្បុរសជនប្រសិនបើមាន។

មន្ត្រីទាំងអស់របស់គណៈមេធាវី ដែលពាក់ព័ន្ធក្នុងការធ្វើសវនកម្មនេះត្រូវសហការជាមួយសវនករ ដើម្បីសម្រួលដល់កិច្ចការនៃការធ្វើសវនកម្មនេះ។

ប្រការ ២៨.- ការធ្វើរបាយការណ៍សវនកម្ម

សវនករត្រូវធ្វើរបាយការណ៍បញ្ចប់សវនកម្ម ហើយដាក់ជូនប្រធានគណៈមេធាវីពិនិត្យមុននឹងចេញរបាយការណ៍ជាផ្លូវការ។ ព័តិមានដែលមាននៅក្នុងរបាយការណ៍ត្រូវមានមូលដ្ឋានច្បាស់លាស់ ហើយមានការបំភ្លឺដ៏ត្រឹមត្រូវពីបុគ្គលពាក់ព័ន្ធ។

របាយការណ៍ជាផ្លូវការនេះត្រូវចម្លងជូនសមាជិកក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងផ្តល់យោបល់។

កំហុសដែលបានរកឃើញនៅក្នុងរបាយការណ៍នេះមិនអាចយកមកធ្វើជាមូលដ្ឋាននៃការដាក់វិន័យឡើយ គឺវាគ្រាន់តែជាព័តិមានសំរាប់យកមកធ្វើជាមូលដ្ឋាននៃការកែទម្រង់ប៉ុណ្ណោះ។

ផ្នែកទី ៦

អវសានបញ្ញត្តិ

ប្រការ ២៩.- ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្មនៃគោលនយោបាយហិរញ្ញវត្ថុនេះអាចធ្វើទៅបាន លុះត្រាតែមានសម្លេងគាំទ្រពីក្រុមប្រឹក្សាគណៈមេធាវីចំនួនពីរភាគបី នៃក្រុមប្រឹក្សាទាំងមូល។

ការស្នើសុំវិសោធនកម្មអាចធ្វើឡើងបានតាមការស្នើសុំរបស់ប្រធានគណៈមេធាវី ឬសមាជិកក្រុមប្រឹក្សាគណៈមេធាវីយ៉ាងតិចប្រាំនាក់ឡើងទៅ។

ប្រការ ៣០.- ការចូលជាធរមាន

គោលនយោបាយហិរញ្ញវត្ថុនេះចូលជាធរមាន បន្ទាប់ពីក្រុមប្រឹក្សាគណៈមេធាវីបានអនុម័តដោយសម្លេងភាគច្រើន និងចាប់ពីថ្ងៃប្រកាសដាក់ឱ្យអនុវត្តដោយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣១.- ការអនុវត្ត

អគ្គលេខាធិការ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងប្រធាននាយកដ្ឋាននានា ចំណុះអគ្គលេខាធិការគណៈមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធាន



មេធាវី សុន_ទិសាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ទិសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ឆេង បូឆល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ឡូនគា
៦-មេធាវី ចេង ប៊ែងហាប់
៧-មេធាវី ឃុត ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី សៅ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុត ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឃុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនឃឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណចុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេន
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំវុត្ថ
២៧-មេធាវី គាន គាង
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរ៉ស់
៣២-មេធាវី ឡូន ផានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ១៥៧ /សសគម/១៩

ថ្ងៃ ស្ដ្រ ៩ ១៧ ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារគ្រប់គ្រងនិងសម្របសម្រួលថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា និងផ្តល់ការអប់រំផ្លែកច្បាប់

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ទិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការចាំបាច់។

ស ម្រ េ ច

ប្រការ ១.- ត្រូវបានបង្កើតក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់កណ្តាលសម្រាប់អនុវត្តគម្រោងផ្តល់សេវាការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា និងផ្តល់ការ

អប់រំផ្នែកច្បាប់ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា**	អគ្គលេខាធិការ	ប្រធាន
២.លោកមេធាវី **លីវ សុវណ្ណា**	អគ្គលេខាធិការរង	អនុប្រធាន
៣.លោកមេធាវី **វ៉ា ពិសី**	ប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ	អនុប្រធាន
៤.លោកមេធាវី **យុង ផានិត**	អនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ	អនុប្រធានប្រចាំការ
៥.លោកស្រីមេធាវី **សុិន សុវ៉ន**	អនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ	អនុប្រធាន
៦.លោកមេធាវី **ឆែ វិបុល**	អនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ	សមាជិក
៧.លោកស្រីមេធាវី **លឹម ច័ន្ទលីដា**	ប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល	សមាជិក
៨.កញ្ញា **ឡុក ម៉ាលីន**	ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ	សមាជិក
៩.កញ្ញាមេធាវី **លី រតនា**	ប្រធានការិយាល័យស្ត្រីនិងកុមារ	លេខាធិការ។

ប្រការ ២. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់កណ្តាលសម្រាប់អនុវត្តគម្រោងផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សា និងផ្តល់ការអប់រំផ្នែកច្បាប់មានភារកិច្ចដូចខាងក្រោម៖

១.សម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

២.រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងធ្វើសេចក្តីណែនាំផ្សេងៗ ដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព។

៣.រៀបចំគម្រោងចំណាយសម្រាប់ប្រតិបត្តិការការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា។

៤.ជម្រុញឱ្យការផ្តល់សេវាការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាប្រកបដោយប្រសិទ្ធភាព និងជម្រុញឱ្យជនរងគ្រោះទទួលបាននូវសិទ្ធិទទួលបានយុត្តិធម៌ឆាប់រហ័ស។

៥.រៀបចំផែនការបណ្តុះបណ្តាលផ្នែកច្បាប់ដល់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌និងអ្នកពាក់ព័ន្ធ។

៦.ធ្វើរបាយការណ៍ការងារនិងចំណាយដាក់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងប្រធានគណៈមេធាវី។

៧.បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រធានគណៈមេធាវី។

ប្រការ ៣. សមាជិកក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់កណ្តាលសម្រាប់អនុវត្តគម្រោងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារថ្នាក់កណ្តាល ឬប្រធានគណៈមេធាវី។

ប្រការ ៤. ត្រូវបានបង្កើតក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងនៅថ្នាក់រាជធានី.ខេត្តដែលមានសមាសភាពដូចខាងក្រោម៖

១.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំរាជធានីភ្នំពេញ៖

.លោកមេធាវី **សំ ឡុង**	ប្រធាន
.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំរាជធានីភ្នំពេញ	សមាជិក
.លោកមេធាវី **ជុំ ចិត្រា**	លេខាធិការ។

២. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកណ្តាល៖

.លោកមេធាវី **ឡាយ ណារ៉ា**	ប្រធាន
.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកណ្តាល	សមាជិក

-កញ្ញា **ផុន ច័ន្ទរស្មី** លេខាធិការ ។

៣. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តព្រៃវែង៖

-លោកមេធាវី **សោ ប៉ែងថារុណ** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តព្រៃវែង សមាជិក

-លោក **ចៅ សុភ័ណ្ឌ** លេខាធិការ ។

៤. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តស្វាយរៀង៖

-លោកមេធាវី **កែន សាន** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តស្វាយរៀង សមាជិក

-កញ្ញា **ហាន ស្រីទូច** លេខាធិការ ។

៥. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តត្បូងឃ្មុំ៖

-លោកមេធាវី **ច័ន្ទ វ៉ាពិសិដ្ឋ** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តត្បូងឃ្មុំ សមាជិក

-កញ្ញា **គីម ចាន់សុផល** លេខាធិការ ។

៦. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកំពង់ចាម៖

-លោកមេធាវី **នៅ រក្សា** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកំពង់ចាម សមាជិក

-កញ្ញា **ឈាន ជាលិកា** លេខាធិការ ។

៧. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកំពង់ធំ៖

-លោកមេធាវី **តូច សាខឿន** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកំពង់ធំ សមាជិក

-កញ្ញា **កង រតនា** លេខាធិការ ។

៨. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តសៀមរាប៖

-លោកមេធាវី **ឈរ លីថៃ** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តសៀមរាប សមាជិក

-លោក **ម៉ក់ ប៊ុនធឹង** លេខាធិការ ។

៩. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តឧត្តរមានជ័យ៖

-លោកមេធាវី **ម៉ឿន សុវណ្ណ** ប្រធាន

-មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តឧត្តរមានជ័យ សមាជិក

-លោក **អិល សាមួយ** លេខាធិការ ។

១០. ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំបន្ទាយមានជ័យ៖

.លោកស្រីមេធាវី **ណុប គុណថុល** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តបន្ទាយមានជ័យ សមាជិក

.លោក **មៀច មាស** លេខាធិការ។

១១.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តបាត់ដំបង៖

.លោកមេធាវី **ហម មុន្នី** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តបាត់ដំបង សមាជិក

.លោក **លូត វាសនា** លេខាធិការ។

១២.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តប៉ៃលិន៖

.លោកមេធាវី **សួស ស៊ីវឆេង** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តប៉ៃលិន សមាជិក

.លោក **ចៅ ធូ** លេខាធិការ។

១៣.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តព្រះវិហារ៖

.លោកមេធាវី **ម៉ន កែវស៊ីវិន** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តព្រះវិហារ សមាជិក

.លោក **ថ្រី សុផល** លេខាធិការ។

១៤.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តពោធិ៍សាត់៖

.លោកមេធាវី **ថន បូរី** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តពោធិ៍សាត់ សមាជិក

.លោក **ឈន ចាន់** លេខាធិការ។

១៥.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកំពង់ឆ្នាំង៖

.លោកមេធាវី **ម៉ិត ឡាយ** ប្រធាន

.**មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកំពង់ឆ្នាំង** **សមាជិក**

.កញ្ញា **ឡាច រស្មី** លេខាធិការ។

១៦.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកំពង់ស្ពឺ៖

.លោកមេធាវី **ហេង ពូង** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកំពង់ស្ពឺ សមាជិក

.លោក **តាំង បាក់ហ័រ** លេខាធិការ។

១៧.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តព្រះសីហនុ៖

.លោកមេធាវី **ឡុង សាលុច្ស** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តព្រះសីហនុ សមាជិក

.កញ្ញា **ទឹម ផានាថ** លេខាធិការ ។

១៨.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកំពតៈ

.លោកស្រីមេធាវី **ជា ដាវី** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកំពត សមាជិក

.លោក **ថៃ ចំរ៉ុង** លេខាធិការ ។

១៩.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តតាកែវៈ

.លោកមេធាវី **ឌុក វាសនា** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តតាកែវ សមាជិក

.លោក **ស្បឿន សត្យាមុន្នី** លេខាធិការ ។

២០.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តកោះកុងៈ

.លោកមេធាវី **ចន្ទ ហួន** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តកោះកុង សមាជិក

.លោក **យ៉ម ឆៃយ៉ា** លេខាធិការ ។

២១.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តស្ទឹងត្រែងៈ

.លោកមេធាវី **ញ៉ូ ញ្យូន** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តស្ទឹងត្រែង សមាជិក

.កញ្ញា **សុវណ្ណ មច្ឆា** លេខាធិការ ។

២២.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តរតនគីរីៈ

.លោកមេធាវី **ម៉ៅ សារី** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តរតនគីរី សមាជិក

.លោក **ឈាវ សុភាវ** លេខាធិការ ។

២៣.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តមណ្ឌលគីរីៈ

.លោកមេធាវី **កុយ វាសនា** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តមណ្ឌលគីរី សមាជិក

.កញ្ញា **ហ៊ាន់ សុផាឡែន** លេខាធិការ ។

២៤.ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងប្រចាំខេត្តក្រចេះៈ

.លោកមេធាវី **លី វីរៈ** ប្រធាន

.មេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រប្រចាំខេត្តក្រចេះ សមាជិក

.លោក **លី ប៊ុនហាប់** លេខាធិការ ។

ប្រការ ៥.- ក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងមានភារកិច្ចដូចខាងក្រោមៈ

១.សម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការជាមួយមន្ទីរកិច្ចការនារីរាជធានី-ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
២.សម្របសម្រួលនិងចាត់តាំងមេធាវីដើម្បីការពារក្តីដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា។
៣.តំណាងឬការពារក្តីឱ្យស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាដោយមិនយកកម្រៃ។
៤.ផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាដោយមិនយកកម្រៃ។
៥.ធ្វើរបាយការណ៍សកម្មភាពការងារនិងចំណាយដាក់ជូនក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់កណ្តាល និងប្រធានគណៈមេធាវី។
៦.បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រធានក្រុមការងារគ្រប់គ្រង។
និងសម្របសម្រួលថ្នាក់កណ្តាល និងប្រធានគណៈមេធាវី។

ប្រការ ៦.. សមាជិកក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់រាជធានី-ខេត្តសម្រាប់អនុវត្តគម្រោងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងាររបស់ខ្លួន ប្រធានក្រុមការងារគ្រប់គ្រង និងសម្របសម្រួលថ្នាក់កណ្តាល ឬប្រធានគណៈមេធាវី។

ប្រការ ៧.. បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.. អគ្គលេខាធិការគណៈមេធាវី និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធាន

មេធាវី **សួន_ឥសាល**

ចម្លងជូន

-អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
-ក្រុមប្រឹក្សាគណៈមេធាវី
-មន្ទីរកិច្ចការនារីរាជធានី-ខេត្ត
"ដើម្បីជ្រាប"
-ដូចប្រការ ៨
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ឡូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ចំន្ទ ឥច្ចិត្រា
១៨-មេធាវី ព្រហ្ម ឥច្ចិត្រសុតា
១៩-មេធាវី ណុប គុណចុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ឡូន ជានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ៥៣៧/សសគម/២០

ថ្ងៃ ស្រ្ត ៣១៦ ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២០

សេចក្តីសម្រេច
ស្តីពី
គោលនយោបាយបុគ្គលិកគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី១៤ ខែ តុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវី អាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ។

ស ម្រេ ច

ដាក់ឱ្យអនុវត្តនូវគោលនយោបាយបុគ្គលិករបស់គណៈមេធាវីដែលមានខ្លឹមសារទាំងស្រុងដូចតទៅៈ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ១ .- គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងបង្កើតនូវយន្តការ សម្រាប់គ្រប់គ្រងបុគ្គលិកប្រកបដោយប្រសិទ្ធភាព តម្លាភាព ស្មើភាព យេនឌ័រ និងផ្តល់ទំនុកចិត្តដល់បុគ្គលិក ដើម្បីជំរុញផលិតភាពការងារ និងនិរន្តរភាពការងាររបស់គណៈមេធាវី ។

ប្រការ២ .- គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់អំពីវិធាន និងគោលការណ៍ណែនាំ សម្រាប់ការជ្រើសរើសបុគ្គលិក ការដំឡើងតួនាទី ការបណ្តុះបណ្តាល ការលើកទឹកចិត្ត ការផ្តល់អត្ថប្រយោជន៍ និងការដាក់វិន័យចំពោះបុគ្គលិករបស់គណៈមេធាវី និងកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិក ។

ប្រការ៣ .- វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពសម្រាប់អនុវត្តចំពោះបុគ្គលិកទាំងអស់របស់គណៈមេធាវី លើកលែងតែបុគ្គលិកមួយចំនួនដែលក្នុងនោះរួមមាន បុគ្គលិកម្តងម្កាល បុគ្គលិកជំនួស បុគ្គលិកស្ម័គ្រចិត្ត អ្នកផ្តល់ប្រឹក្សា អ្នកហាត់ការ និងអ្នកចុះកម្មសិក្សានៅក្នុងក្របខណ្ឌគណៈមេធាវី ។

ប្រការ៤ .- និយមន័យ

បុគ្គលិកគណៈមេធាវី ក្នុងន័យនេះសំដៅដល់ប្រធានគណៈមេធាវី អគ្គលេខាធិការគណៈមេធាវី បុគ្គលិកចំណុះអគ្គលេខាធិការដ្ឋានគណៈមេធាវី នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងបុគ្គលិកចំណុះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី លើកលែងតែមានកំណត់ច្បាស់លាស់ក្នុងប្រការណាមួយជាក់លាក់នៃសេចក្តីសម្រេចនេះ ។

ជំពូកទី ២

ការជ្រើសរើសបុគ្គលិក

ផ្នែកទី១

គោលការណ៍រួម

ប្រការ៥ .- គោលការណ៍នៃការជ្រើសរើសបុគ្គលិក

ក្នុងការជ្រើសរើសបុគ្គលិកគណៈមេធាវីថ្មី ឬជំនួស លើកលែងតែប្រធានគណៈមេធាវី ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក.ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃសកម្មភាព និងគម្រោងវិការបស់គណៈមេធាវី ។

ខ.បេក្ខជនត្រូវមានសមត្ថភាព និងជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាពរបស់គណៈមេធាវីឱ្យមានប្រសិទ្ធភាព ។

គ.ត្រូវមានភាពយុត្តិធម៌ តម្លាភាព ស្មើភាព សមភាពយេនឌ័រ ពុំមានការរើសអើង និងពុំមានទំនាស់ផលប្រយោជន៍ ។

ឃ.ត្រូវអនុវត្តតាមនីតិវិធី ដែលបានកំណត់ក្នុងគោលនយោបាយបុគ្គលិកនេះ ។

ប្រការ៦ .- ទំនាស់ផលប្រយោជន៍

បេក្ខជនដែលមានទំនាក់ទំនងជាញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់បុគ្គលិកគណៈមេធាវីមិនត្រូវបានជ្រើសរើសឱ្យចូលបំរើការងារនៅគណៈមេធាវីជាដាច់ខាត ។

ប្រការ៧ .- នីតិវិធីនៃការជ្រើសរើសបុគ្គលិក

លើកលែងតែប្រធានគណៈមេធាវី នីតិវិធីនៃការជ្រើសរើសបុគ្គលិកធ្វើតាមលំដាប់ដូចខាងក្រោម៖

ក.ការជ្រើសរើសបុគ្គលិកត្រូវពិនិត្យជាបឋមលើចំនួនបុគ្គលិក ដោយត្រូវអនុលោមតាមចំនួនដែលបានកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី ។

ខ.ការប្រកាសជ្រើសរើសបុគ្គលិកត្រូវ ផ្សព្វផ្សាយជាសាធារណៈ ។ ចំពោះការផ្សព្វផ្សាយអាចធ្វើតាមរយៈទំព័រហ្វេសប៊ុករបស់គណៈមេធាវី គេហទំព័ររបស់គណៈមេធាវី សារព័ត៌មាន ឬវិទ្យុ ។

គ.បេក្ខជនដែលបំពេញបានតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ ត្រូវមកដាក់ពាក្យ ដោយភ្ជាប់មកជាមួយនូវឯកសារដូចបានកំណត់ក្នុងការប្រកាសផ្សព្វផ្សាយ ។

ឃ.បេក្ខជនត្រូវឆ្លងកាត់ការសម្ភាសន៍ដោយផ្ទាល់មាត់ ឬទាំងវិញ្ញាសាសរសេរនិងផ្ទាល់មាត់ ដោយ

គណៈកម្មការជ្រើសរើស ដែលមានសមាសភាព ៣(បី)រូប រួមមាន អគ្គលេខាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល និងប្រធាននាយកដ្ឋានពាក់ព័ន្ធ ឬគណៈកម្មការជ្រើសរើសដែលបង្កើតដោយនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី លើកលែងតែអគ្គលេខាធិការគណៈមេធាវី និងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដែលអាចមិនចាំបាច់ឆ្លងកាត់ការសម្ភាសដោយគណៈកម្មការជ្រើសរើស ។

ង. ដោយផ្អែកលើលទ្ធផលនៃកិច្ចសម្ភាសប្រធានគណៈមេធាវីនឹងតែងតាំងបេក្ខជននោះជាបុគ្គលិក ។

ផ្នែកទី២

អគ្គលេខាធិការដ្ឋានគណៈមេធាវី

ប្រការ៩ .- ការជ្រើសរើសអគ្គលេខាធិការគណៈមេធាវី

អគ្គលេខាធិការគណៈមេធាវីត្រូវទទួលបានសេចក្តីទុកចិត្តពីក្រុមប្រឹក្សាគណៈមេធាវី ។ តំណែងអគ្គលេខាធិការគណៈមេធាវីមិនមានអាណត្តិដូចប្រធានគណៈមេធាវី ឬក្រុមប្រឹក្សាគណៈមេធាវីឡើយ ។

ប្រធានគណៈមេធាវីត្រូវកំណត់លក្ខខណ្ឌ និងគុណវុឌ្ឍិនៃបេក្ខជនអគ្គលេខាធិការគណៈមេធាវី ។

បន្ទាប់ពីបានពិនិត្យ និងអនុវត្តតាមគោលការណ៍រួមដូចបានកំណត់ក្នុងផ្នែកទី១ ខាងលើរួចហើយ ប្រធានគណៈមេធាវីត្រូវជ្រើសរើសបេក្ខជនអគ្គលេខាធិការដែលមានសក្តានុពលចំនួន២ (ពីរ) រូប យ៉ាងតិចដើម្បីស្នើសុំសេចក្តីទុកចិត្តពីក្រុមប្រឹក្សាគណៈមេធាវីក្នុងកិច្ចប្រជុំបន្ទាប់ ។ ក្រោយពីទទួលបានសេចក្តីទុកចិត្តពីក្រុមប្រឹក្សាគណៈមេធាវី ប្រធានគណមេធាវីត្រូវតែងតាំងបេក្ខជននោះជាអគ្គលេខាធិការគណៈមេធាវី ។

ក្នុងអំឡុងពេលរង់ចាំការផ្តល់សេចក្តីទុកចិត្តពីក្រុមប្រឹក្សាគណៈមេធាវី ប្រធានគណៈមេធាវីមានសិទ្ធិតែងតាំងអគ្គលេខាធិការស្តីទី ។ ប៉ុន្តែការតែងតាំងអគ្គលេខាធិការស្តីទីនេះមិនត្រូវមានរយៈពេលលើសពី ១(មួយ)ខែឡើយ ។

ប្រការ១០ .- ការជ្រើសរើសបុគ្គលិក

បុគ្គលិកចំណុះអគ្គលេខាធិការដ្ឋានគណៈមេធាវី ចាប់ពីថ្នាក់អគ្គលេខាធិការរងចុះត្រូវជ្រើសរើសដោយប្រធានគណៈមេធាវី ដោយអនុវត្តតាមគោលការណ៍រួមដូចបានកំណត់ក្នុងផ្នែកទី១ ខាងលើ ។ ប្រធានគណៈមេធាវីអាចបង្កើតគណៈកម្មការជ្រើសរើស ដើម្បីជួយប្រធានក្នុងការជ្រើសរើសបុគ្គលិក ។

ផ្នែកទី៣

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ប្រការ១១ .- ការជ្រើសរើសនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវជ្រើសរើសដោយក្រុមប្រឹក្សាគណមេធាវី។ តំណែងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីមិនមានអាណត្តិដូចប្រធានគណៈមេធាវី ឬក្រុមប្រឹក្សាគណៈមេធាវីឡើយ។ បេក្ខជនសម្រាប់តំណែងនេះត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

ក. មានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់។

ខ. ជាមេធាវីដែលបានចុះបញ្ជីគណៈមេធាវីយ៉ាងតិច១០(ដប់)ឆ្នាំ។

គ. មានបទពិសោធន៍បង្រៀនមុខវិជ្ជាផ្នែកច្បាប់នៅតាមសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីយ៉ាងតិច៥(ប្រាំ)ឆ្នាំ។

ឃ. ពុំធ្លាប់ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ ឬទទួលរងនូវទណ្ឌកម្មវិន័យណាមួយពីក្រុមប្រឹក្សាគណៈមេធាវី។

បន្ទាប់ពីអនុវត្តតាមគោលការណ៍រួមដូចបានកំណត់ក្នុងផ្នែកទី១ខាងលើរួចហើយ ប្រធានគណៈមេធាវីត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនទាំងអស់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវី ដើម្បីបោះឆ្នោតជ្រើសរើសនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីក្នុងកិច្ចប្រជុំបន្ទាប់ ដោយផ្អែកលើគុណវុឌ្ឍិនៃបេក្ខជនដូចបានកំណត់ក្នុងកថាខណ្ឌខាងលើ។

ក្រោយពីក្រុមប្រឹក្សាគណៈមេធាវីបោះឆ្នោតជ្រើសរើសរួចហើយ ប្រធានគណៈមេធាវីត្រូវតែងតាំងបេក្ខជននោះជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

ក្នុងអំឡុងពេលរង់ចាំការបោះឆ្នោតជ្រើសតាំងពីក្រុមប្រឹក្សាគណៈមេធាវី ប្រធានគណៈមេធាវីមានសិទ្ធិតែងតាំងនាយកស្តីទីនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ប៉ុន្តែការតែងតាំងនាយកស្តីទីនេះមិនត្រូវមានរយៈពេលលើសពី១(មួយ)ខែឡើយ។

ប្រការ១២ .- ការជ្រើសរើសបុគ្គលិក

បុគ្គលិកចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវជ្រើសរើស ដោយនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដោយអនុវត្តតាមគោលការណ៍រួមដូចបានកំណត់ក្នុងផ្នែកទី១ខាងលើ។ នាយក

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីអាចបង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីជួយនាយកក្នុងការជ្រើសរើសបុគ្គលិក។

ជំពូកទី ៣
កិច្ចសន្យាការងារ

ប្រការ១៣ .- កិច្ចសន្យាការងារ

មុននឹងបំពេញការងារក្នុងគណៈមេធាវី រាល់បុគ្គលិក និងអ្នកដែលមិនមែនជាបុគ្គលិកត្រូវចុះកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជាមួយគណៈមេធាវី ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

កិច្ចសន្យាការងារអាចជាកិច្ចសន្យាមានកំណត់ថិរវេលា ឬកិច្ចសន្យាមានថិរវេលាមិនកំណត់ អាស្រ័យលើការសម្រេចរបស់ប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ១៤ .- កិច្ចសន្យាការងារសាកល្បង

ដំណាក់កាលសាកល្បងការងារ មានគោលបំណងផ្តល់នូវពេលវេលាគ្រប់គ្រាន់ ដើម្បីវាយតម្លៃសមត្ថភាពរបស់បុគ្គលិកថ្មីសម្រាប់មុខដំណែងនោះ ក៏ដូចជាផ្តល់នូវពេលវេលាដល់គណៈមេធាវី ដើម្បីធ្វើការវាយតម្លៃអំពីសមត្ថភាព ទេពកោសល្យ លក្ខណៈសម្បត្តិ អាកប្បកិរិយា និងការព្យាយាមរបស់បុគ្គលិកសាកល្បង។ រយៈពេលសាកល្បងមានចំនួន ៣(បី)ខែ។ ការបន្ត ឬផ្តាច់កិច្ចសន្យាសាកល្បងត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការងារ។

ប្រការ១៥ .- ទម្រង់កិច្ចសន្យាការងារ

កិច្ចសន្យាការងារ ឬឧបសម្ព័ន្ធនៃកិច្ចសន្យាការងារ យ៉ាងហោចណាស់ត្រូវគ្របដណ្តប់លើចំណុចដូចខាងក្រោមនេះ៖

- អត្តសញ្ញាណប័ណ្ណ ឬ សំបុត្រកំណើតរបស់បុគ្គលិក
- ព័ត៌មានលម្អិតអំពីទីកន្លែងស្នាក់នៅ និងលេខទូរស័ព្ទទំនាក់ទំនង
- អត្តសញ្ញាណរបស់បុគ្គលិក
- ប្រាក់ប្រៃវត្សរ៍
- ម៉ោងធ្វើការ និងការឈប់សម្រាក(ប្រចាំឆ្នាំ ឬបុណ្យជាតិនិងអន្តរជាតិ)
- រយៈពេលបម្រើការងារ
- រយៈពេលសាកល្បងការងារ

- ប្រាក់ឧបត្ថម្ភនិងអត្ថប្រយោជន៍នានា
- ការបញ្ចប់កិច្ចសន្យា រួមទាំងប្រាក់បំណាច់បញ្ចប់ការងារ
- ប្រការស្តីពីការសម្ងាត់
- កាលបរិច្ឆេទនិងទីកន្លែងនៃការចុះហត្ថលេខា
- ហត្ថលេខារបស់ប្រធានគណៈមេធាវី និងបុគ្គលិក ។

ជំពូកទី ៤

ការទទួលខុសត្រូវរបស់បុគ្គលិក

ប្រការ១៦ .- ម៉ោងធ្វើការងារ

បុគ្គលិកគណៈមេធាវីត្រូវបំពេញការងារ ៧,៥ (ប្រាំពីរក្បៀសប្រាំ)ម៉ោងក្នុងមួយថ្ងៃ ដែលត្រូវជា ៣៧.៥(សាមសិបប្រាំពីរក្បៀសប្រាំ)ម៉ោងក្នុងមួយសប្តាហ៍ ដោយចាប់ពីម៉ោង៨ ព្រឹក ដល់១២ថ្ងៃត្រង់ និងពីម៉ោង១:៣០ ដល់ម៉ោង ៥ ល្ងាច ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ។ លើកលែងតែបុគ្គលិកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដែលត្រូវធ្វើការតាមកាលវិភាគជាក់ស្តែងរបស់មជ្ឈមណ្ឌល និងបុគ្គលិកសន្តិសុខ ដែលត្រូវធ្វើការតាមការចរចា និងតាមការព្រមព្រៀងដែលបានកំណត់ក្នុងកិច្ចសន្យាការងារ ។

បុគ្គលិកអាចធ្វើការថែមម៉ោងតាមការកំណត់របស់ប្រធានគណៈមេធាវី និងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការងារថែមម៉ោង ដោយអនុលោមតាមគោលនយោបាយហិរញ្ញវត្ថុរបស់គណៈមេធាវី និងបទប្បញ្ញត្តិជាធរមាន ។

ប្រការ១៧ .- ការអនុវត្តការងារ

បុគ្គលិកត្រូវបំពេញការងារដែលបញ្ជាដោយអ្នកគ្រប់គ្រង និងប្រធានគណៈមេធាវី ស្របតាមភារកិច្ចដែលបានកំណត់ក្នុងកិច្ចសន្យាការងារ និងតារាងពិពណ៌នាការងារដែលភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចសន្យានោះ ។

ប្រការ១៨ .- ទិន្នន័យការងារ

បុគ្គលិកចំណុះអគ្គលេខាធិការគណៈមេធាវីត្រូវគោរពពេលម៉ោងធ្វើការ កិច្ចសន្យាការងារ និងវិធានផ្សេងៗទៀតដែលកំណត់ដោយគណៈមេធាវី ។

បុគ្គលិកចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវគោរពពេលម៉ោងធ្វើការ កិច្ចសន្យាការងារ និងវិធានផ្សេងៗទៀតដែលកំណត់ដោយគណៈមេធាវី និងដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។

ជំពូកទី ៥

ការឈប់សម្រាក និងការសុំច្បាប់

ប្រការ១៩ .- ការឈប់សម្រាកប្រចាំសប្តាហ៍

បុគ្គលិកគណៈមេធាវីមានសិទ្ធិឈប់សម្រាកប្រចាំសប្តាហ៍ គឺត្រូវឈប់សម្រាកនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដោយមានប្រាក់ប្សេវត្សរ៍។

ប៉ុន្តែអ្នកគ្រប់គ្រង និងប្រធានគណៈមេធាវីអាចសុំបុគ្គលិកឱ្យបំពេញការងារដោយស្ម័គ្រចិត្តនៅថ្ងៃសៅរ៍ និង/ឬថ្ងៃអាទិត្យ ដោយឱ្យឈប់សម្រាកសងនៅថ្ងៃធ្វើការធម្មតា ឬទូទាត់ប្រាក់ធ្វើការបន្ថែមម៉ោងតាមការសម្រេចពីប្រធានគណៈមេធាវី។

ចំពោះបុគ្គលិកសន្តិសុខត្រូវអនុវត្តតាមការចរចា និងតាមការព្រមព្រៀង ដែលបានកំណត់ក្នុងកិច្ចសន្យាការងារ។

ប្រការ២០ .- ការឈប់សម្រាកបុណ្យសាធារណៈ

បុគ្គលិកគណៈមេធាវីមានសិទ្ធិឈប់សម្រាក ក្នុងឱកាសបុណ្យសាធារណៈតាមការកំណត់ក្នុងអនុក្រឹត្យស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ តាមឆ្នាំនីមួយៗ ដោយមានប្រាក់ប្សេវត្សរ៍។

ប៉ុន្តែអ្នកគ្រប់គ្រង និងប្រធានគណៈមេធាវីអាចសុំបុគ្គលិកឱ្យបំពេញការងារដោយស្ម័គ្រចិត្តនៅថ្ងៃឈប់សម្រាកបុណ្យសាធារណៈ ដោយឱ្យឈប់សម្រាកសងនៅថ្ងៃធ្វើការធម្មតា ឬទូទាត់ប្រាក់ធ្វើការបន្ថែមម៉ោង តាមការសម្រេចពីប្រធានគណៈមេធាវី។

ចំពោះបុគ្គលិកសន្តិសុខត្រូវអនុវត្តតាមការចរចា និងតាមការព្រមព្រៀង ដែលបានកំណត់ក្នុងកិច្ចសន្យាការងារ។

ប្រការ២១ .- ការឈប់សម្រាកប្រចាំឆ្នាំ

បុគ្គលិកគណៈមេធាវីមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំចំនួន១,៥(មួយក្បៀសប្រាំ)ថ្ងៃក្នុងមួយខែ ស្មើនឹង១៨(ដប់ប្រាំបី)ថ្ងៃក្នុងមួយឆ្នាំ ហើយត្រូវបានបង្កើនចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ដោយអនុលោមតាមច្បាប់ស្តីពីការងារ។

ការឈប់សម្រាកប្រចាំឆ្នាំនេះអាចលើកទៅឆ្នាំក្រោយបានយ៉ាងច្រើនបំផុតតែចំនួន ៦(ប្រាំមួយ)ថ្ងៃប៉ុណ្ណោះ។ បុគ្គលិកដែលមានបំណងប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំត្រូវដាក់ពាក្យសុំមកប្រធាន

គណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីយ៉ាងតិច ២ (ពីរ)ថ្ងៃមុនការឈប់ ហើយអាចប្រើប្រាស់បានលុះត្រាតែមានការយល់ព្រមពីប្រធានគណៈមេធាវី ឬពីនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ រាល់ការអនុញ្ញាតត្រូវជូនដំណឹងមកនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល ឬផ្នែករដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីចុះបញ្ជី។

ប្រការ២២ .- ការឈប់សម្រាកពិសេស

បុគ្គលិកគណៈមេធាវីមានសិទ្ធិឈប់សម្រាកពិសេសមិនលើសពី ៧(ប្រាំពីរ)ថ្ងៃ ក្នុងមួយឆ្នាំ ដោយមានប្រាក់ប្សៀវត្សរ៍ ដោយត្រូវស្នើសុំមកប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ រាល់ការអនុញ្ញាតត្រូវជូនដំណឹងមកនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល ឬផ្នែករដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីចុះបញ្ជី។ ការឈប់សម្រាកពិសេសនេះត្រូវកាត់ចេញពីការឈប់សម្រាកប្រចាំឆ្នាំ។ ត្រូវបានអនុញ្ញាតឱ្យបុគ្គលិកខ្ចីការឈប់សម្រាកប្រចាំឆ្នាំនៃឆ្នាំបន្ទាប់ មកប្រើសម្រាប់ការឈប់សម្រាកពិសេស ក្នុងករណីបុគ្គលិករូបនោះបានប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំអស់ហើយ។

ព្រឹត្តិការណ៍ដែលត្រូវកំណត់អំពីអត្ថន័យនៃការឈប់សម្រាកពិសេសនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ២៣ .- ការឈប់សម្រាកដោយមានជម្ងឺ

បុគ្គលិកគណៈមេធាវីដែលមានជម្ងឺត្រូវបានអនុញ្ញាតឱ្យឈប់មិនលើសពី ១៥(ដប់ប្រាំ)ថ្ងៃក្នុងមួយឆ្នាំ។ ករណីឈប់លើសពីនេះត្រូវមានលិខិតពេទ្យផ្លូវការ និងមានការអនុញ្ញាតពីប្រធានគណៈមេធាវី។

បុគ្គលិកថ្នាក់ក្រោមអនុប្រធាននាយកដ្ឋាន ដែលមានជម្ងឺត្រូវជូនដំណឹងដោយផ្ទាល់ខ្លួន ឬតាមរយៈសាច់ញាតិតាមគ្រប់មធ្យោបាយសមស្រប មកប្រធាននាយកដ្ឋាន ប្រសិនបើឈប់មិនលើសពី១(មួយ)ថ្ងៃ ហើយត្រូវជូនដំណឹងមកប្រធានគណៈមេធាវី ប្រសិនបើការឈប់លើសពី១(មួយ)ថ្ងៃ។ ចំពោះអនុប្រធាននាយកដ្ឋាន ប្រធាននាយកដ្ឋាន ជំនួយការប្រធានគណៈមេធាវី អគ្គលេខាធិការរង អគ្គលេខាធិការ ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដែលមានជម្ងឺត្រូវជូនដំណឹងដោយផ្ទាល់ខ្លួន ឬតាមរយៈសាច់ញាតិតាមគ្រប់មធ្យោបាយសមស្របមកប្រធានគណៈមេធាវី។ រាល់ការអនុញ្ញាតត្រូវជូនដំណឹងមកនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ដើម្បីចុះបញ្ជី។

បុគ្គលិកចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដែលមានជម្ងឺត្រូវជូនដំណឹងដោយផ្ទាល់ខ្លួន ឬតាមរយៈសាច់ញាតិតាមគ្រប់មធ្យោបាយសមស្រប មកនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

រាល់ការអនុញ្ញាតត្រូវជូនដំណឹងមកផ្នែករដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីចុះបញ្ជី

ការឈប់ដោយមានជម្ងឺតិចជាង ឬស្មើមួយខែត្រូវរក្សាប្រាក់ប្សេវត្សរ៍។

ការឈប់ដោយមានជម្ងឺលើសពីមួយខែដល់តិចជាង ប្លែស្មើបីខែត្រូវទទួលបានប្រាក់ប្សេវត្សរ៍ចំនួន ៦0%(ហុកសិបភាគរយ)។

ការឈប់ដោយមានជម្ងឺលើសពីបីខែដល់តិចជាង ឬស្មើប្រាំមួយខែពុំទទួលបានប្រាក់ប្សេវត្សរ៍ឡើយ តែត្រូវរក្សាទុកដំណែងដដែល។ ការឈប់ដោយមានជម្ងឺលើសពីប្រាំមួយខែ ប្រធានគណៈមេធាវីមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារ ដោយពុំទទួលបានសំណងឡើយ។

ប្រការ២៤ .- ការឈប់សម្រាកលំហែមាតុភាព

បុគ្គលិកគណៈមេធាវីជាស្ត្រីមានសិទ្ធិឈប់លំហែមាតុភាពចំនួន ៣(បី)ខែ ដោយទទួលបានប្រាក់ប្សេវត្សរ៍ ១00% (មួយរយភាគរយ)។ មុនឈប់សម្រាកលំហែមាតុភាព សាមីខ្លួនត្រូវដាក់ពាក្យសុំមកប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ត្រូវជូនដំណឹងអំពីការឈប់សម្រាកលំហែមាតុភាពនេះមកនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល ឬផ្នែករដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីចុះបញ្ជី។

ប្រការ២៥ .- ការសុំច្បាប់មានធុរៈផ្សេងៗ

បុគ្គលិកគណៈមេធាវីដែលមានធុរៈអាចសុំច្បាប់ឈប់បាន ប្រសិនបើមានមូលហេតុសមស្រប។

បុគ្គលិកថ្នាក់ក្រោមអនុប្រធាននាយកដ្ឋាន ត្រូវសុំច្បាប់មកប្រធាននាយដ្ឋានរបស់សាមីខ្លួន ប្រសិនបើការសុំច្បាប់នេះមិនលើសពី១(មួយ)ថ្ងៃ ហើយត្រូវសុំច្បាប់មកប្រធានគណៈមេធាវី ប្រសិនបើការសុំច្បាប់ឈប់លើសពី១(មួយ)ថ្ងៃ។

បុគ្គលិកជាអនុប្រធាននាយកដ្ឋាន ប្រធាននាយដ្ឋាន ជំនួយការប្រធានគណៈមេធាវី អគ្គលេខាធិការរង អគ្គលេខាធិការ ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវសុំច្បាប់មកប្រធានគណៈមេធាវី។

បុគ្គលិកចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ត្រូវសុំច្បាប់មកនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

រាល់ការអនុញ្ញាតត្រូវជូនដំណឹងមកនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ឬផ្នែករដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីចុះបញ្ជី។

ជំពូកទី ៦

ការលើកទឹកចិត្ត និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

ប្រការ២៦ .- ការតំឡើងប្រាក់ឈ្នៀតត្បូរ

បុគ្គលិកគណៈមេធាវីត្រូវឆ្លងកាត់ការវាយតម្លៃប្រចាំឆ្នាំ។ ទម្រង់ និងនីតិវិធីនៃការវាយតម្លៃប្រចាំឆ្នាំត្រូវកំណត់ដោយប្រធានគណៈមេធាវី។

ការតំឡើងប្រាក់ឈ្នៀតត្បូរត្រូវអនុលោមតាមធនធាន គម្រោងថវិកាប្រចាំឆ្នាំ គោលនយោបាយ ហិរញ្ញវត្ថុរបស់គណៈមេធាវី និងលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំរបស់បុគ្គលិកម្នាក់ៗ។

ប្រការ២៧ .- ប្រាក់រង្វាន់ប្រចាំឆ្នាំ

នៅបំណាច់ឆ្នាំនីមួយៗ បុគ្គលិកគណៈមេធាវីអាចទទួលបានប្រាក់រង្វាន់លើកទឹកចិត្តស្មើនឹងចំនួនប្រាក់ឈ្នៀតត្បូរបស់ខ្លួន១ខែ ទៅតាមគម្រោងថវិកាប្រចាំឆ្នាំ។ ប្រាក់នេះត្រូវបើកនៅពេលបុណ្យចូលឆ្នាំប្រពៃណីជាតិចំនួនកន្លះខែ និងនៅពេលបុណ្យភ្ជុំបិណ្ឌចំនួនកន្លះខែ។

ប្រការ២៨ .- ការបណ្តុះបណ្តាលបុគ្គលិក

បុគ្គលិកគណៈមេធាវីអាចទទួលបានការគាំទ្រពីគណៈមេធាវី ដើម្បីបណ្តុះបណ្តាលបន្ថែមលើមុខវិជ្ជាណាមួយដែលចាំបាច់ សម្រាប់បំពេីការងាររបស់គណៈមេធាវី ដោយមានការឆ្លងយោបល់ពីប្រធានគ្រប់គ្រងផ្ទាល់លើបុគ្គលិកនោះ និងសម្រេចដោយប្រធានគណៈមេធាវី។ ការចំណាយនេះមិនអាចលើសពី ៣០០(បីរយ)ដុល្លារអាមេរិកសម្រាប់បុគ្គលិកម្នាក់ ហើយមិនអាចលើសពីពានាក់ក្នុង១ឆ្នាំ។

ជំពូកទី ៧

សុខភាព សុវត្ថិភាព និងអនាម័យ

ប្រការ២៩ .- សុខភាព សុវត្ថិភាពការងារ និងអនាម័យ

បុគ្គលិកគណៈមេធាវីត្រូវបានលើកកម្ពស់ និងយកចិត្តទុកដាក់ពីសំណាក់គណៈមេធាវីទៅលើសុខភាព សុវត្ថិភាព និងអនាម័យនៅកន្លែងការងារ ស្របតាមបទប្បញ្ញត្តិស្តីពីការងារជាធរមាន។

ប្រការ៣០ .- ការធានារ៉ាប់រងចំពោះបុគ្គលិក

បុគ្គលិកគណៈមេធាវីត្រូវបានធានារ៉ាប់រងលើផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

ការធានានេះត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិស្តីពីរបបសន្តិសុខសង្គម ដោយអនុលោមតាមគោលការណ៍របស់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីបទប្បញ្ញត្តិស្តីពីរបបសន្តិសុខសង្គម បានដាក់ឱ្យអនុវត្តទៅលើផ្នែកណាមួយផ្សេងទៀតក្រៅអំពីផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព គណៈមេធាវីនឹងអនុវត្តតាម ដើម្បីធានានូវផលប្រយោជន៍របស់បុគ្គលិក។

ជំពូកទី ៨

ប្រភេទកំហុស កំរិតទណ្ឌកម្ម នីតិវិធីនៃការដាក់ទិន្ន័យ និងដោះស្រាយវិវាទ

ប្រការ៣១ .- ប្រភេទនៃកំហុស និងកម្រិតទណ្ឌកម្ម

កំហុសការងារមាន២(ពីរ)ប្រភេទកំហុសស្រាល និងកំហុសធ្ងន់។

ទណ្ឌកម្មមាន៤(បួន)កម្រិតគឺ៖

ក.ការស្តីបន្ទោសផ្ទាល់មាត់។

ខ.ការព្រមានជាលាយលក្ខណ៍អក្សរ។

គ.ការព្យួរកិច្ចសន្យាការងារ។

ឃ.ការបញ្ឈប់ពីការងារ។

ទណ្ឌកម្មសម្រាប់កំហុសស្រាលមាន៣(បី)កម្រិតគឺ៖

ក.ការស្តីបន្ទោសផ្ទាល់មាត់។

ខ.ការព្រមានជាលាយលក្ខណ៍អក្សរ។

គ.ការព្យួរកិច្ចសន្យាការងារ។

ទណ្ឌកម្មសម្រាប់កំហុសធ្ងន់មាន១(មួយ)កម្រិតគឺ ការបញ្ឈប់ពីការងារ។

ប្រការ៣២ .- កំហុសស្រាល

កំហុសស្រាលរួមមាន៖

ក- ការមិនគោរពម៉ោងការងារ។

ខ- ការខ្ជីខ្ជា ឬធ្វេសប្រហែសក្នុងការងារ។

គ- ការឈប់គ្មានច្បាប់ក្រោម៦(ប្រាំមួយ)ថ្ងៃក្នុងមួយឆ្នាំ។

ឃ-ការមិនគោរពសណ្តាប់ធ្នាប់នៅកន្លែងការងារ។

ង-ការមិនបំពេញការងារតាមបញ្ជា។

ច-កំហុសផ្សេងទៀតដែលកំណត់ដោយប្រធានគណៈមេធាវី ។

ការសម្រេចអំពីកម្រិតនៃទណ្ឌកម្មវិន័យសម្រាប់កំហុសស្រាល របស់បុគ្គលិកនៃអគ្គលេខាធិការគណៈមេធាវី ជាសមត្ថកិច្ចរបស់ប្រធានគណៈមេធាវី ឬគណៈកម្មការវិន័យ ដែលបង្កើតឡើងដោយប្រធានគណៈមេធាវី ។

ការសម្រេចអំពីកម្រិតនៃទណ្ឌកម្មវិន័យសម្រាប់កំហុសស្រាល របស់បុគ្គលិកនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ជាសមត្ថកិច្ចរបស់នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឬគណៈកម្មការវិន័យ ដែលបង្កើតឡើងដោយនាយកមជ្ឈមណ្ឌល ។

ប្រការ៣៣ .- កំហុសធ្ងន់

កំហុសធ្ងន់រួមមាន៖

ក-ការប្រព្រឹត្តកំហុសទាំងឡាយដូចបានកំណត់ក្នុងមាត្រា៨៣ នៃច្បាប់ស្តីពីការងារ ។

ខ-ការបំពានលើវិធានវិន័យដូចបានកំណត់ក្នុងប្រការ៣៤ ខាងក្រោម ។

គ-ការឈប់គ្មានច្បាប់ដែលសរុបក្នុងមួយឆ្នាំចាប់ពី៦(ប្រាំមួយ)ថ្ងៃឡើងទៅ ។

ឃ-ការព្រមានជាលាយលក្ខណ៍អក្សរចំនួនបីដងក្នុងមួយឆ្នាំ ។

ង-ការប្រព្រឹត្តកំហុសស្រាលណាមួយ នៅក្នុងអំឡុងពេលមួយឆ្នាំ គិតចាប់ពីទទួលរងនូវទណ្ឌកម្មព្យួរការងារមួយរយៈ ។

ប្រការ៣៤ .- វិធានវិន័យ

នៅកន្លែងការងារ ឬនៅក្នុងពេលបំពេញការងារ បុគ្គលិកគណៈមេធាវីត្រូវគោរពនូវវិធានវិន័យដូចខាងក្រោម៖

ក-ហាមប្រើគ្រឿងញៀន ផឹកគ្រឿងស្រវឹង ឬលេងល្បែងស៊ីសងគ្រប់ប្រភេទ ។

ខ-ហាមប្រើហិង្សា និយាយឡូឡា ឈ្លោះប្រកែកគ្នា ជេរប្រមាថ បៀតបៀនផ្លូវភេទ ឬប្រព្រឹត្តនូវអំពើដែលគ្មានសីលធម៌ ។

គ-ហាមបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់គណៈមេធាវី និងទ្រព្យសម្បត្តិរបស់បុគ្គលិកដទៃ ។

ឃ-ហាមបង្កនូវអំពើដែលបណ្តាលឱ្យខូចនូវសណ្តាប់ធ្នាប់នៅកន្លែងការងារ ។

ង-ការឈប់គ្មានច្បាប់ដែលសរុបក្នុងមួយឆ្នាំចាប់ពី៧(ប្រាំពីរ)ថ្ងៃឡើងទៅ ។

ក្រៅពីវិធានវិន័យខាងលើ ប្រធានគណៈមេធាវីអាចកំណត់អំពីប្រភេទនៃវិធានវិន័យផ្សេងៗបន្ថែមទៀតបាន។

ការប្រព្រឹត្តបំពានលើចំណុចណាមួយនៃវិធានវិន័យដែលបានកំណត់ក្នុងកថាខណ្ឌទី១ និងទី២ ខាងលើត្រូវចាត់ទុកជាកំហុសធ្ងន់ ដែលត្រូវបញ្ឈប់ពីការងារ។

ប្រការ៣៥ .- ទិន័យការងារ

នៅកន្លែងការងារ ឬនៅក្នុងពេលបំពេញការងារ បុគ្គលិកគណៈមេធាវីត្រូវគោរពជាដាច់ខាតនូវវិធានវិន័យ និងបទបញ្ជាការងារទាំងអស់ដែលបានកំណត់ក្នុងច្បាប់ស្តីពីការងារ ជាពិសេសបទបញ្ជាដែលទាក់ទងនឹងសុខភាព សុវត្ថិភាព និងអនាម័យនៅកន្លែងការងារ។

បុគ្គលិកគណៈមេធាវីត្រូវគោរពពេលម៉ោងធ្វើការ កិច្ចសន្យាការងារ និងវិធានផ្សេងៗទៀតដែលកំណត់ដោយគណៈមេធាវី។

ប្រការ៣៦ .- សិទ្ធិរបស់បុគ្គលិក

បុគ្គលិកគណៈមេធាវីដែលរងការចោទប្រកាន់ មានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់បុគ្គលិកណាមួយ ឬពឹងពាក់មេធាវីឱ្យអមខ្លួននៅចំពោះមុខគណៈកម្មការវិន័យ ឬប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

ប្រការ៣៧ .- នីតិវិធីនៃការដាក់ទិន័យ

មុននឹងពិនិត្យលើទណ្ឌកម្មវិន័យចំពោះបុគ្គលិកគណៈមេធាវីណាមួយ ប្រធានគណៈមេធាវីមានសិទ្ធិបង្កើតគណៈកម្មការវិន័យ ដើម្បីស៊ើបអង្កេត និងលើកយោបល់ជូនប្រធានគណៈមេធាវីសម្រេច។

ការដាក់ទណ្ឌកម្មវិន័យចំពោះអគ្គលេខាធិការគណៈមេធាវី និងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាគណៈមេធាវី តាមសំណើរបស់ប្រធានគណៈមេធាវី។

ការដាក់ទណ្ឌកម្មវិន័យចំពោះបុគ្គលិកគណៈមេធាវីក្រៅពីអគ្គលេខាធិការ និងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ជាសមត្ថកិច្ចរបស់ប្រធានគណៈមេធាវី។

ការដាក់ទណ្ឌកម្មវិន័យចំពោះបុគ្គលិកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ជាសមត្ថកិច្ចរបស់នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ហើយក្នុងករណីបញ្ឈប់ពីការងារ នាយកត្រូវស្នើសុំសេចក្តីសម្រេចពីប្រធានគណៈមេធាវី។

ប្រការ៣៨ .- ការប្តឹងតវ៉ា

បុគ្គលិកគណៈមេធាវីដែលទទួលរងនូវការដាក់វិន័យមានសិទ្ធិប្តឹងតវ៉ាស្របតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី ៩

ការបញ្ចប់កិច្ចសន្យាការងារ

ប្រការ៣៩ .- ការលាលែងពីការងារ

បុគ្គលិកគណៈមេធាវី ដែលមានបំណងលាលែងពីការងារត្រូវជូនដំណឹងមកប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីយ៉ាងតិច ២ (ពីរ)ខែមុនពេលឈប់។ ក្នុងករណីដែលមិនអនុវត្តតាមចំណុចនេះ បុគ្គលិកនោះត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់គណៈមេធាវីទាំងស្រុង។

ប្រការ៤០ .- ការមិនបន្តកិច្ចសន្យាការងារ

ប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាការងារចំពោះបុគ្គលិកណាមួយ ក្នុងចិរវេលាដែលបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីការងារ ប្រសិនបើបុគ្គលិករូបនោះមិនត្រូវបានបន្តការងារ។ ក្នុងករណីនេះ គណៈមេធាវីត្រូវទូទាត់អត្ថប្រយោជន៍ជូនបុគ្គលិកនោះស្របតាមបទប្បញ្ញត្តិស្តីពីការងារ។

ប្រការ៤១ .- ការផ្តាច់កិច្ចសន្យាការងារ

ក្នុងករណីមានបុគ្គលិកណាមួយបានប្រព្រឹត្តកំហុសធ្ងន់ ដូចមានបញ្ជាក់ក្នុងបទប្បញ្ញត្តិស្តីពីការងារជាធរមាន គោលនយោបាយនេះ និងសេចក្តីសម្រេចរបស់ប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ប្រធានគណៈមេធាវី ឬនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីមានសិទ្ធិផ្តាច់កិច្ចសន្យាការងាររបស់បុគ្គលិកនោះបាន។

ជំពូកទី ១០

អនុសាសនប្បញ្ញត្តិ

ប្រការ៤២ .- ការធ្វើវិសោធនកម្ម

ការស្នើសុំវិសោធនកម្មអាចធ្វើឡើងបានតាមការស្នើសុំរបស់ប្រធានគណៈមេធាវី ឬសមាជិកក្រុមប្រឹក្សាគណៈមេធាវីយ៉ាងតិច៥(ប្រាំ)រូបឡើងទៅ។

ប្រការ៤៣ .- ការចូលជាធរមាន

គោលនយោបាយបុគ្គលិកនេះចូលជាធរមាន បន្ទាប់ពីក្រុមប្រឹក្សាគណៈមេធាវីបានអនុម័តដោយ សម្លេងភាគច្រើននិងចាប់ពីថ្ងៃប្រកាសដាក់ឱ្យអនុវត្តដោយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយនេះពុំមានអានុភាពប្រតិសកម្មឡើយ។


ប្រការ៤៤ .- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីគោលនយោបាយនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៤៥ .- ការអនុវត្ត

អគ្គលេខាធិការ និងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រ ធា ន



មេធាវី សួន-ទិសាល

ចម្លងជូន៖

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ៤៥
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី លី ចំន្ទគុណា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ធេង បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ឡូនគា
៦-មេធាវី ចេង ម៉េងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ភៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន្ទ ឥច្ចិត្រា
១៨-មេធាវី ព្រាប្ត ឥច្ចិត្រសុតា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យ៉ីម ថាវី
២១-មេធាវី ឱម ភៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំអ
៣២-មេធាវី ឡូន ជានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ០៩៨ /សសគម/២១

គោលនយោបាយស្តីពីការពិគ្រោះយោបល់ និងការការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ

សេចក្តីផ្តើម៖

គោលការណ៍ណែនាំនេះ មានចក្ខុវិស័យក្នុងការចូលរួមចំណែកធ្វើឱ្យមានប្រសិទ្ធភាពការងារដើម្បីជួយការពារក្តី និងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្រ ក៏ដូចជាសាធារណជនគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដែលត្រូវការជាចាំបាច់នូវជំនួយការផ្នែកច្បាប់ទូទៅ និងគ្រប់កិច្ចនីតិវិធីរបស់តុលាការគ្រប់ជាន់ថ្នាក់។ ក្នុងដំណើរការនេះ នាពេលកន្លងមកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈនាយកដ្ឋានការពារក្តីជូនជនក្រីក្របានអនុវត្តយ៉ាងល្អប្រសើរូចមកហើយ។ ប៉ុន្តែ ដើម្បីធានានិងពង្រីកបន្ថែមនូវវិសាលភាពនៃនាយកដ្ឋានការពារក្តីជូនជនក្រីក្រ ក្នុងការចូលរួមចំណែកបម្រើវិស័យយុត្តិធម៌សង្គមឱ្យកាន់តែទូលំទូលាយបន្តទៀត ក៏ដូចជាដើម្បីលើកស្ទួយឧត្តមភាពនិងកិត្យានុភាពគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីសូមដាក់ចេញនូវគោលនយោបាយមួយចំនួនបន្ថែមពីលើគោលការណ៍ដែលមានស្រាប់ដូចខាងក្រោម៖

គោលនយោបាយនេះ សំដៅលើការពង្រីកវិសាលភាព ក៏ដូចជាតួនាទីនៃនាយកដ្ឋានការពារក្តីជូនជនក្រីក្រ ក្នុងការចូលរួមបម្រើវិស័យយុត្តិធម៌សង្គម ដែលតាមរយៈនេះ នាយកដ្ឋានការពារក្តីជូនជនក្រីក្រនឹងលើកយកយន្តការចំនួនពីរ ដើម្បីធ្វើជាធាតុចម្បងនៃការពង្រីកវិសាលភាពរបស់ខ្លួន គឺ (១) ***ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្រ និងសាធារណជនទូទៅដោយមិនគិតកម្រៃ*** និង (២) ***ការការពារក្តីជូនជនក្រីក្រ ឬអ្នកខ្វះលទ្ធភាពដោយមិនគិតកម្រៃ*** ដែលមានខ្លឹមសារលម្អិតដូចខាងក្រោម៖

១/-ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្រ និងសាធារណជនទូទៅដោយមិនគិតកម្រៃ

ក្នុងយន្តការនៃការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្រ និងសាធារណជនទូទៅដោយមិនគិតកម្រៃនេះ នាយកដ្ឋានការពារក្តីជូនជនក្រីក្រផ្តោតសំខាន់ទៅលើ ៣ ចំណុចដូចខាងក្រោម៖

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

១/១- ប្រភេទនៃអ្នកអាចទទួលសេវាកម្ម

១-ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ជាជនក្រីក្រ ហើយជាប់ចោទពីបទឧក្រិដ្ឋ។

២-ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ជាអនីតិជន ហើយជាប់ចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម។

៣-ជនរងគ្រោះក្នុងបទឧក្រិដ្ឋ និងបទមជ្ឈិម គ្មានលទ្ធភាពរកមេធាវីការពារខ្លួនដោយខ្លួនឯងបាន។

៤-កម្មករ-កម្មការិនី។

៥-ស្ត្រី និងកុមារដែលជាជនសង្ស័យ ឬជាជនរងគ្រោះ។ និង

៦ -សាធារណៈជនគ្រប់ស្រទាប់វណ្ណៈដែលមានបំណងទទួលយកសេវាកម្មប្រឹក្សាយោបល់ផ្នែកច្បាប់។

១/២- អ្នកផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់

នាយកដ្ឋានការពារក្តីជូនជនក្រីក្រនឹងធ្វើការអំពាវនាវស្នើសុំឱ្យមេធាវីទាំងអស់ចូលរួមដោយស្ម័គ្រចិត្ត ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ដោយមិនគិតកម្រៃជូន៖

១-ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ជាជនក្រីក្រ ហើយជាប់ចោទពីបទឧក្រិដ្ឋ។

២-ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ជាអនីតិជន ហើយជាប់ចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម។

៣-ជនរងគ្រោះក្នុងបទឧក្រិដ្ឋ និងបទមជ្ឈិម គ្មានលទ្ធភាពរកមេធាវីការពារខ្លួនដោយខ្លួនឯងបាន។

៤-ស្ត្រី និងកុមារដែលជាជនសង្ស័យ ឬជាជនរងគ្រោះ។

៥-កម្មករ-កម្មការិនី។ និង

៦-សាធារណៈជនគ្រប់ស្រទាប់វណ្ណៈដែលមានបំណងទទួលយកសេវាកម្មប្រឹក្សាយោបល់ផ្នែកច្បាប់។

ចំពោះការស្ម័គ្រចិត្តនេះ នាយកដ្ឋានការពារក្តីជូនជនក្រីក្រ ស្នើសុំឱ្យមេធាវីស្ម័គ្រចិត្ត ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវីទាំងអស់ផ្តល់នូវតារាងកាលវិភាគអំពីពេលវេលា ម៉ោង និងទីតាំង ដែលខ្លួនអាចផ្តល់ការប្រឹក្សាបានមកនាយកដ្ឋានការពារក្តីជូនជនក្រីក្រ។ បន្ទាប់មកនាយកដ្ឋានការពារក្តីជូនជនក្រីក្រ នឹងរៀបចំបែងចែកតារាងកាលវិភាគចំពោះមេធាវីស្ម័គ្រចិត្តទាំងអស់ដែលត្រូវមកប្រចាំការ ឱ្យបានសមស្របទៅនឹងពេលវេលាដែលមេធាវីស្ម័គ្រចិត្តបានដាក់ជូននាយកដ្ឋានការពារក្តីជូនជនក្រីក្រ។

បន្ទាប់ពីគណៈមេធាវីទទួលបានចំនួនមេធាវីស្ម័គ្រចិត្តរួចរាល់ គណៈមេធាវីនឹងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនសាធារណជនគ្រប់ស្រទាប់វណ្ណៈបានដឹងនូវព័ត៌មាននេះ។

១/៣- អំពីទីតាំងផ្តល់ការពិគ្រោះយោបល់

ការពិគ្រោះយោបល់ផ្នែកច្បាប់អាចផ្តល់ជូនតាមរយៈការពិគ្រោះយោបល់ផ្នែកច្បាប់តាមប្រព័ន្ធទូរស័ព្ទ និងការពិគ្រោះយោបល់ផ្នែកច្បាប់នៅទីតាំងផ្ទាល់។

ក.ការពិគ្រោះយោបល់ផ្នែកច្បាប់តាមប្រព័ន្ធទូរស័ព្ទ

នាយកដ្ឋានការពារក្តីជូនជនក្រីក្រ បានធ្វើការបែងចែកចំពោះការពិគ្រោះយោបល់ផ្នែកច្បាប់តាមប្រព័ន្ធទូរស័ព្ទដូចខាងក្រោម៖

១-ប្រព័ន្ធទូរស័ព្ទបន្ទាន់ (Hotline) ដែលមានលេខទូរស័ព្ទ **១២៨១** រៀងរាល់ម៉ោងធ្វើការ ។

២-ប្រព័ន្ធទូរស័ព្ទផ្សេងទៀតដែលកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ.ការពិគ្រោះយោបល់ផ្នែកច្បាប់នៅទីតាំងផ្ទាល់

នាយកដ្ឋានការពារក្តីជូនជនក្រីក្រ កំណត់យកទីតាំងដើម្បីធ្វើការពិគ្រោះយោបល់ផ្នែកច្បាប់នៅទីតាំងផ្ទាល់ គឺនៅទីតាំងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

ខ១.ទីតាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់នៅរាជធានីភ្នំពេញ

នាយកដ្ឋានការពារក្តីជូនជនក្រីក្រ មានការបែងចែកជា ៥ កន្លែង ដូចខាងក្រោម៖

១-ទីស្នាក់ការគណៈមេធាវី មានអាស័យដ្ឋាននៅអាគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ១៩៣0 សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ (បន្ទប់នាយកដ្ឋានការពារក្តីជូនជនក្រីក្រ) ។

២-អាគារទីស្នាក់ការចាស់របស់គណៈមេធាវីមានទីតាំងនៅផ្ទះលេខ១0-១១E0E1E2 ផ្លូវ១៨0 សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៣-ការិយាល័យប្រតិភូតាំងនៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ។

៤-តាមការិយាល័យមេធាវីស្ម័គ្រចិត្តដែលតាំងនៅ ។

៥-ទីតាំងដែលកំណត់ផ្សេងទៀត ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ២.ចំពោះទីតាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់នៅតាមខេត្ត

នាយកដ្ឋានការពារក្តីជូនជនក្រីក្រមានការបែងចែកជា ៤ កន្លែង ដូចខាងក្រោម៖

១- ការិយាល័យប្រតិភូដែលតាំងនៅតាមសាលាដំបូងនីមួយៗ និងសាលាឧទ្ធរណ៍តំបន់ ។

២- ការិយាល័យវិជ្ជាជីវៈរបស់ប្រតិភូតាំងនៅតាមបណ្តាខេត្ត ។

៣- តាមការិយាល័យមេធាវីស្ម័គ្រចិត្តដែលតាំងនៅ ។ និង

៤-ទីតាំងផ្សេងទៀតដែលកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីការផ្តល់ការពិគ្រោះយោបល់រួច ក្នុងករណីអតិថិជនមានបំណងតែងតាក់ ឬទទួលសេវាកម្មមេធាវីនោះមេធាវីស្ម័គ្រចិត្តដែលជាអ្នកផ្តល់ការពិគ្រោះយោបល់នេះ អាចណែនាំឱ្យអតិថិជនស្វែងរកមេធាវីតាមរយៈបញ្ជីឈ្មោះមេធាវីដែលគណៈមេធាវីបានផ្សព្វផ្សាយជាសាធារណៈ និង/ឬ តែងតាក់មេធាវីស្ម័គ្រចិត្តដែលជាសាមីអ្នកផ្តល់ការពិគ្រោះយោបល់ផ្ទាល់ ទៅតាមការពិភាក្សាយកជម្រើសជាមួយអតិថិជន ។

២/- ការការពារក្តីជូនជនក្រីក្រ និងអ្នកខ្វះលទ្ធភាព ដោយមិនគិតកម្រៃ

២/-១ ការការពារក្តីជូនជនក្រីក្រ ដែលនាយកដ្ឋានការពារក្តីជូនជនក្រីក្រ អនុវត្តកន្លងមករួមមាន៖

១-ការការពារជនជាប់ចោទ ជាជនក្រីក្រ ហើយជាប់ចោទពីបទឧក្រិដ្ឋ ។

២-ជនជាប់ចោទជាអនីតិជន ហើយជាប់ចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម ។

៣-ជនរងគ្រោះស្ត្រីជាអនីតិជន (បទរំលោភសេពសន្ថវៈ ហិង្សាក្នុងគ្រួសារ និងការជួញដូរ) ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម គ្មានលទ្ធភាពរកមេធាវីការពារសិទ្ធិដោយខ្លួនឯងបាន។

២/-២ យន្តការដែលត្រូវបន្ថែមទៅលើការការពារដែលមានស្រាប់:

ក. ការអំពាវនាវ

នាយកដ្ឋានការពារក្តីជូនជនក្រីក្រនឹងធ្វើការអំពាវនាវ ស្នើសុំឱ្យមេធាវីទាំងអស់ចូលរួមដោយស្ម័គ្រចិត្តក្នុងការការពារក្តីដោយមេធាវីស្ម័គ្រចិត្តទាំងអស់ត្រូវផ្តល់ឈ្មោះមេធាវីដែលស្ម័គ្រចិត្ត និងចំនួនរឿងក្តីដែលស្ម័គ្រចិត្តជួយ និងទីតាំងនៃតុលាការណាមួយដែលស្ម័គ្រចិត្តជួយជូនមកគណៈមេធាវី ដើម្បីឱ្យគណៈមេធាវីធ្វើការរៀបចំបញ្ជីឈ្មោះដែលបានចូលជាមេធាវីស្ម័គ្រចិត្ត បញ្ជូលបន្ថែមក្នុងបញ្ជីឈ្មោះប្រតិភូ ដែលតាំងនៅតាមបណ្តារាជធានី/ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប្រតិភូប្រចាំនៅតាមរាជធានី/ខេត្ត និងសាលាឧទ្ធរណ៍ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលលើការទទួលសំណុំរឿងជូនមេធាវីស្ម័គ្រចិត្ត ក្នុងការការពារក្តីជូនជនក្រីក្រ។ ចំពោះតុលាការកំពូល នាយកដ្ឋានការពារក្តីជូនជនក្រីក្រជាអ្នកទទួលបន្ទុកសម្របសម្រួល។

ខ. ប្រភេទអ្នកដែលត្រូវទទួលបានការការពារ

ដោយអនុលោមតាមគោលការណ៍ចាស់ដែលមានស្រាប់ និងការពង្រីកវិសាលភាពថ្មីបន្ថែមទៀតតាមរយៈការការពារក្តី ឬតំណាងដោយអាណត្តិនូវគ្រប់ប្រភេទនៃសំណុំរឿង និងគ្រប់កិច្ចនីតិវិធីទាំងអស់ ដូចខាងក្រោម៖

- **ការងារសម្រាប់ផ្តល់ជូនប្រតិភូជាអាទិភាពមាន:**

  ១-ជនជាប់ចោទជាជនក្រីក្រ ឬមិនមានលទ្ធភាព ហើយជាប់ចោទពីបទឧក្រិដ្ឋ។

  ២-ជនជាប់ចោទជាអនីតិជន ហើយជាប់ចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម។

  ៣-ស្ត្រី និងកុមារដែលជាជនរងគ្រោះ ក្នុងបទឧក្រិដ្ឋ និងបទមជ្ឈិម គ្មានលទ្ធភាពរកមេធាវីការពារខ្លួនដោយខ្លួនឯងបាន។

- **ការងារសម្រាប់ផ្តល់ជូនមេធាវីស្ម័គ្រចិត្តជាអាទិភាពមាន:**

  ១-ប្រជាពលរដ្ឋជាជនក្រីក្រ ក្នុងរឿងរដ្ឋប្បវេណី។

  ២-ជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ គ្មានលទ្ធភាពរកមេធាវីការពារសិទ្ធិដោយខ្លួនឯងបាន។

  ៣-កម្មករ-កម្មការិនីដែលមិនមានលទ្ធភាពរកមេធាវីក្នុងរឿងរដ្ឋប្បវេណី។

សូមលោក និងលោកស្រី ទទួលនូវមនោសញ្ចេតនារាប់អានដោយស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ចន្ទ ៥ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

ប្រធាន



មេធាវី លី-ចំន្ទតុលា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី លី ចំន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ចូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ភៅ ប៊ុនហួន
៩-មេធាវី រស់ មុនិទ្ធ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ បន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនល្មឿន
១៥-មេធាវី កេង សុម៉ាគន់
១៦-មេធាវី ពិន ឥណ្ណ:
១៧-មេធាវី ចំន្ទ ឥចិត្រ
១៨-មេធាវី ព្រហ្ម ឥចិត្រសុគា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យ៉ីម ថាវ៉ី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឃ្មួយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំព្រ
២៧-មេធាវី គាន គារ
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ទួន ជានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ១០៤ /សសគម/២១

សេចក្តីសម្រេច
ស្តីពី
ការបែងចែកតារកិច្ចរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី ១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- បានឃើញសេចក្តីសម្រេចលេខ១០១៣/សសគម/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់គណៈមេធាវី

ស ម្រេ ច

ប្រការ ១. ត្រូវបានបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានដូចខាងក្រោម:

១.លោកអគ្គលេខាធិការ **លីវ សុវណ្ណា** ទទួលបន្ទុកដឹកនាំកិច្ចការរបស់អគ្គលេខាធិការដ្ឋានគណៈមេធាវី និងជួយប្រធានគណៈមេធាវីលើកិច្ចការទូទៅរបស់គណៈមេធាវី។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

២.លោកអគ្គលេខាធិការរង **កេង សុម៉ាឡា** ជួយអគ្គលេខាធិការគណៈមេធាវីលើកិច្ចការទូទៅរបស់អគ្គលេខាធិការដ្ឋានគណៈមេធាវី និងទទួលបន្ទុកសម្របសម្រួលកិច្ចការរបស់នាយកដ្ឋានអធិការកិច្ច នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ ព្រមទាំងនាយកដ្ឋានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ។

៣.លោកអគ្គលេខាធិការរង **សួស សារឿន** ជួយអគ្គលេខាធិការគណៈមេធាវីលើកិច្ចការទូទៅរបស់អគ្គលេខាធិការដ្ឋានគណៈមេធាវី និងទទួលបន្ទុកសម្របសម្រួលកិច្ចការរបស់នាយកដ្ឋានការពារក្តីជូនជនក្រីក្រ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល ព្រមទាំងនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ។

ប្រការ ២. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ ៣. អគ្គលេខាធិការ និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១១ កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២១

ប្រធាន

មេធាវី លី ចំណុតុលា

ចម្លងជូន
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ធាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុភណ្ណាលី
៥-មេធាវី ប៉ា ឆូនគា
៦-មេធាវី ចេត ប៉េងហាប់
៧-មេធាវី ឃុត ឆានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឃ្មាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ថ្លៃ សំរស់
៣២-មេធាវី នួន ឆានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ៤៣៦ /សសគម/២០

ថ្ងៃព្រហស្បតិ៍ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២០

សេចក្តីសម្រេច
ស្តីពី
ការប្រើត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងគ្រប់គ្រង និងធានានូវការប្រើត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ដែលបានចុះបញ្ជីស្របច្បាប់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ប្រការ២ .. គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់វិធានសម្រាប់ពិនិត្យ និងអនុញ្ញាតឱ្យប្រើត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ដែលបានចុះបញ្ជីស្របច្បាប់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣ .. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ដែលបានចុះបញ្ជីស្របច្បាប់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
អំពីត្រា និងការប្រើត្រា

ប្រការ៤ .. ទម្រង់ត្រា

ត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ត្រូវជាប្រភេទត្រា"មូល" ដែលមានទំហំប៉ុននឹងត្រាមូលមេធាវី(ត្រាវិជ្ជាជីវៈ) ហើយមានឆ្លាក់ឈ្មោះការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី ដោយមានអក្សរខ្មែរនៅផ្នែកខាងលើ និងអក្សរអង់គ្លេសនៅផ្នែកខាងក្រោម ហើយមានក្បាច់ផ្កាច័ន្ទនៅកណ្តាលរវាងអក្សរខ្មែរ និងអក្សរអង់គ្លេស។ អក្សរខ្មែរមិនត្រូវមានទំហំតូចជាងអក្សរអង់គ្លេសឡើយ។ ផ្នែកណ្តាលនៃត្រាអាចដាក់សញ្ញា ឬរូបសញ្ញា(LOGO) របស់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី ដែលមិនជាន់គ្នាជាមួយរូបសញ្ញាការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីផ្សេងទៀត ហើយដែលមិនផ្ទុយពីបទប្បញ្ញត្តិជាធរមាន។

ត្រារបស់មេធាវីត្រូវប្រើជាមួយទឹកថ្នាំដែលមានពណ៌ខ្មៅ។

គំរូនៃត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវីមានទម្រង់ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្រការ៥ .. ការដាក់ពាក្យសុំ

មេធាវីដែលមានបំណងប្រើត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីត្រូវដាក់ពាក្យសុំមកគណៈមេធាវី ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ពាក្យសុំរបស់ម្ចាស់ការិយាល័យមេធាវី មេធាវីតំណាងក្រុមមេធាវី ឬមេធាវីតំណាងក្រុមហ៊ុនមេធាវី
- រូបសញ្ញារបស់ត្រាដែលត្រូវស្នើសុំ
- វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅមានសុពលភាព (ថតចម្លង)
- វិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវីនៅមានសុពលភាព (ថតចម្លង)។

ប្រធានគណៈមេធាវីជាអ្នកចេញសេចក្តីសម្រេចអនុញ្ញាតឱ្យប្រើត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី។

ប្រការ៦ .. ការប្រើត្រា

ត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីត្រូវប្រើក្នុងកិច្ចការដូចខាងក្រោម៖

- កិច្ចការរដ្ឋបាល និងគណនេយ្យរបស់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី
- ការទទួលខុសត្រូវរបស់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីជាមួយអតិថិជន
- កិច្ចការផ្សេងទៀតតាមការចាំបាច់បស់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី ។

ប្រការ៧ .. ការហាមឃាត់

ការប្រើត្រាការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី លើឯកសារសម្រាប់ដាក់ទៅតុលាការ ឬស្ថាប័នមានសមត្ថកិច្ចនានាក្នុងក្របខ័ណ្ឌវិជ្ជាជីវៈមេធាវីត្រូវបានហាមឃាត់ជាដាច់ខាត ។

ប្រការ៨ .. ការកែប្រែ ឬការផ្លាស់ប្តូរ

ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីដែលមានបំណងកែប្រែ ឬផ្លាស់ប្តូរត្រា ត្រូវដាក់ពាក្យសុំជាថ្មីមកគណៈមេធាវី ។

ប្រការ៩ .. ការបាត់បង់ ឬខូច

ក្នុងករណីបាត់បង់ ឬខូចត្រាដោយប្រការណាមួយ ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីត្រូវជូនដំណឹងមកគណៈមេធាវី និងត្រូវដាក់ពាក្យស្នើសុំធ្វើត្រាថ្មីមកគណៈមេធាវី ។

ជំពូកទី៣
ទណ្ឌកម្ម

ប្រការ១០ .. ការប្រើត្រាដោយគ្មានការអនុញ្ញាត ឬផ្ទុយពីសេចក្តីសម្រេច

បុគ្គលណាដែលបានប្រើប្រាស់ត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី ដោយគ្មានការអនុញ្ញាតជាមុនពីប្រធានគណៈមេធាវី ឬផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចនេះត្រូវទទួលរងនូវការដាក់ទណ្ឌកម្មខាងវិន័យពីក្រុមប្រឹក្សាគណៈមេធាវី និង/ឬត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមច្បាប់ជាធរមាន ។

ជំពូកទី៤
អន្តរប្បញ្ញត្តិ

ប្រការ១១ .. ការអនុវត្តចំពោះត្រាដែលមានស្រាប់

ចំពោះការិយល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីទាំងឡាយណា ដែលបានប្រើត្រាសម្គាល់ ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីនៅមុនពេលសេចក្តីសម្រេចនេះចូលជាធរមាន ហើយត្រានោះស្របតាមទម្រង់ដូចមានចែងក្នុងប្រការ៤(ទម្រង់ត្រា) នៃសេចក្តីសម្រេចនេះអាចបន្តប្រើបាន តែត្រូវដាក់ពាក្យសុំមកគណៈមេធាវីក្នុងរយៈពេល១(មួយ)ខែយ៉ាងយូរ បន្ទាប់ពីសេចក្តីសម្រេចនេះចូលជាធរមាន ។

ក្នុងករណីត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីដែលបានប្រើនោះ មិនស្របតាមទម្រង់នៃត្រាដូចមានចែងក្នុងប្រការ៤(ទម្រង់ត្រា)នៃសេចក្តីសម្រេចនេះ ការិយាល័យមេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីនោះត្រូវបញ្ឈប់ការប្រើត្រាសម្គាល់នោះភ្លាម ហើយត្រូវដាក់ពាក្យសុំមកគណៈមេធាវីតាមប្រការ៥(ការដាក់ពាក្យសុំ) នៃសេចក្តីសម្រេចនេះ ។

ជំពូកទី៥

អវសានបញ្ញត្តិ

ប្រការ១២ .. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៣ .. ការអនុវត្ត

អគ្គលេខាធិការ និងសមាជិក.សមាជិកាគណៈមេធាវីទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធាន

មេធាវី. សួន-ទិសាល

ចម្លងជូន

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ផ្សព្វផ្សាយជាសាធារណៈ

-ដូចប្រការ ១៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី លី ចំន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ ឆាម
២-មេធាវី ឆេង បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ឌួនគា
៦-មេធាវី ចេង ប៉េងហាម់
៧-មេធាវី ឃុត ឆានិត
៨-មេធាវី ភៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន ឥណ្ណៈ
១៧-មេធាវី ចំន្ទ ឥច្ចិត្រា
១៨-មេធាវី ព្រហ្ម ឥច្ចិត្រាសុភា
១៩-មេធាវី ណុប គុណឌុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំក្រូ
២៧-មេធាវី គាន គារ
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ទួន ឆានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ៤៨៥ /សសគម/២១

សេចក្តីសម្រេច
ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការ
របស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវីគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ ១. គោលបំណង

ត្រូវបានបង្កើតក្រុមតេឡេក្រាមផ្លូវការ របស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះផ្លូវការថា "**សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)**" និងមានរូបសញ្ញារបស់គណៈមេធាវីជាសម្គាល់ ក្នុងគោលបំណងបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការប្រមូលផ្តុំសមាជិក-សមាជិកាតាមប្រព័ន្ធទំនាក់ទំនងបែបបច្ចេកវិទ្យាសម័យទំនើប ដើម្បីចែករំលែកព័ត៌មានវិជ្ជាជីវៈ ការជូនដំណឹង និងការឆ្លើយតបរាល់បញ្ហារបស់សហភាគា ប្រកបដោយភាពឆាប់រហ័ស។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខៈ ១៥៨៧. ទូរស័ព្ទៈ ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

ប្រការ ២. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះសហភាគាទាំងអស់ដែលបានចុះបញ្ជីជា មេធាវីកំពុងប្រកបវិជ្ជាជីវៈ មេធាវីសុំមិនប្រកបវិជ្ជាជីវៈ មេធាវីកម្មសិក្សា មេធាវីសុំព្យួរកម្មសិក្សា និងមេធាវីសុំនៅក្រៅបញ្ជី ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ជំពូកទី ២
ការគ្រប់គ្រងក្រុមតេឡេក្រុម

ប្រការ ៣. គណៈគ្រប់គ្រងក្រុមតេឡេក្រាម

គណៈគ្រប់គ្រងក្រុមតេឡេក្រាមមានសមាសភាពដូចខាងក្រោម៖

- ប្រធានគណៈមេធាវី
- អគ្គលេខាធិការ និងអគ្គលេខាធិការរង
- ប្រធាន និងអនុប្រធាននាយកដ្ឋានអធិការកិច្ច
- ប្រធាន និងអនុប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ
- និង ប្រធាន និងអនុប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល។

ប្រការ ៤. តួនាទីភារកិច្ចនៃគណៈគ្រប់គ្រងក្រុមតេឡេក្រាម

គណៈគ្រប់គ្រងក្រុមតេឡេក្រាមមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជូនដំណឹងដល់សមាជិក-សមាជិកាទាំងអស់ ក្នុងការផ្តល់ព័ត៌មានអំពីលេខទូរស័ព្ទផ្ទាល់ខ្លួនដែលភ្ជាប់ជាមួយកម្មវិធីតេឡេក្រាម
- ផ្តល់ការណែនាំអំពីការទាញយកកម្មវិធី ការចុះឈ្មោះ ការប្រើប្រាស់ និងការអនុលោមបទបញ្ជាក្រុម
- ពិនិត្យ និងសម្រេច ការដកសមាជិកភាពពីក្នុងក្រុមតេឡេក្រាម ដោយមូលហេតុ ការទទួលមរណៈភាព ការឈប់ប្រកបវិជ្ជាជីវៈមេធាវី ការលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី និងការផ្អាកពីមុខងារជាបណ្តោះអាសន្ន
- ធ្វើបច្ចុប្បន្នភាពសមាជិកភាពជាប្រចាំ
- ត្រួតពិនិត្យ និងតាមដានសកម្មភាពរបស់សមាជិកក្នុងក្រុមជាប្រចាំ
- ធ្វើការក្រើនរំលឹក ដាស់តឿន ដល់សមាជិក ដែលបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ក្រុម
- ដាក់ពិន័យសមាជិកក្រុមដែលបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ក្រុម
- ឆ្លើយតបនូវារាល់បញ្ហា ចម្ងល់ ដោយផ្តល់ជាអនុសាសន៍ដល់សមាជិក-សមាជិកា
- ផ្តល់នូវារាល់ព័ត៌មានផ្លូវការរបស់គណៈមេធាវី
- បំពេញតួនាទី ភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានគណៈមេធាវី។

ប្រការ ៥.. សកម្មភាពគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈគ្រប់គ្រងក្រុមតេឡេក្រាមអាចធ្វើសកម្មភាពដូចខាងក្រោម៖

- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការ ដល់សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ ឬសមាជិកគណៈមេធាវីណាម្នាក់
- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការអំពីសេចក្តីសម្រេច សេចក្តីជូនដំណឹង សេចក្តីថ្លែងការណ៍ សេចក្តីអំពាវនាវ គោលនយោបាយ ឬលិខិតនានា របស់គណៈមេធាវី
- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការអំពីកម្មវិធីសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាលផ្សេងៗ ជាអាទិ៍
- ផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់គណៈមេធាវី
- ឆ្លើយតបបន្ទាន់ទៅនឹងបញ្ហា ឬចម្ងល់នានាទាក់ទងនឹងការប្រកបវិជ្ជាជីវៈរបស់សមាជិក-សមាជិកា
- ធ្វើសកម្មភាពផ្សេងៗទៀតដែលចាំបាច់។

ប្រការ ៦.. ក្រុមការងារផ្សេងៗ

ប្រធានគណៈមេធាវីមានសិទ្ធិបង្កើតក្រុមការងារផ្សេងៗតាមការចាំបាច់។

ជំពូកទី ៣
ប្រភេទ និងទម្រង់ព័ត៌មានរបស់សមាជិកក្រុមតេឡេក្រាម

ប្រការ ៧.. ប្រភេទនៃព័ត៌មានរបស់សមាជិកក្រុមតេឡេក្រាម

ព័ត៌មានដែលសមាជិកក្រុមអាចលើកយកមកដាក់ក្នុងក្រុមតេឡេក្រាមបាន មានជាអាទិ៍ ការរាយការណ៍ ការស្នើសុំអន្តរាគមន៍ ការចែករំលែក ការលើកយោបល់ទូទៅ ការលើកអំពីបញ្ហាប្រឈម ការលើកនូវចម្ងល់ ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ និងការយោសនាបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ ៨.. ការរាយការណ៍

សមាជិកក្រុមតេឡេក្រាម អាចធ្វើសេចក្តីរាយការណ៍តាមរយៈក្រុមតេឡេក្រាមនេះ ហើយអាចដាក់ចូលក្នុងក្រុមនូវករណីដូចខាងក្រោម៖

- ភាពមិនប្រក្រតីនៃការប្រកបវិជ្ជាជីវៈ
- ភាពមិនប្រក្រតីនៃការបើកការិយាល័យ ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី
- ការប្រព្រឹត្តខុសវិធានវិជ្ជាជីវៈមេធាវី
- សកម្មភាពផ្សេងទៀតទាក់ទងនឹងការប្រកបវិជ្ជាជីវៈមេធាវី។

គណៈគ្រប់គ្រងក្រុមតេឡេក្រាមត្រូវចាត់ឲ្យនាយកដ្ឋានអធិការកិច្ចនៃគណៈមេធាវី ចាប់ផ្តើមនីតិវិធីនៃការធ្វើអធិការកិច្ចលើករណីទាំងនោះ រួចដាក់ជូនប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច។

ប្រការ ៩. ការស្នើសុំអន្តរាគមន៍

សមាជិកក្រុមតេឡេក្រាម អាចស្នើសុំអន្តរាគមន៍តាមរយៈក្រុមតេឡេក្រាមនេះការដាក់ចូលមកក្នុងក្រុមនូវករណីដូចខាងក្រោម៖

- ការស្នើសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី ចំពោះមេធាវីដែលទទួលរងបណ្តឹង ត្រូវបានឃាត់ខ្លួន ឬចាប់ខ្លួន ដោយសារការប្រកបវិជ្ជាជីវៈ
- ការស្នើសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី ចំពោះមេធាវីដែលត្រូវរងគ្រោះមកលើខ្លួនដោយសារការប្រកបវិជ្ជាជីវៈ
- ការស្នើសុំអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ច ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដើម្បីប្រយោជន៍រួមរបស់វិជ្ជាជីវៈមេធាវី
- មេធាវីណាម្នាក់ដែលកំពុងជួបបញ្ហា។

ប្រការ ១០. ការចែករំលែក បញ្ហាប្រឈម ចម្ងល់ ឬយោបល់ទូទៅ

សមាជិកក្រុមតេឡេក្រាម អាចចែករំលែកនូវព័ត៌មាន ឯកសារ ឬតំណភ្ជាប់ផ្សេងៗ ដែលមានលក្ខណៈជាការផ្តល់ចំណេះដឹង និងបទពិសោធន៍។

សមាជិកក្រុមតេឡេក្រាមអាចលើកអំពីបញ្ហាប្រឈម ចម្ងល់ ឬយោបល់ទូទៅ អំពីច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ សម្រាប់ជាធាតុចូលដល់គណៈមេធាវីក្នុងការរៀបចំជាសេចក្តីសម្រេច សេចក្តីណែនាំ ការពន្យល់ ឬដំណោះស្រាយ ជូនសមាជិក-សមាជិកាក្នុងការតម្រង់ទិសដល់ការប្រកបវិជ្ជាជីវៈមេធាវីឲ្យបានត្រឹមត្រូវទៅតាមការកំណត់របស់គតិច្បាប់។

ប្រការ ១១. ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ

សមាជិកក្រុមតេឡេក្រាម អាចបញ្ជូនយោបល់ ឬសំណូមពរនានារបស់ខ្លួនសម្រាប់មហាសន្និបាតប្រចាំឆ្នាំបាន តាមការកំណត់របស់គណៈមេធាវី។

ប្រការ ១២. ការយោសនាបោះឆ្នោតប្រធាន ឬក្រុមប្រឹក្សាគណៈមេធាវី

សមាជិក-សមាជិកាដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតប្រធាន ឬក្រុមប្រឹក្សាគណៈមេធាវី អាចធ្វើសកម្មភាពយោសនារបស់ខ្លួននៅក្នុងក្រុមតេឡេក្រាមបាន ដោយអនុលោមតាមបទបញ្ជានៃការយោសនាបោះឆ្នោត។

សមាជិកក្រុមតេឡេក្រាម ពុំអាចបរិយាយរិះគន់ ឬសម្តែងឆន្ទៈគាំទ្រ ឬមិនគាំទ្រ ចំពោះបេក្ខជនបានឡើយ តែអាចស្នើសុំឱ្យបេក្ខជនណាមួយពន្យល់ ឬបកស្រាយចំពោះគោលនយោបាយរបស់ខ្លួនបាន។

ជំពូកទី ៤
បទឧបញ្ញាផ្ទៃក្នុងរបស់ក្រុមតេឡេក្រាម

ប្រការ ១៣.. ការរក្សាការសម្ងាត់របស់ក្រុមតេឡេក្រាម

សមាជិក-សមាជិកា មិនត្រូវផ្សព្វផ្សាយ ឬចែករំលែកបន្ត នូវសកម្មភាព ឬព័ត៌មានទាំងឡាយដូចមានចែងក្នុងប្រការ៨ ប្រការ៩ ប្រការ១១ និងប្រការ១២ នៃសេចក្តីសម្រេចនេះ លើកលែងតែមានការអនុញ្ញាតពីប្រធានគណៈមេធាវី។

ប្រការ ១៤.- សីលធម៌ជាមូលដ្ឋានក្នុងការជជែកពិភាក្សា

រាល់ការជជែកពិភាក្សាទាំងឡាយរបស់សមាជិក-សមាជិកា គឺត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ជាមូលដ្ឋានដូចខាងក្រោម៖

- គោរពហានុក្រមនៃគណៈមេធាវី ភាពចាស់ទុំនៃវ័យ និងភាពចាស់ទុំក្នុងវិជ្ជាជីវៈ
- គោរពតាមការណែនាំរបស់គណៈគ្រប់គ្រងក្រុមតេឡេក្រាម
- មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឯកសារផ្នែកទន់ ឬការជជែកពិភាក្សាមានលក្ខណៈប្រមាថមើលងាយដល់ ប្រធានគណៈមេធាវី សមាជិកក្រុមប្រឹក្សាគណៈមេធាវី អគ្គលេខាធិការដ្ឋានគណៈមេធាវី គណៈគ្រប់គ្រងក្រុមតេឡេក្រាម និងសមាជិកក្នុងក្រុមតេឡេក្រាម
- មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឬឯកសារផ្នែកទន់បែបអាសអាភាស
- មិនត្រូវប្រើពាក្យពេចន៍អសុរោះ ជេរត្មះ ប្រទេចផ្តាសា។

ប្រការ ១៥.- ទម្រង់នៃទំនាក់ទំនង

សមាជិកក្រុម អាចទំនាក់ទំនងមកក្នុងក្រុមដោយត្រូវសរសេរជាខេមរភាសា ឬអាចប្រើជារូបភាព វីដេអូ ឬជាឯកសារផ្នែកទន់ សម្រាប់ការជជែកពិភាក្សា និងការដាក់សំណើរផ្សេងៗ។

សមាជិកក្រុម ពុំត្រូវប្រើប្រាស់សារជាស្ទីកគ័រ(Stickers) ឬរូបភាពមានចលនា(GIF) ជាមធ្យោបាយនៃការជជែកពិភាក្សាឡើយ។

ប្រការ ១៦.- ការហាមឃាត់ជាច់ខាត

ពុំអនុញ្ញាតឱ្យសមាជិកក្រុម ធ្វើសកម្មភាព និយាយ សរសេរ សម្តែង វីដេអូ ដាក់រូបភាព ដាក់ឯកសារផ្នែកទន់ ឬការជជែកពិភាក្សា ដូចខាងក្រោម៖

- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ក្រសួង ស្ថាប័ន អង្គភាពនានា
- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ឥស្សរជន ឬបុគ្គលនយោបាយ ឬមន្ត្រី នៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈនានា
- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

- ប្រកាន់និន្នាការនយោបាយ និងការឃោសនាពីគណបក្សនយោបាយ
- ប្រមាថដល់វិជ្ជាជីវៈមេធាវី
- ជជែកដោយកំហឹង
- បង្កជម្លោះ
- លុបក្រុមតេឡេក្រាមចោល
- ដកសមាជិកក្រុមដោយពុំមានការអនុញ្ញាត
- ចាកចេញពីក្រុមដោយពុំមានការអនុញ្ញាត
- បំពានតាមបែបបច្ចេកវិទ្យា (Hack)
- បង្កការរំខាន
- បង្កការញុះញង
- គំរាមកំហែង
- បង្កើតបញ្ហាផ្សេងៗដែលមិនមានគុណតម្លៃ ឬគុណប្រយោជន៍សម្រាប់សមាជិក។

ជំពូកទី ៥
បទវិន័យ

ប្រការ ១៧. កម្រិតវិន័យ

កម្រិតបទវិន័យរួមមាន៖

- ការក្រើនរំលឹក ដាស់តឿនអំពីការប្រព្រឹត្តកំហុស
- ការដកសិទ្ធិបណ្តោះអាសន្នក្នុងការរាយការណ៍ ការចែករំលែក ការលើកយោបល់ទូទៅ ការលើកអំពីបញ្ហាប្រឈម ការលើកនូវចម្ងល់ ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ និងការឃោសនាបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី មិនលើសរយៈពេល ៦(ប្រាំមួយ)ខែ។

ប្រការ ១៨. ការអនុវត្តបទវិន័យ

សមាជិកក្រុមតេឡេក្រាម ដែលបានប្រព្រឹត្តខុសនឹងប្បញ្ញត្តិនៃប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦ នៃសេចក្តីសម្រេចនេះ ត្រូវទទួលរងនូវបទវិន័យដូចមានចែងក្នុងប្រការ១៧ ខាងលើ និងទទួលខុសត្រូវចំពោះមុខច្បាប់។ គណៈគ្រប់គ្រងក្រុមតេឡេក្រាម មានសមត្ថកិច្ចផ្តាច់មុខក្នុងការអនុវត្តបទវិន័យនេះ។

ជំពូកទី ៦
អវសាន្តប្បញ្ញត្តិ

ប្រការ ១៩. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ ២០.- ការអនុវត្ត

សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៩រុ១កើត ខែ ភិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

ប្រធានគណៈមេធាវី



មេធាវី លី_ចំណុលា

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំ វណ្ណៈ
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ទុច ឆីវិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំន្ទសុជាតា
១០-មេធាវី លី ធិត្យប៊ុនាមី
១១-មេធាវី ឃុន ចិន្តណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជៈ
១៤-មេធាវី អ៊ុក ភីរិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ឫចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ុ ធីតារ៉ៅ
២០-មេធាវី ចួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ឥន្ធា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាឥស្ស
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ តុលា
២៩-មេធាវី ហាក់ សុភារិទ្ធ
៣០-មេធាវី សួន សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

លេខ ២២៨ /សសគម/២៣

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចមូល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)"

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៤
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០
- បានឃើញសេចក្តីសម្រេចលេខ២៨៥/សសគម/២១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការរបស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសម្រេចលេខ៤០៦/សសគម/២១ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចមូល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)"
- យោងតាមការចាំបាច់របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ស ម្រេ ច

ប្រការ១ .- ត្រូវបានកែសម្រួលសមាសភាពក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចមូល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃ

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខៈ ១៥៨៧, ទូរស័ព្ទៈ ០២៣ ៦២២ ៧០៧០
Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

ព្រះរាជាណាចក្រកម្ពុជា(BAKC)" ដូចខាងក្រោម:

១-លោកមេធាវី	**អាន សុវឌ្ឍនា**	ប្រធាន
២-លោកមេធាវី	**ឃូ លីមហួត**	អនុប្រធាន
៣-លោកស្រីមេធាវី	**ម៉ី ឧសនា**	អនុប្រធាន
៤-លោកមេធាវី	**គីម រ័ត្នណារ៉ុង**	អនុប្រធាន
៥-លោកមេធាវី	**ស្រ៊ុន ធីរិទ្ធ**	អនុប្រធាន
៦-លោកស្រីមេធាវី	**ទេព បូផល**	អនុប្រធាន
៧-លោកមេធាវី	**ង៉ាន់ថាន់ ពៅជាវ៉ា**	អនុប្រធាន
៨-លោកមេធាវី	**តែ ចំណាន**	សមាជិក
៩-លោកមេធាវី	**អាស បូវ៉ា**	សមាជិក
១០-លោកស្រីមេធាវី	**អាន ឌីរៈ**	សមាជិកា
១១-កញ្ញាមេធាវី	**ធីម សុភាព**	សមាជិកា
១២-លោកមេធាវី	**អ៊ីវ ប៉ូលី**	សមាជិក
១៣-លោកមេធាវី	**ឆាង បញ្ញា**	សមាជិក
១៤-លោកស្រីមេធាវី	**ជា សុភន្ឌន**	សមាជិកា
១៥-លោកមេធាវី	**ខៀវ តុលា**	សមាជិក
១៦-លោកមេធាវី	**ឌុច ផារី**	សមាជិក
១៧-លោកស្រីមេធាវី	**ស៊ិន សុវ៉ន**	សមាជិកា
១៨-កញ្ញាមេធាវី	**លី រតនា**	សមាជិកា
១៩-លោកមេធាវី	**សែម ស៊ីនរិទ្ធ**	សមាជិក
២០-កញ្ញាមេធាវី	**ឈុំ មុនីសុជាតា**	សមាជិកា
២១-កញ្ញាមេធាវី	**ឃ្លី ជាលីន**	សមាជិកា
២២-លោកមេធាវី	**យិន សាវ៉ាត**	សមាជិក
២៣-លោកមេធាវី	**សន់ សុជាតិ**	សមាជិក

ប្រការ២ .. ក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចម្ងល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)" ត្រូវបំពេញតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងសេចក្តីសម្រេចលេខ៤០៦/សសគម/២១ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចម្ងល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)" និងត្រូវតាមដាន ប្រមូល ឆ្លើយតប និងរាយការណ៍ជូនគណៈគ្រប់គ្រងនូវរាល់ការធ្វើសារចូលក្នុងប្រព័ន្ធទំនាក់ទំនងសង្គមរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣ .. សេចក្តីសម្រេចលេខ៧៦៥/សសគម/២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ស្តីពីការកែសម្រួលសមាសភាពក្រុមឆ្លើយតបបន្ទាន់ទៅនឹងសំណូមពរ ចម្ងល់ ឬសកម្មភាពផ្សេងៗរបស់សមាជិកក្រុមតេឡេក្រាម "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៤ .. អគ្គលេខាធិការគណៈមេធាវីនិងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

ប្រធាន

មេធាវី ណី ចំន្ទតុលា

ចម្លងជូន:
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី លី ចំណុតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បុថល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ចូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុត ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុក គីមសួន
១៣-មេធាវី ឌុយ សុខសុលីជា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន ចិច្រា
១៨-មេធាវី ព្រហ្ម ចិច្រាសុតា
១៩-មេធាវី ណុប គុណាថុប
២០-មេធាវី យ៉ឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំក្រែ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ទូច ជានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ១១៦ /សសគម/២១

សេចក្តីសម្រេច

ស្តីពី

នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំណុតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

ស ម្រ េ ច

ដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២១ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខៈ ១៥៨៧, ទូរស័ព្ទៈ ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងបង្កើននូវប្រសិទ្ធភាព តម្លាភាព ជំនឿទុកចិត្តលើការធ្វើអធិការកិច្ច និងការធ្វើសេចក្តីសម្រេចជ្រើសរើសបេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវី ប្រកបដោយគុណភាព និងសមត្ថភាព ព្រមទាំងការត្រួតពិនិត្យលើការធ្វើកម្មសិក្សា តាមរយៈការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី និងការត្រួតពិនិត្យលើការធ្វើកម្មសិក្សារបស់មេធាវីជាកម្មសិក្សាការី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ប្រការ២ .. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះបេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី តាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មេធាវីជាគ្រូកម្មសិក្សា និងមេធាវីជាកម្មសិក្សាការី ។

ជំពូកទី២
លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ផ្នែកទី១
លក្ខខណ្ឌ និងការដាក់ពាក្យសុំ

ប្រការ៣ .. លក្ខខណ្ឌ

ជនដែលមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-ត្រូវមានបរិញ្ញាបត្រច្បាប់ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល ។

៣-ត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលចេញដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។

៤-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៥-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

ប្រការ៤ .. ទម្រង់នៃពាក្យសុំ

ជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបានកំណត់ក្នុងប្រការខាងលើ ហើយមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវមកទិញពាក្យសុំចូលប្រកបវិជាជីវៈមេធាវីនៅនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការប្រកាសរបស់គណៈមេធាវីនៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ។

តម្លៃនៃពាក្យសុំត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

ប្រការ៥ .. ការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី នៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

២-ប្រវត្តិរូបសង្ខេបសាមីខ្លួន

៣-កិច្ចសន្យាផ្ទាល់ខ្លួន

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៥-រូបថត ៤ គុណ ៦ ចំនួន៤ (បួន)សន្លឹក

៦-វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ចំនួន២ (ពីរ)ច្បាប់ ដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

៧-លិខិតថ្កោលទោសដែលនៅមានសុពលភាព

៨-ឯកសារតម្រូវផ្សេងៗ ដែលកំណត់ដោយគណៈមេធាវី ។

ផ្នែកទី២
នីតិវិធីនៃការធ្វើសេចក្តីសម្រេច និងការប្តឹងតវ៉ា

ប្រការ៦ .. ការស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា

ក្រោយពីពិនិត្យឃើញថាពាក្យសុំត្រូវបានបំពេញគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការខាងលើរួចរាល់ គណៈមេធាវីត្រូវបញ្ជូនសំណុំឯកសាររបស់បេក្ខជនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីត្រួតពិនិត្យលើលក្ខខណ្ឌដែលកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា ។ សំណុំឯកសារដែលត្រូវបញ្ជូនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល រួមមានពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ប្រវត្តិរូបសង្ខេប កិច្ចសន្យាផ្ទាល់ខ្លួន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងលិខិតថ្កោលទោស ។

ប្រការ៧ .. ការពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី

ការយល់ព្រមឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ការបោះឆ្នោតដើម្បីអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវធ្វើជាសម្ងាត់ ។ ការសម្រេចគាំទ្របេក្ខជនត្រូវធ្វើឡើងតាមសំឡេងភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាននិងសំឡេងផ្ទេរសិទ្ធិ ដោយធៀបទៅនឹងលទ្ធផលសំឡេងយល់ព្រម មិនយល់ព្រម អនុប្បវាទឬមិនបានការ ។

ករណីសំឡេងអនុប្បវាទឬមិនបានការ ច្រើនជាងឬស្មើនឹងសំឡេងយល់ព្រមឬ/និងមិនយល់ព្រម ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី ។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ ។

ក្នុងករណីសំឡេងយល់ព្រមនិងមិនយល់ព្រមស្មើគ្នា ហើយច្រើនជាងសំឡេងអនុប្បវាទឬមិនបានការ ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធ្យៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ។

ក្នុងករណីដែលក្រុមប្រឹក្សាគណៈមេធាវី សម្រេចមិនអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវៈមេធាវី ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញបេក្ខជនរូបនោះមកបញ្ចេញយោបល់នៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី។ ការកោះអញ្ជើញនេះត្រូវធ្វើឡើងយ៉ាងតិច១០(ដប់)ថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី។ បន្ទាប់ពីស្តាប់យោបល់របស់សាមីខ្លួនរួចហើយ សមាជិកក្រុមប្រឹក្សាគណៈមេធាវីអាចតាំងសំណួរបន្ថែមបាន។ ក្រោយការសួរសំណួរចប់សព្វគ្រប់ សាមីខ្លួនត្រូវចាកចេញពីបន្ទប់ប្រជុំ ហើយក្រុមប្រឹក្សាគណៈមេធាវីត្រូវពិភាក្សាគ្នានិងធ្វើការសម្រេចជាថ្មី។

ប្រការ៨ .. ការប្តឹងតវ៉ាពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី

ក្នុងករណីក្រុមប្រឹក្សាគណៈមេធាវីសម្រេចមិនអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី គណៈមេធាវីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅសាមីខ្លួន ហើយសាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងរយៈពេល២(ពីរ)ខែចាប់ពីថ្ងៃទទួលដំណឹង។

ប្រការ៩ .. ការពិនិត្យនិងសម្រេចឡើងវិញ

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យលើសេចក្តីសម្រេចរបស់ខ្លួននិងសម្រេចឡើងវិញ តាមសាលដីការបស់តុលាការ។

ជំពូកទី៣
លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ផ្នែកទី១
លក្ខខណ្ឌសម្រាប់បេក្ខជន

ប្រការ១០ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលជាចៅក្រមនិងអតីតចៅក្រម

បេក្ខជនជាចៅក្រមដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី៥(ប្រាំ)ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ ហើយដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី២(ពីរ)ឆ្នាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហួតងារអំពីអំពើផ្តុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

ប្រការ១១ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ

បេក្ខជនជាមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៤-ត្រូវមានការបញ្ជាក់អំពីការចុះបញ្ជីពីគណៈមេធាវីនៃប្រទេសណាមួយដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ។

ប្រការ១២ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលមានសញ្ញាបត្របណ្ឌិតច្បាប់

បេក្ខជនដែលមានសញ្ញាបត្របណ្ឌិតច្បាប់ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៤-ក្នុងករណីសញ្ញាបត្របណ្ឌិតចេញដោយប្រទេសក្រៅ បេក្ខជនត្រូវមានលិខិតបញ្ជាក់ពីក្រសួងទទួលបន្ទុកវិស័យអប់រំថាមានតម្លៃសមមូលជាមួយសញ្ញាបត្របណ្ឌិតច្បាប់ ។

ប្រការ១៣ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលបានបម្រើការងារក្នុងវិស័យច្បាប់ឬតុលាការ

បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រច្បាប់ ហើយដែលបានបម្រើការងារក្នុងវិស័យច្បាប់ឬតុលាការលើសពី២(ពីរ)ឆ្នាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

ការងារក្នុងវិស័យច្បាប់ គឺជាការងារដែលបុគ្គលនោះបានបំពេញទាក់ទងនឹងច្បាប់ទាំងក្នុងស្ថាប័នសាធារណៈឬឯកជន ដូចជា: ការពិគ្រោះច្បាប់ ការតាក់តែងលិខិតស្មាមគតិយុត្ត ការផ្សះផ្សាការសម្របសម្រួលដែលមានវិជ្ជាជីវៈទទួលស្គាល់ដោយច្បាប់ មជ្ឈត្តករ ការបង្រៀនមុខវិជ្ជាច្បាប់ ការស្រាវជ្រាវច្បាប់ និងការងារទាក់ទងវិជ្ជាជីវៈមេធាវី ។

ផ្នែកទី២
ការដាក់ពាក្យសុំ

ប្រការ១៤ .. ទម្រង់នៃពាក្យសុំ

បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបានកំណត់ក្នុងប្រការខាងលើ ហើយមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវមកទិញពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី នៅនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការប្រកាសរបស់គណៈមេធាវីនៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ។

តម្លៃនៃពាក្យសុំនិងថ្លៃដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

ប្រការ១៥ .. ការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី នៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

២-ប្រវត្តិរូបសង្ខេបសាមីខ្លួន

៣-កិច្ចសន្យាផ្ទាល់ខ្លួន

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៤-រូបថត ៤ គុណ ៦ ចំនួន៤សន្លឹក

៥-បរិញ្ញាបត្រច្បាប់ឬសញ្ញាប័ត្រសមមូល(ច្បាប់ដើម) ឬសញ្ញាបត្រមធ្យមសិក្សាច្បាប់(ច្បាប់ដើម) ឬព្រះរាជក្រឹត្យតែងតាំងជាចៅក្រម ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១០ និងប្រការ១៣

៦-សញ្ញាបត្របណ្ឌិតច្បាប់(ច្បាប់ដើម) ឬលិខិតបញ្ជាក់ពីក្រសួងទទួលបន្ទុកវិស័យអប់រំថាមានតម្លៃសមមូលជាមួយសញ្ញាបត្របណ្ឌិតច្បាប់ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១២

៧-ត្រូវមានការបញ្ជាក់អំពីការចុះបញ្ជីពីគណៈមេធាវីនៃប្រទេសណាមួយ ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១១

៨-លិខិតថ្កោលទោសដែលនៅមានសុពលភាព

៩-លិខិតបញ្ជាក់ការងារ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១៣

១០-ឯកសារតម្រូវផ្សេងៗ ដែលកំណត់ដោយគណៈមេធាវី ។

ប្រការ១៦ .. ការទទួលខុសត្រូវរបស់បេក្ខជន

បេក្ខជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ឯកសារទាំងឡាយដែលមាននៅក្នុងពាក្យសុំរបស់ខ្លួន ។

ប្រការ១៧.. ការទទួល និងបញ្ជូនឯកសារពាក្យសុំ

នៅពេលទទួលពាក្យសុំ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលគណៈមេធាវីត្រូវពិនិត្យមើលឯកសារជាមូលដ្ឋានដែលបានកំណត់នៅក្នុងពាក្យសុំ ។ ប្រសិនបើពិនិត្យឃើញថាពាក្យសុំមិនមានឯកសារឬមិនបានបំពេញគ្រប់លក្ខខណ្ឌទេ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលត្រូវជូនដំណឹងដល់បេក្ខជនឬបេក្ខនារីអោយបំពេញបន្ថែមអំពីការខ្វះខាតនោះ និងតម្រូវឱ្យបេក្ខជនបង់ប្រាក់ថ្លៃដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ។

ផ្នែកទី៣
ការធ្វើអធិការកិច្ច

ប្រការ១៨ .. ការចាត់តាំងអធិការកិច្ច

ក្រោយពេលទទួលពាក្យសុំរបស់បេក្ខជន ប្រធានគណៈមេធាវីចាត់តាំងក្រុមអធិការកិច្ចតាមសំណើរបស់ប្រធាននាយកដ្ឋានអធិការកិច្ច ដើម្បីត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ និងធ្វើការសម្ភាសន៍បុគ្គលដែលពាក់ព័ន្ធ ដើម្បីពិនិត្យភាពត្រឹមត្រូវនៃព័ត៌មានដែលអះអាងដោយបេក្ខជន។

ក្នុងករណីបេក្ខជនជាមេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីក្រៅប្រទេស ក្រុមអធិការកិច្ចត្រូវស្រាវជ្រាវរកភាពត្រឹមត្រូវនៃការបញ្ជាក់របស់គណៈមេធាវីនោះ តាមគ្រប់មធ្យោបាយ ហើយការចំណាយជាក់ស្តែងចាំបាច់ណាមួយ ជាបន្ទុករបស់បេក្ខជន។

ប្រការ១៩ .. សមាសភាពអធិការកិច្ច

ក្រុមអធិការកិច្ចដែលទទួលបន្ទុកពិនិត្យលើពាក្យសុំរបស់បេក្ខជនត្រូវមានសមាសភាពចំនួន០២(ពីរ)នាក់ ដោយមានម្នាក់ជាប្រធានក្រុមនិងម្នាក់ទៀតជាសមាជិក ត្រូវបំពេញការងារនិងទទួលខុសត្រូវរួមគ្នាលើលទ្ធផលនៃការធ្វើអធិការកិច្ច ដោយត្រូវរាយការណ៍អំពីលទ្ធផល ឧបសគ្គ ឬបញ្ហាដែលអាចកើតមានជាយថាហេតុជូនប្រធានគណៈមេធាវី។

ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ មានសីលធម៌ និងស្មោះត្រង់។ សមាសភាពក្រុមអធិការកិច្ចដែលត្រូវបានចាត់តាំង ប្រសិនបើក្នុងចំណោមនោះមានទំនាក់ទំនងញាតិដល់ថ្នាក់ទីបី ឬស្ថានភាពដែលនាំឱ្យមានភាពលំអៀងក្នុងការធ្វើអធិការកិច្ច ត្រូវដកខ្លួន និងរាយការណ៍ជូនប្រធានគណៈមេធាវី ដើម្បីធ្វើការផ្លាស់ប្តូរសមាសភាព។

ប្រសិនបើសមាសភាពក្រុមអធិការកិច្ចណាម្នាក់មានទំនាក់ទំនងញាតិរហូតដល់ថ្នាក់ទី៣ ហើយមិនបានស្នើសុំដកខ្លួន ឬរាយការណ៍តាមឋានានុក្រមទេ លទ្ធផលនៃការធ្វើអធិការកិច្ចនោះនឹងត្រូវចាត់ទុកជាមោឃៈ។ អធិការដែលមិនបានរាយការណ៍ពីករណីបែបនេះត្រូវទទួលរងទណ្ឌកម្មពីគណៈមេធាវី ដូចជាត្រូវដកឈ្មោះចេញពីក្រុមអធិការកិច្ច ឬ/និងស្តីបន្ទោសជាលាយលក្ខណ៍អក្សរ ឬដាក់វិន័យផ្សេងទៀតតាមក្រមសីលធម៌មេធាវី និងពុំអាចទទួលបានទូវប្រាក់ឧបត្ថម្ភសម្រាប់អធិការកិច្ចឡើយ។ ក្នុងករណីនេះ ប្រធានគណៈមេធាវីត្រូវចាត់តាំងក្រុមអធិការកិច្ចថ្មី ដើម្បីដំណើរនីតិវិធីអធិការកិច្ចសារជាថ្មីឡើងវិញលើសំណុំឯកសារពាក្យសុំរបស់បេក្ខជន។

ប្រការ២០ .. រយៈពេលធ្វើអធិការកិច្ច

បន្ទាប់ពីទទួលការចាត់តាំងពីប្រធានគណៈមេធាវី ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងចប់សព្វគ្រប់ ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលការចាត់តាំង។ ប្រសិនបើមិនអាចធ្វើអធិការកិច្ចបានតាមអំឡុងពេលកំណត់នេះទេ ប្រធានក្រុមអធិការកិច្ចត្រូវរាយការណ៍ជូនប្រធានគណៈមេធាវីអំពីមូលហេតុនិងឧបសគ្គដែលបានកើតឡើងនៅពេលធ្វើអធិការកិច្ចនោះ។ ក្នុងករណីនេះ ប្រធានគណៈមេធាវីអាចសម្រេចពន្យារពេលដោយកំណត់អំឡុងពេលសមរម្យម្តងទៀត ឬចាត់តាំងក្រុមអធិការកិច្ចថ្មីដើម្បីបញ្ចប់កិច្ចការអធិការកិច្ចប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ។

ក្នុងករណីក្រុមអធិការកិច្ចបានទាក់ទងទៅបេក្ខជនតាមរយៈអាសយដ្ឋាន ឬលេខទូរស័ព្ទដែលបេក្ខជនបានសរសេរនៅក្នុងពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីរបស់សាមីខ្លួន ហើយនៅតែមិនអាចទំនាក់ទំនងបាន ក្រុមអធិការកិច្ចត្រូវរាយការណ៍ជូនប្រធានគណៈមេធាវី ។ ប្រធានគណៈមេធាវីមានឆន្ទានុសិទ្ធិក្នុងការលើកចោលពាក្យសុំចូលប្រកបវិជ្ជាជីវៈនោះដោយពុំបង្គិលប្រាក់ថ្លៃដាក់ពាក្យសុំជូនទៅបេក្ខជនវិញឡើយ ។

ប្រការ២១ .. របាយការណ៍អធិការកិច្ច

ក្រោយពីបញ្ចប់បេសកកម្មរបស់ខ្លួន ក្រុមអធិការកិច្ចត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើអធិការកិច្ចរបស់ខ្លួនជូនមកប្រធានគណៈមេធាវី ក្នុងអំឡុងពេលដូចមានកំណត់ក្នុងប្រការ ២០ ខាងលើ ។

ទម្រង់របាយការណ៍អធិការកិច្ចត្រូវកំណត់ដោយគណៈមេធាវី សម្រាប់ប្រើជាផ្លូវការនៅក្នុងការបំពេញការងាររបស់ក្រុមអធិការកិច្ច ។

របាយការណ៍ត្រូវរៀបរាប់រាល់ព័តិមានដែលទទួលបានពីការធ្វើអធិការកិច្ច ដោយគួសបញ្ជាក់នូវព័តិមាននានាទាក់ទងនឹងលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវី តែមិនត្រូវធ្វើសេចក្តីសន្និដ្ឋានថា បេក្ខជនមានលក្ខណៈសម្បត្តិ ឬមិនមានលក្ខណៈសម្បត្តិចូលប្រកបវិជ្ជាជីវៈមេធាវីនោះទេ ។

របាយការណ៍ត្រូវបញ្ជូនមកប្រធាននាយកដ្ឋានអធិការកិច្ចដើម្បីត្រួតពិនិត្យ និងវាយតម្លៃ មុននឹងបញ្ជូនមកប្រធានគណៈមេធាវីតាមចរន្តការឯកសារ ។

ប្រការ២២ .. ការទទួលខុសត្រូវរបស់អធិការ

ក្រុមអធិការកិច្ចដែលបាន ឬមានបំណងបិតបាំងនូវកំហុសរបស់បេក្ខជននឹងត្រូវទទួលទណ្ឌកម្មពីប្រធានគណៈ-មេធាវី ដោយពុំទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌដែលចែងនៅក្នុងច្បាប់ ។

ប្រការ២៣ .. ការពិនិត្យរបាយការណ៍

បន្ទាប់ពីទទួលបានរបាយការណ៍អធិការកិច្ចពីប្រធាននាយកដ្ឋានអធិការកិច្ច ប្រធានគណៈមេធាវីត្រូវត្រួតពិនិត្យអំពីទម្រង់ និងខ្លឹមសារនៃការធ្វើអធិការកិច្ច ។

ប្រសិនបើត្រឹមត្រូវតាមការកំណត់ ប្រធានគណៈមេធាវីត្រូវកំណត់ពេលសម្រាប់ធ្វើការប្រឡងសមត្ថភាពបេក្ខជនដូចបានកំណត់ក្នុងផ្នែកទី៤នៃជំពូកនេះ ។

ប្រសិនបើរបាយការណ៍នោះមិនត្រឹមត្រូវឬមានចំណុចខ្វះខាត ប្រធានគណៈមេធាវីនឹងបញ្ជូនសំណុំឯកសារនេះទៅក្រុមអធិការកិច្ចឱ្យធ្វើអធិការកិច្ចឡើងវិញ ក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយប្រធានគណៈមេធាវី ។

ផ្នែកទី៤
ការធ្វើតេស្តសមត្ថភាពបេក្ខជន

ប្រការ២៤ .. ការប្រឡងសមត្ថភាពបេក្ខជន

បេក្ខជនត្រូវឆ្លងកាត់ការប្រឡងសមត្ថភាពលើវិញ្ញាសាសរសេរ និងសួរផ្ទាល់មាត់ នៅមុនពេលសំណុំឯកសាររបស់បេក្ខជនរូបនោះត្រូវបានបញ្ជូនទៅសុំយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ការប្រឡងលើវិញ្ញាសាសរសេរ ត្រូវរៀបចំដោយគណៈមេប្រយោគដែលដឹកនាំដោយប្រធានគណៈមេធាវី និងតំណាងអគ្គលេខាធិការដ្ឋាន១ (មួយ)រូប ជាសមាជិក។

ប្រការ២៥ .. ការប្រឡងលើវិញ្ញាសាសរសេរ

គណៈមេប្រយោគត្រូវរៀបចំការប្រឡងសមត្ថភាពលើវិញ្ញាសាសរសេរក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលបញ្ចប់របាយការណ៍របស់ក្រុមអធិការកិច្ច។

មុខវិជ្ជានៃការប្រឡងវិញ្ញាសាសរសេររួមមាន ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវី។

បែបបទនៃការប្រឡងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈមេធាវី។

ប្រការ២៦ .. ការប្រឡងលើវិញ្ញាសាសួរផ្ទាល់មាត់

ប្រធានគណៈកម្មការត្រូវរៀបចំការប្រឡងសមត្ថភាពលើវិញ្ញាសាសួរផ្ទាល់មាត់ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការប្រឡងលើវិញ្ញាសាសរសេរត្រូវបានបញ្ចប់។

សមាសភាពរបស់គណៈកម្មការសម្ភាសន៍មានចំនួន ០៣រូបរួមមាន៖

-ប្រធានគណៈមេធាវី

-សមាជិកក្រុមប្រឹក្សាគណៈមេធាវី ០១រូប

-លេខាកត់ត្រា ០១រូប ដែលត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។

ប្រការ២៧ .. ករណីលើកលែង

បេក្ខជនដែលអាចរួចផុតពីការប្រឡងលើវិញ្ញាសាសរសេរត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

-ឥស្សរៈជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ ដូចជា សមាជិកឬមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យច្បាប់

-ចៅក្រម ឬព្រះរាជអាជ្ញា ដែលបានបម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រច្បាប់

-សិស្សមេធាវីដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល ហើយបានបម្រើការងារជាចៅក្រម ឬព្រះរាជអាជ្ញារយៈពេល ៥(ប្រាំ)ឆ្នាំ

-ជនជាតិខ្មែរដែលបានចុះបញ្ជី និងធ្វើជាមេធាវីពេញសិទ្ធិនៅបរទេស។

ផ្នែកទី៥
ការធ្វើសេចក្តីសម្រេចលើការស្នើសុំ

ប្រការ២៨ .. ការស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា

ក្រោយពីឆ្លងកាត់ការប្រឡងសមត្ថភាពរួចរាល់ គណៈមេធាវីត្រូវបញ្ជូនសំណុំឯកសាររបស់បេក្ខជនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីត្រួតពិនិត្យលើលក្ខខណ្ឌដែលកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិក:មេធាវី និងស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា។

សំណុំឯកសារដែលត្រូវបញ្ជូនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល រួមមាន ពាក្យសុំចូលប្រកបវិជ្ជាជីវ:មេធាវី ប្រវត្តិរូបសង្ខេប កិច្ចសន្យាផ្ទាល់ខ្លួន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សញ្ញាបត្រច្បាប់ លិខិតបញ្ជាក់ការងារ របាយការណ៍របស់អធិការកិច្ចគណៈមេធាវី និងលិខិតថ្កោលទោស។

ក្នុងករណីបេក្ខជនជាជំនួយការមេធាវីឬទីប្រឹក្សាច្បាប់របស់មេធាវី ត្រូវភ្ជាប់ឯកសារបន្ថែមនូវលិខិតទទួលស្គាល់ជំនួយការមេធាវីឬទីប្រឹក្សាមេធាវី និងប័ណ្ណសម្គាល់ជំនួយការឬទីប្រឹក្សា។

ក្នុងករណីបេក្ខជនមានលិខិតបញ្ជាក់ការងារចេញដោយវិស័យឯកជនត្រូវភ្ជាប់ឯកសារបន្ថែមនូវកិច្ចសន្យាការងារ។

ប្រការ២៩ .. នីតិវិធីនៃការសម្រេច

ការយល់ព្រមឱ្យចូលប្រកបវិជ្ជាជីវ:មេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិក:មេធាវី ត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

ក្នុងការសម្រេចអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវ:មេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិក:មេធាវី ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យនិងសម្រេចតាមលំដាប់លំដោយមួយម្តងៗ លើលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវ:មេធាវី រួមមាន សញ្ញាបត្រ បទពិសោធន៍ការងារ សមត្ថភាព និងការមានទោសពីមុន។

ការបោះឆ្នោតដើម្បីអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវ:មេធាវីត្រូវធ្វើជាសម្ងាត់។ ការសម្រេចគាំទ្របេក្ខជនត្រូវធ្វើឡើងតាមសំឡេងភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាននិងសំឡេងផ្ទេរសិទ្ធិ ដោយធ្យៃបទៅនឹងលទ្ធផលសំឡេងយល់ព្រម មិនយល់ព្រម អនុប្បវាទឬមិនបានការ។

ករណីសំឡេងអនុប្បវាទឬមិនបានការ ច្រើនជាងឬស្មើនឹងសំឡេងយល់ព្រមឬ/និងមិនយល់ព្រម ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធ្យៃបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ។

ក្នុងករណីសំឡេងយល់ព្រមនិងមិនយល់ព្រមស្មើគ្នា ហើយច្រើនជាងសំឡេងអនុប្បវាទឬមិនបានការ ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធ្យៃបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ។

ក្នុងករណីដែលក្រុមប្រឹក្សាគណៈមេធាវី សម្រេចមិនអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវ:មេធាវី ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញបេក្ខជនរូបនោះមកបញ្ចេញយោបល់នៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី។ ការកោះអញ្ជើញនេះត្រូវធ្វើឡើងយ៉ាងតិច ១០(ដប់)ថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី។ បន្ទាប់ពីស្តាប់យោបល់របស់

សាមីខ្លួនរួចហើយ សមាជិកក្រុមប្រឹក្សាគណៈមេធាវីអាចតាំងសំណួរបន្ថែមបាន។ ក្រោយការសួរសំណួរចប់សព្វគ្រប់ សាមីខ្លួនត្រូវចាកចេញពីបន្ទប់ប្រជុំ ហើយក្រុមប្រឹក្សាគណៈមេធាវីត្រូវពិភាក្សាគ្នានិងធ្វើការសម្រេចជាថ្មី។

ប្រការ៣០ .. ការប្តឹងតវ៉ាពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី

ក្នុងករណីក្រុមប្រឹក្សាគណៈមេធាវីសម្រេចមិនអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី គណៈមេធាវីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅសាមីខ្លួន ហើយសាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងរយៈពេល ២(ពីរ)ខែចាប់ពីថ្ងៃទទួលដំណឹង។

ប្រការ៣១ .. ការពិនិត្យនិងសម្រេចឡើងវិញ

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យលើសេចក្តីសម្រេចរបស់ខ្លួននិងសម្រេចឡើងវិញ តាមសាលដីការបស់តុលាការ។

ជំពូកទី៤
ការធ្វើសច្ចាប្រណិធាន

ប្រការ៣២ .. ការស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាន

ប្រធានគណៈមេធាវី ត្រូវបញ្ជូនឈ្មោះបេក្ខជនដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ដោយភ្ជាប់ជាមួយនូវសេចក្តីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី ដោយមានការបញ្ជាក់ពីនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលគណៈមេធាវីថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ការស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាននេះត្រូវធ្វើឡើងយ៉ាងយូរបំផុត ៣០(សាមសិប)ថ្ងៃ ដោយគិតពីថ្ងៃចេញសេចក្តីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី។

បេក្ខជនត្រូវចូលរួមធ្វើសច្ចាប្រណិធានតាមកាលបរិច្ឆេទកំណត់។

ប្រការ៣៣ .. តំណាងគណៈមេធាវីក្នុងកិច្ចសច្ចាប្រណិធាន

បន្ទាប់ពីបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃការធ្វើសច្ចាប្រណិធាន ប្រធានគណៈមេធាវីឬតំណាងដែលចាត់តាំងដោយប្រធានគណៈមេធាវី ត្រូវចូលរួមក្នុងកិច្ចសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ។

ជំពូកទី៥
ការធ្វើកម្មសិក្សា និងការសុំព្យួរកម្មសិក្សា

ប្រការ៣៤ .. ការដាក់ពាក្យសុំធ្វើកម្មសិក្សា

បេក្ខជនត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សាក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ជាមួយគ្រូកម្មសិក្សាណាម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានទីតាំងប្រកបវិជ្ជាជីវៈមេធាវីច្បាស់លាស់ និងងាយស្រួលទំនាក់ទំនងទៅវិញទៅមកររវាងគណៈមេធាវីនិងគ្រូកម្មសិក្សា។

ទម្រង់នៃពាក្យសុំធ្វើកម្មសិក្សាត្រូវកំណត់ដោយគណៈមេធាវី។ ពាក្យសុំនេះត្រូវមានសេចក្តីបញ្ជាក់យល់ព្រមរបស់គ្រូកម្មសិក្សា ដោយមានចុះហត្ថលេខា ត្រាមេធាវី និងឈ្មោះរបស់គ្រូកម្មសិក្សា ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុសច្ចាប្រណិធាន។ ទម្រង់នៃពាក្យសុំធ្វើកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ១ នៃសេចក្តីសម្រេចនេះ។

កម្មសិក្សាការីត្រូវបង្ហាញជូនគណៈមេធាវីឱ្យបានច្បាស់លាស់ថា ខ្លួនពុំមានវិសមិតភាពក្នុងការប្រកបវិជ្ជាជីវៈមេធាវីនោះឡើយ។ ក្នុងករណីមានវិសមិតភាព កម្មសិក្សាការីត្រូវសុំព្យួរឬលាឈប់ពីការងារ ដែលមានវិសមិតភាពនោះសិន។ ឯកសារដែលបញ្ជាក់ពីការព្យួរឬលាឈប់ពីការងារនេះត្រូវភ្ជាប់មកជាមួយពាក្យសុំធ្វើកម្មសិក្សា។

ប្រការ៣៥ .. ការដាក់ពាក្យសុំព្យួរកម្មសិក្សា

ដោយមានមូលហេតុសមស្រប បេក្ខជនអាចដាក់ពាក្យសុំព្យួរកម្មសិក្សាក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ សម្រាប់រយៈពេលមិនលើសពី២(ពីរ)ឆ្នាំម្តង។ បេក្ខជនអាចដាក់ពាក្យសុំបន្តការព្យួរកម្មសិក្សាជាបន្តបន្ទាប់ទៀតបាន ដោយមានបញ្ជាក់នូវមូលហេតុសមស្រប។ ទម្រង់នៃពាក្យសុំព្យួរកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ២ នៃសេចក្តីសម្រេចនេះ។

មូលហេតុសមស្របមានជាអាទិ៍៖

១-បេក្ខជនសាមីបំពេញការងារមានវិសមិតភាពជាមួយនឹងវិជ្ជាជីវៈមេធាវី ឬ

២-បេក្ខជនសាមីកំពុងបំពេញការងារ ឬសិក្សា ឬស្រាវជ្រាវនៅបរទេស ឬ

៣-បេក្ខជនសាមីកំពុងសម្រាកព្យាបាលជម្ងឺ នៅក្នុងស្រុក ឬបរទេស ឬ

៤-បេក្ខជនសាមីមានបញ្ជាក់នូវមូលហេតុសមស្របផ្សេងទៀត។

ក្នុងរយៈពេលព្យួរកម្មសិក្សា បេក្ខជនមានកាតព្វកិច្ចបង់ប្រាក់ស្មើនឹងពាក់កណ្តាលនៃប្រាក់ភាគទានរបស់មេធាវីពេញសិទ្ធិ។

ការអនុញ្ញាតឱ្យព្យួរកម្មសិក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ៣៦ .. ការខកខានក្នុងការដាក់ពាក្យសុំធ្វើកម្មសិក្សា ឬដាក់ពាក្យសុំព្យួរកម្មសិក្សា

ក្នុងករណីបេក្ខជនមិនបានដាក់ពាក្យសុំធ្វើកម្មសិក្សា ឬដាក់ពាក្យសុំព្យួរកម្មសិក្សាក្នុងរយៈពេលកំណត់ក្នុងប្រការ ៣៤ និងប្រការ ៣៥ ខាងលើ គណៈមេធាវីចាត់ទុកថា បេក្ខជនបោះបង់ចោលការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីសម្រេចលុបចោលការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី។

ប្រការ៣៧ .. រយៈពេលនៃការធ្វើកម្មសិក្សា

រយៈពេលនៃការធ្វើកម្មសិក្សាជាមួយគ្រូកម្មសិក្សាគឺមានរយៈពេល១២(ដប់ពីរ)ខែគត់ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចអនុញ្ញាតឱ្យធ្វើកម្មសិក្សា។ សាមីខ្លួនអាចដាក់ពាក្យសុំពន្យារពេលការដាក់របាយការណ៍បញ្ចប់កម្មសិក្សា ដោយបញ្ជាក់មូលហេតុសមស្របជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមិនលើសពី ២ (ពីរ)ខែ គិតចាប់ពីថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា។ ក្នុងករណីខកខានក្នុងការដាក់ពាក្យសុំពន្យារពេលដាក់របាយការណ៍បញ្ចប់កម្មសិក្សា គណៈមេធាវីចាត់ទុកថា បេក្ខជនបោះបង់ចោលការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីសម្រេចលុបឈ្មោះចេញពីបញ្ជីមេធាវីកម្មសិក្សា។ ទម្រង់នៃពាក្យសុំពន្យារពេលការដាក់របាយការណ៍បញ្ចប់កម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ៣ នៃសេចក្តីសម្រេចនេះ។

ការអនុញ្ញាតឱ្យពន្យារពេលការដាក់ឧបាយការណ៍បញ្ចប់កម្មសិក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងរយៈពេលនៃការពន្យារការដាក់ឧបាយការណ៍បញ្ចប់កម្មសិក្សា បេក្ខជនត្រូវបង់ប្រាក់ ស្មើនឹងពាក់កណ្តាលនៃប្រាក់ភាគទានមេធាវីពេញសិទ្ធិ ។

ប្រការ៣៨ .. ការជ្រើសរើសគ្រូកម្មសិក្សា

គ្រូកម្មសិក្សាត្រូវជ្រើសរើសដោយស្ម័គ្រចិត្តនិងតាមការព្រមព្រៀងរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការី ដោយត្រូវមានកិច្ចសន្យាសហការរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការី ។

ទម្រង់កិច្ចសន្យាសហការរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការីត្រូវកំណត់ដោយគណៈមេធាវី និងអាចកំណត់បន្ថែមតាមការព្រមព្រៀង ។ ទម្រង់គំរូនៃកិច្ចសន្យាសហការរវាងគ្រូកម្មសិក្សា និងកម្មសិក្សាការីមានភ្ជាប់ជាឧបសម្ព័ន្ធ៤នៃសេចក្តីសម្រេចនេះ ។

គ្រូកម្មសិក្សាត្រូវមានលក្ខណៈសម្បត្តិតាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើគ្រូកម្មសិក្សាមិនមានលក្ខណៈសម្បត្តិដូចកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាគណៈមេធាវីនឹងមិនសម្រេចអនុញ្ញាតឱ្យកម្មសិក្សាការីធ្វើកម្មសិក្សាជាមួយគ្រូកម្មសិក្សានោះទេ ។ ករណីនេះ កម្មសិក្សាការីត្រូវជ្រើសរើសគ្រូថ្មីក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពេលទទួលដំណឹង ។

កម្មសិក្សាការីអាចផ្លាស់ប្តូរគ្រូកម្មសិក្សាបានលុះត្រាតែគោរពតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

-មានមូលហេតុគ្រប់គ្រាន់ដែលបញ្ជាក់ថាគ្រូកម្មសិក្សាពុំអាចបន្តការដឹកនាំតទៅទៀតបាន ដូចជា ទទួលមរណៈភាព ត្រូវទណ្ឌកម្មវិន័យផ្អាកការប្រកបវិជ្ជាជីវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬមូលហេតុប្រធានសក្តិជាដើម

-ករណីចង់ប្តូរគ្រូកម្មសិក្សាក្រៅពីលក្ខខណ្ឌខាងលើ អាចធ្វើទៅបានលុះត្រាតែកម្មសិក្សាការីធ្វើកម្មសិក្សាបានរយៈពេលពេញ ០៦(ប្រាំមួយ)ខែរួចហើយ ។

ទម្រង់នៃពាក្យសុំប្តូរគ្រូកម្មសិក្សា មានភ្ជាប់ជាឧបសម្ព័ន្ធ៥នៃសេចក្តីសម្រេចនេះ ។

ប្រការ៣៩ .. ភាតព្វកិច្ចរបស់កម្មសិក្សាការី

កម្មសិក្សាការីត្រូវគោរពការណែនាំរបស់គ្រូកម្មសិក្សា និងត្រូវបំពេញការងាររបស់ខ្លួនឱ្យស្របតាមច្បាប់ ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងគណៈមេធាវី និងសេចក្តីសម្រេចនានារបស់គណៈមេធាវី ។

កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គសុក្រឹតការវិជ្ជាជីវៈមេធាវី និងការបណ្តុះបណ្តាលនានាតាមការកំណត់របស់គណៈមេធាវី ។

ក្នុងរយៈពេលកម្មសិក្សា កម្មសិក្សាការីមានកាតព្វកិច្ចការពារក្តី ឬតំណាងដោយអាណត្តិជូនជនក្រីក្រដោយឥតយកកម្រៃ និងផ្តល់ការពិគ្រោះយោបល់ឥតយកកម្រៃជូនជនក្រីក្រ តាមការចាត់តាំងរបស់គណៈមេធាវី ។ ការការពារក្តី ការតំណាងដោយអាណត្តិ និងការពិគ្រោះយោបល់នេះ ត្រូវបញ្ចូលក្នុងរបាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី ។

ទណ្ឌកម្មដែលក្រុមប្រឹក្សាគណៈមេធាវីអាចដាក់ចំពោះកម្មសិក្សាការី គឺឱ្យធ្វើកម្មសិក្សាបន្ថែមក្នុងរយៈពេលមិនលើសពី១២(ដប់ពីរ)ខែ ដោយបង់ប្រាក់ដូចបានកំណត់ក្នុងប្រការ៣៧(រយៈពេលនៃការធ្វើកម្មសិក្សា)នៃសេចក្តីសម្រេចនេះ ឬលុបឈ្មោះពីបញ្ជីមេធាវីកម្មសិក្សា ។

ប្រការ៤០ .. ភារតួកិច្ចរបស់គ្រូកម្មសិក្សា

គ្រូកម្មសិក្សាត្រូវទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ចំពោះការប្រកបវិជ្ជាជីវៈមេធាវី និងការធ្វើរបាយការណ៍កម្មសិក្សា។

បើកម្មសិក្សាការីមានកំហុសក្នុងការប្រកបវិជ្ជាជីវៈមេធាវីក្នុងអំឡុងពេលកម្មសិក្សា ដូចជា ការបំពេញឯកសារពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី ការតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត ឬការផ្តល់យោបល់ផ្នែកច្បាប់ ជាអាទិ៍ ត្រូវចាត់ទុកជាកំហុសរួមរបស់គ្រូកម្មសិក្សានិងកម្មសិក្សាការី។

ទណ្ឌកម្មដែលក្រុមប្រឹក្សាគណៈមេធាវីអាចដាក់ចំពោះគ្រូកម្មសិក្សាមានជាអាទិ៍ ការដកសិទ្ធិជាគ្រូកម្មសិក្សាមិនលើសពី ០២(ពីរ)ឆ្នាំ ឬការប្តូរគ្រូកម្មសិក្សា ឬទណ្ឌកម្មដទៃទៀត អាស្រ័យលើទំហំនៃកំហុសជាក់ស្តែងរបស់គ្រូកម្មសិក្សា។

ជំពូកទី៦
ការលើកលែងការធ្វើកម្មសិក្សា

ប្រការ៤១ .. ការដាក់ពាក្យសុំ

បេក្ខជនដែលមានបំណងសុំលើកលែងការធ្វើកម្មសិក្សា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងប្រការ៤២ (លក្ខណៈសម្បត្តិ)ខាងក្រោម ហើយអាចដាក់ពាក្យសុំដោយភ្ជាប់ជាមួយនឹងមូលហេតុជាលាយលក្ខណ៍អក្សរ និងភស្តុតាងគាំទ្រនូវមូលហេតុទាំងនោះមកគណៈមេធាវី។ សំណើនេះនឹងដាក់ជូនក្រុមប្រឹក្សាសម្រេច ក្នុងរយៈពេលសមរម្យ។

ទម្រង់នៃពាក្យសុំលើកលែងកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ៦នៃសេចក្តីសម្រេចនេះ។

ប្រការ៤២ .. លក្ខណៈសម្បត្តិ

បេក្ខជនដែលមានលក្ខណៈសម្បត្តិដូចបានកំណត់ខាងក្រោមនេះអាចពិចារណាឱ្យរួចផុតពីកម្មសិក្សា៖

-ឥស្សរៈជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច ១០(ដប់)ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ ដូចជា សមាជិកឬមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យច្បាប់

-ចៅក្រមឬព្រះរាជអាជ្ញា ដែលបានបម្រើការងារយ៉ាងតិច ១០(ដប់)ឆ្នាំ និងមានបរិញ្ញាបត្រច្បាប់

-អ្នកដែលមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ហើយបានបម្រើការងារជាចៅក្រម ឬព្រះរាជអាជ្ញារយៈពេល ០៧(ប្រាំពីរ)ឆ្នាំ

-ជនជាតិខ្មែរដែលបានចុះបញ្ជីនិងធ្វើជាមេធាវីពេញសិទ្ធិនៅបរទេស។

ប្រការ៤៣ .. ភារតួកិច្ចរបស់បេក្ខជនស្នើសុំរួចផុតកម្មសិក្សា

បេក្ខជនដែលស្នើសុំរួចផុតកម្មសិក្សាត្រូវគោរពកាតព្វកិច្ចនានាដែលបានកំណត់ដោយបទប្បញ្ញត្តិទាក់ទងនឹងវិធានវិជ្ជាជីវៈមេធាវីនិងសេចក្តីសម្រេចនានារបស់គណៈមេធាវី។

បេក្ខជនដែលស្នើសុំរួចផុតកម្មសិក្សាត្រូវចូលរួមក្នុងវគ្គសុក្រឹតការវិជ្ជាជីវៈមេធាវីនិងការបណ្តុះបណ្តាលនានាដែលតម្រូវដោយគណៈមេធាវីទៅតាមការកំណត់និងចំនួនម៉ោងនៃការសិក្សារបស់គណៈមេធាវី លើកលែងតែបេក្ខជន

នោះបានបញ្ចប់ការសិក្សានិងទទួលវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ ប្រសិនបើបេក្ខជននោះមិនបានចូលរួមនិងបញ្ចប់វគ្គសុក្រឹតការដែលតម្រូវដោយគណៈមេធាវីទេនោះ បេក្ខជននោះមិនអាចប្រកបវិជ្ជាជីវៈមេធាវីបានឡើយ ។

ជំពូកទី៧
ការបញ្ចប់ការធ្វើកម្មសិក្សា

ប្រការ៤៤ .. ការធ្វើរបាយការណ៍

កម្មសិក្សាការីដែលបានបំពេញកម្មសិក្សារបស់ខ្លួនជាមួយគ្រូកម្មសិក្សានៅក្នុងរយៈពេលដែលបានកំណត់ដោយគណៈមេធាវីរួចហើយ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពនៃការបំពេញវិជ្ជាជីវៈមេធាវីរបស់ខ្លួនមកគណៈមេធាវី ដើម្បីឱ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យនិងសម្រេច អំពីការអនុញ្ញាតឬមិនអនុញ្ញាតឱ្យចុះបញ្ជីគណៈមេធាវី ។

របាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី ត្រូវមានភ្ជាប់ជាមួយនឹងលិខិតដែលបញ្ជាក់អំពីយោបល់របស់គ្រូកម្មសិក្សានិងភស្តុតាងនានាដែលបញ្ជាក់អំពីការបំពេញការងារវិជ្ជាជីវៈមេធាវី សម្រាប់គាំទ្រសកម្មភាពដែលបានបរិយាយក្នុងរបាយការណ៍ និងជាមូលដ្ឋាននៃការបញ្ជាក់អំពីសមត្ថភាពនៃការប្រកបវិជ្ជាជីវៈមេធាវី ។

ប្រការ៤៥ .. ទម្រង់និងខ្លឹមសារនៃរបាយការណ៍

កម្មសិក្សាការីត្រូវធ្វើរបាយការណ៍តាមទម្រង់ដែលកំណត់ដោយគណៈមេធាវីដូចខាងក្រោម ៖

១. ទម្រង់

របាយការណ៍ត្រូវមាន៖

- កំរាស់យ៉ាងច្រើនចំនួន ២០(ម្ភៃ)ទំព័រ ដោយមានរឹមខាងលើទំហំ ២០ (ម្ភៃ)មីលីម៉ែត្រ និងខាងក្រោមទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ ។ ចំពោះរឹមខាងស្តាំមានទំហំ ១៥ (ដប់ប្រាំ)មីលីម៉ែត្រ និងខាងឆ្វេងទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ ។
- សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ។

២. ចំនួនរឿងក្តី

ក្នុងរយៈពេលកម្មសិក្សា កម្មសិក្សាការីត្រូវបំពេញកិច្ចការពារក្តីនិងតំណាងដោយអាណត្តិដូចខាងក្រោម៖

- រឿងក្តីព្រហ្មទណ្ឌចំនួន ០៣ (បី) យ៉ាងតិច
- រឿងក្តីរដ្ឋប្បវេណីចំនួន ០៣ (បី) យ៉ាងតិច
- ការពិគ្រោះយោបល់ច្បាប់ចំនួន ០៥ (ប្រាំ) ករណីយ៉ាងតិច ។

៣. ខ្លឹមសារ

- ត្រូវសង្ខេបកិច្ចការដែលខ្លួនបានបំពេញក្នុងរយៈពេលធ្វើកម្មសិក្សា
- ត្រូវលើកយករឿងក្តីព្រហ្មទណ្ឌ ០១ (មួយ)ករណី ដែលការពារសិទ្ធិឱ្យជនជាប់ចោទ នៅដំណាក់កាលជំនុំជម្រះ និងរឿងក្តីរដ្ឋប្បវេណី ០១ (មួយ)ករណី ដែលខ្លួនបានបញ្ចប់ការការពារនិងតំណាងដោយអាណត្តិមកបង្ហាញ
- ត្រូវបង្ហាញសមត្ថភាពក្នុងការការពារក្តីក្នុងរឿងនោះ ដោយផ្តល់យុទ្ធសាស្ត្រសម្រាប់ការការពាររឿងក្តីរួមមានអង្គហេតុសង្ខេប ចំណុចខ្សោយ ចំណុចខ្លាំង ទ្រឹស្តីការពារ សេចក្តីសន្និដ្ឋានឬសេចក្តីថ្លែងការណ៍ និងលទ្ធផលនៃការការពារឬតំណាងដោយអាណត្តិ

- ត្រូវមានឯកសារយោងភ្ជាប់មកជាមួយ ចំពោះរឿងក្តីទាំងពីរដែលបានលើកមកបង្ហាញនៅក្នុងរបាយការណ៍។ ចំពោះរឿងក្តីផ្សេងទៀតត្រូវដាក់ក្នុងលេខយោងនៅចុងទំព័រ។
- កម្មសិក្សាការីត្រូវផ្តល់ព័តិមានឱ្យបានត្រឹមត្រូវនៅរបាយការណ៍បញ្ចប់កម្មសិក្សា។ ក្នុងករណីកម្មសិក្សាការីផ្តល់ព័តិមានមិនពិតត្រូវទទួលទណ្ឌកម្មវិន័យ។

ប្រការ៤៦ .. ការដាក់និងការពិនិត្យលើរបាយការណ៍

កម្មសិក្សាការីត្រូវដាក់របាយការណ៍បញ្ចប់កម្មសិក្សាចំនួន ៥ (ប្រាំ)ច្បាប់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ជាទម្រង់អេឡិចត្រូនិក (PDF)។

របាយការណ៍នោះត្រូវបញ្ជូនមកប្រធានគណៈមេធាវីដើម្បីចាត់តាំងគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងវាយតម្លៃទៅលើរបាយការណ៍នោះ។

សមាសភាពគណៈកម្មការចំពោះកិច្ចនេះ គឺជាសមាជិកក្រុមប្រឹក្សា ដែលត្រូវពិនិត្យទៅលើយោបល់របស់គ្រូកម្មសិក្សា ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ដូចមានកំណត់ក្នុងប្រការ៤៥ ខាងលើ។

ប្រការ៤៧ .. ការសម្រេចលើការបញ្ចប់កម្មសិក្សា និងការចូលពេញសិទ្ធិ

ក្រុមប្រឹក្សាគណៈមេធាវីនឹងពិនិត្យទៅលើរបាយការណ៍របស់កម្មសិក្សាការី យោបល់របស់គណៈកម្មការចំពោះកិច្ច និងវាយតម្លៃលើរបាយការណ៍ យោបល់គ្រូកម្មសិក្សា និងស្ថានភាពជាក់ស្តែងនៃការបំពេញការងារវិជ្ជាជីវៈមេធាវីរបស់កម្មសិក្សាការី។

ប្រសិនបើរបាយការណ៍មានលក្ខណៈត្រឹមត្រូវតាមការកំណត់នៃលក្ខខណ្ឌ ទម្រង់ និងខ្លឹមសារ ដូចមានកំណត់ក្នុងប្រការ៤៥ នៃសេចក្តីសម្រេចនេះ។

ជំពូកទី៨
អន្តរប្បញ្ញត្តិ

ប្រការ៤៨ .. ការលើកលែងអនុវត្ត

ផ្នែកទី ៤ ជំពូកទី ៣ នៃសេចក្តីសម្រេចនេះមិនអនុវត្តចំពោះបេក្ខជនដែលទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញរួចហើយគិតត្រឹមកាលបរិច្ឆេទនៃសេចក្តីសម្រេចនេះ។

ជំពូកទី៩
អវសាន្តប្បញ្ញត្តិ

ប្រការ៤៩ .. និរាករណ៍

សេចក្តីសម្រេចលេខ០១១/សសគម/១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីការដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ សេចក្តីសម្រេចលេខ៧១១/សសគម/១៧ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងសេចក្តីសម្រេចលេខ០៩៦/សសគម/១៩ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលប្រការ២៣ និងប្រការ២៤ នៃសេចក្តីសម្រេចលេខ៧១១/សសគម/១៧ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី

នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៥០ .. ការចូលជាធរមាន

សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខារបស់ប្រធានគណៈមេធាវីតទៅ។

ថ្ងៃ ច័ន្ទ ៤ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

ប្រធាន

មេធាវី លី ចំណុលា

ចម្លងជូន:

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ចំណុតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ឡូនគា
៦-មេធាវី ចេង ប៊ែងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ខុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន្ទ ទិចិត្រ
១៨-មេធាវី ព្រហ្ម ទិចិត្រសុតា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យីម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឃ្មាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ្រា
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ឡូន ជានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ៣៧៤៤ /សសគម/២១

សេចក្តីសម្រេច
ស្តីពី
បែបបទនៃការប្រឡងវិញ្ញាសាសរសេរសម្រាប់បេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំណុតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- បានឃើញសេចក្តីសម្រេចលេខ ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងត្រួតពិនិត្យសមត្ថភាពរបស់បេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី តាមរយៈការកំណត់អំពីបែបបទនៃការប្រឡងលើវិញ្ញាសាសរសេរ។

ប្រការ២ .. និយមន័យ

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះបេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី សម្រាប់ការប្រឡងលើវិញ្ញាសាសរសេរ។

ជំពូកទី២
គណៈមេប្រយោគ

ប្រការ៣ .. សមាសភាពរបស់គណៈមេប្រយោគ

គណៈមេប្រយោគមានសមាសភាព ២(ពីរ)រូបគឺ៖

១.ប្រធានគណៈមេធាវី	ប្រធានគណៈមេប្រយោគ
២.តំណាងអគ្គលេខាធិការដ្ឋានគណៈមេធាវី	សមាជិកគណៈមេប្រយោគ។

សមាជិកគណៈមេប្រយោគ ត្រូវតែងតាំងដោយប្រធានគណៈមេប្រយោគ តាមសំណើរបស់អគ្គលេខាធិការគណៈមេធាវី។

តាមការចាំបាច់ ប្រធានគណៈមេប្រយោគអាចចាត់តាំងបុគ្គលិកគណៈមេធាវីម្នាក់ឬច្រើននាក់ឱ្យជួយដល់ការងារប្រឡងលើវិញ្ញាសាសរសេរនេះបាន។

ប្រការ៤ .. តួនាទីរបស់គណៈមេប្រយោគ

គណៈមេប្រយោគមានការកិច្ចដូចខាងក្រោម៖

- កំណត់កាលបរិច្ឆេទប្រឡង ទីកន្លែងប្រឡង និងចំនួនបេក្ខជនដែលត្រូវមកប្រឡង
- ចេញវិញ្ញាសាសម្រាប់ប្រឡង
- ត្រួតពិនិត្យការប្រឡង
- ដាក់ទណ្ឌកម្មលើបេក្ខជនណាមួយដែលរំលោភលើបទបញ្ជានៃការប្រឡង
- ចាត់តាំងគ្រូកំណែលើវិញ្ញាសាប្រឡងរបស់បេក្ខជន
- ប្រកាសលទ្ធផលនៃការប្រឡង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

គណៈមេប្រយោគមានសិទ្ធិប្រើត្រា លេខលិខិតរដ្ឋបាល និងធនធានផ្សេងៗរបស់គណៈមេធាវី ដើម្បីសម្រួលដល់ការប្រឡង។

ជំពូកទី៣
បែបបទនៃការប្រឡង

ប្រការ៥ .. រយៈពេលនិងមុខវិជ្ជាប្រឡង

រយៈពេលនៃការប្រឡងមានចំនួន៣ (បី)ម៉ោង លើមុខវិជ្ជាដែលត្រូវប្រឡងចំនួន៣(បី)គឺ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៦ .. ការជូនដំណឹងអំពីការប្រឡង

ប្រធានគណៈមេប្រយោគត្រូវជូនដំណឹងដល់បេក្ខជនដែលត្រូវចូលរួមប្រឡងអំពី ម៉ោង ថ្ងៃ និងទីកន្លែងប្រឡងឱ្យបានយ៉ាងតិច ១(មួយ)សប្តាហ៍មុនថ្ងៃប្រឡង។ ការជូនដំណឹងនេះអាចធ្វើជាលាយលក្ខណ៍អក្សរផ្ញើជូនបេក្ខជនផ្ទាល់ដៃឬតាមរយៈទូរស័ព្ទទៅបេក្ខជនម្នាក់ៗ ដោយមានបញ្ជាក់តាមការធ្វើចូលប្រព័ន្ធទំនាក់ទំនងសង្គមផ្ទាល់ខ្លួនរបស់បេក្ខជននោះ។

ប្រធានគណៈមេប្រយោគត្រូវចាត់ឱ្យបិទបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡង នៅក្នុងបញ្ជរព័ត៌មានរបស់គណៈមេធាវីនិងអាចផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់គណៈមេធាវីបាន។

ប្រការ៧ .. ការចេញវិញ្ញាសាប្រឡង

ប្រធានគណៈមេប្រយោគជាអ្នកចេញវិញ្ញាសាសម្រាប់ការប្រឡងវិញ្ញាសាសរសេរមួយលើកៗ។ វិញ្ញាសាសរសេរត្រូវចែកជា២(ពីរ)គឺ វិញ្ញាសាលើមុខវិជ្ជាក្រមនីតិវិធីព្រហ្មទណ្ឌនិងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់រយៈពេល ១:៣០(មួយម៉ោងនិងសាមសិបនាទី) និងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល១:៣០(មួយម៉ោងនិងសាមសិបនាទី)។

ប្រការ៨ .. ភាគព្វកិច្ចរបស់បេក្ខជនដែលត្រូវប្រឡង

បេក្ខជនប្រឡងត្រូវអនុវត្តតាមបទបញ្ជាប្រឡងដូចបានកំណត់ក្នុងជំពូកទី៤ នៃសេចក្តីសម្រេចនេះនិងអនុវត្តតាមការណែនាំរបស់គណៈមេប្រយោគឱ្យបានម៉ឺងម៉ាត់។

បេក្ខជនដែលមិនគោរពតាមបទបញ្ជាប្រឡងឬការណែនាំរបស់គណៈមេប្រយោគ ត្រូវទទួលទណ្ឌកម្មវិន័យតាមការសម្រេចរបស់គណៈមេប្រយោគ។

ប្រការ៩ .. ការធ្វើកំណែលើវិញ្ញាសាប្រឡង

ប្រធានគណៈមេប្រយោគនិងគ្រូកំណែជាអ្នកកំណត់អត្រាកំណែ។ គ្រូកំណែជាអ្នកធ្វើកំណែលើវិញ្ញាសាប្រឡងរបស់បេក្ខជន ដោយកំណត់ពិន្ទុ២០/២០។

ប្រការ១០ .. លទ្ធផលប្រឡង

លទ្ធផលប្រឡងត្រូវទទួលស្គាល់ដោយគណៈមេប្រយោគ។ លទ្ធផលនេះទុកសម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិចារណាជាមូលដ្ឋាន នៅពេលពិនិត្យនិងសម្រេចលើការអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវៈមេធាវី។

ជំពូកទី៤
បទបញ្ជាប្រឡង

ប្រការ១១ .. បទបញ្ជា

បេក្ខជនប្រឡងត្រូវ៖

១.យកមកជាមួយនូវអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន ដើម្បីបង្ហាញគណៈមេប្រយោគ។

២.មកដល់កន្លែងប្រឡងឱ្យបានមុនពេលដំណើរការប្រឡង។

៣.ស្លៀកពាក់ឯកសណ្ឋានសមរម្យ។

៤.ប្រកាន់អាកប្បកិរិយាសមរម្យ ថ្លៃថ្នូរ។

៥.គោរពការណែនាំរបស់គណៈមេប្រយោគ។

៦.បំពេញក្បាលសន្លឹកកិច្ចការប្រឡងឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់តាមការណែនាំរបស់គណៈមេប្រយោគ។

៧.សរសេរលើសន្លឹកកិច្ចការសម្រាប់ធ្វើវិញ្ញាសាសរសេរដែលចែកជូនដោយគណៈមេប្រយោគ។

៨.ប្រើប្រាស់សន្លឹកកិច្ចការទាំងមូល ដើម្បីតាក់តែងចម្លើយ។

៩.ប្រើក្រដាសព្រាងដែលមានត្រាគណៈមេធាវីដែលរៀបចំដោយគណៈមេប្រយោគ និងត្រូវចុះលេខតុរបស់បេក្ខជននៅចុងសន្លឹក។

១០.សុំការអនុញ្ញាតពីគណៈមេប្រយោគ នៅពេលមានធុរៈចាំបាច់ឬទៅបន្ទប់ទឹក។

១១.ប្រគល់សន្លឹកកិច្ចការជូនគណៈមេប្រយោគវិញនៅពេលដល់ម៉ោងកំណត់ ទោះបីជាកិច្ចការនោះធ្វើរួចរាល់ឬមិនទាន់រួចរាល់ក្តី។

១២.រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងពេលប្រឡង និងគោរពឱ្យបានត្រឹមត្រូវតាមការណែនាំផ្សេងទៀតដែលត្រូវអនុវត្តក្នុងពេលប្រឡង។

បេក្ខជនប្រឡងមិនត្រូវ៖

១.យកសំណៅឯកសារច្បាប់ សៀវភៅច្បាប់ ឯកសារ ឬកំណត់ត្រាផ្សេងៗចូលបន្ទប់ប្រឡងឡើយ លើកលែងតែវិញ្ញាសាបានកំណត់ឱ្យបេក្ខជនមើលឯកសារបាន។

២.យកសម្ភារដទៃទៀតដូចជា អារុធជាតិផ្ទុះ ទូរស័ព្ទ វិទ្យុទាក់ទងផ្សេងៗ កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិច ឬឧបករណ៍ផ្សេងៗគ្រប់ប្រភេទ ចូលបន្ទប់ប្រឡងឡើយ។ គណៈមេប្រយោគមានសិទ្ធិដកហូតនូវគ្រប់សម្ភារនិងឧបករណ៍ទាំងនោះ **<u>ហើយមិនទទួលខុសត្រូវចំពោះការខូចខាតឬការបាត់បង់ឡើយ</u>**។

៣.ចូលបន្ទប់ប្រឡងមុនពេលគណៈមេប្រយោគហៅឈ្មោះឱ្យចូល។

៤.ប្តូរសន្លឹកកិច្ចការ ឬក្រដាសព្រាងឱ្យគ្នាទៅវិញទៅមក ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា ឬដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួន បង្កឱ្យអ្នកដទៃមើល ឬឆក់យកបានឡើយ។

៥.ឱ្យអ្នកដទៃមកប្រឡងជំនួស ឬមកប្រឡងជំនួសអ្នកដទៃឡើយ។

៦.ចូលបន្ទប់ប្រឡងក្រោយ ១៥ នាទី បន្ទាប់ពីការចែកវិញ្ញាសា។

៧.ចុះហត្ថលេខា ឬហត្ថលេខាសង្ខេប ឬធ្វើសញ្ញាសម្គាល់ណាមួយលើសន្លឹកកិច្ចការខុសពីសេចក្តីណែនាំរបស់គណៈមេប្រយោគ។

៨.ពិភាក្សា ឆ្លើយឆ្លង លួចចម្លង ឱ្យគេចម្លង និងទទួលព័ត៌មានពីខាងក្រៅ។

៩.សរសេរលើសន្លឹកកិច្ចការណាដែលគ្មានហត្ថលេខារបស់គណៈមេប្រយោគ។

១០.សរសេររំលងបន្ទាត់ ឬក្រោមបន្ទាត់ ឬមិនជាប់បន្ទាត់ នៅលើសន្លឹកកិច្ចការ។

១១.សរសេររំលងទំព័រ ឬទុកទំព័រសន្លឹកកិច្ចការណាមួយឱ្យនៅទំនេរ។

១២.គូសបន្ទាត់ពុះសន្លឹកកិច្ចការជាពីរ។

ប្រការ១២ .. ឧណ្ហភម្ភ

ត្រូវបានកំណត់ឱ្យពិន្ទុសូន្យលើសន្លឹកកិច្ចការរបស់បេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖

១.ដើរចុះដើរឡើងចេញពីកន្លែងអង្គុយ ដោយគ្មានការអនុញ្ញាតពីគណៈមេប្រយោគ។

២.ហែកសន្លឹកកិច្ចការ ឬមិនព្រមប្រគល់សន្លឹកកិច្ចការជូនគណៈមេប្រយោគ។

៣.ផ្លាស់កន្លែងអង្គុយ ឬលុបលេខតុពីកន្លែងដែលបានកំណត់ ឬទៅសរសេរលេខតុរបស់ខ្លួននៅកន្លែងផ្សេង ដោយគ្មានការអនុញ្ញាតពីគណៈមេប្រយោគ។

៤.ឱ្យ ឬទទួលសន្លឹកកិច្ចការ ឬសំណៅក្រដាសព្រាងរបស់ខ្លួនទៅ ឬពីអ្នកដទៃចម្លង ឬផ្ទៀងផ្ទាត់ចម្លើយ។

៥.ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន ឬជួយសរសេរលើសន្លឹកកិច្ចការរបស់អ្នកដទៃ។
៦.បន្លំមកប្រឡងជំនួសអ្នកដទៃ ឬឱ្យអ្នកដទៃមកប្រឡងជំនួស។
៧.ធ្វើសញ្ញាសម្គាល់ ឬគំនូសសម្គាល់លើសន្លឹកកិច្ចការប្រឡង។
៨.ប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទង កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ ដែលប្រើប្រាស់សម្រាប់ទំនាក់ទំនងក្នុងការធ្វើវិញ្ញាសាសរសេរ។

ហាមមិនឱ្យប្រឡង និងត្រូវបណ្តេញចេញពីបន្ទប់ប្រឡង ឬលទ្ធផលដែលប្រឡងជាប់នឹងត្រូវបដិសេធចំពោះបេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖

១.បោះវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកឯកសារ ឬក្លែងបន្លំឯកសារ ឬយកសំណៅចម្លើយពាក់ព័ន្ធនឹងវិញ្ញាសាចូលក្នុងបន្ទប់ប្រឡងក្នុងពេលកំពុងធ្វើវិញ្ញាសា។
២.បង្កជម្លោះនៅក្នុងបន្ទប់ប្រឡង ឬគំរាមកំហែងលើបេក្ខជនដទៃ។
៣.ដណ្តើមយកសន្លឹកកិច្ចការរបស់អ្នកដទៃមកចម្លង ឬហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ ឬយកសន្លឹកកិច្ចការអ្នកដទៃមកធ្វើជាសន្លឹកកិច្ចការរបស់ខ្លួន។
៤.យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង។
៥.ធ្វើឱ្យខូចខាតសម្ភារក្នុងបន្ទប់ប្រឡងដោយចេតនា។
៦.បង្កបាតុភាពជាពាក្យសំដី ជាកាយវិការ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬរាងកាយ ឬគំរាមកំហែងដល់គណៈកម្មការរៀបចំការប្រឡង ឬអ្នកមានសមត្ថកិច្ចត្រួតពិនិត្យការប្រឡង។

ជំពូកទី៥
អវសានប្បញ្ញត្តិ

ប្រការ១៣ .. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ១៤ .. ការអនុវត្ត

អគ្គលេខាធិការគណៈមេធាវី ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១
ប្រធានគណៈមេធាវី

មេធាវី លី-ចំន្ទគុណា

ចម្លងជូន៖
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ច័ន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ទាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុភណ្ណាលី
៥-មេធាវី ប៉ា ចូនគា
៦-មេធាវី ចេង ម៉េងហាប់
៧-មេធាវី ឃុត ឆានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កែង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន្ទ ទិចិត្រា
១៨-មេធាវី ព្រហ្ម ទិចិត្រសុតា
១៩-មេធាវី ណុប គុណចុល
២០-មេធាវី យីម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឃ្មាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំវត្ត
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ធ្វី សំរស់
៣២-មេធាវី ទួន ឆានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ២៤៤/សសគម/២១

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងគណៈមេប្រយោគសម្រាប់ការប្រឡងវិញ្ញាសាសរសេរ សម្រាប់បេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី ១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
ការបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១១
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧។

ស ម្រេ ច

ប្រការ ១. ត្រូវបានបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា គ.ក.គ.ម ដែលមានប្រធានគណៈមេធាវី ជាប្រធាន និងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ចំនួន **០៧រូប** ព្រមទាំងអគ្គលេខាធិការគណៈមេធាវី ជាសមាជិក-សមាជិកា។
ក្នុងករណីចាំបាច់ សមាសភាពនេះ អាចបន្ថែម ឬបន្ថយតាមការសម្រេចរបស់ប្រធាន។
សមាសភាពជាក់ស្តែង ត្រូវតែងតាំងដោយប្រធានគណៈមេធាវី។
អគ្គលេខាធិការគណៈមេធាវី ទទួលបន្ទុកជាលេខាធិការ និងហេរញ្ញិក។

ប្រការ ២._ គ.ក.គ.ម មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលការណ៍ណែនាំសម្រាប់ក្រុមកីឡានានារបស់គណៈមេធាវី
- រៀបចំកម្មវិធីប្រកួតជាមិត្តភាពជាមួយក្រសួង ស្ថាប័ន និងអង្គការនានា
- ពង្រឹងចំណងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងអង្គការនានាតាមរយៈសកម្មភាពកីឡា
- ផ្តល់ថវិកាសម្រាប់អនុគណៈកម្មាការកីឡា តាមគម្រោងថវិកាដែលរៀបចំដោយ គ.ក.គ.ម ។

ប្រការ ៣._ គ.ក.គ.ម អាចបង្កើតអនុគណៈកម្មការជំនាញតាមប្រភេទកីឡានីមួយៗតាមការចាំបាច់ ។

ប្រការ ៤._ គ.ក.គ.ម អាចប្រជុំបានលុះត្រាតែមានវត្តមានសមាជិក-សមាជិកាលើសពីពាក់កណ្តាល ។

សេចក្តីសម្រេចរបស់ គ.ក.គ.ម ត្រូវធ្វើឡើងតាមសម្លេងភាគច្រើននៃសមាជិក-សមាជិកា គ.ក.គ.ម ដែលមានវត្តមាន ។

ប្រការ ៥._ ថវិកាសម្រាប់ដំណើរការ គ.ក.គ.ម មានប្រភពមកពី ៖

- ថវិការបស់គណៈមេធាវី
- ជំនួយឧបត្ថម្ភពីសមាជិក-សមាជិកាគណៈមេធាវី
- ជំនួយឧបត្ថម្ភពីសប្បុរសជននានា ។

ប្រការ ៦._ បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧._ អគ្គលេខាធិការ ប្រធាននាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធាន



មេធាវី សួន_ឥសាវ

ចម្លងជូន ÷

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៧
-ឯកសារ-កាលប្បវត្តិ

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទគុណា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ឥណ្ណៈ
២-មេធាវី សួស សារឿន
៣-មេធាវី ទូច ធីរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ខាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លីម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំន្ទសុជាតា
១០-មេធាវី លី ទិត្យបូនាមី
១១-មេធាវី ឃុន ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជនៈ
១៤-មេធាវី អ៊ុំ ភារិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ថលស៊ុ
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ូ ធីតារ៉ៅ
២០-មេធាវី ធួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ឥន្ធា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុគន្ធន
២៦-មេធាវី កែ ឆជាឋស្យ
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុគារិទ្ធ
៣០-មេធាវី សួន សុថល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

លេខ ៣៧៣ /សសគម/២២

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពគណៈកម្មការកីឡា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទគុណា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០
- បានឃើញសេចក្តីសម្រេចលេខ ៥០៣/សសគម/១៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់គណៈមេធាវី ស្តីពីការបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់គណៈមេធាវី

ស ម្រេ ច

ប្រការ១.. តែងតាំងសមាសភាពគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានដូចខាងក្រោម៖

១- ឯកឧត្តម	**លី ចំន្ទគុណា**	ប្រធាន
២- លោកមេធាវី	**សាំង ឥណ្ណៈ**	សមាជិក
៣- លោកមេធាវី	**ទូច ធីរិទ្ធ**	សមាជិក
៤- លោកមេធាវី	**គីម ខាសនា**	សមាជិក
៥- លោកមេធាវី	**កេង សុម៉ាឡា**	សមាជិក
៦- លោកមេធាវី	**លីម ស៊ីម**	សមាជិក
៧- លោកមេធាវី	**លី ទិត្យបូនាមី**	សមាជិក

៨- លោកមេធាវី	**ឃ៉ុន ប៊ុនណា**	សមាជិក
៩- លោកស្រីមេធាវី	**ម៉ែន សុភណ្ឌនី**	សមាជិកា
១០- លោកមេធាវី	**គឹម ផលស៊ី**	សមាជិក
១១- លោកស្រីមេធាវី	**អ៊ូ ធីតាភៅ**	សមាជិកា
១២- លោកមេធាវី	**ឆួន សុធា**	សមាជិក
១៣- លោកមេធាវី	**ខៀវ សំបូរ**	សមាជិក
១៤- លោកមេធាវី	**ហាក់ សុភារិទ្ធ**	សមាជិក
១៥- លោកមេធាវី	**លីវ សុភណ្ណា**	សមាជិក

ប្រការ២.. គណៈកម្មការកីឡាគណៈមេធាវីនេះ ត្រូវបំពេញតួនាទីនិងភារកិច្ចដូចបានកំណត់ក្នុងសេចក្តីសម្រេចលេខ ៥០៣/សសគម/១៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣.. បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤.. អគ្គលេខាធិការគណៈមេធាវី និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០២២

ប្រ ធា ន



មេធាវី លី-ចំន្ទគុណា

ចម្លងជូន៖
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ៥០៣/ /សសគម/២២

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទគុណា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង វណ្ណៈ
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ទូច ធីរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ខាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំន្ទសុជាតា
១០-មេធាវី លី ធិត្យបុនាមី
១១-មេធាវី ម៉ុង ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជៈ
១៤-មេធាវី អ៊ុំ ភីរិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា តាក់
១៩-មេធាវី អ៊ូ ធីតាពៅ
២០-មេធាវី ជួន សុជា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ទិទ្យា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាឥស្ស
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុគារិទ្ធ
៣០-មេធាវី សួង សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

សេចក្តីសម្រេច
ស្តីពី
ការបង្កើតអនុគណៈកម្មការកីឡាវាយសីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទគុណា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០
- បានឃើញសេចក្តីសម្រេចលេខ ៥០៣/សសគម/១៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេចរបស់គណៈកម្មការកីឡាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នាអង្គប្រជុំថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២

ស ម្រេ ច

ប្រការ១ ..ត្រូវបានបង្កើតអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**សេង ប៊ុនហាង**	ប្រធានកិត្តិយស
២.លោកមេធាវី	**គីម ខាសនា**	ប្រធាន
៣.លោកមេធាវី	**ទូច ធីរិទ្ធ**	អនុប្រធាន
៤.លោកមេធាវី	**លី រដ្ឋធី**	អនុប្រធាន
៥.លោកមេធាវី	**ហ៊ីន ពិណ្ណារិទ្ធ**	សមាជិក
៦. លោកមេធាវី	**ជា ពុទ្ធារិន**	សមាជិក
៧.លោកមេធាវី	**គីម រ័ត្នណារ៉ុង**	សមាជិក

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរសព្ទ: ០២៣ ៦២២ ៧០៧០
Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

៨.លោកមេធាវី	**ទាំង ជួនជីវន្ត**	សមាជិក
៩.លោកស្រីមេធាវី	**ហួត លីនដា**	សមាជិក
១០.លោកមេធាវី	**សាយ មុន្នី**	សមាជិក

ប្រការ២ .. អនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលការណ៍ណែនាំសម្រាប់ការប្រកួតកីឡាវាយសីពានរង្វាន់គណៈមេធាវី
- រៀបចំព្រឹត្តិការណ៍កីឡាវាយសីនិងប្រភេទពានរង្វាន់សម្រាប់ព្រឹត្តិការណ៍កីឡានីមួយៗ ដាក់ជូន គ.ក.គ.ម. ពិនិត្យនិងសម្រេច
- រៀបចំឯកសណ្ឋានសម្រាប់កីឡាករ ដោយភ្ជាប់រូបសញ្ញាគណៈមេធាវី ដាក់ជូន គ.ក.គ.ម. ពិនិត្យ និងសម្រេច
- រៀបចំកម្មវិធីប្រកួតវាយសីជាមិត្តភាពជាមួយក្រសួង ស្ថាប័ន និងអង្គការនានា ដាក់ជូន គ.ក.គ.ម. ពិនិត្យនិងសម្រេច
- រៀបចំគម្រោងចំណាយសម្រាប់ការប្រកួតកីឡាវាយសី ដាក់ជូន គ.ក.គ.ម. ពិនិត្យនិងសម្រេច
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិ វិស័យឯកជន និងសប្បុរសជននានា ដើម្បីសហការក្នុងការរៀបចំព្រឹត្តិការណ៍កីឡាវាយសី និងកៀរគរជំនួយឧបត្ថម្ភ
- បំពេញការកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធាន គ.ក.គ.ម.។

ប្រការ៣ .. អនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំបង្កើតក្រុមការងារផ្សេងៗ ដើម្បីជួយដល់អនុគណៈកម្មការនេះបាន។ តួនាទីនិងភារកិច្ចរបស់ក្រុមការងារនីមួយៗ និងសមាសភាពនៃក្រុមការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ក.គ.ម.។

ប្រការ៤ .. អនុគណៈកម្មការកីឡាវាយសីអាចប្រជុំបានលុះត្រាតែមានវត្តមាន សមាជិកលើសពីពាក់កណ្តាល។ ប្រធានអនុគណៈកម្មការកីឡាវាយសីត្រូវកោះប្រជុំ ដើម្បីលើកសំណើនិង យោបល់ផ្សេងៗ ដាក់ជូន គ.ក.គ.ម. ពិនិត្យ និងសម្រេច។

ប្រការ៥ .. បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៦ .. អគ្គលេខាធិការគណៈមេធាវីនិងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែឆេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២២

ប្រ ធា ន



មេធាវី លី ច័ន្ទតុលា

ចម្លងជូន:
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៦
-ឯកសារ-កាលប្បវត្តិ

៧. លោក	**ជុន ជារ៉ូ**	សមាជិក
៨.លោក	**ម៉ម ឡង់ឌី**	សមាជិក
៩.លោក	**តាំង សៀរៀង**	សមាជិក
១០.លោក	**អ៊ុំ សុធា**	សមាជិក
១១.លោក	**រឿន រ៉ុងអាន**	សមាជិក
១២.លោក	**តែ ប៊ុនហុង**	សមាជិក
១៣.លោក	**លាង ឆាយហួត**	សមាជិក
១៤.លោក	**ប៉ុល ពិដេដ្ឋ**	សមាជិក
១៥.កញ្ញា	**ខា មួយហ្គេច**	សមាជិកា

ប្រការ២ .. ក្រុមការងាររៀបចំទូទៅនៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំទម្រង់ បែបបទ និងទទួលចុះឈ្មោះសម្រាប់កីឡាករប្រកួត
- រៀបចំលក្ខខណ្ឌក្នុងការចុះឈ្មោះ និងការប្រកួត រួមទាំងរៀបចំឯកសារសម្រាប់ផ្សព្វផ្សាយ
- ផ្សព្វផ្សាយរាល់ព័ត៌មានទាំងអស់ទាក់ទងនឹងការប្រកួតដល់កីឡាករ
- ផ្តល់ព័ត៌មាននិងផ្សព្វផ្សាយដល់មេធាវីទាំងអស់ដែលមានចំណាប់អារម្មណ៍ចំពោះការចូលរួមប្រកួតវាយសី
- រៀបចំឯកសារនិងបញ្ជីឈ្មោះផ្សេងៗសម្រាប់សម្រួលដល់ការប្រកួត
- រៀបចំចងក្រងជាឯកសារនៃការប្រកួតក្នុងពានរង្វាន់វាយសីគណៈមេធាវី
- ការគ្រប់គ្រងចំណូលនិងចំណាយទូទៅរបស់កម្មវិធីនិងគណៈកម្មការទាំងមូល
- ពិនិត្យមើលនិងផ្តល់ថវិកាលើការស្នើសុំផ្សេងៗរបស់អនុគណៈកម្មការផ្សេងៗទៀត តាមការណែនាំរបស់ប្រធាន និងធ្វើការចាត់ចែងថវិកាតាមការចាំបាច់រួចធ្វើរបាយការណ៍ជូនប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំកិច្ចការងារពិធីការដល់ប្រធាននិងភ្ញៀវកិត្តិយស
- ទទួលបន្ទុកក្នុងការរៀបចំកម្លាំងក្នុងការដឹកជញ្ជូន រក្សាទុក និងចាត់ចែងសម្ភារៈផ្សេងៗក្នុងកម្មវិធីទាំងមូល
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣ .. ត្រូវបានបង្កើតក្រុមការងារអាហារនិងកេសជ្ជៈ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**ទូច ធីរិទ្ធ**	ប្រធាន
២.លោកមេធាវី	**គង់ សុភ័ក្ត្រ**	អនុប្រធាន
៣.លោកមេធាវី	**ជាង លាងសេង**	សមាជិក
៤.លោកមេធាវី	**វង្ស ភុត្ថា**	សមាជិក
៥.កញ្ញា	**អ៊ុន កញ្ញានា**	សមាជិកា

៦.កញ្ញា	**ឌីណាល់ ស្រីម៉ុច**	សមាជិកា
៧.លោក	**ធា សីហា**	សមាជិក
៨.លោក	**ប៉ុក ចិន្តា**	សមាជិក

ប្រការ៤ .. ក្រុមការងារអាហារនិងភេសជ្ជៈ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ចាត់ចែង គ្រប់គ្រង និងសម្របសម្រួលលើអាហារ និងភេសជ្ជៈសម្រាប់កម្មវិធីប្រកួតទាំងមូល
- ចាត់ចែង គ្រប់គ្រង សម្របសម្រួល និងផ្តត់ផ្តង់លើអាហារនិងភេសជ្ជៈសម្រាប់ក្រុមការងារកីឡាករនិងអ្នកចូលរួមទាំងអស់
- រៀបចំមធ្យោបាយដឹកជញ្ជូនអាហារនិងភេសជ្ជៈ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៥ .. ត្រូវបានបង្កើតក្រុមការងារអាវនិងពានរង្វាន់ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**ជា ពុទ្ធារិន**	ប្រធាន
២.លោក	**ជន ហុកលី**	អនុប្រធាន
៣.លោក	**លាច សត្ថារ័ត្ន**	សមាជិក
៤.លោក	**ចំរើន ចារ័ត្ន**	សមាជិក
៥.កញ្ញា	**ទូ រតនា**	សមាជិកា
៦.កញ្ញា	**ប្រាក់ ច័ន្ទវល័ក្ខ**	សមាជិកា
៧.កញ្ញា	**ម៉ែន លក្ខិណា**	សមាជិកា

ប្រការ៦ .. ក្រុមការងារអាវនិងពានរង្វាន់ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំ គ្រប់គ្រង ចាត់ចែង និងផ្តល់អាវដល់គណៈកម្មការរៀបចំការប្រកួតនិងកីឡាករទាំងអស់ ដែលចូលរួមប្រកួតឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា
- រៀបចំអាវសម្រាប់គណៈអធិបតី និងភ្ញៀវកិត្តិយសដែលបានត្រូវចូលរួមកម្មវិធី
- រៀបចំនិងកែច្នៃវត្ថុជាពាននិងរង្វាន់សម្រាប់ជ័យលាភីផ្សេងៗនៃការការប្រកួត
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៧ .. ត្រូវបានបង្កើតក្រុមការងាររចនាបទ គ្រប់គ្រងទីតាំង និងរូបថតនៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**គីម រ័ត្នណារ៉ុង**	ប្រធាន
២.លោក	**អ៊ុក ឥចិត្រ**	អនុប្រធាន
៣.លោកមេធាវី	**ទាំង ដួងជីវន្ត**	សមាជិក
៤.លោកមេធាវី	**ឡាយ យូសេង**	សមាជិក

៥.លោក	**សុខ សុជាតិត**	សមាជិក
៦.លោក	**សែម ច័ន្ទជា**	សមាជិក

ប្រការ៨ .. ក្រុមការងាររចនាបទ គ្រប់គ្រងទីតាំង និងរូបថត នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំរចនាបទទីតាំងប្រកួតសម្រាប់កម្មវិធីប្រកួតឱ្យបានស្រស់ស្អាត
- រៀបបដាក្នុងទីតាំងប្រកួតសម្រាប់កម្មវិធីទាំងមូល
- រៀបចំបញ្ចូលឡូហ្គូរបស់អ្នកឧបត្ថម្ភទាំងអស់ចូលក្នុងវ៉ែនណឺ
- រៀបចំបដានិងសម្ភារៈផ្សេងៗ ដើម្បីលម្អឱ្យការប្រកួតរឹតតែមើលទៅឱ្យមានភាពល្អប្រសើរ
- រៀបចំក្រុមការងារសម្រាប់ថតរូបនិងចងក្រងរូបថតទាំងអស់
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៩ .. ត្រូវបានបង្កើតក្រុមការងារអាជ្ញាកណ្តាលនិងសុខាភិបាល នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**ហ៊ីន ពិណ្ណារិទ្ធ**	ប្រធាន
២.លោកមេធាវី	**ហ៊ឹង សៅលិញ**	អនុប្រធាន
៣.លោកមេធាវី	**ណុប គុជ**	សមាជិក
៤.លោកមេធាវី	**អ៊ុក កុសល**	សមាជិក
៥.លោកមេធាវី	**ម៉ម ចាន់ធី**	សមាជិក

ប្រការ១០ .. អាជ្ញាកណ្តាលនិងសុខាភិបាល នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគណៈកម្មការសម្រាប់ការប្រកួតទាំង៣ថ្ងៃ និងជំនួយការផ្សេងៗតាមការចំបាច់របស់អាជ្ញាកណ្តាលគ្រប់រូប
- រៀបចំចេញជាតារាងសម្រាប់ការប្រកួត និងអាជ្ញាកណ្តាលប្រចាំការតាមតារាងនីមួយៗសម្រាប់ការផ្តល់ពិន្ទុ
- ជាអ្នកគ្រប់គ្រង ចាត់ចែង និងសម្របសម្រួលទីតាំងក្នុងរយៈពេលប្រកួត
- ជាអ្នកផ្តល់និងប្រមូលឯកសារពិន្ទុដល់ក្រុមការងាររៀបចំទូទៅឱ្យបានទាន់ពេលវេលា
- រៀបចំឧបករណ៍ទំនាក់ទំនង(ID)សម្រាប់គណៈកម្មការនិងគ្រប់ផ្នែកទាំងអស់
- រៀបចំក្រុមគ្រូពេទ្យនិងទីតាំងសម្រាប់ក្រុមគ្រូពេទ្យប្រចាំការដើម្បីសង្គ្រោះបឋម
- វិភាគ គ្រប់គ្រង និងវាយតម្លៃលើការប្រកួតនិងការផ្តល់ពិន្ទុរបស់អាជ្ញាកណ្តាល
- អនុវត្តលំហូរការងារក្នុងរយៈពេលកម្មវិធីឱ្យមានសណ្តាប់ធ្នាប់និងរបៀបរៀបរយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ១១ .. ត្រូវបានបង្កើតក្រុមការងារទំនាក់ទំនងសាធារណៈ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី	**លី រដ្ឋធី**	ប្រធាន
២.លោកមេធាវី	**ហេង ឥណ្ណាបុត្រ**	អនុប្រធាន
៣.លោកមេធាវី	**ឈឹម សុឥណ្ណារ៉ុង**	សមាជិក
៤.កញ្ញាមេធាវី	**ទ្រី ស្រីលក្ខ័ណា**	សមាជិកា
៥.លោកមេធាវី	**ម៉េង ឥណ្ណី**	សមាជិក
៦.លោកមេធាវី	**ប៊ុន ឥន្ទ**	សមាជិក

ប្រការ១២ .. ក្រុមការងារទំនាក់ទំនងសាធារណៈ នៃអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ទទួលបន្ទុកទំនាក់ទំនងជាមួយបណ្តាក្រុមហ៊ុនផ្សេងៗក្នុងការស្វែងរកដៃគូសហការ
- ទទួលជួបនិងពិភាក្សាការងារជាមួយនឹងបណ្តាស្ថាប័នផ្សេងៗដែលមានបំណងសហការ
- ទំនាក់ទំនងនិងសម្របសម្រួលលើកិច្ចការងារផ្នែកច្បាប់និងផ្នែករដ្ឋបាលផ្សេងៗ ដើម្បីដំណើរការកម្មវិធីបានល្អប្រសើរ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានអនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ១៣ .. បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៤ .. អគ្គលេខាធិការគណៈមេធាវី អនុគណៈកម្មការកីឡាវាយសីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

ប្រ ធា ន



មេធាវី លី_ចំន្ទតុលា

ចម្លងជូន:
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤
-ឯកសារ-កាលប្បវត្តិ

សេចក្តីសម្រេចនិងសេចក្តីណែនាំ
ពាក់ព័ន្ធនឹងវិធានសម្រាប់
មេធាវីអនុវត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION
OF THE KINGDOM OF CAMBODIA

ប្រធានគណៈមេធាវី :
President of Bar
មេធាវី គី តិច
Me. KY TECH
ក្រុមប្រឹក្សាគណៈមេធាវី :
Bar council member
១- មេធាវី ជីវ សុខហាក់
Me. Chiv Songhak
២- មេធាវី ប៊ូ សាវុន
Me. Bou Savon
៣- មេធាវី កែត ឃី
Me. Ket Khy
៤- មេធាវី ពុត ធាវី
Me. Put Theavy
៥- មេធាវី ស សុវាន
Me. Sa Sovan
៦- លោកស្រីមេធាវី ស៊ឹ នីផា
Me. Sum Nipha
៧- មេធាវី ចាន់ សុខយ៉ាន
Me. Chan Sok Yeang
៨- មេធាវី យីម សារី
Me. Yim Sary
៩- លោកស្រីមេធាវី ពឹង ធីតា
Me. Poeung Thyda
១០- មេធាវី ម្ងួន អរុណ
Me. Muong Akrun
១១-លោកស្រីមេធាវី ទូច វរលក្ស
Me. Touch Voleak
១២- មេធាវី នូ ទេពិរិទ្ធ
Me. Nou Tepirith
១៣- មេធាវី សួង ចាន់ថន
Me. Suong Chanthan
១៤- មេធាវី ហែម វុន
Me. Hem Von
១៥- មេធាវី កុយ នាម
Me. Koy Neam
១៦- មេធាវី ខៀវ សុផល
Me. Khiev Sophal
១៧- មេធាវី ប៊ុន ហុន
Me. Bun Honn
១៨- កញ្ញាមេធាវី មាស សុគន្ធា
Me. Meas Sokun Thea
១៩- មេធាវី សៅ ទីតា
Me. Sao Vita

លេខ : ៤.៣. /សសគម/០៣

សេចក្តីសំរេច
ស្តីពី
ការដាក់ទណ្ឌកម្មវិន័យលើមេធាវីដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទាន

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។
-បានឃើញក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។
-បានឃើញកំណត់ហេតុចុះថ្ងៃទី ១៦ ខែ តុលា ២០០២ នៃមហាសន្និបាតគណៈមេធាវី ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី ៥ និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៤ ។
-បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ចុះថ្ងៃទី ១៤-០៥-១៩៩៩ ស្តីពីការដាក់ទណ្ឌកម្មវិន័យលើសមាជិកសមាជិកាមេធាវី ដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ។
-បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ចុះថ្ងៃទី ០៦-០៣-២០០៣ ស្តីពីការដាក់ទណ្ឌកម្មវិន័យលើសមាជិកសមាជិកាមេធាវី ដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ។

សំរេច

ប្រការ ១ : សមាជិក សមាជិកាគណៈមេធាវី ដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទានចំនួន ចាប់ពី ២ ត្រីមាសឡើងទៅ ត្រូវបានក្រុមប្រឹក្សាគណៈមេធាវី សំរេចឱ្យទទួលទណ្ឌកម្មជាបទវិន័យដូចខាងក្រោម :

ទណ្ឌកម្មកំរិតទី ១ : ត្រូវបានព្យួរការប្រកបវិជ្ជាជីវៈមេធាវីរយៈពេល ៦ ខែ ។

ទណ្ឌកម្មកំរិតទី ២ : ក្នុងរយៈពេលព្យួរ ៦ ខែ នេះ បើសាមីខ្លួននៅតែពុំអនុវត្តកាតព្វកិច្ចបង់ភាគទាន ទោសវិន័យព្យួរការប្រកបវិជ្ជាជីវៈមេធាវី ត្រូវអនុវត្តដល់រយៈពេល ២ ឆ្នាំ ។

ឧណ្ឌកម្មកំរិតទី ៣ : ក្នុងរយៈពេលប្បុរ ២ ឆ្នាំ នេះ បើសាមីខ្លួននៅតែពុំអនុវត្តកាតព្វកិច្ចនោះទៀត នឹងត្រូវលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី ។

ប្រការ ២ : ក្នុងកំឡុងពេលកំពុងអនុវត្តទណ្ឌកម្មវិន័យ ទោះបីសាមីខ្លួនមកបំពេញកាតព្វកិច្ចបង់ភាគទានក៏ដោយ ក៏ការដាក់ទណ្ឌកម្មនេះត្រូវអនុវត្តតាមរយៈពេលដែលបានកំណត់ដោយពុំមានការលើកលែង ។

ប្រការ ៣ : មេធាវីដែលទទួលទណ្ឌកម្ម ត្រូវបន្តជាប់កាតព្វកិច្ចបង់ភាគទានក្នុងរយៈពេលប្បុរការប្រកបវិជ្ជាជីវៈមេធាវី និងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី ទោះបីជាមិនត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈមេធាវីក៏ដោយ ។

ប្រការ ៤ : សេចក្តីសំរេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី ០៦-០៣-២០០៣ នេះតទៅ ។

ប្រការ ៥ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គលេខាធិការ រដ្ឋបាល អគ្គបោរញ្ជឹក និងគណនេយ្យ មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្តសេចក្តីសំរេចនេះ ។

ភ្នំពេញ , ថ្ងៃទី ..៣១.ខែ....៣....ឆ្នាំ ២០០៣

ហត្ថលេខា និងត្រា

ចំលងជូន :

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-គ្រប់សមាជិក-សមាជិកាគណៈមេធាវី

-ឯកសារ-កាលប្បវត្តិ

ប្រធានគណៈមេធាវី :
President of Bar
មេធាវី គី តិច
Mr. KY Tech
ក្រុមប្រឹក្សាគណៈមេធាវី :
Bar Council Member
១.មេធាវី យិន មេងគា
Mr. YIN Wengka
២.មេធាវី ខូវ ចន្ថា
Mr. KHOV Chantha
៣.មេធាវី លុង សុខា
Mr. LOUNG Sokha
៤.មេធាវី លុង ដារ៉ា
Mr. LONG Dara
៥.មេធាវី ពិច ចិច្ឆិកា
Mr. PICH Vicheka
៦.លោកស្រីមេធាវី នេត ថាវរី
Mrs. NETH Thavary
៧.មេធាវី ហាក់ សៀគលី
Mr. HAK Seakly
៨.មេធាវី យុង ផានិត
Mr. YONG Phanith
៩.មេធាវី សុខ ម៉ាថឿង
Mr. SOK Mathoeung
១០.កញ្ញាមេធាវី សាង បូរ៉ាវី
Ms. SEANG Boravy
១១.មេធាវី គា អ៊ាវ
Mr. KEA Eav
១២.មេធាវី ហុង គឹមសួន
Mr. HONG Kimsoun
១៣.មេធាវី ហ៊ាង ហុង
Mr. HEANG Hong
១៤.មេធាវី លីមអេង រតនៈ
Mr. LIMENG Ratanak
១៥.មេធាវី លុង នរិន្ទ
Mr. LONG Norin
១៦.មេធាវី លីម វណ្ណា
Mr. LIM Vanna
១៧.មេធាវី តែ ចំណាន
Mr. TE Chamnan
១៨.មេធាវី អ៊ុក ភូរិ
Mr. UK Phourik
១៩.មេធាវី នូ ចន្ថា
Mr. NOU Chantha

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

លេខ : ២៤០..... /សសគម/០៧

រាជធានីភ្នំពេញ , ថ្ងៃទី ...០១.....ខែ ម.ក..ឆ្នាំ ២០០៧

សេចក្តីសំរេច

ស្តីពី

ការបង្គុះភាគទានប្រចាំត្រីមាស សំរាប់សមាជិក-សមាជិការមេធាវី

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។
-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។
-បានឃើញកំណត់ហេតុចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៦ នៃមហាសន្និបាតគណៈមេធាវី ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី ៦ និង សមាជិក-សមាជិការក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៥ ។
-បានឃើញសេចក្តីសំរេចលេខ ៤៣/សសគម/០៣ ចុះថ្ងៃទី ៣០-៧-២០០៣ របស់គណៈមេធាវី ស្តីពីការដាក់ទណ្ឌកម្មវិន័យលើមេធាវីដែលខកខានពុំបានបំពេញកាតព្វកិច្ចបង់ភាគទាន ។
-បានឃើញសំណើរបស់សមាជិក-សមាជិការមេធាវីភាគច្រើន ។
-បានឃើញការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។

សំ រ ឹ ច

ប្រការ ១ : បង្គុះភាគទានពី ៥០ ដុល្លារក្នុងមួយត្រីមាស ដែលសមាជិក-សមាជិការមេធាវី ត្រូវបង់ជូនគណៈមេធាវី មកត្រឹម ៣០ ដុល្លារអាមេរិក ក្នុងមួយត្រីមាសវិញ ។

អគារលេខ ១០-១១$E_mE_1E_2$ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ :១៥៨៧ . ទូរស័ព្ទ: (៨៥៥-២៣) ២២០ ២៣៧,ទូរសារ:(៨៥៥-២៣) ២១៣ ៦៥៨
10-11 $E_oE_1E_2$ St 180 S/K Beoung Raing. Daun Penh. Phnom Penh. P.O Box: 1587 . Tel: (855-23) 220 237. Fax: (855-23) 213 658 . E-mail:bakc@online.com.kh

ប្រការ ២ : ការបង់ភាគទានមកត្រឹម ៣០ ដុល្លារអាមេរិកក្នុងមួយត្រីមាសនេះ ត្រូវអនុវត្តគិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ៣ : ភាគទាន (៣០ ដុល្លារអាមេរិក/ត្រីមាស) នេះ សមាជិក-សមាជិកាមេធាវី ត្រូវបំពេញកាតព្វកិច្ចអនុវត្តនៅរៀងរាល់ដើមខែទីមួយៗនៃត្រីមាស (ដោយពុំចាំបាច់មានការជូនដំណឹង ពី រំលឹកពីគណៈមេធាវីនោះឡើយ) ។

ប្រការ ៤ : សមាជិក-សមាជិកាមេធាវី ដែលពុំទាន់បានអនុវត្តកាតព្វកិច្ចបង់ភាគទាន (ជំពាក់) មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ ត្រូវរួសរាន់អនុវត្តអោយបានទាន់ពេលវេលា ដោយត្រូវបង់តាមកំរិតចាស់ដដែល (៥០ ដុល្លារអាមេរិក/ត្រីមាស) ។

ប្រការ ៥ : ការខកខានពុំបានបំពេញកាតព្វកិច្ចតាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ខាងលើនេះ ទណ្ឌកម្មវិន័យនឹងត្រូវបានអនុវត្តតាមស្មារតីសេចក្តីសំរេចលេខ ៤៣/សសគម/០៣ ចុះថ្ងៃទី ៣០.០៧.២០០៣ របស់គណៈមេធាវី ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គលេខាធិការ អគ្គហេរញ្ញិក រដ្ឋបាល និង សាមីខ្លួន មានការកិច្ចរៀងៗខ្លួន ដើម្បីអនុវត្តសេចក្តីសំរេចនេះ ។

ហត្ថលេខា និងត្រា

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

ចម្លងជូន :

-ឯកឧត្តម អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍
-សមាជិក-សមាជិកាមេធាវីទាំងអស់
-ដូចប្រការ ៧
-ឯកសារ-កាលប្បវត្តិ

ប្រធានគណៈមេធាវី :
President of Bar
មេធាវី គី តិច
Mr. KY Tech
ក្រុមប្រឹក្សាគណៈមេធាវី :
Bar Council Member
១.មេធាវី យិន វេងកា
Mr. YIN Wengka
២.មេធាវី ខូវ ចន្ថា
Mr. KHOV Chantha
៣.មេធាវី ឈួន សុខា
OUNG Sokha
៤.មេធាវី ឡុង ដារ៉ា
Mr. LONG Dara
៥.មេធាវី ពិច វិចិត្រកា
Mr. PICH Vicheka
៦.លោកស្រីមេធាវី ណេត ថាវរី
Mrs. NETH Thavary
៧.មេធាវី ហាក់ សៀគលី
Mr. HAK Seakly
៨.មេធាវី យុង ផានិត
Mr. YONG Phanith
៩.មេធាវី សុខ ម៉ាថឿង
Mr. SOK Mathoeung
១០.កញ្ញាមេធាវី សាង បូរ៉ាវី
Ms. SEANG Boravy
១១.មេធាវី គា អ៊ាវ
Ms. KEA Eav
១២.មេធាវី ហុង គឹមសួន
Mr. HONG Kimsoun
១៣.មេធាវី ហ៊ាង ហុង
Mr. HEANG Hong
១៤.មេធាវី លីមរេន រតនៈ
Mr. LIMENG Ratanak
១៥.មេធាវី ឡុង នរិន្ទ
Mr. LONG Norin
១៦.មេធាវី លីម វណ្ណា
Mr. LIM Vanna
១៧.មេធាវី តែ ចំរើនន
Mr. TE Chamnan
១៨.មេធាវី អ៊ុក ភូរិ
Mr. UK Phourik
១៩.មេធាវី នូ ចន្ថា
Mr. NOU Chantha

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

លេខ : ០៣៩/សសគម/០៨

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨

សេចក្តីសម្រេច

ស្តីពី

លក្ខខណ្ឌផ្សព្វផ្សាយព័ត៌មានវិជ្ជាជីវៈមេធាវី និង ការប្រើប្រាស់នាមប័ណ្ណមេធាវី

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញក្រមសីលធម៌មេធាវី និង បទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ៦ និង សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៥ នៃព្រះរាជាណាចក្រកម្ពុជា

-តាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧។

ស ម្រ េ ច

ប្រការ ១ : ត្រូវបានកំណត់លក្ខខណ្ឌផ្សព្វផ្សាយព័ត៌មានវិជ្ជាជីវៈមេធាវី និង ការប្រើប្រាស់នាមប័ណ្ណមេធាវី ដែលមានជាអាទិ៍ ដូចខាងក្រោម :

ក-លក្ខខណ្ឌផ្តល់ព័ត៌មានអំពីវិជ្ជាជីវៈមេធាវី

អនុញ្ញាតឱ្យសមាជិក-សមាជិកាធ្វើការផ្តល់ព័ត៌មានអំពីវិជ្ជាជីវៈមេធាវីនៃការិយាល័យនីមួយៗ តាមរយៈគេហទំព័រ(Website) ឬ តាមការបោះពុម្ពជាសៀវភៅ ឬ ជាខិត្តប័ណ្ណ ដោយកំណត់លក្ខខណ្ឌត្រឹមតែ :

១-ប្រាប់អំពីទីតាំង ឬ អាសយដ្ឋានការិយាល័យដើម ឬ ការិយាល័យសាខាមេធាវី ។

២-ប្រាប់អំពីនាមការិយាល័យ និង ប្រវត្តិនៃការបង្កើតការិយាល័យមេធាវី ។

៣-ប្រាប់អំពីចំនួនសមាជិកក្នុងការិយាល័យមេធាវី ។

៤-ប្រាប់អំពីកម្រិតសញ្ញាបត្រជំនាញពិតប្រាកដរបស់សមាជិកការិយាល័យមេធាវី ។

៥-ប្រាប់អំពីប្រភេទនៃសេវាកម្មច្បាប់ដែលទទួល និង ផ្តល់ដោយការិយាល័យមេធាវី ។

ដោយគោរពតាមបញ្ញត្តិមាត្រា ៥៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី, មាត្រា១៣, មាត្រា១៤ និង មាត្រា១៥ នៃក្រមសីលធម៌មេធាវី ការផ្សព្វផ្សាយព័ត៌មានអំពីវិជ្ជាជីវៈមេធាវីក្នុងលក្ខខណ្ឌកំណត់ខាងលើ មិនអនុញ្ញាតឱ្យភ្ជួតកុហក ឬ អួត ឬ ប្រើប្រាស់មធ្យោបាយ ឬ រូបភាពណាមួយដែលមានលក្ខណៈជាការអួសទាញអតិថិជនឱ្យមករកខ្លួនឡើយ ។

ការផ្សព្វផ្សាយក្នុងលក្ខខណ្ឌកំណត់ខាងលើនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែអត្ថបទដែលនឹងត្រូវផ្សព្វផ្សាយ ត្រូវបានផ្ញើមក ទទួលការពិនិត្យពីគណៈកម្មការជំនាញនៃក្រុមប្រឹក្សាគណៈមេធាវី និង បានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានគណៈមេធាវីជាមុនសិន ។

ខ-នាមប័ណ្ណមេធាវី

ចំពោះតួនាទី និង មុខងារដាក់លើនាមប័ណ្ណ ប្រើប្រាស់ក្នុងក្របខ័ណ្ឌវិជ្ជាជីវៈមេធាវី អនុញ្ញាតឱ្យដាក់ត្រឹមតែមុខងារជាមេធាវីតែប៉ុណ្ណោះ។ ការប្រើប្រាស់ឋានៈ មុខងារ តួនាទី លាយឡំ ដែលមានលក្ខណៈអួត និង អួសទាញ អតិថិជនក្នុងវិជ្ជាជីវៈមេធាវី ត្រូវបានហាមឃាត់ ។ ការប្រើប្រាស់ឋានៈ មុខងារ តួនាទីដទៃទៀត ត្រូវប្រើលើនាមប័ណ្ណដោយឡែក ។

គ-ការបញ្ចេញមតិជាសាធារណៈ

គ្រប់អន្តរាគមន៍សាធារណៈ ឬ តាមប្រព័ន្ធផ្សាយព័ត៌មានជាសាធារណៈរបស់មេធាវីក្នុងឋានៈខ្លួនជាមេធាវី នឹងអាចអនុញ្ញាតឱ្យធ្វើបានតែក្នុងក្របខ័ណ្ឌនៃការគោរពដោយម៉ឺងម៉ាត់នូវកាតព្វកិច្ចនៃវិជ្ជាជីវៈ។ អន្តរាគមន៍បែបនេះ ទាមទារឱ្យមានការប្រុងប្រយ័ត្នជាទីបំផុត ។

ប្រធានគណៈមេធាវីត្រូវតែបានទទួលដំណឹង និង ទទួលពិគ្រោះយោបល់ជាមុនក្នុងរឿងនេះ ។

ប្រការ ២ : បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធានការិយាល័យរដ្ឋបាល និង គ្រប់សមាជិក-សមាជិកា មេធាវី ត្រូវអនុវត្តសេចក្តីសម្រេចនេះ ។

កន្លែងទទួល :
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍
-ឯកសារ-កាលប្បវត្តិ

អគារលេខ ១០-១១E₀E₁E₂ ផ្លូវលេខ ១៨០ សង្កាត់បឹងកាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ :១៥៨៧ . ទូរស័ព្ទ៖ (៨៥៥-២៣) ២២០ ២៣៧,ទូរសារ:(៨៥៥-២៣) ២១៣ ៦៥៨
#10-11 E₀E₁E₂ St 180 S/K Beoung Raing. Daun Penh. Phnom Penh. P.O Box:1587. Tel: (855-23) 220 237. Fax: (855-23) 213 658. E-mail:bakc@online.com.kh

ប្រធានគណៈមេធាវី :
President of Bar
មេធាវី គី តិច
Mr. KY Tech
ក្រុមប្រឹក្សាគណៈមេធាវី :
Bar Council Member
១.មេធាវី យិន ឆេងកា
Mr. YIN Wengka
២.មេធាវី ខុវ ចន្ថា
Mr. KHOV Chantha
៣.មេធាវី លុង សុខា
Mr. LOUNG Sokha
៤.មេធាវី ឡុង ដារ៉ា
Mr. LONG Dara
៥.មេធាវី ពិច ឥច្ឆិកា
Mr. PICH Vicheka
៦.លោកស្រីមេធាវី ណេត ថាវរី
Mrs. NETH Thavary
៧.មេធាវី ហាក់ សៀគលី
Mr. HAK Seakly
៨.មេធាវី យុង ផានិត
Mr. YONG Phanith
៩.មេធាវី សុខ ម៉ាថឿន
Mr. SOK Mathoeung
១០.កញ្ញាមេធាវី សាង បុរាវី
Ms. SEANG Boravy
១១.មេធាវី គា អ៊ាវ
Mr. KEA Eav
១២.មេធាវី ហុង គីមសួន
Mr. HONG Kimsoun
១៣.មេធាវី ហ៊ាង ហុង
Mr. HEANG Hong
១៤.មេធាវី លីមអេង រតនៈ
Mr. LIMENG Ratanak
១៥.មេធាវី ឡុង នរិន្ទ
Mr. LONG Norin
១៦.មេធាវី លីម វណ្ណា
Mr. LIM Vanna
១៧.មេធាវី តែ ចំណាន
Mr. TE Chamnan
១៨.មេធាវី អ៊ុក ភួរី
Mr. UK Phourik
១៩.មេធាវី នូ ចន្ថា
Mr. NOU Chantha

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

លេខ : ០៥២/សសគម/០៨

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨

សេចក្តីសម្រេច
ស្តីពី
ការកំណត់ឱ្យបង់ប្រាក់ចូលមូលនិធិទ្រទ្រង់រដ្ឋបាលគណៈមេធាវី ចំពោះមេធាវីសុំនៅក្រៅបញ្ជី

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញក្រមសីលធម៌មេធាវី និង បទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ៦ និង សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៥ នៃព្រះរាជាណាចក្រកម្ពុជា
-តាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨។

ស ម្រ េ ច

ប្រការ ១ : ចាប់ពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ គ្រប់សមាជិក-សមាជិកានៃគណៈមេធាវីដែលបានសុំនៅក្រៅបញ្ជី ត្រូវបំពេញកាតព្វកិច្ចបង់ប្រាក់ **"មូលនិធិទ្រទ្រង់រដ្ឋបាលគណៈមេធាវី"** ស្មើនឹងពាក់កណ្តាលនៃប្រាក់ភាគទានសមាជិកភាពគណៈមេធាវី ចូលក្នុងបេឡាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ : ការបង់ប្រាក់នេះ ត្រូវបង់សរុបជាមុន តាមរយៈពេលដែលសាមីខ្លួនបានស្នើសុំនៅក្រៅបញ្ជី។ ប្រាក់ដែលបានបង់ មិនអាចដកវិញ ឬ/និង មិនអាចគិតបញ្ចូលទៅជាប្រាក់ភាគទានសមាជិកភាពគណៈមេធាវីឡើយ នៅក្នុងករណីដែលសាមីខ្លួនបានសុំចូលប្រកបវិជ្ជាជីវៈមេធាវីវិញមុនផុតរយៈពេលដែលសុំនៅក្រៅបញ្ជី ។

ប្រការ ៣ : សមាជិក-សមាជិកាមេធាវី ដែលត្រូវបានដាក់ឱ្យនៅក្រៅបញ្ជី នឹងទទួលបាននូវឯកសារព័ត៌មាននានាពីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤ : សេចក្តីសម្រេចនេះ មានអានុភាពអនុវត្ត លើពាក្យសុំនៅក្រៅបញ្ជី(ពាក្យសុំបន្ត ឬ ពាក្យសុំថ្មី) ដែលធ្វើនៅក្រោយថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨ ប៉ុណ្ណោះ ។

ប្រការ ៥ : បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធានការិយាល័យរដ្ឋបាល និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ។

ហត្ថលេខា និងត្រា

ចម្លងជូន :

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

-គ្រប់សមាជិក-សមាជិកាមេធាវី

-ដូចប្រការ ៦

-ឯកសារ-កាលប្បវត្តិ

អគារលេខ ១០-១១E₀E₁E₂ ផ្លូវលេខ ១៨០ សង្កាត់បឹងកក់ង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ :១៥៨៧ . ទូរស័ព្ទ: (៨៥៥) ២៣ ២២០ ២៣៧.ទូរសារ: (៨៥៥) ២៣ ២១៣ ៦៥៨
Building No. 10-11 EoE₁E₂, St 180, S/K Boeung Raing, Khan Daun Penh, Phnom Penh, P.O Box: 1587, Tel: (855) 23 220 237, Fax: (855) 23 213 658
E-mail: bakc@online.com.kh / info@bakc.org.kh / www.bakc.org.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ជីវ សុខហាក់

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី ជូ ចាន់ធីរ៉ា

២-មេធាវី ទូ ទេពីន្ទ

៣-មេធាវី យឹម សារី

៤-មេធាវី ពុធ ឆាវី

៥-មេធាវី ឈឹត ប៉ាវុធ

៦-មេធាវី ប៊ូ សាវុន

៧-មេធាវី ឯក ចំនួនបុល

៨-មេធាវី សាន់ ជួយ

៩-មេធាវី កែត ឃី

១០-មេធាវី សោម ចំនួនណា

១១-មេធាវី ថែន ពៅ

១២-មេធាវី រស់ មុនិន្ទ

១៣-មេធាវី អ៊ុក រី

១៤-លោកស្រីមេធាវី ពិន ធីតា

១៥-មេធាវី សួន សុផល

១៦-មេធាវី សាំន ឥណ្ណៈ

១៧-លោកស្រីមេធាវី ម៉ូច ធនលាភ

១៨-មេធាវី ធី ពៅ

១៩-មេធាវី ឈឺ សម្បត្តិ

២០-មេធាវី ឥឡូ គង្គី

២១-មេធាវី លីវ សុវណ្ណា

២២-មេធាវី ឡោ ជុនធី

២៣-មេធាវី ផន បញ្ញា

២៤-មេធាវី ស៊ុយ ឈុនហាក់

២៥-មេធាវី លី ពិន

២៦-មេធាវី ខៀវ សំបូរ

២៧-មេធាវី អ៊ិន ច័ន្ទឈន

លេខ : ០០៦ /សសគម/១១

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១

សេចក្តីសម្រេច

ស្តីពី

ការលុបឈ្មោះចេញពីបញ្ជីជំពាក់ប្រាក់ភាគទាន

ចំពោះសមាជិក-សមាជិកាគណៈមេធាវី ដែលបានទទួលមរណភាព

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៦

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ៨ នៃព្រះរាជាណាចក្រកម្ពុជា

-ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

ស ម្រេ ច

ប្រការ ១ : ត្រូវលុបឈ្មោះចេញពីបញ្ជីជំពាក់ប្រាក់ភាគទានជាស្ថាយប្រវត្តិចំពោះសមាជិក-សមាជិកាគណៈមេធាវីណាដែលមិនទាន់បង់ប្រាក់ភាគទាន បើយបានទទួលមរណភាព។

ប្រការ ២ : បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គលេខាធិការ អគ្គហេរញ្ញិក និងប្រធានការិយាល័យរដ្ឋបាល ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ។/

ចម្លងជូន :

-ក្រុមប្រឹក្សាគណៈមេធាវី

-សមាជិក-សមាជិកាគណៈមេធាវី

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ភ្នំពេញ ថ្ងៃទី ១៨

ជីវ សុខហាក់

អគារលេខ ១០-១១E₀E₁E₂ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ :១៥៨៧ . ទូរស័ព្ទ: (៨៥៥) ២៣ ២២០ ២៣៧,ទូរសារ: (៨៥៥) ២៣ ២១៣ ៦៥៨
Building No. 10-11 E₀E₁E₂, St 180, S/K Beoung Raing, Khan Daun Penh, Phnom Penh, P.O Box: 1587, Tel: (855) 23 220 237, Fax: (855) 23 213 658
E-mail: bakc@online.com.kh / info@bakc.org.kh / www.bakc.org.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ជឹង សុខហាក់

ក្រុមប្រឹក្សាគណៈមេធាវី

១.មេធាវី ជូ ចាន់ធីតា

២.មេធាវី នូ ធេការិទ្ធ

៣.មេធាវី យឹម សារី

៤.មេធាវី ពុធ ធារី

៥.មេធាវី ឈិត ចូរ៉ាតុង

៦.មេធាវី ប៊ូ សាតុន

៧.មេធាវី ឯក ចំរើនពិបុល

៨.មេធាវី សាន់ ជុយ

៩.មេធាវី កែត ឃី

១០.មេធាវី សោម ចំរើនណា

១១.មេធាវី ខែម ពៅ

១២.មេធាវី រស់ មុនិន្ទៈ

១៣.មេធាវី អ៊ុក រី

១៤.លោកស្រីមេធាវី ពិន ធីតា

១៥.មេធាវី សួន សុផល

១៦.មេធាវី សាំន ទណ្ឌៈ

១៧.លោកស្រីមេធាវី មួន ធនឃាតី

១៨.មេធាវី ង៉ី ពៅ

១៩.មេធាវី ឈឺ សម្បត្តិ

២០.មេធាវី ទឿ គង្គី

២១.មេធាវី លឹម សុទណ្ណា

២២.មេធាវី ឡោ ជុនធី

២៣.មេធាវី ឋន បញ្ញា

២៤.មេធាវី ស៊ីម ឈុនហាក់

២៥.មេធាវី លី ពិន

២៦.មេធាវី ខៀវ សំបូរ

២៧.មេធាវី អ៊ិន ចាន់ឈន

លេខ : ០៤៧ /សសគម/១១

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

សេចក្តីសម្រេច

ស្តីពី

ការជាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវ របស់គ្រូកម្មសិក្សា ក្នុងអំឡុងពេលអន្តរកាលក្រោយការ បញ្ចប់កម្មសិក្សារយៈពេល ១២ខែ របស់កម្មសិក្សាការី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៦
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ៨ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើសុំរបស់មេធាវីកម្មសិក្សាជិនាន់ ១០ ទាំងអស់
- បានឃើញការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១។

សម្រេច

ប្រការ ១.- មេធាវីកម្មសិក្សាដែលបានធ្វើកម្មសិក្សាគ្រប់រយៈពេលដប់ពីរ(១២)ខែ ហើយក្រុមប្រឹក្សាគណៈមេធាវីមិនទាន់បានសម្រេចឱ្យក្លាយជាមេធាវីពេញសិទ្ធិ គឺនៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេធាវីជាគ្រូកម្មសិក្សាដដែល។

ប្រការ ២.- រាល់ទំនាក់ទំនង និងគ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា ។
គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការីនៅក្នុងអំឡុងពេលអន្តរកាលនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សាដែល រហូតដល់ក្រុមប្រឹក្សាគណៈមេធាវីសម្រេចឱ្យក្លាយជាមេធាវីពេញសិទ្ធិ ។

ប្រការ ៣.- បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤.- អគ្គលេខាធិការ អគ្គបោរញ្ជិក ប្រធានការិយាល័យរដ្ឋបាល និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ។

ចម្លងជូន:

-ក្រុមប្រឹក្សាគណៈមេធាវី
-សមាជិក-សមាជិកាគណៈមេធាវី
-គ្រូកម្មសិក្សា
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ

ភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២៤

ជីវ សុខហាក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី ជា ឌួនគា
២-មេធាវី កែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំន្ទ ទិចិត្រ
៥-មេធាវី ចេង ម៉េងហាប់
៦-មេធាវី ជូន ជូនី
៧-មេធាវី លី ច័ន្ទគុណា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិត សុខាចា
១០-មេធាវី ពេជ្រ សុរិយោ
១១-មេធាវី គង់ ធីលីន
១២-មេធាវី ឃុត ថានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុក ស៊ីថាន់ណា
១៥-មេធាវី ស្រ៊ី គីមឃុ
១៦-មេធាវី កុយ នាម
១៧-មេធាវី ឡុច ធីរិទ្ធ
១៨-មេធាវី គីម ទាសនា
១៩-មេធាវី សួស សារឿន
២០-មេធាវី ឡូន មករា
២១-មេធាវី លឹម អេងគេន:
២២-មេធាវី ហុង គីមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឡុង ជាវ៉ា
២៥-មេធាវី សួង ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀង ចិន្តា

លេខ : ០០៩ /សសគម/១៤

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤

សេចក្តីសម្រេច

ស្តីពី

ការបង់ថវិកា សម្រាប់ឧបត្ថម្ភដល់ប្រតិបត្តិការការពារក្តីជូនជនក្រីក្រ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវ:មេធាវី
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ៩
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣។


ស ម្រេ ច

ប្រការ ១. តម្រូវឱ្យបេក្ខជនដែលបានចូលប្រកបវិជ្ជាជីវ:មេធាវី តាមមាត្រា ៣២ បង់ថវិកាចំនួន **៥00 (ប្រាំរយ) ដុល្លារអាមេរិកយ៉ាងតិច** សម្រាប់ឧបត្ថម្ភលើប្រតិបត្តិការការពារក្តីជូនជនក្រីក្រ។ ៤

ប្រការ ២.. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣.. អគ្គលេខាធិការ អគ្គហេរញ្ញិក និងនាយកដ្ឋានការពារក្តីជូនជនក្រីក្រ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន៕

ប្រធាន



មេធាវី.ប៊ុន-ហ៊ុន

ចម្លងជូន :

-ក្រុមប្រឹក្សាគណៈមេធាវី "ដើម្បីជ្រាប"

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី ជា ឡូនគា

២-មេធាវី កែវ ជា

៣-មេធាវី ហាក់ សៀកលី

៤-មេធាវី ចំន្ទ ទិចិត្រ

៥-មេធាវី ចេង ប៉េងហាប់

៦-មេធាវី ជុំ ជុំនី

៧-មេធាវី លី ចំន្ទគុណា

៨-មេធាវី តែ ចំណាន

៩-មេធាវី ទិត សុខាទា

១០-មេធាវី ពេជ្រ សុវីយោ

១១-មេធាវី គង់ ធីលីន

១២-មេធាវី ឃុត ថានិត

១៣-មេធាវី លឹម តណ្ណា

១៤-មេធាវី សុក ស៊ីថាន់ណា

១៥-មេធាវី ស្រ៊ុ គីមឃួ

១៦-មេធាវី កុយ នាម

១៧-មេធាវី ឡុច ធីរិទ្ធ

១៨-មេធាវី គីម ខាសនា

១៩-មេធាវី សូស សារម៉ឿន

២០-មេធាវី ឡូន មករា

២១-មេធាវី លឹម អេងគេន:

២២-មេធាវី ហុង គីមសួន

២៣-មេធាវី ឯក ហាលា

២៤-មេធាវី ឆាយ ជារ៉ា

២៥-មេធាវី សួង ចាន់ថន

២៦-មេធាវី ស សុខាន

២៧-មេធាវី លៀន ចិន្តា

លេខ : ១១៩ /សសគម/១៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៤

សេចក្តីសម្រេច
ស្តីពី
ការសម្រេចផ្តល់សិទ្ធិជូនប្រធានគណៈមេធាវី

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ៩
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

សម្រេច

ប្រការ ១. ត្រូវបានផ្តល់សិទ្ធិជូនប្រធានគណៈមេធាវីក្នុងការសម្រេច ដោយមិនចាំបាច់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច ចំពោះកិច្ចការមួយចំនួនដូចខាងក្រោម៖

-ការស្នើសុំប្រើប្រាស់រូបសញ្ញា (Logo) របស់ការិយាល័យមេធាវី ឬ ក្រុមមេធាវី ឬ ក្រុមហ៊ុនមេធាវី។

-ការស្នើសុំបើកការិយាល័យមេធាវីសាខា។

-កិច្ចព្រមព្រៀងសហការរវាងមេធាវីខ្មែរជាមួយមេធាវីខ្មែរ ឬ ជាមួយមេធាវីបរទេស ឬ សមាជិកនៃវិជ្ជាជីវៈសេរីណាមួយ។

ប្រការ ២. ប្រធានគណៈមេធាវីអាចដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច ចំពោះកិច្ចការដែលបានកំណត់ក្នុងប្រការ ១ ខាងលើ ក្នុងករណីដែលពិនិត្យឃើញថាមានភាពស្មុគស្មាញមិនអាចសម្រេចបាន។

ប្រការ ៣. សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ចម្លងជូន:

-ក្រុមប្រឹក្សាគណៈមេធាវី


-សមាជិកគណៈមេធាវី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ភ្នំពេញ ថ្ងៃទី ០៤



មេធាវី.ប៊ុន-ហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី ជា ចូនគា
២-មេធាវី គែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំន្ទ វិចិត្រ
៥-មេធាវី ចេង ម៉េងហាប់
៦-មេធាវី ជុន ជុំនី
៧-មេធាវី លី ចំន្ទគុណា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិត សុខាភា
១០-មេធាវី តេជ្ជ សុរិយោ
១១-មេធាវី គង់ ធីលីន
១២-មេធាវី ឃុន ជានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុក ស៊ុជាន់ណា
១៥-មេធាវី ស្រ៊ី គីមឃុ
១៦-មេធាវី កុយ នាម
១៧-មេធាវី ឆុត ធីរិទ្ធ
១៨-មេធាវី គីម ភាសនា
១៩-មេធាវី សួស សាម៉ឿន
២០-មេធាវី ទូន មករា
២១-មេធាវី លឹម អេងគេង
២២-មេធាវី ហ៊ុន គីមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឆុន ជារ៉ា
២៥-មេធាវី សួន ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀន ចិន្តា

លេខ : ០៣៩ /សសគម/១៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥

សេចក្តីសម្រេច
ស្តីពី
ការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី
និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥

សម្រួច
ជំពូកទី១
វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី

ប្រការ ១.-

មេធាវីដែលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចប្រកបវិជ្ជាជីវៈមេធាវីបានលុះត្រាតែមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ។

គណៈមេធាវីជាស្ថាប័នមានសមត្ថកិច្ចតែមួយគត់ ក្នុងការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ដល់មេធាវីជាសមាជិក ។

ប្រការ ២.-

ជារៀងរាល់ឆ្នាំ មេធាវីកំពុងប្រកបវិជ្ជាជីវៈគ្រប់រូបត្រូវដាក់ពាក្យមកគណៈមេធាវីដើម្បីស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ដោយត្រូវបញ្ជាក់នូវព័ត៌មាន និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១- នាម និងគោត្តនាម ។

២- ព័ត៌មានទំនាក់ទំនងផ្ទាល់ខ្លួន ។

៣- ឈ្មោះ និងព័ត៌មានទំនាក់ទំនង ការិយាល័យវិជ្ជាជីវៈ ។

៤- បណ្ណសម្គាល់ខ្លួនមេធាវីដែលមានសុពលភាព (ឯកសារថតចម្លង) ។

៥- សេចក្តីបញ្ជាក់ពីការអនុវត្តកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ឬការលើកលែងការអនុវត្តកាតព្វកិច្ចនេះ ។

៦- សេចក្តីបញ្ជាក់ពីការចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល រៀបចំដោយគណៈមេធាវី ។

ប្រការ ៣.-

មេធាវីកម្មសិក្សាត្រូវអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ដោយស្ថិតក្រោមការទទួលខុសត្រូវរបស់គ្រូកម្មសិក្សាដែលជាមេធាវីកំពុងប្រកបវិជ្ជាជីវៈ ដែលមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីមានសុពលភាព ។ មេធាវីកម្មសិក្សាមិនចាំបាច់មានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីទេ ។

ប្រការ ៤.-

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈនេះមានសុពលភាពរយៈពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ ។

មេធាវីកំពុងប្រកបវិជ្ជាជីវៈត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រកវិជ្ជាជីវៈមេធាវី ឱ្យបានយ៉ាងហោចណាស់ ០១ (មួយ) ខែ មុនពេលដែលវិញ្ញាបនបត្រប្រកវិជ្ជាជីវៈមេធាវីអស់សុពលភាព។

មេធាវីកំពុងប្រកបវិជ្ជាជីវៈ ត្រូវដាក់តាំងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងការិយាល័យវិជ្ជាជីវៈរបស់ខ្លួន ដើម្បីឱ្យសាធារណជនអាចមើលឃើញ។

ប្រការ ៥.-

រាល់ការផ្លាស់ប្តូរ ឬកែប្រែព័ត៌មានទាំងឡាយដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងមកគណៈមេធាវី និងស្នើសុំកែប្រែវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី។

ការកែប្រែព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីឡើយ។

ប្រការ ៦.-

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីត្រូវចេញឱ្យមេធាវីកំពុងប្រកបវិជ្ជាជីវៈដោយមិនគិតកម្រៃ។

រាល់ការស្នើសុំកែប្រែវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ត្រូវបង់ប្រាក់ជូនគណៈមេធាវីចំនួន ២0,000 (ពីរម៉ឺន) រៀល។

ជំពូកទី២
ការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី

ប្រការ ៧.-

មេធាវីកំពុងប្រកបវិជ្ជាជីវៈ អាចប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តបុគ្គល ឬជាក្រុម។

មេធាវីកំពុងប្រកបវិជ្ជាជីវៈ ដែលប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តបុគ្គល ត្រូវដាក់ពាក្យស្នើសុំមកគណៈមេធាវី ដើម្បីចុះបញ្ជីការិយាល័យវិជ្ជាជីវៈរបស់ខ្លួន ក្រោមទម្រង់ជា "ការិយាល័យមេធាវី" ជាភាសាអង់គ្លេស "Law Office"។

មេធាវីកំពុងប្រកបវិជ្ជាជីវៈ ដែលប្រកបវិជ្ជាជីវៈមេធាវីជាក្រុម ត្រូវដាក់ពាក្យស្នើសុំមកគណៈមេធាវី ដើម្បីចុះបញ្ជីការិយាល័យវិជ្ជាជីវៈរបស់ខ្លួន ក្រោមទម្រង់ជា៖

១- "ក្រុមមេធាវី" ជាភាសាអង់គ្លេស "Law Group" ឬ

២- ក្រុមហ៊ុនមេធាវី ជាភាសាអង់គ្លេស "Law Firm"។

ប្រការ ៨.-

មេធាវីកំពុងប្រកបវិជ្ជាជីវៈ អាចប្រើប្រាស់នាមករណ៍ និងរូបសញ្ញា (logo) នៃការិយាល័យវិជ្ជាជីវៈរបស់ខ្លួនបាន។ នាមករណ៍ និងរូបសញ្ញា (logo) នោះ៖

- មិនត្រូវធ្វើឱ្យប៉ះពាល់ ឬបាត់បង់តម្លៃនៃវិជ្ជាជីវៈមេធាវី ឬកិត្យានុភាពរបស់គណៈមេធាវី។
- មិនត្រូវស្រដៀងគ្នា ឬដូច ឬធ្វើឱ្យមានការភាន់ច្រឡំ ជាមួយនាមករណ៍ ឬរូបសញ្ញា (logo) របស់ការិយាល័យវិជ្ជាជីវៈដទៃទៀត ឬរបស់ក្រសួង-ស្ថាប័នសាធារណៈជាតិ និងអន្តរជាតិ សហគ្រាសពាណិជ្ជកម្ម ឬសហគ្រាសសាធារណៈឡើយ លើកលែងតែមានការអនុញ្ញាតជាមុនពីស្ថាប័នទាំងនោះ។
- ត្រូវដាក់ពាក្យ "ការិយាល័យមេធាវី (Law Office)" ឬ "ក្រុមមេធាវី (Law Group)" ឬ "ក្រុមហ៊ុនមេធាវី (Law Firm or Law)" ជាមួយនាមករណ៍ឬឈ្មោះនៃការិយាល័យរបស់ខ្លួន ដើម្បីសម្គាល់ទម្រង់នៃការប្រកបវិជ្ជាជីវៈ។

ប្រការ ៩.-

មេធាវីកំពុងប្រកបវិជ្ជាជីវៈ ត្រូវស្នើសុំចុះបញ្ជីការិយាល័យវិជ្ជាជីវៈរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវ៖

១- នាមករណ៍ការិយាល័យវិជ្ជាជីវៈ។

២- អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង។

៣- រូបសញ្ញា (logo) ប្រសិនបើមាន។

៤- បញ្ជីឈ្មោះមេធាវីជាសមាជិក (ប្រសិនបើជាក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី)។

៥- កិច្ចសន្យាសហការរវាងមេធាវីជាសមាជិក (ប្រសិនបើជាក្រុមមេធាវី)។

៦- លក្ខន្តិកៈក្រុមហ៊ុន (ប្រសិនបើជាក្រុមហ៊ុនមេធាវី)។

ប្រការ ១០.-

វិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

ប្រធាន ឬអ្នកតំណាង ការិយាល័យវិជ្ជាជីវៈ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ឱ្យបានយ៉ាងហោចណាស់ ០១ (មួយ) ខែ មុនពេលដែលវិញ្ញាបនបត្រចុះបញ្ជីការិយាល័យផុតសុពលភាព។

វិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ត្រូវដាក់តាំងនៅខាងក្នុងការិយាល័យវិជ្ជាជីវៈ ដើម្បីឱ្យសាធារណជនអាចមើលឃើញ។

ប្រការ ១១.-

រាល់ការផ្លាស់ប្តូរ ឬកែប្រែព័ត៌មានទាំងឡាយដូចមានចែងក្នុងប្រការ ៩ នៃសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងមកគណៈមេធាវី និងស្នើសុំកែប្រែវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ។

ការកែប្រែព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈឡើយ។

ប្រការ ១២.-

កម្រៃដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការិយាល័យមេធាវី៖	៤00,000 (សែសិបម៉ឺន) រៀល។
២- ក្រុមមេធាវី៖	៨00,000 (ប៉ែតសិបម៉ឺន) រៀល។
៣- ក្រុមហ៊ុនមេធាវី	១,២00,000 (មួយលានពីរសែន) រៀល។

ប្រការ ១៣.-

កម្រៃក្នុងការដាក់ពាក្យស្នើសុំកែប្រែព័ត៌មាននៅក្នុងវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ត្រូវបានកំណត់ស្មើនឹង ៨0,000 (ប្រាំបីម៉ឺន) រៀល។

ជំពូកទី៣

ទណ្ឌកម្ម

ប្រការ ១៤.-

សមាជិកគណៈមេធាវីរូបណាដែលប្រព្រឹត្តផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

ជំពូកទី៤

អន្តរប្បញ្ញត្តិ

ប្រការ ១៥.-

គ្រប់ការិយាល័យវិជ្ជាជីវៈមេធាវីទាំងអស់ដែលកំពុងដំណើរការប្រកបវិជ្ជាជីវៈមេធាវី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីការិយាល័យវិជ្ជាជីវៈក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ។

ជំពូកទី៥

អវសានប្បញ្ញត្តិ

ប្រការ ១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៧.-

អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព។

ចម្លងជូន÷

-ក្រុមប្រឹក្សាគណៈមេធាវី

-ដូចប្រការ ១៧

-ឯកសារ-កាលប្បវត្តិ

ប្រធាន

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី.ប៊ុន-ហួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី ប៊ុន ហុន
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី ជា ឡូនគា
២-មេធាវី កែម ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំន្ទ ទិចិត្រ
៥-មេធាវី ចេង ម៉េងហាប់
៦-មេធាវី ជុន ជុំ
៧-មេធាវី លី ចំន្ទគុណា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិត សុខាន
១០-មេធាវី ពេជ្រ សុមៀត
១១-មេធាវី គង់ ធីលីន
១២-មេធាវី ឃុន ជានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុត ស៊ីថាន់ណា
១៥-មេធាវី ស្រ៊ុ គីមយូ
១៦-មេធាវី គុយ ឆាម
១៧-មេធាវី ឡុច ធីរិទ្ធ
១៨-មេធាវី គីម ខាសនា
១៩-មេធាវី សូស សារឿន
២០-មេធាវី ឡូន មករា
២១-មេធាវី លឹម អេងតេង
២២-មេធាវី ហុង គីមសួន
២៣-មេធាវី ឯក ហាលា
២៤-មេធាវី ឆួន ជារ៉ា
២៥-មេធាវី សួន ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី សៀន ចំណុះ

លេខ : ១៤១ /សសគម/១៥

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសេចក្តីសម្រេចស្តីពីការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- បានឃើញសេចក្តីសម្រេចលេខ ០៣៩/សសគម/១៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥

សម្រេច

ប្រការតែមួយ.-

ត្រូវបានកែសម្រួលប្រការ ២ ប្រការ ៤ ប្រការ ១២ ប្រការ ១៣ និងប្រការ ១៥ នៃសេចក្តីសម្រេចលេខ ០៣៩/សសគម/១៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី ដែលមានខ្លឹមសារដូចខាងក្រោម៖

ប្រការ ២ ថ្មី.-

ជារៀងរាល់ ០២ (ពីរ) ឆ្នាំម្តង មេធាវីកំពុងប្រកបវិជ្ជាជីវៈគ្រប់រូបត្រូវដាក់ពាក្យមកគណៈមេធាវីដើម្បីស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ដោយត្រូវបញ្ជាក់នូវព័ត៌មាន និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១- នាម និងគោត្តនាម។

២- ព័ត៌មានទំនាក់ទំនងផ្ទាល់ខ្លួន។

៣- ឈ្មោះ និងព័ត៌មានទំនាក់ទំនង ការិយាល័យវិជ្ជាជីវៈ។

៤- បណ្ណសម្គាល់ខ្លួនមេធាវីដែលមានសុពលភាព។

៥- សេចក្តីបញ្ជាក់ពីការអនុវត្តកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ឬការលើកលែងការអនុវត្តកាតព្វកិច្ចនេះ។

៦- សេចក្តីបញ្ជាក់ពីការចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល រៀបចំដោយគណៈមេធាវី បានយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ម៉ោង។

ប្រការ ៤ ថ្មី.-

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈនេះមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

មេធាវីកំពុងប្រកបវិជ្ជាជីវៈត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រកវិជ្ជាជីវៈមេធាវី ឱ្យបានយ៉ាងហោចណាស់ ០១ (មួយ) ខែ មុនពេលដែលវិញ្ញាបនបត្រប្រកវិជ្ជាជីវៈមេធាវីអស់សុពលភាព។

មេធាវីកំពុងប្រកបវិជ្ជាជីវៈ ត្រូវដាក់តាំងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងការិយាល័យវិជ្ជាជីវៈរបស់ខ្លួន។

ប្រការ ១២ ថ្នី.- ៦

កម្រៃដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការិយាល័យមេធាវី៖	២00,000 (ពីរសែន) រៀល។
២- ក្រុមមេធាវី៖	៤00,000 (បួនសែន) រៀល។
៣- ក្រុមហ៊ុនមេធាវី	៤00,000 (បួនសែន) រៀល។

ប្រការ ១៣ ថ្នី.-

កម្រៃក្នុងការដាក់ពាក្យស្នើសុំកែប្រែព័ត៌មាននៅក្នុងវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ត្រូវបានកំណត់ស្មើនឹង ៤0,000 (បួនម៉ឺន) រៀល។

ប្រការ ១៥ ថ្នី.-

មេធាវីកំពុងប្រកបវិជ្ជាជីវៈ និងការិយាល័យវិជ្ជាជីវៈទាំងអស់ដែលកំពុងដំណើរការ ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈ ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និងការចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី។

ប្រធាន



មេធាវី.ប៊ួន-ហួន

ចម្លងជូន៖
-ក្រុមប្រឹក្សាគណៈមេធាវី
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី ង៉ ឡូនគា
២-មេធាវី កែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំន្ទ ទិចិត្រ
៥-មេធាវី ចេង ប៉េងហាប់
៦-មេធាវី ជូន ជូនី
៧-មេធាវី លី ចំន្ទគុណា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិច សុខាចា
១០-មេធាវី ពេជ្រ សុរិយោ
១១-មេធាវី គង់ ធីលីន
១២-មេធាវី ឃុត ជានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុក ស៊ីថាន់ណា
១៥-មេធាវី ស្រ៊ុ គីមឃុ
១៦-មេធាវី កុយ ឆាម
១៧-មេធាវី ឡុច ធីរិទ្ធ
១៨-មេធាវី គីម ទាសនា
១៩-មេធាវី សួស សាម៉ឿន
២០-មេធាវី ឡូន មករា
២១-មេធាវី លឹម អេងគេន:
២២-មេធាវី ហុក គីមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឃុត ជារ៉ា
២៥-មេធាវី សួន ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀង ចិន្តា

លេខ : ០៤៣/សសគម/១៥

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៥

សេចក្តីសម្រេច
ស្តីពី
ការកំណត់អត្តលេខមេធាវីកម្មសិក្សា

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥។

សម្រេច

ប្រការ ១.- ត្រូវបានបង្កើតអត្តលេខសម្រាប់មេធាវីកម្មសិក្សា ចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ។

ប្រការ ២. អត្តលេខត្រូវបានកំណត់ដោយយកអត្តលេខបន្តពីអត្តលេខមេធាវីកម្មសិក្សាចុងក្រោយ ហើយបន្ថែមអក្សរឡាតាំង “T” នៅពីខាងក្រោយ ។

ប្រការ ៣. បន្ទាប់ពីបានបញ្ចប់កម្មសិក្សា និងត្រូវបានសម្រេចឱ្យពេញសិទ្ធិដោយក្រុមប្រឹក្សាគណៈមេធាវី មេធាវី(កម្មសិក្សា) ត្រូវទទួលបានអត្តលេខបន្តពីអត្តលេខចុងក្រោយនៃមេធាវីនៅក្នុងបញ្ជីមេធាវីពេញសិទ្ធិ ។

ប្រការ ៤. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥. អគ្គលេខាធិការ អគ្គហេរញ្ញិក និងកម្មសិក្សាការី ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ។

ចម្លងជូន:

-សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី
-សមាជិក-សមាជិកាគណៈមេធាវី
-ដូចប្រការ ៥
-ឯកសារ-កាលប្បវត្តិ

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី.ប៊ុន-ហួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំន ទណ្ឌៈ
២-មេធាវី អ៊ុន គឹរីយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ុត ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុគន្ធន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ថានិត
៩-មេធាវី ជុំ ចាន់ធីតា
១០-មេធាវី កេង សុម៉ាឌ្យា
១១-មេធាវី ម៉ុ ទ្ធសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី ឃីវ សុវណ្ណា
១៤-មេធាវី ឈឹង គឹមឃួ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង ម៉ានន្ទ
១៧-មេធាវី អ៊ូ ធីតារ៉ៅ
១៨-មេធាវី លី ធីង
១៩-មេធាវី យឹម ទិសបុត
២០-មេធាវី លឹម ចំណលីដា
២១-មេធាវី កែ ទិសាល
២២-មេធាវី ហូ លីហួរ
២៣-មេធាវី ង៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ទិមានចំណា
២៧-មេធាវី ឈឺ សម្បត្តិ

លេខ : ០០៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៦

សេចក្តីសម្រេច
ស្តីពី
ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៧
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងកំណត់អំពីគោលការណ៍ លក្ខខណ្ឌ វិសាលភាព និងទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាបាននូវគុណភាពនៃការផ្តល់សេវាកម្មច្បាប់ការពារផលប្រយោជន៍ស្របច្បាប់របស់សាធារណជន និងចូលរួមពង្រឹងនីតិរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២. វិសាលភាពនៃការអនុវត្ត

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះគ្រប់មេធាវីបរទេស និងក្រុមហ៊ុនមេធាវីបរទេស ទាំងអស់ដែលមានបំណងប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមេធាវីបរទេសដែលបម្រើការងារនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិដោយឡែក។

ប្រការ ៣. និយមន័យនៃពាក្យបច្ចេកទេស

- **គណៈមេធាវី** សំដៅដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- **មេធាវីបរទេស** សំដៅដល់ជនបរទេសដែលបានចុះបញ្ជីត្រឹមត្រូវជាមេធាវី នៅក្នុងគណៈមេធាវីនៃប្រទេសកំណើត ឬប្រទេសដទៃក្រៅពីព្រះរាជាណាចក្រកម្ពុជា។
- **ក្រុមហ៊ុនមេធាវីបរទេស** សំដៅដល់ក្រុមហ៊ុនមេធាវីដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា។
- **ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស** សំដៅដល់ក្រុមហ៊ុនមេធាវីដែលបង្កើតឡើងស្របតាមសេចក្តីសម្រេចនេះ ហើយមានម្ចាស់ភាគហ៊ុនជាមេធាវីខ្មែរ និងមេធាវីបរទេស ដែលក្នុងនោះមេធាវីខ្មែរកាន់កាប់ភាគហ៊ុនជាក់ស្តែងនិងពិតប្រាកដ និងមានសិទ្ធិបោះឆ្នោតចំនួនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ឡើងទៅ។
- **កិច្ចសហការផ្តល់សេវាកម្មច្បាប់** សំដៅដល់កិច្ចសហការរវាងក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬការិយាល័យវិជ្ជាជីវៈមេធាវីខ្មែរ ដែលបានទទួលការយល់ព្រមពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី ២

ការចុះបញ្ជី និងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

ប្រការ ៤. ការចុះបញ្ជី និងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី

មេធាវីបរទេសមិនអាចប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ប្រសិនបើមិនបានចុះបញ្ជីនៅគណៈមេធាវី និងមិនមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅមានសុពលភាព។

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសកំណត់អំពីវិសាលភាពនៃសេវាកម្មច្បាប់ដែលផ្តល់ដោយមេធាវីបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៥. លក្ខខណ្ឌ

មេធាវីបរទេសដែលអាចដាក់ពាក្យស្នើសុំចុះបញ្ជីនៅគណៈមេធាវី ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវជាមេធាវីពេញសិទ្ធិដែលប្រកបវិជ្ជាជីវៈមេធាវី និងមានបទពិសោធន៍ក្នុងការប្រកបវិជ្ជាជីវៈមេធាវីនៅគណៈមេធាវីដែលខ្លួនបានចុះបញ្ជី យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ

២. អាជ្ញាធរមានសមត្ថកិច្ច ឬគណៈមេធាវីដែលខ្លួនបានចុះបញ្ជី ត្រូវផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរ

៣. ត្រូវមានកាយសម្បទាគ្រប់គ្រាន់ និងសីលធម៌ល្អ

៤. មិនធ្លាប់ទទួលទណ្ឌកម្មរដ្ឋបាល ឬផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈឹមណាមួយ និង

៥. មិនធ្លាប់ត្រូវបានប្រកាសក្ស័យធនផ្ទាល់ខ្លួន ។

ប្រការ ៦. ពាក្យស្នើសុំចុះបញ្ជីរបស់មេធាវីបរទេស

មេធាវីបរទេសអាចដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជីដែលត្រូវចុះហត្ថលេខាផ្ទាល់ដោយមេធាវីបរទេសដែលបានដាក់ពាក្យស្នើសុំ ។

២. ប្រវត្តិរូបសង្ខេប ។

២. លិខិតបញ្ជាក់សមាជិកភាព នៅក្នុងគណៈមេធាវីនៃប្រទេសណាមួយ (ច្បាប់ដើម) ។

៣. លិខិតបញ្ជាក់អំពីបទពិសោធន៍នៃការប្រកបវិជ្ជាជីវៈមេធាវីលើសពី ៥ (ប្រាំ) ឆ្នាំ (ច្បាប់ដើម) ។

៤. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈមេធាវីដែលនៅមានសុពលភាព ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសណាមួយ (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៥. ច្បាប់ ឬបទប្បញ្ញត្តិដែលគ្រប់គ្រងលើវិជ្ជាជីវៈមេធាវីនៃប្រទេសដែលមេធាវីបរទេសបានចុះបញ្ជី (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៦. ក្រមសីលធម៌មេធាវីនៃប្រទេសដែលមេធាវីបរទេសបានចុះបញ្ជី (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៧. លិខិតឆ្លងដែន និងទិដ្ឋាការនៅមានសុពលភាព (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៨. លិខិតថ្កោលទោស ។

៩. ឯកសារផ្សេងទៀតដែលតម្រូវដោយគណៈមេធាវី ។

ឯកសារទាំងអស់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវបកប្រែជាភាសាខ្មែរ ។

ប្រការ ៧. ការពិនិត្យសមត្ថភាព

ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចឱ្យមេធាវីបរទេសធ្វើការប្រឡងលើមុខវិជ្ជាគ្រឹះចំនួន ២ (ពីរ) គឺ គោលការណ៍ទូទៅផ្នែកច្បាប់កម្ពុជា និងវិធានវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មុននឹងសម្រេចឱ្យចុះបញ្ជីនៅគណៈមេធាវី ។

បែបបទ និងនីតិវិធីនៃការប្រឡងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

ប្រការ ៨. ការធ្វើសច្ចាប្រណិធាន

បន្ទាប់ពីត្រូវបានសម្រេចអនុញ្ញាតឱ្យចុះបញ្ជីនៅគណៈមេធាវី មេធាវីបរទេសត្រូវធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍រាជធានីភ្នំពេញ មុនពេលប្រកបវិជ្ជាជីវៈមេធាវីរបស់ខ្លួន។

ប្រការ ៩. វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

មេធាវីបរទេសត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ដើម្បីកំណត់អំពីវិសាលភាពនៃការប្រកបវិជ្ជាជីវៈមេធាវីរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសនេះមានសុពលភាព ១ (មួយ) ឆ្នាំ ហើយអាចបន្តទៀតបានប្រសិនបើមេធាវីបរទេសអនុវត្តស្របទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងសេចក្តីសម្រេចនេះ។

មេធាវីបរទេស ត្រូវដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសមកគណៈមេធាវីឱ្យបានយ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ មុនពេលវិញ្ញាបនបត្រផុតសុពលភាព។

ប្រការ ១០. ការតំណាងក្នុងក្តី

មេធាវីបរទេសអាចអមមេធាវីខ្មែរ ប៉ុន្តែមិនអាចតំណាងក្នុងក្តីដោយផ្ទាល់នៅចំពោះមុខតុលាការ ឬស្ថាប័នសាធារណៈដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ។

ជំពូកទី ៣
ទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស
និងការចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស

ប្រការ ១១. ទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនក្នុងទម្រង់ដូចខាងក្រោម៖

១. ក្រុមហ៊ុនមេធាវីបរទេស។

២. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស។

ប្រការ ១២. ក្រុមហ៊ុនមេធាវីបរទេស

ក្រុមហ៊ុនមេធាវីបរទេសអាចផ្តល់សេវាកម្មច្បាប់លើច្បាប់បរទេស និងច្បាប់អន្តរជាតិ ប៉ុន្តែមិនអាចផ្តល់សេវាកម្មច្បាប់លើច្បាប់កម្ពុជាបានទេ លើកលែងតែមានកិច្ចសហការផ្តល់សេវាកម្មច្បាប់ស្របតាមជំពូកទី ៥ នៃសេចក្តីសម្រេចនេះ។

ប្រការ ១៣. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស

ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស អាចផ្តល់សេវាកម្មច្បាប់លើច្បាប់កម្ពុជា ច្បាប់បរទេស និងច្បាប់អន្តរជាតិបាន។ មេធាវីបរទេសដែលជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន អាចផ្តល់សេវាកម្មច្បាប់លើច្បាប់កម្ពុជាបាន តែត្រូវស្ថិតក្រោមការដឹកនាំ ត្រួតពិនិត្យ និងទទួលខុសត្រូវរបស់មេធាវីដែលជាម្ចាស់ភាគហ៊ុនខ្មែរ។

ប្រការ ១៤. ការចុះបញ្ជី

ក្រុមហ៊ុនមេធាវីបរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជី ដែលត្រូវចុះហត្ថលេខាដោយមេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

២. មេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌ និងចុះបញ្ជីនៅគណៈមេធាវី ស្របតាមជំពូកទី ២ នៃសេចក្តីសម្រេចនេះ។

៣. លិខិតបញ្ជាក់ការតម្កល់ដើមទុនអប្បបរមា ១ 000 000 000 (មួយពាន់លាន) រៀល ចេញដោយធនាគារណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

៤. ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ របស់ក្រុមហ៊ុន។

៥. លក្ខន្តិកៈក្រុមហ៊ុនដែលចុះហត្ថលេខាដោយមេធាវីជាម្ចាស់ភាគហ៊ុន។

៦. លក្ខន្តិកៈក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន វិញ្ញាបនបត្រចុះបញ្ជី អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ និងរបាយការណ៍ហិរញ្ញវត្ថុរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)។

៧. លិខិតផ្ទេរសិទ្ធិពីក្រុមហ៊ុនមេធាវីបរទេស ឱ្យមេធាវីបរទេសណាមួយធ្វើជាតំណាងស្របច្បាប់ក្នុងការគ្រប់គ្រងសាខារបស់ក្រុមហ៊ុន។

៨. លិខិតបញ្ជាក់ពីកេរ្តិ៍ឈ្មោះ (Good Standing) របស់ក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន។

ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជី ដែលត្រូវចុះហត្ថលេខាដោយមេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

២. មេធាវីបរទេសជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌ និងចុះបញ្ជីនៅគណៈមេធាវី ស្របតាមជំពូកទី ២ នៃសេចក្តីសម្រេចនេះ។

៣. លិខិតបញ្ជាក់ការតម្កល់ដើមទុនអប្បបរមា ៤00 000 000 (បួនរយលានរៀល) ចេញដោយធនាគារណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

៤. លក្ខន្តិកៈក្រុមហ៊ុនដែលចុះហត្ថលេខាដោយមេធាវីជាម្ចាស់ភាគហ៊ុន។

ប្រការ ១៥. លក្ខន្តិកៈក្រុមហ៊ុន

លក្ខន្តិកៈក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវមានចែងអំពីព័ត៌មានអប្បបរមាដូចខាងក្រោម៖ ៤.៥

១. នាមករណ៍ក្រុមហ៊ុន។

២. អាសយដ្ឋានរបស់ក្រុមហ៊ុន។

៣. ឈ្មោះម្ចាស់ភាគហ៊ុន និងចំណែកភាគហ៊ុន។

៤. អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

៥. កម្មវត្ថុនៃសេវាកម្មច្បាប់ និងវិស័យច្បាប់ដែលក្រុមហ៊ុនមានបំណងប្រកបវិជ្ជាជីវៈ។

៦. រចនាសម្ព័ន្ធ ការគ្រប់គ្រងក្រុមហ៊ុន និងទំនាក់ទំនងរវាងម្ចាស់ភាគហ៊ុន។

៧. គណនេយ្យ និងសវនកម្ម។

៨. ការផ្ទេរ និងអនុប្បទានភាគហ៊ុន។

៩. ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុន។

១០. ការដោះស្រាយវិវាទរវាងម្ចាស់ភាគហ៊ុន តាមយន្តការនៃការផ្សះផ្សាដោយប្រធានគណៈមេធាវី។

ប្រការ ១៦. ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំចុះបញ្ជី

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យ និងសម្រេចលើពាក្យស្នើសុំចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់គ្រប់គ្រាន់។

ប្រការ ១៧. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស មានសុពលភាព ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចអនុញ្ញាតឱ្យចុះបញ្ជី។

តំណាងស្របច្បាប់របស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំបន្តចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស ឬក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស មកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានយ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ មុនពេលវិញ្ញាបនបត្រចុះបញ្ជីផុតសុពលភាព។

ជំពូកទី ៤

ការផ្សព្វ ការដកហូតវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស និងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស និងការលុបឈ្មោះមេធាវីបរទេស

ប្រការ ១៨. ភាតព្វកិច្ចរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស

មេធាវីបរទេសត្រូវមានភាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវីចំនួន ១ ២០០ ០០០ (មួយលានពីរសែន) រៀលក្នុងមួយត្រីមាស។

មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលបានចុះបញ្ជីនៅគណៈមេធាវី ត្រូវអនុវត្តស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១៩. ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

វិញ្ញាបនប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសអាចត្រូវបានព្យួរ ឬត្រូវបានដកហូតក្នុងករណីដែលមេធាវីបរទេសបានប្រព្រឹត្តបំពានទៅនឹង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២០. ការលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេស

មេធាវីបរទេសអាចត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេសនៅគណៈមេធាវី ក្នុងករណីដូចខាងក្រោម៖

១. ត្រូវបានលុបឈ្មោះចេញពីគណៈមេធាវីដើមរបស់ខ្លួន។

២. ទទួលមរណភាព ឬពិការភាពមិនអាចអនុវត្តវិជ្ជាជីវៈមេធាវីបាន។

៣. ខកខានមិនបានស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យចុះបញ្ជី។

៤. មិនបំពេញកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ២ (ពីរ) ត្រីមាស។

៥. ត្រូវបានសម្រេចលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេស ដោយក្រុមប្រឹក្សាគណៈមេធាវី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ប្រការ ២១. ការព្យួរ និងការដកហូតលិខិតអនុញ្ញាតចុះបញ្ជី

លិខិតអនុញ្ញាតចុះបញ្ជីរបស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស អាចត្រូវបានព្យួរ ឬដកហូត ក្នុងករណីខាងក្រោម៖

១. មេធាវីបរទេសដែលជាតំណាងក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេសនៅគណៈមេធាវី ហើយពុំមានអ្នកជំនួសក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ។

២. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានប្រកាសក្ស័យធន។

៣. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈឹម ឬបទល្មើសឧក្រិដ្ឋ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស បានផ្តល់ព័តិមានមិនពិត ឬ លាក់បាំងការពិត សម្រាប់ការស្នើសុំចុះបញ្ជី ឬ កែប្រែលក្ខន្តិក: ឈ្មោះ អាសយដ្ឋាន ឬ ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ឬ សកម្មភាពរបស់ក្រុមហ៊ុន ត្រូវបានហាមឃាត់ដោយតុលាការ។

ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលការអនុញ្ញាតចុះបញ្ជីត្រូវបានដកហូត ត្រូវធ្វើការដម្រះបញ្ជីតាមច្បាប់ជាធរមាន។

ជំពូកទី ៥

ការគ្រប់គ្រង និងត្រួតពិនិត្យការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

ប្រការ ២២. សិទ្ធិអំណាចរបស់គណៈមេធាវី

គណៈមេធាវីជាស្ថាប័នតែមួយគត់ដែលគ្រប់គ្រងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស។

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងដោះស្រាយលើគ្រប់បញ្ហាដែលពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស។

ប្រការ ២៣. ការធ្វើអធិការកិច្ច

ក្រុមអធិការកិច្ចរបស់គណៈមេធាវីមានសិទ្ធិចូលត្រួតពិនិត្យ សាកសួរ និងស្រាវជ្រាវក្នុងទីស្នាក់ការរបស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬទីកន្លែងដែលសង្ស័យថាមានការលួចប្រកបវិជ្ជាជីវៈមេធាវីដោយជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២៤. កិច្ចសហការផ្តល់សេវាកម្មច្បាប់

រាល់កិច្ចសន្យាសហការផ្តល់សេវាកម្មច្បាប់ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម។

ក្រុមហ៊ុនមេធាវីបរទេសទាំងអស់ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ពាក់ព័ន្ធនឹងកិច្ចសហការផ្តល់សេវាកម្មច្បាប់ ដាក់ជូនគណៈមេធាវី។

របាយការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវមានព័តិមានពាក់ព័ន្ធនឹង:

១. ឈ្មោះរបស់ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬការិយាល័យវិជ្ជាជីវៈមេធាវីខ្មែរ ដែលធ្វើសហការផ្តល់សេវាកម្មច្បាប់។

២. ឈ្មោះមេធាវីទទួលបន្ទុកក្នុងការផ្តល់សេវាកម្ម។

៣. វិសាលភាពនៃការផ្តល់សេវាកម្មច្បាប់។

ជំពូកទី ៦

កម្រៃសេវាក្នុងការចុះបញ្ជី

ប្រការ ២៥. កម្រៃជាក់ពាក្យស្នើសុំ

មេធាវីបរទេសត្រូវបង់ថ្លៃដាក់ពាក្យស្នើសុំចុះបញ្ជី និងសៅហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធីជូនគណៈមេធាវី ដូចខាងក្រោម៖

១. ពាក្យស្នើសុំតម្លៃ ២00 000 (ពីរសែន) រៀល។

២. សៅហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ចំនួន ២ 000 000 (ពីរលាន) រៀល។

ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបង់ថ្លៃពាក្យស្នើសុំចុះបញ្ជី និងសៅហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធីជូនគណៈមេធាវី ដូចខាងក្រោម៖

១. ពាក្យស្នើសុំតម្លៃ ៤00 000 (បួនសែន) រៀល។

២. សៅហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ចំនួន ៤ 000 000 (បួនលាន) រៀល។

ថ្លៃពាក្យស្នើសុំ និងសៅហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ដូចមានចែងខាងលើ មិនត្រូវបានប្រគល់ឱ្យវិញទេ ទោះបីជាមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅគណៈមេធាវីក៏ដោយ។

ប្រការ ២៦. កម្រៃចុះបញ្ជី និងបន្តការចុះបញ្ជី

បន្ទាប់ពីមានការសម្រេចអនុញ្ញាតឱ្យចុះបញ្ជី មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបង់ថ្លៃចុះបញ្ជី និងស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈ ជូនគណៈមេធាវី ដូចខាងក្រោម៖

១. មេធាវីបរទេស ២ 000 000 (ពីរលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

២. ក្រុមហ៊ុនមេធាវីបរទេស ២0 000 000 (ម្ភៃលាន) រៀល សម្រាប់រយៈពេល ១ (មួយ)ឆ្នាំ។

៣. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ១0 000 000 (ដប់លាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

ជំពូកទី ៧

ទោសប្បញ្ញត្តិ

ប្រការ ២៧. ទណ្ឌកម្មវិន័យ និង ការដាក់ពិន័យ

ជនណាដែលប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំបានចុះបញ្ជីនៅគណៈមេធាវី និង/ឬ គ្មានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និង/ឬ មានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីហួសសុពលភាព ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលបានប្រព្រឹត្តបំពាននឹងបញ្ញត្តិណាមួយនៃសេចក្តីសម្រេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ជំពូកទី ៨

អន្តរប្បញ្ញត្តិ

ប្រការ ២៨. ការកែតម្រូវ

មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស ឬក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី និងស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ ក្នុងរយៈពេល ៦០ (ហុបសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ។

ជំពូកទី ៩

អវសានប្បញ្ញត្តិ

ប្រការ ២៩. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៣០. ការអនុវត្ត

អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានអធិការកិច្ច ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ចម្លងជូន៖
-ខុទ្ទការល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
"ដើម្បីជូនជ្រាបដ៏ខ្ពង់ខ្ពស់"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ



មេធាឌី.ប៊ុន ហួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ណាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ចូនគា
៦-មេធាវី ចេង ម៉េងហាប់
៧-មេធាវី យុង ជានិត
៨-មេធាវី ថៅ ប៊ុនហួន
៩-មេធាវី រស់ ហុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុត ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន ឥន្ទ្រ:
១៧-មេធាវី ចំន្ទ ឥច្ចិត្រា
១៨-មេធាវី ព្រាប្ត ឥច្ចិត្រសុគា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ថៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ថ្រី សំអាល
៣២-មេធាវី ឆួន ជានិត
៣៣-មេធាវី ឃុត កែវសុផ្កា

លេខ ១៩៧ /សសគម/១៩

ថៃ សុក្រ ៩រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩

សេចក្តីសម្រេច

ស្តីពី

ការតម្រូវឱ្យមេធាវីដែលមានបំណងបន្តសុំនៅក្រៅបញ្ជី ដាក់ពាក្យសុំនៅក្រៅបញ្ជីបន្តជាថ្មីឡើងវិញ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

ស ម្រ េ ច

ប្រការ ១. មេធាវីដែលបានអនុញ្ញាតឱ្យនៅក្រៅបញ្ជី ដែលមានបំណងសុំនៅក្រៅបញ្ជីបន្តទៀត ត្រូវដាក់ពាក្យសុំនៅក្រៅបញ្ជីបន្តជាថ្មីឡើងវិញឱ្យបានមុនពេលអស់សុពលភាព នៃសេចក្តីសម្រេចស្តីពីការដាក់ឱ្យនៅក្រៅបញ្ជី។

ប្រការ ២. ក្នុងករណីមេធាវីនៅក្រៅបញ្ជីណា ដែលមិនបានដាក់ពាក្យសុំនៅក្រៅបញ្ជីបន្តជាថ្មីឡើងវិញមុនពេលអស់សុពលភាព នៃសេចក្តីសម្រេចស្តីពីការដាក់ឱ្យនៅក្រៅបញ្ជី

អគ្គលេខាធិការគណៈមេធាវីត្រូវចុះឈ្មោះមេធាវីរូបនេះ ក្នុងបញ្ជីមេធាវីប្រកបវិជ្ជាជីវៈជាស្ថ័យប្រវត្ត។ ហើយប្រសិនបើមេធាវីរូបនេះបានបំពេញការងារ ដែលមានវិសមិតភាពជាមួយវិជ្ជាជីវៈមេធាវី មេធាវីរូបនេះត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី និងក្រមសីលធម៌មេធាវី។

ប្រការ ៣. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤. អគ្គលេខាធិការគណៈមេធាវី និងសមាជិក-សមាជិកាគណៈមេធាវីទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធាន

មេធាវី **សួន_ទិសាល**

ចម្លងជូន

-ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃ
មហាអយ្យការអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ងួនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ឆានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ាវតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ ឥចិត្រ
១៨-មេធាវី ព្រហ្ម ឥចិត្រសុតា
១៩-មេធាវី ណុប គុណចុល
២០-មេធាវី យីម ថាវី
២១-មេធាវី ឌីម ចៅសេង
២២-មេធាវី លី សុខឃ្លាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ធ្វី សំរស់
៣២-មេធាវី ឡូ ឆានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ៤៦៧ /សសគម/២០

ថ្ងៃ ចន្ទ ៧កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២០

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារសិក្សាអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០

ស ម្រេ ច

ប្រការ ១. ត្រូវបានបង្កើតក្រុមការងារសិក្សាអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី ដែលមានសមាសភាពដូចខាងក្រោម៖

១.លោកមេធាវី **កុយ នាម**	សមាជិកក្រុមប្រឹក្សាគណៈមេធាវី	ប្រធាន
២.លោកមេធាវី **ប៉ា ងួនគា**	សមាជិកក្រុមប្រឹក្សាគណៈមេធាវី	សមាជិក

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

៣.លោកមេធាវី	**វស់ មុនិន្ទៈ**	សមាជិកក្រុមប្រឹក្សាគណៈមេធាវី	សមាជិក
៤.លោកមេធាវី	**គង់ សំអុន**	សមាជិកក្រុមប្រឹក្សាគណៈមេធាវី	សមាជិក
៥.លោកមេធាវី	**លីវ សុវណ្ណា**	អគ្គលេខាធិការរងគណៈមេធាវី	លេខាធិការ។

ប្រការ ២.- ក្រុមការងារសិក្សាអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីមានភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី
- សិក្សា ស្រាវជ្រាវទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីនៅបណ្តាប្រទេសផ្សេងៗ
- ពិនិត្យលើទម្រង់នៃការប្រកបវិជ្ជាជីវៈរបស់សមាជិកគណៈមេធាវីជាក់ស្តែង
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនប្រធានគណៈមេធាវីជាប្រចាំ
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី ដើម្បីដាក់ជូនប្រធានពិនិត្យ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រធានគណៈមេធាវី។

ប្រការ ៣.- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤.- អគ្គលេខាធិការគណៈមេធាវី និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធាន

មេធាវី សួន ឥសាល

ចម្លងជូន

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទគុណា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ឆាម
២-មេធាវី ឆេង បុនលេ
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ជា ឌួនគា
៦-មេធាវី ចេង ម៉េងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុវ បន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ខុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន ឥណ្ណៈ
១៧-មេធាវី ចំន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យ៉ឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឃ្មាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ធ្វី សំរស់
៣២-មេធាវី ឌួន ជានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ៧១៦ /សសគម/២០

សេចក្តីសម្រេច
ស្តីពី
កាតព្វកិច្ចបង់ប្រាក់របស់បេក្ខជនដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទគុណា** ជាប្រធានគណៈមេធាវីអាណត្តិទី ១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- បានឃើញសេចក្តីសម្រេចលេខ៦៨៣/សសគម/១៨ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីគោលនយោបាយហិរញ្ញវត្ថុរបស់គណៈមេធាវី
- បានឃើញសេចក្តីសម្រេចលេខ ០០៦/សសគម/១៤ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង់ថវិកាសម្រាប់ឧបត្ថម្ភដល់ប្រតិបត្តិការការពារក្តីជូនជនក្រីក្រ
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

ស ម្រ េ ច

ប្រការ១ .. បេក្ខជនដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីមានកាតព្វកិច្ចបង់ប្រាក់រៀល ដែលមានចំនួនស្មើនឹង ៣ ៥០០(បីពាន់ប្រាំរយ)ដុល្លារអាមេរិក ចូលក្នុងគណនីរបស់គណៈមេធាវី

អគារការ៉ាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

សម្រាប់ចំណាយលើការបណ្តុះបណ្តាលក្នុងវគ្គសុក្រឹតការចំនួន១៨០(មួយរយប៉ែតសិប)ម៉ោងនិងបង់ប្រាក់រៀលដែលមានចំនួនស្មើនឹង ៥០០(ប្រាំរយ)ដុល្លារអាមេរិក សម្រាប់ឧបត្ថម្ភដល់ប្រតិបត្តិការការពារក្តីជូនជនក្រីក្រ ស្របតាមសេចក្តីសម្រេចលេខ ០០៦/សសគម/១៤ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង់ថវិកាសម្រាប់ឧបត្ថម្ភដល់ប្រតិបត្តិការការពារក្តីជូនជនក្រីក្រ។

ប្រការ២ ..វគ្គសុក្រឹតការនេះត្រូវរៀបចំឡើងដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី។ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីមានភារកិច្ចបណ្តុះបណ្តាលនិងចេញវិញ្ញាបនបត្រដល់កម្មសិក្សាការី ដើម្បីបញ្ជូនមកប្រធានគណៈមេធាវីពិនិត្យ យល់ព្រមនិងចុះហត្ថលេខា។

ប្រការ៣ ..សេចក្តីសម្រេចនេះត្រូវអនុវត្តចំពោះបេក្ខជនដែលបានដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីមុនសេចក្តីសម្រេចនេះ ហើយដែលក្រុមប្រឹក្សាគណៈមេធាវីពុំទាន់បានសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីនៅឡើយ និងបេក្ខជនដែលមានបំណងដាក់ពាក្យចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ។

ប្រការ៤ .. បេក្ខជនដែលបានដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីមុនសេចក្តីសម្រេចនេះ អាចសុំដកយកប្រាក់ថ្លៃដាក់ពាក្យចំនួន ៣០០(បីរយ)ដុល្លារអាមេរិកវិញ ក្នុងករណីដែលខ្លួនពុំអាចអនុវត្តតាមសេចក្តីសម្រេចនេះ។ ថវិកាដែលត្រូវបង្វិលនេះជាបន្ទុករបស់គណៈមេធាវី។

ប្រការ៥ .. សេចក្តីសម្រេចលេខ១៩៦/សសគម/០៦ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង់ប្រាក់សំរាប់វគ្គសុក្រឹតការចំពោះកម្មសិក្សាការីដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសំរេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិង បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៦ .. អគ្គលេខាធិការគណៈមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០

ប្រធាន



មេធាវី លី-ចំន្ទគុណា

ចម្លងជូន
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
- ក្រុមប្រឹក្សាគណៈមេធាវី
  "ដើម្បីជ្រាប"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ ណាម
២-មេធាវី ឆេង បុផ្ផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ជា ឡូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុត ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុក គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណប៉ុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន គារ
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ឡូន ជានិត
៣៣-មេធាវី ឃុត កែវសុត្ថា

លេខ ១០១៤ /សសគម/២០

សេចក្តីសម្រេច
ស្តីពី
ការចុះបញ្ជីនិងការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសម្រាប់មេធាវីបរទេស ដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

ស ម្រ េ ច

ប្រការ១ .. មេធាវីបរទេសដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវចុះបញ្ជីជាមុនជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ២ .. មេធាវីបរទេសដែលបំពេញបានតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ប្រការ៣ .. អង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុង

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

តុលាការកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់និងបកប្រែឯកសារទាំងអស់របស់មេធាវីបរទេសមកជាភាសាខ្មែរនិង ទទួលខុសត្រូវលើការបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនីមួយៗ។ ក្នុងករណីពិនិត្យឃើញថាពាក្យសុំនោះបាន បំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់ហើយ អង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបញ្ជូនសំណុំឯកសារនោះមកគណៈមេធាវី។

ប្រការ៤ .. គណៈមេធាវីត្រូវពិនិត្យនិងសម្រេចលើពាក្យសុំនោះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសំណុំ ឯកសារត្រឹមត្រូវ លើកលែងតែករណីដែលមិនអាចជម្នះបាន។

ប្រការ៥ .. ក្នុងករណីគណៈមេធាវីសម្រេចចុះបញ្ជីមេធាវីបរទេសណាមួយ គណៈមេធាវីត្រូវជូនដំណឹងទៅមេធាវីបរទេស រូបនោះតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាឱ្យបង់ប្រាក់ថ្លៃចុះបញ្ជីចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុងរយៈពេលកំណត់ជាក់លាក់មួយ។ ក្នុង ករណីមេធាវីបរទេសពុំបានបង់ប្រាក់ថ្លៃចុះបញ្ជីតាមការកំណត់ទេ សេចក្តីសម្រេចចុះបញ្ជីមេធាវីបរទេសរូប នោះត្រូវលុបចោលជាស្វ័យប្រវត្តិ។ ក្នុងករណីមេធាវីបរទេសបានបង់ប្រាក់តាមការកំណត់ គណៈមេធាវីត្រូវ ស្នើសុំកម្មវិធីធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ។ មេធាវីបរទេសត្រូវមានវត្តមានតាម ការកំណត់របស់សាលាឧទ្ធណ៍ភ្នំពេញ។

ប្រការ៦ .. មេធាវីបរទេសត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាមកគណៈមេធាវីក្នុងរយៈពេល១(មួយ)សប្តាហ៍ បន្ទាប់ពីធ្វើសច្ចាប្រណិធាន ដោយភ្ជាប់មកជាមួយនូវ រូបថតពាក់អាវវិជ្ជាជីវៈទំហំ៤គុណ៦ចំនួន២(ពីរ)សន្លឹក។ វិញ្ញាបនបត្រនេះមានសុពលភាព១(មួយ)ឆ្នាំ។

ប្រការ៧ .. មេធាវីបរទេសដែលមានបំណងបន្តចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រកប វិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវផ្តល់ឯកសារបញ្ជាក់អំពីសុពលភាពនៃការចុះ ឈ្មោះរបស់ខ្លួនក្នុងបញ្ជីគណៈមេធាវីដែលត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ហើយដែលមានកេរ្តិ៍ឈ្មោះល្អច្បាប់ដើមឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជាក់ដោយអង្គភាពគាំពារ ការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការបកប្រែជា ភាសាខ្មែរ មកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានយ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃ មុនពេលវិញ្ញាបនបត្រ ប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអស់សុពលភាព។ ឯកសារនេះអាច ដាក់ដោយមេធាវីបរទេសផ្ទាល់ ឬតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ក្នុងករណីមិនបានផ្តល់ឯកសារបញ្ជាក់ពីសុពលភាពតាមកាលកំណត់នេះ ទេ នោះគណៈមេធាវីនឹងសម្រេចលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី។

ប្រការ៨ .. មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មុនចេញសេចក្តីសម្រេច នេះ ត្រូវផ្តល់ឯកសារបញ្ជាក់អំពីសុពលភាពនៃការចុះឈ្មោះរបស់ខ្លួនក្នុងបញ្ជីគណៈមេធាវីដែលត្រូវបានទទួល ស្គាល់ដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ហើយដែលមានកេរ្តិ៍ឈ្មោះល្អច្បាប់ដើមឬថតចម្លងត្រឹម ត្រូវតាមច្បាប់ដើម បញ្ជាក់ដោយអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជានិងការបកប្រែជាភាសាខ្មែរ ដោយភ្ជាប់មកជាមួយនូវរូបថតពាក់អាវវិជ្ជាជីវៈ ទំហំ៤គុណ៦ចំនួន២(ពីរ)សន្លឹក មកគណៈមេធាវីឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ដើម្បីធ្វើ

បច្ចុប្បន្នភាពនិងផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ឯកសារនេះអាចដាក់ដោយមេធាវីបរទេសផ្ទាល់ ឬតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ក្នុងករណីមិនបានផ្តល់ឯកសារបញ្ជាក់ពីសុពលភាពតាមកាលកំណត់នេះទេ នោះគណៈមេធាវីត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី។

ប្រការ៩ .. សេចក្តីសម្រេចលេខ៦៩៨/សសគម/១៨ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈ និងកាតព្វកិច្ចបង់ភាគទានរបស់មេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ១០ .. អគ្គលេខាធិការគណៈមេធាវីនិងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ศุក្រ ៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២០

ប្រធាន



មេធាវី លី_ច័ន្ទតុលា

ចម្លងជូន

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ១០
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុង ភីរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុភន្ធន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ថានិត
៩-មេធាវី ជូ ចាន់ធីតា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឡសតា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុភណ្ណា
១៤-មេធាវី ឈីវ ភីរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី ឆេ មានន្ទ
១៧-មេធាវី អ៊ូ ធីតារ៉ៅ
១៨-មេធាវី លី ធីង
១៩-មេធាវី យឹម ឥសុត
២០-មេធាវី លឹម ចំណុលជា
២១-មេធាវី កែ ឥសាល
២២-មេធាវី ហូ លីហួត
២៣-មេធាវី ង៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ឥមានចំណា
២៧-មេធាវី ឈឺ សម្បត្តិ

លេខ: ១៤៤៤/គ.ម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៦

សេចក្តីណែនាំ
ស្តីពី
ការប្រកបវិជ្ជាជីវៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសមាជិក-សមាជិកាគណៈមេធាវីឱ្យបានជ្រាបថា៖ រយៈពេលកន្លងមក គណៈមេធាវីបានសង្កេតឃើញថា នៅក្នុងការប្រកបវិជ្ជាជីវៈមេធាវី មេធាវីភាគច្រើនបានអនុវត្តវិជ្ជាជីវៈរបស់ខ្លួនបានត្រឹមត្រូវ ដោយគោរពបានយ៉ាងខ្ជាប់ខ្ជួនទូរច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ក៏ប៉ុន្តែ មេធាវីមួយចំនួននៅមិនទាន់អនុវត្តតាមវិធានទាំងនេះឱ្យបានត្រឹមត្រូវនៅឡើយ។ ដើម្បីធានាឱ្យបានទូវប្រសិទ្ធភាព និងភាពថ្លៃថ្នូរនៃការប្រកបវិជ្ជាជីវៈមេធាវី គណៈមេធាវីសូមធ្វើការណែនាំដូចខាងក្រោម៖

១. <u>ការធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងមកគណៈមេធាវី</u> នៅរាល់ពេលដែលមានការផ្លាស់ប្តូរ៖ ការផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង ដែលរួមមាន ការិយាល័យវិជ្ជាជីវៈ អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ អ៊ីម៉ែល ត្រូវធ្វើការជូនដំណឹងជាបន្ទាន់មកគណៈមេធាវី តាមមធ្យោបាយសមស្រប។

២. <u>ការទទួលលិខិតរបស់គណៈមេធាវី៖</u> នៅពេលមានការបញ្ជូនលិខិតរបស់គណៈមេធាវីទៅដល់ការិយាល័យវិជ្ជាជីវៈមេធាវី មេធាវីសាមី ឬបុគ្គលិកប្រចាំការិយាល័យមួយចំនួន មិនព្រមចុះហត្ថលេខាថាបានទទួលឡើយ។ ទម្លាប់នេះជាទម្លាប់ដែលមិនត្រឹមត្រូវតាមបែបបទរដ្ឋបាល និងគ្មានការទទួលខុសត្រូវលើវិជ្ជាជីវៈរបស់ខ្លួនឡើយ។ មេធាវីខ្លះ បានយកលេសថាមិនបានទទួលលិខិត ហើយឆ្លើយតបមកគណៈមេធាវីថាមិនដឹង មិនបានទទួលលិខិត។ គណៈមេធាវីសូមបញ្ជាក់ជូនសមាជិក-សមាជិកាទាំងអស់ថា ក្នុងនាមជាមេធាវីដែលទទួលខុសត្រូវការិយាល័យវិជ្ជាជីវៈរបស់ខ្លួន មេធាវីត្រូវទទួលលិខិតដែលបញ្ជូនទៅដល់ការិយាល័យរបស់ខ្លួន និងចុះហត្ថលេខាថាបានទទួល។ ហត្ថលេខានេះ មិនមានន័យជាការទទួលយកកំហុស ឬទទួលខុសត្រូវលើអ្វីមួយឡើយ។

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧, ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

៣. <u>ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងងាយស្រួលតាមរយៈអ៊ីមែល សម្រាប់ទទួលព័ត៌មាន</u>៖ គណៈមេធាវីធ្លាប់បានជូនដំណឹងដល់សមាជិក-សមាជិកាទាំងអស់ឱ្យបង្កើតអ៊ីមែល និងប្រើប្រាស់ឱ្យបានគ្រប់ៗគ្នា ស្របតាមយុគ្គសម័យព័ត៌មានវិទ្យាដែលរីកចម្រើនឥតឈប់ ហើយដែលអាចជួយសម្រួលដល់ការប្រាស្រ័យទាក់ទង ព្រមទាំងចំណេញពេលវេលា និងថវិកាផងដែរ។ មេធាវីត្រូវមានអ៊ីមែលសម្រាប់ទំនាក់ទំនង និងត្រូវទទួលយកមធ្យោបាយទំនាក់ទំនងនេះ ជាមធ្យោបាយផ្លូវការ។

៤. <u>ការចូលរួមសិក្ខាសាលាដែលរៀបចំឡើងដោយគណៈមេធាវី</u>៖ គណៈមេធាវីបានខិតខំស្វែងរកកិច្ចសហការជាមួយដៃគូនានា ក្នុងការរៀបចំសិក្ខាសាលាលើប្រធានបទសំខាន់ផ្សេងៗ សម្រាប់បង្កើនចំណេះដឹងរបស់សមាជិក-សមាជិការបស់ខ្លួន ដើម្បីឱ្យទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗ ពីជុំវិញពិភពលោក។ ប៉ុន្តែសមាជិក-សមាជិកាមួយចំនួនមិនបានយល់ពីសារៈសំខាន់នៃការចូលរួមសិក្ខាសាលាទាំងនេះឡើយ។ មេធាវីខ្លះចុះឈ្មោះតែមិនចូលរួម មេធាវីខ្លះទៀត ចុះឈ្មោះតែបែរជាឱ្យជំនួយការមេធាវីចូលរួមទៅវិញ។ ដូច្នេះដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន មេធាវីត្រូវចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំឡើងដោយគណៈមេធាវី។

៥. <u>ការការពារក្តីជូនជនក្រីក្រ</u>៖ មេធាវីមានកាតព្វកិច្ចការពារក្តី និងប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជនរបស់ខ្លួន។ ជនក្រីក្រក៏ជាអតិថិជនរបស់ខ្លួនដែរ។ ហេតុនេះ មេធាវីមានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រ ឱ្យដូចជាជួយការពារក្តីឱ្យអតិថិជនទូទៅរបស់ខ្លួនដែរ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយភាពយុត្តិធម៌ចំពោះមុខច្បាប់ មានន័យថាជនក្រីក្រក៏ត្រូវបានការពារដោយមេធាវី ដូចជនទូទៅដែលមានប្រាក់គ្រប់គ្រាន់សម្រាប់បង់សេវាមេធាវីដែរ។

៦. <u>ការប្រកបវិជ្ជាជីវៈដោយថ្លៃថ្នូរ និងគោរពតាមក្រមសីលធម៌</u>៖ មេធាវីដែលល្អនិងមានសមត្ថភាព មិនមែនជាមេធាវីរត់ការទេ។ មេធាវីគឺជាជំនួយការយុត្តិធម៌សង្គម និងមិនមែនជាជំនួយការតុលាការទេ។ មេធាវីមិនមែនជាអន្តរការី ក្នុងការរត់ការសំណុំរឿងឡើយ។ មេធាវីត្រូវប្រើប្រាស់សមត្ថភាពរបស់ខ្លួនដើម្បីការពារផលប្រយោជន៍កូនក្តី។ គណៈមេធាវីមិនគាំទ្រការប្រព្រឹត្តអំពើពុករលួយរបស់មេធាវីឡើយ។

៧. <u>ការបកស្រាយច្បាប់ និងការលើកមតិនៅតាមបណ្តាញសារព័ត៌មានដោយមានការទទួលខុសត្រូវខ្ពស់</u>៖ មេធាវីត្រូវធ្វើការស្រាវជ្រាវឱ្យបានល្អិតល្អន់ មុនពេលធ្វើការបកស្រាយច្បាប់ ឬបញ្ចេញមតិក្នុងការអប់រំ និងផ្សព្វផ្សាយច្បាប់ ជូនសាធារណជន។ ការសិក្សាស្រាវជ្រាវជាមុនឱ្យបានល្អិតល្អន់ រក្សាបាននូវគុណភាពនៃការផ្សព្វផ្សាយច្បាប់ និងធ្វើឱ្យសាធារណជនមានទំនុកចិត្តមកលើមេធាវី។

៨. <u>ការផ្តល់សេវាជូនអតិថិជនប្រកបដោយការទទួលខុសត្រូវ</u>៖ វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈសេរី មានន័យថា មេធាវីមានសេរីភាពគ្រប់គ្រាន់ក្នុងការកំណត់កម្រៃសេវា និងការទទួល ឬមិនទទួលរឿងក្តី។ ក៏ប៉ុន្តែនៅពេលដែលមេធាវីសម្រេចចិត្តទទួលរឿងក្តីហើយ មេធាវីត្រូវបំពេញកិច្ចការរបស់ខ្លួនឱ្យចប់

ចុងចប់ដើម និងទៅតាមការពីងពាក់របស់កូនក្តី លើកលែងតែក្នុងករណីមានទំនាស់ផលប្រយោជន៍។ ទោះជាយ៉ាងនេះក្តី មេធាវីត្រូវជូនដំណឹងដល់កូនក្តីអំពីករណីទំនាស់ផលប្រយោជន៍នេះមុនពេលបញ្ចប់សេវាកម្មរបស់ខ្លួន។

៩. <u>ការគោរពកាតព្វកិច្ចបង់ភាគទាន</u>៖ ដូចដែលសហភាគីទាំងអស់បានជ្រាបហើយថា ប្រភពចំណូលសំខាន់បំផុតរបស់គណៈមេធាវីគឺបានមកពីការបង់ភាគទានរបស់សហភាគីទាំងអស់គ្នា។ ថវិកានេះប្រើប្រាស់សម្រាប់យកមកចំណាយលើដំណើរការការងាររដ្ឋបាល និងពង្រឹងស្ថាប័នគណៈមេធាវី ដើម្បីជាប្រយោជន៍ដល់សមាជិក-សមាជិកាទាំងអស់ ព្រមទាំងវិជ្ជាជីវៈមេធាវីទាំងមូល។ ហេតុនេះ មេធាវីគ្រប់រូបត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចទាំងឡាយដែលដាក់ចេញដោយគណៈមេធាវី។

ដើម្បីឱ្យសម្រេចបានតាមភាសិត “**សមត្ថភាព និងសីលធម៌វិជ្ជាជីវៈ នាំមកនូវគុណភាព និងភាពថ្លៃថ្នូរនៃវិជ្ជាជីវៈ**” ដែលជាប្រធានបទនៃមហាសន្និបាតគណៈមេធាវីលើកទី ១៩ កាលពីឆ្នាំ២០១៤ កន្លងទៅនេះ សូមសមាជិក-សមាជិកាគណៈមេធាវីទាំងអស់លុបបំបាត់នូវសកម្មភាពអវិជ្ជមាន និងសកម្មភាពដែលខុសឆ្គងផ្សេងៗទៀត និងអនុវត្តតាមការណែនាំខាងលើ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងគណៈមេធាវី ព្រមទាំងច្បាប់និងបទប្បញ្ញត្តិជាធរមាន ឱ្យបានខ្ជាប់ខ្ជួន។ គណៈមេធាវីនឹងចាត់វិធានការចំពោះសមាជិក-សមាជិការូបណាដែលបង្កការលំបាកដល់គណៈមេធាវី និងមិនគោរពតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដោយមិនអត់អោនចំពោះអ្នកដែលប្រព្រឹត្តបំពានឡើយ។

សូមសមាជិក-សមាជិកាគណៈមេធាវី ទទួលនូវការរាប់អានដ៏ស្មោះស្ម័ត្រអំពីខ្ញុំ៕

ប្រធាន

មេធាវី.ប៊ួន-ហួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ឌួនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី ឃុន ផានិត
៨-មេធាវី ភៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ចំន្ទ ឥចិត្រ
១៨-មេធាវី ព្រាហ្ម ឥចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌីម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន គារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ថ្លៃ សំរស់
៣២-មេធាវី ឆួន ផានិត
៣៣-មេធាវី ឃុត កែវសុភ្ពា

លេខ : ០៩៧៩ /គម/២០

ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០២០

សេចក្តីណែនាំ
ស្តីពី
ការបំពេញបេសកកម្មជាអនុតំណាង

កន្លងមកនេះ គណៈមេធាវីបានទទួលព័ត៌មានពីតុលាការ និងសង្កេតឃើញថា មានមេធាវីមួយចំនួនបានទទួលការពឹងពាក់ ឬបានទទួលលិខិតផ្ទេរសិទ្ធិតំណាងដោយអាណត្តិពីអតិថិជន តែមិនបានទៅបំពេញបេសកកម្មដោយផ្ទាល់ បែរជាចាត់តាំងមេធាវីម្នាក់ទៀតឱ្យបំពេញបេសកកម្មនៅចំពោះមុខតុលាការជំនួសខ្លួន ដោយគ្មានការប្រគល់សិទ្ធិពីអតិថិជន។ ការធ្វើបែបនេះផ្ទុយពីបទប្បញ្ញត្តិមួយចំនួនដូចខាងក្រោម៖

-មាត្រា២នៃច្បាប់ស្តីពីលក្ខន្តិក:មេធាវី ដែលបានចែងថា *"មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី..."*

-មាត្រា២៣នៃក្រមសីលធម៌មេធាវី ដែលបានចែងថា*"ក្នុងគ្រប់រឿងអ្វីទាំងអស់ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិ ឬលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬពាក្យពឹងពាក់ពីអតិថិជនរបស់ខ្លួន។....."*

-មាត្រា៤៧នៃក្រមសីលធម៌មេធាវី ដែលបានចែងថា *"មេធាវីទទួលបេសកកម្មពីអតិថិជនអាចផ្ទេរបេសកកម្មនោះទាំងស្រុង ឬមួយភាគទៅឱ្យសហភាគាណាមួយធ្វើជាអនុតំណាងបានលុះត្រាតែការប្រគល់សិទ្ធិរបស់អតិថិជនផ្តល់ឱ្យមេធាវីដើម មានសិទ្ធិជ្រើសតាំងអនុតំណាងរបស់ខ្លួន។....."*។

ក្នុងករណីខាងលើនេះ គណៈមេធាវីសូមធ្វើការណែនាំដូចតទៅ៖

១.មេធាវីដែលទទួលបានការពឹងពាក់ឱ្យជួយការពារកូនក្តីក្នុងរឿងព្រហ្មទណ្ឌ ពុំអាចផ្ទេរសិទ្ធិការពារក្តីនេះឱ្យទៅមេធាវីម្នាក់ទៀតបានឡើយ លើកលែងតែមានការពឹងពាក់បន្ថែមពីអតិថិជន។

២.មេធាវីដែលទទួលបានការផ្ទេរសិទ្ធិឱ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌ ឬទទួលបានការផ្ទេរសិទ្ធិតំណាងដោយអាណត្តិក្នុងរឿង

រដ្ឋប្បវេណីពីអតិថិជនអាចប្រគល់សិទ្ធិឱ្យសហភាគាណាម្នាក់ បំពេញបេសកកម្មជាអនុតំណាងរបស់ខ្លួនបាន លុះត្រាតែនៅក្នុងលិខិតផ្ទេរសិទ្ធិទាំងនោះបានកំណត់អំពីសិទ្ធិជ្រើសតាំងអនុតំណាង។ ក្នុងករណីដែលនៅក្នុងលិខិតផ្ទេរសិទ្ធិពុំបានកំណត់អំពីសិទ្ធិជ្រើសតាំងអនុតំណាងទេ មេធាវីអាចប្រគល់សិទ្ធិឱ្យសហភាគាណាម្នាក់ បំពេញបេសកកម្មជាអនុតំណាងរបស់ខ្លួនបាន លុះត្រាតែមានលិខិតផ្សេងទៀតរបស់អតិថិជន ដែលបានប្រគល់សិទ្ធិឱ្យខ្លួនជ្រើសតាំងអនុតំណាង។

ក្រោយទទួលបាននូវសេចក្តីណែនាំនេះ សមាជិក-សមាជិកាគណៈមេធាវី និងមេធាវីដែលកំពុងធ្វើកម្មសិក្សាទាំងអស់ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់តាមភារកិច្ចរៀងៗខ្លួន ៕

ភ្នំពេញ

មេធាវី សួន-ឥសាល

ចម្លងជូន

-សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

-អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទគុណា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំន វណ្ណៈ
២-មេធាវី សួស សារឿន
៣-មេធាវី ទូច ឆីវន្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំន្ទសុជាតា
១០-មេធាវី លី ធិត្យឫទ្ធាមី
១១-មេធាវី ឃុន ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជៈ
១៤-មេធាវី អ៊ុច ភីរិយា
១៥-មេធាវី ឃិច សមិទ្ធិ
១៦-មេធាវី សេង ទូចប៊ុន
១៧-មេធាវី គីម ផល្លី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ូ ធីតារ៉ៅ
២០-មេធាវី ឆួន សុភា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ទិទ្យា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុភនួន
២៦-មេធាវី កែ ឆជាឥស្សរ
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុគារិទ្ធ
៣០-មេធាវី សួង សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

លេខ ១៧៦ /គម/២៣

ថ្ងៃ សុក្រ ១៤ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២៣

សេចក្តីណែនាំ
ស្តីពី
ការធ្វើកម្មសិក្សានិងការដាក់របាយការណ៍បញ្ចប់កម្មសិក្សា

កន្លងមក **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**ពិនិត្យឃើញថា មានកម្មសិក្សាការីមួយចំនួនពុំបានអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី(សេចក្តីសម្រេចលេខ១១៦) ដូចជាការដាក់ពាក្យសុំធ្វើកម្មសិក្សាហួសរយៈពេលកំណត់ ការដាក់របាយការណ៍បញ្ចប់កម្មសិក្សាហួសរយៈពេលកំណត់ ការរៀបចំរបាយការណ៍បញ្ចប់កម្មសិក្សាពុំបានត្រឹមត្រូវតាមទម្រង់និងខ្លឹមសារជាដើម។

ក្នុងគោលបំណងការពារតម្លៃនៃវិជ្ជាជីវៈមេធាវីនិងការត្រួតពិនិត្យឱ្យបានម៉ត់ចត់លើសមត្ថភាពរបស់កម្មសិក្សាការី គណៈមេធាវីសូមធ្វើការណែនាំដល់គ្រូកម្មសិក្សានិងកម្មសិក្សាការីទាំងអស់ដូចខាងក្រោម៖

១-កម្មសិក្សាការីត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សាក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីធ្វើសច្ចាប្រណិធាន ដោយបង្ហាញជូនគណៈមេធាវីឱ្យបានច្បាស់លាស់អំពីវិសមិតភាពជាមួយវិជ្ជាជីវៈមេធាវី។ ក្នុងករណីមានវិសមិតភាព កម្មសិក្សាការីត្រូវភ្ជាប់ជាមួយពាក្យសុំធ្វើកម្មសិក្សានូវឯកសារបញ្ជាក់ពីការលាឈប់ ឬឯកសារបញ្ជាក់ពីការអនុញ្ញាតឱ្យព្យួរការងារក្នុងរយៈពេលយ៉ាងតិច២(ពីរ)ឆ្នាំ។ បើបេក្ខជនពុំទាន់រកគ្រូកម្មសិក្សាបាន ឬពុំទាន់មានឯកសារបញ្ជាក់ពីការលាឈប់ ឬឯកសារបញ្ជាក់ពីការអនុញ្ញាតឱ្យព្យួរការងារ បេក្ខជនត្រូវដាក់ពាក្យសុំព្យួរកម្មសិក្សាក្នុងរយៈពេលមិនលើសពី២(ពីរ)ឆ្នាំ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីធ្វើសច្ចាប្រណិធាន។ ករណីបេក្ខជនពុំបានដាក់ពាក្យសុំធ្វើកម្មសិក្សា ឬសុំព្យួរកម្មសិក្សាក្នុងរយៈពេលកំណត់នេះ គណៈមេធាវីចាត់ទុកបេក្ខជនបោះបង់ការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីនឹងសម្រេចលុបចោលការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី។

២-ការធ្វើកម្មសិក្សាមានរយៈពេល ១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យធ្វើកម្មសិក្សា។ ក្នុងរយៈពេលធ្វើកម្មសិក្សានេះ គ្រូកម្មសិក្សានិងកម្មសិក្សាការីត្រូវអនុវត្តកាតព្វកិច្ចរៀងៗខ្លួនដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខៈ ១៥៨៧, ទូរស័ព្ទៈ ០២៣ ៦២២ ៧០៧០
Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

៣-គ្រូកម្មសិក្សាត្រូវចុះហត្ថលេខាអនុញ្ញាតឱ្យកម្មសិក្សាការីតំណាងដោយអាណត្តិ ឬការពារក្តី នៅលើលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិឬលិខិតពឹងពាក់មេធាវី។ ករណីអតិថិជនប្រគល់សិទ្ធិតំណាងដោយអាណត្តិឬពឹងពាក់ទាំងគ្រូទាំងកម្មសិក្សាការី នោះគ្រូនិងកម្មសិក្សាការីត្រូវចុះហត្ថលេខាទាំងអស់គ្នា ដោយពុំចាំបាច់គ្រូកម្មសិក្សាចុះហត្ថលេខាអនុញ្ញាតឱ្យកម្មសិក្សាការីតំណាងដោយអាណត្តិឬការពារក្តីបន្ថែមទៀតឡើយ។

៤-ក្នុងរយៈពេលធ្វើកម្មសិក្សា កម្មសិក្សាការីអាចដាក់ពាក្យមកគណៈមេធាវីស្នើសុំប្តូរគ្រូកម្មសិក្សាបាន លុះត្រាតែមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា គ្រូកម្មសិក្សាពុំអាចដឹកនាំការធ្វើកម្មសិក្សាបន្តទៀតបានដូចជា គ្រូបានទទួលមរណភាព គ្រូត្រូវបានហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈដោយទណ្ឌកម្មវិន័យ គ្រូត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ មូលហេតុប្រធានស័ក្តដាដើម ឬបានធ្វើកម្មសិក្សាជាមួយគ្រូកម្មសិក្សាចាស់បានរយៈពេលយ៉ាងតិច៦(ប្រាំមួយ)ខែ។

៥-នៅពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការីត្រូវរៀបចំរបាយការណ៍បញ្ចប់កម្មសិក្សាចំនួន៥(ប្រាំ)ច្បាប់ដោយភ្ជាប់មកជាមួយរបាយការណ៍ជាទម្រង់អេឡិចត្រូនិច(PDF)។ បើកម្មសិក្សាការីមិនអាចរៀបចំរបាយការណ៍ទាន់ពេលកំណត់ ឬពុំទាន់មានឯកសារគ្រប់ចំនួនតាមការកំណត់ក្នុងសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី កម្មសិក្សាការីត្រូវដាក់ពាក្យសុំពន្យារពេលដាក់របាយការណ៍បញ្ចប់កម្មសិក្សាក្នុងរយៈពេលមិនលើសពី៦ខែម្តង មកគណៈមេធាវីក្នុងរយៈពេលមិនលើសពី២(ពីរ)ខែ គិតចាប់ពីថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ដោយមានហត្ថលេខាឯកភាពពីគ្រូកម្មសិក្សា។ បើកម្មសិក្សាការីពុំបានដាក់ដាក់របាយការណ៍បញ្ចប់កម្មសិក្សា ឬមិនបានដាក់ពាក្យសុំពន្យារពេលដាក់របាយការណ៍បញ្ចប់កម្មសិក្សា ក្នុងរយៈពេលកំណត់នេះ គណៈមេធាវីចាត់ទុកបេក្ខជនបោះបង់ការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីនឹងសម្រេចលុបឈ្មោះកម្មសិក្សាការីចេញពីបញ្ជីមេធាវីកម្មសិក្សា។

៦-របាយការណ៍ការបញ្ចប់កម្មសិក្សាត្រូវមានខ្លឹមសារដូចខាងក្រោម៖

១. ទម្រង់

របាយការណ៍ត្រូវមាន៖

- កំរាស់យ៉ាងច្រើនចំនួន ២០(ម្ភៃ)ទំព័រ ដោយមានរឹមខាងលើទំហំ ២០ (ម្ភៃ)មីលីម៉ែត្រ និងខាងក្រោមទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ។ ចំពោះរឹមខាងស្តាំមានទំហំ ១៥ (ដប់ប្រាំ)មីលីម៉ែត្រ និងខាងឆ្វេងទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ
- សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

២. ចំនួនរឿងក្តី

កម្មសិក្សាការីត្រូវបំពេញកិច្ចការពារក្តីនិងតំណាងដោយអាណត្តិដូចខាងក្រោម៖

- រឿងក្តីព្រហ្មទណ្ឌចំនួន៣(បី)យ៉ាងតិច
- រឿងក្តីរដ្ឋប្បវេណីចំនួន៣(បី)យ៉ាងតិច
- ការពិគ្រោះយោបល់ច្បាប់ចំនួន៥(ប្រាំ)ករណីយ៉ាងតិច ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់ដូចជាកិច្ចសន្យា ឬឯកសារបញ្ជាក់ពីការពិគ្រោះយោបល់។

៣. ខ្លឹមសារ

- ត្រូវសង្ខេបកិច្ចការដែលខ្លួនបានបំពេញក្នុងរយៈពេលធ្វើកម្មសិក្សា
- ត្រូវលើកយករឿងក្តីព្រហ្មទណ្ឌ១(មួយ)ករណី ដែលការពារសិទ្ធិឱ្យជនជាប់ចោទនៅដំណាក់កាលជំនុំជម្រះ និងរឿងក្តីរដ្ឋប្បវេណី១(មួយ)ករណី ដែលខ្លួនបានបញ្ចប់ការការពារនិងតំណាងដោយ

អាណត្តិមកបង្ហាញ (អាចលើកយកសំណុំរឿងរក្សាការពារឬសំណុំរឿងអនុវត្តដោយបង្ខំមកបង្ហាញបានដែរ)

- ត្រូវបង្ហាញសមត្ថភាពក្នុងការការពារក្តីក្នុងរឿងនោះ ដោយផ្តល់យុទ្ធសាស្ត្រសម្រាប់ការការពាររឿងក្តីរួមមានអង្គហេតុសង្ខេប ចំណុចខ្សោយរបស់កូនក្តី ចំណុចខ្លាំងរបស់កូនក្តី ទ្រឹស្តីការពារ សេចក្តីសន្និដ្ឋានឬសេចក្តីថ្លែងការណ៍ និងលទ្ធផលនៃការការពារឬតំណាងដោយអាណត្តិ
- ត្រូវមានឯកសារយោងភ្ជាប់មកជាមួយចំពោះរឿងក្តីទាំងពីរ ដែលបានលើកមកបង្ហាញនៅក្នុងរបាយការណ៍។ ចំពោះរឿងក្តីផ្សេងទៀតត្រូវដាក់ក្នុងលេខយោងនៅចុងទំព័រ។

៧-គ្រូកម្មសិក្សាត្រូវចូលរួមពិនិត្យរបាយការណ៍បញ្ចប់កម្មសិក្សា ដោយយកចិត្តទុកដាក់និងការទទួលខុសត្រូវខ្ពស់។

៨-ក្រៅពីចំណុចដែលបានណែនាំខាងលើ កម្មសិក្សាការីនិងគ្រូកម្មសិក្សាត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី និងសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីផងដែរ។

ក្រោយទទួលបាននូវសេចក្តីណែនាំនេះ គ្រូកម្មសិក្សានិងកម្មសិក្សាការីទាំងអស់ត្រូវអនុវត្តតាមការណែនាំខាងលើឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់តាមភារកិច្ចរៀងៗខ្លួន៕

ប្រធាន

មេធាវី ឈិ-ចំន្ទគុលា

ចម្លងជូន:
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

ប្រធានគណៈមេធាវី

មេធាវី លី ចំរើនគុណា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង ឥន្ទ្រា
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ឆួច ធីរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំរើនសុជាតា
១០-មេធាវី លី ធិត្យបូនាមី
១១-មេធាវី ប៉ុង ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្រៈ
១៤-មេធាវី អ៊ុច ភីរិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ភូចហ៊ុន
១៧-មេធាវី គីម ជលស៊ី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ុ ធីតារ៉ៅ
២០-មេធាវី ជួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ទិទ្យា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាវស្ស
២៧-មេធាវី កេត ចំរើនម៉ានិន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុភារិទ្ធ
៣០-មេធាវី សួន សុជល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ៨៣៧/គម/២៣

ថ្ងៃ ១៨ ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៣

សេចក្តីណែនាំ
ស្តីពី
ជំនួយការមេធាវី

កន្លងមក **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** ពិនិត្យឃើញថា ការកំណត់អំពីលក្ខខណ្ឌនៃការចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីនៅពុំទាន់ច្បាស់លាស់ នាំឱ្យមានការតវ៉ា យោបល់ និងសំណូមពរផ្សេងៗគ្នាពីសហភាគាលើការចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីនេះ។ លើសពីនេះ ក៏នៅមានជំនួយការមេធាវីមួយចំនួនតូចបានយកប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីនេះ ទៅប្រើខុសពីតួនាទីនិងការកិច្ចដែលមេធាវីបានប្រគល់ឱ្យ បណ្តាលឱ្យប៉ះពាល់ដល់កិត្តិយសរបស់មេធាវីនិងវិជ្ជាជីវៈមេធាវីទាំងមូល។

ក្នុងគោលបំណងការពារកិត្តិយសនិងតម្លៃនៃវិជ្ជាជីវៈមេធាវី និងដើម្បីឱ្យមានភាពច្បាស់លាស់ដល់ការអនុវត្ត គណៈមេធាវីសូមធ្វើការណែនាំដល់សហភាគាដែលស្នើសុំចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីនិងអគ្គលេខាធិការដ្ឋានគណៈមេធាវី ដូចតទៅ៖

១-លក្ខខណ្ឌនៃការស្នើសុំប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវី៖

- ត្រូវដាក់ពាក្យស្នើសុំដោយមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ។ មេធាវីសុំមិនប្រកបវិជ្ជាជីវៈ មេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី និងមេធាវីកម្មសិក្សាពុំមានសិទ្ធិស្នើសុំប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីឡើយ
- មេធាវីម្នាក់អាចសុំប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីបានយ៉ាងច្រើន៥នាក់
- ជំនួយការមេធាវីត្រូវមានសញ្ជាតិខ្មែរ
- ជំនួយការមេធាវីត្រូវតែជាបុគ្គលដែលកំពុងសិក្សាឬបានបញ្ចប់ថ្នាក់បរិញ្ញាបត្ររង ឬបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រឬផ្នែករដ្ឋបាលសាធារណៈ
- ត្រូវបង់ប្រាក់ចំនួន ២០(ម្ភៃ)ដុល្លារអាមេរិក
- ត្រូវភ្ជាប់មកជាមួយពាក្យសុំនូវប្រវត្តិរូបរបស់ជំនួយការ ពាក្យសុំធ្វើជាជំនួយការរបស់សាមីខ្លួន កិច្ចសន្យាការងារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដោយមានហត្ថលេខា ស្នាមមេដៃស្តាំ និងឈ្មោះរបស់សាមីខ្លួន និងរូបថតទំហំ ៤X៦ ចំនួន២សន្លឹក (ទម្រង់គំរូពាក្យសុំមាននៅក្នុងគេហទំព័រ bakc.org.kh របស់គណៈមេធាវី)។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរសព្ទ: ០២៣ ៦២២ ៧០៧០
Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

២-គណៈមេធាវីចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីឱ្យមេធាវីម្នាក់ៗដែលស្នើសុំ ពុំចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីឱ្យការិយាល័យវិជ្ជាជីវៈណាមួយឡើយ។ ការចេញប័ណ្ណសម្គាល់ខ្លួនជំនួយការមេធាវីឱ្យតែចំពោះមេធាវី ដើម្បីជួយសម្រួលដល់ការស្នើសុំរបស់មេធាវីដែលប្រកបវិជ្ជាជីវៈជាក្រុមមេធាវីឬនៅតាមការិយាល័យមេធាវី ហើយងាយស្រួលក្នុងការគ្រប់គ្រងនិងមានការទទួលខុសត្រូវច្បាស់លាស់។ គំរូប័ណ្ណសម្គាល់ខ្លួនជំនួយមេធាវីមានភ្ជាប់ជាមួយសេចក្តីណែនាំនេះ។

៣-ដើម្បីរក្សាបាននូវតម្លៃវិជ្ជាជីវៈមេធាវីនិងកិត្យានុភាពរបស់គណៈមេធាវី មេធាវីដែលជាក់ពាក្យស្នើសុំជំនួយការ ត្រូវត្រួតពិនិត្យនូវរាល់សកម្មភាពជំនួយការរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ ជៀសវាងការអនុវត្តសកម្មភាពណាដែលប៉ះពាល់ដល់តម្លៃវិជ្ជាជីវៈមេធាវី។ ក្នុងករណីជំនួយការមេធាវីណាម្នាក់ប្រព្រឹត្តអំពើដែលប៉ះពាល់ដល់តម្លៃវិជ្ជាជីវៈឬកិត្យានុភាពរបស់គណៈមេធាវី ឬអំពើផ្ទុយពីច្បាប់ មេធាវីដែលស្នើសុំជំនួយការនោះ ត្រូវទទួលខុសត្រូវចំពោះមុខគណៈមេធាវីនិងទទួលខុសត្រូវលើការខូចខាតដែលកើតចេញពីអំពើអនីត្យានុកូលរបស់ជំនួយការរូបនោះ។

ក្រោយពីទទួលបាននូវសេចក្តីណែនាំនេះ សមាជិក-សមាជិកាគណៈមេធាវីនិងអគ្គលេខាធិការដ្ឋានគណៈមេធាវី ត្រូវអនុវត្តតាមការណែនាំខាងលើឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់តាមការកិច្ចរៀងៗខ្លួន៕

ប្រធាន



មេធាវី លី ច័ន្ទសុលា

ចម្លងជូន:
-ក្រុមប្រឹក្សាគណៈមេធាវី
ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ចំនួតុលា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង វណ្ណៈ
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ទូច ចិន្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លីម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំនួសុជាតា
១០-មេធាវី លី ធិត្យបុនាមី
១១-មេធាវី ឃ៉ុន ប៊ុនណា
១២-មេធាវី ម៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជនៈ
១៤-មេធាវី អ៊ុក ភីរិយា
១៥-មេធាវី ឃិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ុ ធីតាពៅ
២០-មេធាវី ជួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ចិន្តា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាឥស្សរ
២៧-មេធាវី កេត ចំនួម៉ានីន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុគារិទ្ធ
៣០-មេធាវី សួន សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

លេខ ១៣៧៥/គម/២៣

ថ្ងៃ ១៤ ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែសីហា ឆ្នាំ២០២៣

សេចក្តីណែនាំ
ស្តីពី
ភាតព្វកិច្ចផ្តល់ព្រឹត្តិបត្រថ្កោលទោសដែលមានសុពលភាពនៅពេលដាក់ពាក្យសុំធ្វើកម្មសិក្សា ពាក្យសុំរួចផុតកម្មសិក្សា និងរបាយការណ៍បញ្ចប់កម្មសិក្សា

មាត្រា៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានតម្រូវលក្ខខណ្ឌរបស់បេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវីជាបុគ្គលដែលមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ។ ដើម្បីអនុវត្តតាមបញ្ញត្តិនេះឱ្យមានប្រសិទ្ធភាព **គណៈមេធាវី** សូមធ្វើការណែនាំដូចតទៅៈ

១-កម្មសិក្សាការីដែលដាក់ពាក្យសុំធ្វើកម្មសិក្សាត្រូវភ្ជាប់មកជាមួយនូវព្រឹត្តិបត្រថ្កោលទោសនៅមានសុពលភាព បន្ថែមលើឯកសារដែលបានតម្រូវក្នុងសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី។

២-បេក្ខជនដែលដាក់ពាក្យសុំរួចផុតកម្មសិក្សាត្រូវភ្ជាប់មកជាមួយនូវព្រឹត្តិបត្រថ្កោលទោសនៅមានសុពលភាព បន្ថែមលើឯកសារដែលបានតម្រូវក្នុងសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី។

៣-កម្មសិក្សាការីដែលដាក់របាយការណ៍បញ្ចប់កម្មសិក្សាត្រូវភ្ជាប់មកជាមួយនូវព្រឹត្តិបត្រថ្កោលទោសនៅមានសុពលភាព។

ក្រោយពីទទួលបាននូវសេចក្តីណែនាំនេះ អ្នកដាក់ពាក្យសុំនិងអគ្គលេខាធិការដ្ឋានគណៈមេធាវីត្រូវអនុវត្តតាមការណែនាំខាងលើឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់តាមភារកិច្ចរៀងៗខ្លួន។

ប្រធាន

មេធាវី លី ចំនួតុលា

ចម្លងជូនៈ
-ក្រុមប្រឹក្សាគណៈមេធាវី
ដើម្បីជ្រាប
-ឯកសារ-កាលប្បវត្តិ

សេចក្តីសម្រែចពាក់ព័ន្ធនឹង
ការលើកឧទ្ធរណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ទិសាល

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី ភុយ នាម
២-មេធាវី ឆេង បូផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ចូនគា
៦-មេធាវី ចេង ចេងហាប់
៧-មេធាវី ឃុន ជានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំន ទិចិត្រ
១៨-មេធាវី ព្រហ្ម ទិចិត្រសុគា
១៩-មេធាវី ណុប គុណឌុប
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគ៌ន្ធ
២៧-មេធាវី គាន គារ
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី រ៉ូ សំរស់
៣២-មេធាវី នួន ជានិត
៣៣-មេធាវី ឃុត កែវសុគ្គា

លេខ ៣៦៩ /សសគម/១៩

ថ្ងៃ សុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៩

សេចក្តីសម្រេច
ស្តីពី
ការកំណត់ប្រភេទអាវទ៉ាជាំងៈមេធាវី និងអាវសម្រាប់មេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យរបស់គណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ទិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៩។

ស ម្រ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងលើកស្ទួយតម្លៃ សេចក្តីថ្លៃថ្នូរ និងការគោរពវិជ្ជាជីវៈមេធាវី ព្រមទាំងលើកតម្កើងកិត្តិយសរបស់គណៈមេធាវី និងមេធាវីគ្រប់រូប តាមរយៈការជំរុញ និងលើកទឹកចិត្តឱ្យមានការគោរព និងឱ្យតម្លៃគ្នាទៅវិញទៅមកវាងមេធាវី និងមេធាវី ក្នុងការប្រកបវិជ្ជាជីវៈមេធាវី និងក្នុងពិធីជាផ្លូវការនានារបស់គណៈមេធាវី ។

ប្រការ ២.. គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់អំពីប្រភេទអាវសម្រាប់ពាក់ក្នុងពេលប្រកបវិជ្ជាជីវៈមេធាវី និងប្រភេទអាវសម្រាប់ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ។

ប្រការ ៣.. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះមេធាវីកម្មសិក្សា និងមេធាវី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ២

ប្រភេទអាវមេធាវី

ប្រការ ៤.. ប្រភេទអាវសម្រាប់មេធាវី

អាវសម្រាប់មេធាវីមានចំនួន ០៦(ប្រាំមួយ)ប្រភេទដូចខាងក្រោម៖

១-អាវសម្រាប់ប្រធានគណៈមេធាវី ។

២-អាវសម្រាប់អតីតប្រធានគណៈមេធាវី ។

៣-អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវី ។

៤-អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី ។

៥-អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ ឆ្នាំឡើងទៅ ។

៦-អាវវិជ្ជាជីវៈមេធាវី ។

ប្រការ ៥.. អាវសម្រាប់ប្រធានគណៈមេធាវី

អាវសម្រាប់ប្រធានគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណិខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមួលពណិខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណិមាសប្រវែង ៤ សម។ ហើយនៅចំកណ្តាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណិមាស និងមានអង្កត់ផ្ចិតប្រវែង ៨សម។ រូបសញ្ញាគណៈមេធាវីនេះស្ថិតនៅប្រវែង១៥សម គិតពីចំណុចកណ្តាលនៃបូលើស្មាចុះមកក្រោម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណិមាសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណិសទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណិមាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១0 សម។

ង-នៅជុំវិញកអាវមានក្បាច់ភ្ជីទេសពណិមាសដែលមានទទឹងប្រវែង ៤ សម។

ច-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណិមាស និងមានឆ្នូតសក្តិពណិមាសចំនួនបី ដាក់នៅពីលើភ្ជីទេសនោះ ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់ប្រធានគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ។

ប្រការ ៦.. អាវសម្រាប់អតីតប្រធានមេធាវី

អាវសម្រាប់អតីតប្រធានគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណិខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណិខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមួលពណិខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២0 សម មានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណិសប្រវែង ៤ សម

- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណិសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណិសទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណិមាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១0 សម។

ង-នៅជុំវិញកអាវមានក្បាច់ភ្ជីទេសពណិមាសដែលមានទទឹងប្រវែង ៤ សម។

ច-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណិមាស និងមានឆ្នូតសក្តិពណិមាសចំនួនបី ដាក់នៅពីលើភ្ជីទេសនោះ ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់អតីតប្រធានគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ។

ប្រការ ៧.. អាវសម្រាប់សមាជិកក្រុមប្រឹក្សាមេធាវី

អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណិខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ស្មាពណិខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណិខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម

-ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២0 សម មានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណិសប្រវែង ៤ សម។ ហើយនៅចំកណ្តាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណិមាស និងមានអង្កត់ផ្ចិតប្រវែង ៨សម។ រូបសញ្ញាគណៈមេធាវីនេះស្ថិតនៅប្រវែង១៥សម គិតពីចំណុចកណ្តាលនៃបូលើស្មាចុះមកក្រោម

- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណិសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណិសទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូច៧ចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណិមាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១0 សម។

ង-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណិមាស ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃសេចក្តីសម្រេចនេះ។

ប្រការ ៨.. អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាមេធាវី

អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណិខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ស្មានៅលើស្មាខាងឆ្វេងពណិខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណិខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២0 សម មានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណិសប្រវែង ៤ សម។ ហើយនៅចំកណ្តាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណិមាស និងមានអង្កត់ផ្ចិតប្រវែង ៨ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណិសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណិសទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ចត់ធំចំកណ្តាលមួយអមដោយផ្ចត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណិមាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១0 សម។

ង-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណិមាស ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃសេចក្តីសម្រេចនេះ។

ប្រការ ៩.. អាវសម្រាប់មេធាវីដែលបានចុះបញ្ជីគណៈមេធាវីចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំឡើង

អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ (ដប់ប្រាំ)ឆ្នាំឡើងទៅត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណិខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណិខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណិខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម

- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្ដត់ធំចំកណ្ដាលមួយអមដោយផ្ដត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹង ផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌មាសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្ដាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ដត់ធំចំកណ្ដាលមួយអមដោយផ្ដត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានឆ្នូតសក្ដិពណ៌មាសចំនួនបីសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ៥ សម ហើយក្នុងឆ្នូតសក្ដិនីមួយៗមានទទឹងប្រវែង ១,២ សម។

ង-នៅចុងដៃអាវទាំងសងខាងមានឆ្នូតសក្ដិពណ៌មាសចំនួនបី ដែលមានទទឹងប្រវែង ៥ សម ហើយក្នុងឆ្នូតសក្ដិនីមួយៗមានទទឹងប្រវែង ១,២ សម។

រូបភាពនៃអាវសម្រាប់មេធាវី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅមានភ្ជាប់ជាឧបសម្ព័ន្ធទី៥ នៃសេចក្ដីសម្រេចនេះ។

ប្រការ ១០.. អាវសម្រាប់មេធាវីដែលបានចុះបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សា

អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សាត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្ដាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្ដត់ធំចំកណ្ដាលមួយអមដោយផ្ដត់តូចៗចំនួនបីអមសងខាងនៅលើ ជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌សប្រវែង ៤ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម (រួមទាំងរំយោល) ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌សប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្ដាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ដត់ធំចំកណ្ដាលមួយអមដោយផ្ដត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្រណាត់រលោងពណ៌ខ្មៅសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១៥ សម

ង-នៅចុងដៃអាវទាំងសងខាងមានក្រណាត់រលោងពណ៌ខ្មៅ ដែលមានទទឹងប្រវែង ១៥ សម។

រូបភាពនៃអាវវិជ្ជាជីវៈមេធាវីនេះមានភ្ជាប់ជាឧបសម្ព័ន្ធទី៦ នៃសេចក្តីសម្រេចនេះ។

ជំពូកទី ៣
ការប្រើប្រាស់អាវមេធាវី

ប្រការ ១១.- ការប្រើប្រាស់អាវក្នុងពេលប្រកបវិជ្ជាជីវៈមេធាវី

ក្នុងពេលប្រកបវិជ្ជាជីវៈមេធាវីនៅចំពោះមុខសវនាការ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងនៅចំពោះមុខយុត្តាធិការគ្រប់ប្រភេទ មេធាវីគ្រប់រូប រួមទាំងប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវីដូចបានកំណត់ក្នុងប្រការ ១០ ខាងលើ លើកលែងតែមានប្រពៃណីផ្ទុយពីនេះ។

ប្រការ ១២.- ការប្រើប្រាស់អាវក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ប្រធានគណៈមេធាវីក្នុងតំណែងត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៥ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី អតីតប្រធានគណៈមេធាវីត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៦ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី សមាជិកក្រុមប្រឹក្សាគណៈមេធាវីក្នុងតំណែងត្រូវពាក់អាវដូចបានកំណត់ក្នុងប្រការ ៧ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវពាក់អាវដូចបានកំណត់ក្នុងប្រការ ៨ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ (ដប់ប្រាំ)ឆ្នាំឡើងទៅត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៩ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សាត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ១០ នៃសេចក្តីសម្រេចនេះ។

ជំពូកទី ៤
ទណ្ឌកម្មវិន័យ

ប្រការ ១៣.- ការដាក់ទណ្ឌកម្ម និង/ឬការផ្តន្ទាទោសចំពោះមេធាវី និងជនទូទៅ

បុគ្គលដែលខ្លួនពុំមានសិទ្ធិបានពាក់ជាសាធារណៈនូវអាវប្រភេទណាមួយដូចបានកំណត់ក្នុងប្រការ ៥ ប្រការ ៦ ប្រការ ៧ ប្រការ ៨ ប្រការ ៩ និងប្រការ ១០ នៃសេចក្តីសម្រេចនេះនឹងត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ឬត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ ១៤.- ការដាក់ទណ្ឌកម្មចំពោះមេធាវី

មេធាវីជាសមាជិកគណៈមេធាវី រួមទាំងមេធាវីកម្មសិក្សាណាម្នាក់ ដែលបានប្រើប្រាស់អាវមេធាវីផ្ទុយនឹងខ្លឹមសារដូចមានចែងក្នុងប្រការខាងលើនៃសេចក្តីសម្រេចនេះ ត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

ប្រការ ១៥.- ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៦.- ការអនុវត្ត

អគ្គលេខាធិការ និងសមាជិក សមាជិកាគណៈមេធាវី និងមេធាវីកម្មសិក្សាទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។


ប្រធាន

មេធាវី សួន ឥសាល

ចម្លងជូន
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ ១៦
-ឯកសារ-កាលប្បវត្តិ


ឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចលេខ ៣៦៩ /សសគម/១៩ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៩

អាវសម្រាប់ប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យទានរបស់គណៈមេធាវី




ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចលេខ ៣៧៩/សសគម/១៩ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩

អាវសម្រាប់អតីតប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យជាតិរបស់គណៈមេធាវី




ឧបសម្ព័ន្ធទី៣ នៃសេចក្តីសម្រេចលេខ៣៧៩ /សសគម/១៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យទានរបស់គណៈមេធាវី



ឧបសម្ព័ន្ធទី៤ នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យទានរបស់គណៈមេធាវី



ឧបសម្ព័ន្ធទី៥នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៩

អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យទានរបស់គណៈមេធាវី




① កអាវពណ៌ខ្មៅប្រវែង ៣.៥សម

② ក្រវ៉ាត់ក ខ្លីជាង រំយោលប្រវែង ១៥ ស.ម

③ដៃអាវសក្តិពណ៌មាសចំនួនបីប្រវែង ៥សម

④ រំយោលខ្លីជាង ដៃអាវប្រវែង ១២ សម

⑤ជាយអាវពណ៌មាសប្រវែង ៥សម



⑥ប្រវែង១៣សម

⑦ រំយោលពណ៌មាសប្រវែង ៤សម

⑧ ក្រវ៉ាត់ទម្លាក់ទៅខាងក្រោយប្រវែង ៦៥សម

⑨ បូមូលពណ៌ខ្មៅចំកណ្តាលប្រវែង ៥.៥សម

⑩ ប្រវែង ៤សម

⑪ ប្រវែង ២០សម





⑫ប្រវែង ៤សម

⑬ប្រវែង១៣សម

ឧបសម្ព័ន្ធទី៦ នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩

អាវធិជ្ញាជីវៈមេធាវី និងសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី តិចជាង១៥ឆ្នាំ និងមេធាវី កម្មសិក្សាពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី







ប្រធានគណៈមេធាវី

មេធាវី សួន ឥសាល

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម

២-មេធាវី ទេព បូផល

៣-មេធាវី ពេជ្រ សុរិយោ

៤-មេធាវី ជុំ សុវណ្ណាលី

៥-មេធាវី ង៉ា ចូនគា

៦-មេធាវី ចេង ប៉េងហាប់

៧-មេធាវី ឃុន ផានិត

៨-មេធាវី ចៅ ប៊ុនហួន

៩-មេធាវី រស់ ហុនឡុ:

១០-មេធាវី តែ ចំណាន

១១-មេធាវី ខូវ ចន្ថា

១២-មេធាវី ហុង គីមសួន

១៣-មេធាវី ឌុយ សុខសុលីដា

១៤-មេធាវី សួន ប៊ុនធឿន

១៥-មេធាវី កេង សុម៉ារគន់

១៦-មេធាវី ពិន វណ្ណៈ

១៧-មេធាវី ចំន្ទ ឥច្ចិត្រា

១៨-មេធាវី ហ្គួហ្គ ឥច្ចិត្រសុភា

១៩-មេធាវី ណុប គុណាថុល

២០-មេធាវី យឹម ថាវី

២១-មេធាវី ឌឹម ចៅសេង

២២-មេធាវី លី សុខឃ្មាយ

២៣-មេធាវី ស៊ុយ ឈុនហាក់

២៤-មេធាវី គង់ សំអុន

២៥-មេធាវី ហាក់ សៀកលី

២៦-មេធាវី គង់ សុភ័ក្ត្រ

២៧-មេធាវី គាន គារ

២៨-មេធាវី ហ៊ាង ហុង

២៩-មេធាវី ឈរ លីថៃ

៣០-មេធាវី ម៉ុម ពិសី

៣១-មេធាវី ថ្លៃ សំអេ

៣២-មេធាវី ទួន ផានិត

៣៣-មេធាវី ឃុត កែវសុត្ថា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ៧២៦ /សសគម/២០

ថ្ងៃ អង្គារ ១៣កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២០

សេចក្តីសម្រេច

ស្តីពី

អាវកិត្តិយសរបស់គណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឥសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០

ស ម្រ េ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងបង្កើតឱ្យមានអាវកិត្តិយសរបស់គណៈមេធាវី សម្រាប់ផ្តល់ជូនមេធាវី ដែលមានគុណបំណាច់ចំពោះគណៈមេធាវី តាមរយៈការចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយវិជ្ជាជីវៈមេធាវី និងការអភិវឌ្ឍធនធានរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

ប្រការ២ .. គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់អំពីលក្ខណៈនៃអាវកិត្តិយស លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់អាវកិត្តិយស និងការប្រើប្រាស់អាវកិត្តិយសរបស់គណៈមេធាវី ។

ប្រការ៣ .. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ២
ចំណាត់ថ្នាក់ និងលក្ខណៈនៃអាវកិត្តិយស

ប្រការ៤ .. ចំណាត់ថ្នាក់នៃអាវកិត្តិយសរបស់គណៈមេធាវី

អាវកិត្តិយសរបស់គណៈមេធាវីមាន៣(បី)ថ្នាក់គឺ៖

- ថ្នាក់លេខ១
- ថ្នាក់លេខ២
- ថ្នាក់លេខ៣ ។

ប្រការ៥ .. លក្ខណៈនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ១

អាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ១ ត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូប ដៃវែង មានពណ៌ខ្មៅ ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅឱនក្បាច់ភ្ញីទេសពណ៌មាស មានទទឹងប្រវែង ១០ សង់ទីម៉ែត្រ ទម្លាក់ចុះទៅមុខនិងទៅក្រោយ ដោយក្រវ៉ាត់ទម្លាក់មកមុខមានប្រវែង ៥០ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រនិងក្រវ៉ាត់ទម្លាក់ទៅក្រោយមានប្រវែង ៦៥ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់ នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រ ។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងមានប្រវែង ៣៥ សង់ទីម៉ែត្រ (ចាប់ពីកអាវមកក្រោម) ទទឹងផ្នែកខាងលើប្រវែង ៤ សង់ទីម៉ែត្រ ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សង់ទីម៉ែត្រ និងមានផ្ទៃត់ធំចំកណ្តាលមួយអមដោយផ្ទៃត់តូចៗចំនួន ៣ សងខាង ។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ញីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សង់ទីម៉ែត្រ ។

ង-នៅជុំវិញកអាវមានក្បាច់ភ្ញីទេសពណ៌មាសដែលមានទទឹងប្រវែង ៤ សង់ទីម៉ែត្រ ។

ច-នៅជើមដៃអាវ ប្រវែង ១០ សង់ទីម៉ែត្រចាប់ពីស្មាចុះមកក្រោមមានក្បាច់ភ្ញីទេសពណ៌មាសដែលមានទទឹងប្រវែង ៧ សង់ទីម៉ែត្រ ។

ឆ-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណ៌មាស និងមានឆ្នូតសក្តិពណ៌មាសចំនួនបីដាក់នៅពីលើភ្ជីទេសនោះ ដែលមានទទឹងប្រវែង ៧ សង់ទីម៉ែត្រ។

រូបភាពនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ១ មានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ។

ប្រការ៦ .. លក្ខណៈនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ២

អាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ២ ត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូប ដៃវែង មានពណ៌ខ្មៅ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅឱនក្បាច់ភ្ជីទេសពណ៌មាស មានទទឹងប្រវែង ១០ សង់ទីម៉ែត្រ ទម្លាក់ចុះទៅមុខនិងទៅក្រោយ ដោយក្រវ៉ាត់ទម្លាក់មកមុខមានប្រវែង ៥០ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រនិងក្រវ៉ាត់ទម្លាក់ទៅក្រោយមានប្រវែង ៦៥ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រ។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងមានប្រវែង ៣៥ សង់ទីម៉ែត្រ (ចាប់ពីកអាវមកក្រោម) ទទឹងផ្នែកខាងលើប្រវែង ៤ សង់ទីម៉ែត្រ ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សង់ទីម៉ែត្រ និងមានផ្ទត់ធំចំកណ្តាលមួយអមដោយផ្ទត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សង់ទីម៉ែត្រ។

ង-នៅជុំវិញកអាវមានក្បាច់ភ្ជីទេសពណ៌មាស ដែលមានទទឹងប្រវែង ៤ សង់ទីម៉ែត្រ។

ច-នៅដើមដៃអាវ ប្រវែង ១០ សង់ទីម៉ែត្រចាប់ពីស្មាចុះមកក្រោមមានឆ្នូតសក្តិពណ៌មាសចំនួនពីរ ដែលមានទទឹងប្រវែង ២ សង់ទីម៉ែត្រ។

ឆ-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណ៌មាស និងមានឆ្នូតសក្តិពណ៌មាសចំនួនបី ដាក់នៅពីលើភ្ជីទេសនោះ ដែលមានទទឹងប្រវែង ៧ សង់ទីម៉ែត្រ។

រូបភាពនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ២ មានភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ។

ប្រការ៧ .. លក្ខណៈនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ៣

អាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ៣ ត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូប ដៃវែង មានពណ៌ខ្មៅ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅឱនក្បាច់ភ្ជីទេសពណ៌មាស មានទទឹងប្រវែង ១០ សង់ទីម៉ែត្រ ទម្លាក់ចុះទៅមុខនិងទៅក្រោយ ដោយក្រវ៉ាត់ទម្លាក់មកមុខមានប្រវែង ៥០ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រនិងក្រវ៉ាត់

ទម្លាក់ទៅក្រោយមានប្រវែង ៦៥ សង់ទីម៉ែត្រ (រួមទាំងរំយោល) នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សង់ទីម៉ែត្រ។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងមានប្រវែង ៣៥ សង់ទីម៉ែត្រ (ចាប់ពីកអាវមកក្រោម) ទទឹងផ្នែកខាងលើប្រវែង ៤ សង់ទីម៉ែត្រ ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សង់ទីម៉ែត្រ និងមានផ្កត់ធំចំកណ្តាលមួយអមដោយផ្កត់តូច៧ចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ញីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១0 សង់ទីម៉ែត្រ។

ង-នៅជុំវិញកអាវមានក្បាច់ភ្ញីទេសពណ៌មាសដែលមានទទឹងប្រវែង ៤ សង់ទីម៉ែត្រ។

ច-នៅដើមដៃអាវ ប្រវែង ១0 សង់ទីម៉ែត្រចាប់ពីស្មាចុះមកក្រោមមានឆ្នូតសក្តិពណ៌មាសចំនួនមួយ ដែលមានទទឹងប្រវែង ២ សង់ទីម៉ែត្រ។

ឆ-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ញីទេសពណ៌មាស និងមានឆ្នូតសក្តិពណ៌មាសចំនួនបីដាក់នៅពីលើភ្ញីទេសនោះ ដែលមានទទឹងប្រវែង ៧ សង់ទីម៉ែត្រ។

រូបភាពនៃអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ៣ មានភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃសេចក្តីសម្រេចនេះ។

ជំពូកទី ៣

លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់អាវកិត្តិយស និងការប្រើប្រាស់អាវកិត្តិយស

ប្រការ៨ .. លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់អាវកិត្តិយស

លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់អាវកិត្តិយសរបស់គណៈមេធាវី ដល់មេធាវីណាមួយត្រូវគោរពតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក-ជាមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ខ-ពុំធ្លាប់ទទួលរងនូវទណ្ឌកម្មវិន័យ។

គ-ជាឥស្សរជនជាន់ខ្ពស់។

ឃ-មានគុណបំណាច់ធំធេងចំពោះគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៩ .. សមត្ថកិច្ចក្នុងការផ្តល់អាវកិត្តិយសរបស់គណៈមេធាវី

មេធាវីដែលត្រូវបានផ្តល់ជូននូវអាវកិត្តិយសរបស់គណៈមេធាវីត្រូវមានគុណសម្បត្តិ ដូចបានកំណត់ក្នុងប្រការ៨ ខាងលើ។

ការផ្តល់អាវកិត្តិយសរបស់គណៈមេធាវីជូនមេធាវីណាមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ១០ .. ការប្រើប្រាស់អាវកិត្តិយសរបស់គណៈមេធាវី

មេធាវីដែលបានទទួលអាវកិត្តិយសរបស់គណៈមេធាវី អាចពាក់អាវនេះបានតែក្នុងពិធីផ្លូវការ និងពិធីបុណ្យ របស់គណៈមេធាវីតែប៉ុណ្ណោះ។

ជំពូកទី ៤

ទណ្ឌកម្មវិន័យ

ប្រការ១១ .. ការដាក់ទណ្ឌកម្ម និង/ឬផ្តន្ទាទោសចំពោះមេធាវី និងជនឆ្លៀវ

បុគ្គលដែលពុំមានសិទ្ធិប្រើប្រាស់អាវកិត្តិយសរបស់គណៈមេធាវី ហើយបានប្រើប្រាស់អាវកិត្តិយសរបស់គណៈ-មេធាវីជាសាធារណៈ ត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី និង/ឬត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

ប្រការ១២ .. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ១៣ .. ការអនុវត្ត

អគ្គលេខាធិការគណៈមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធាន

មេធាវី សួន_ឥសាល

ចម្លងជូន

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ដូចប្រការ១៣
-ឯកសារ-កាលប្បវត្តិ

គំរូអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ១



គំរូអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ២



គំរូអាវកិត្តិយសរបស់គណៈមេធាវីថ្នាក់លេខ៣



ប្រធានគណៈមេធាវី

មេធាវី លី ចំន្ទគុណា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ទុច ឆិរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី ឆាង បញ្ញា
៩-មេធាវី ង៉ៅ ចំន្ទសុជាតា
១០-មេធាវី លី ធិត្យឫទ្ធាមី
១១-មេធាវី ឃ្លុន ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជនៈ
១៤-មេធាវី អ៊ុច ភីរិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ូ ធីតារ៉ៅ
២០-មេធាវី ធួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ឥន្ទ្រា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាឥស្សរ
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ គុណា
២៩-មេធាវី ហាក់ សុភារិទ្ធ
៣០-មេធាវី សួង សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ៥៥៧ /សសគម/២២

សេចក្តីសម្រេច

ស្តីពី

សុខុមាលភាពមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទគុណា** ជាប្រធានគណៈមេធាវី អាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សា គណៈមេធាវីអាណត្តិទី១០
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះ មានគោលបំណងក្នុងការជួយសម្រាលបន្ទុកហិរញ្ញវត្ថុ ការចូលរួមចំណែកទទួលខុសត្រូវដោយសហភាពភាព និងការយកចិត្តទុកដាក់របស់គណៈមេធាវីចំពោះមេធាវីដែលជួបការលំបាក រួមមាន មេធាវីមានវ័យចាស់ មេធាវីទទួលរងទុព្វលភាព មេធាវីលំហែមាតុភាព មេធាវីទទួលមរណភាព និងសហព័ទ្ធឬកូនរបស់មេធាវីដែលទទួលមរណភាព តាមរយៈមូលនិធិសុខុមាលភាពមេធាវី។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០

Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

ប្រការ២ .. គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់អំពីប្រភេទ បុគ្គលដែលមានសិទ្ធិទទួលបានតាវកាលិក នីតិវិធីនិងលក្ខខណ្ឌនៃការស្នើសុំតាវកាលិកសុខុមាលភាពមេធាវី និងការគ្រប់គ្រងនិងការបែងចែកមូលនិធិសុខុមាលភាពមេធាវី។

ប្រការ៣ .. និយមន័យ

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ មេធាវីសុំមិនប្រកបវិជ្ជាជីវៈ មេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី និងមេធាវីកម្មសិក្សា ព្រមទាំងសហព័ទ្ធនិងកូនរបស់មេធាវី។

ជំពូកទី២
ការគ្រប់គ្រងមូលនិធិសុខុមាលភាពមេធាវី

ប្រការ៤ .. ការបង្កើតគណៈកម្មការមូលនិធិសុខុមាលភាពមេធាវី

ត្រូវបានបង្កើត**គណៈកម្មការមូលនិធិសុខុមាលភាពមេធាវី** ដែលសរសេរជាអក្សរកាត់ថា "**គ.ម.ស.**" ដើម្បីគ្រប់គ្រងនិងបែងចែកមូលនិធិសុខុមាលភាពមេធាវី ប្រកបដោយប្រសិទ្ធភាព និរន្តរភាព សុក្រឹតភាព និងតម្លាភាព។

ប្រការ៥ .. សមាសភាពរបស់ គ.ម.ស.

គ.ម.ស.មានសមាសភាពដូចខាងក្រោម៖

១.ប្រធានគណៈមេធាវី	ជាប្រធាន
២.សមាជិកក្រុមប្រឹក្សាគណៈមេធាវី៣រូប ជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី	ជាសមាជិក
៣.អគ្គលេខាធិការគណៈមេធាវី	ជាសមាជិក
៤.ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ	ជាសមាជិក
៥.ប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល	ជាសមាជិក

សមាសភាពជាក់ស្តែងត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានគណៈមេធាវី។

ប្រការ៦ .. តួនាទីនិងភារកិច្ចរបស់ គ.ម.ស.

គ.ម.ស.មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងចំណូលនិងចំណាយនៃមូលនិធិសុខុមាលភាពមេធាវី
- រាយការណ៍អំពីចំណូល ចំណាយនៃមូលនិធិសុខុមាលភាពមេធាវី ជូនអង្គប្រជុំក្រុមប្រឹក្សាគណៈមេធាវីរៀងរាល់១ត្រីមាសម្តង
- ពិនិត្យនិងសម្រេចលើពាក្យស្នើសុំតាវកាលិកសុខុមាលភាពមេធាវី ក្រៅពីករណីមេធាវីទទួលមរណភាព
- រៀបចំផែនការយុទ្ធសាស្ត្រក្នុងការស្វែងរកមូលនិធិ

- រៀបចំផែនការនៃការប្រើប្រាស់មូលនិធិសម្រាប់ការវិនិយោគរកចំណូលបន្ថែម ដោយឆ្លងកាត់ការអនុម័តពីក្រុមប្រឹក្សាគណៈមេធាវី
- ផ្តល់ការលើកទឹកចិត្តចំពោះមេធាវី ការិយាល័យមេធាវី ក្រុមមេធាវី ក្រុមហ៊ុនមេធាវី ឬសប្បុរសជន ដែលបានស្ម័គ្រចិត្តក្នុងការចូលរួមចំណែកជាមួយមូលនិធិសុខុមាលភាពមេធាវី
- លើកសំណើជូនក្រុមប្រឹក្សាគណៈមេធាវី ដើម្បីពិនិត្យនិងវាយតម្លៃអំពីចំនួននៃ តារាងកាលិកសុខុមាលភាពមេធាវី ក្នុងករណីចាំបាច់
- លើកសំណើជូនក្រុមប្រឹក្សាគណៈមេធាវី ដើម្បីពិនិត្យនិងវាយតម្លៃពីចំនួនអប្បបរមានៃមូលនិធិដែលត្រូវបម្រុងទុក
- សិក្សាស្រាវជ្រាវលើពាក្យស្នើសុំនិងឯកសារផ្សេងៗ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវក្នុងករណីចាំបាច់។

ប្រការ៧ .. ដំណើរការកិច្ចប្រជុំរបស់ គ.ម.ស.

គ.ម.ស. ត្រូវប្រជុំតាមការអញ្ជើញនិងរបៀបវារៈដែលកំណត់ដោយប្រធាន **គ.ម.ស.**។

កិច្ចប្រជុំត្រូវដឹកនាំដោយប្រធាន **គ.ម.ស.**។ កិច្ចប្រជុំអាចដំណើរការបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិក **គ.ម.ស.** ទាំងអស់។

ប្រធាន **គ.ម.ស.** ត្រូវចាត់តាំងលេខាធិការកត់ត្រាមួយរូបសម្រាប់ធ្វើកំណត់ហេតុនៃរាល់កិច្ចប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំត្រូវមានចុះហត្ថលេខាដោយប្រធាន **គ.ម.ស.** ហើយត្រូវបញ្ជូនទៅសមាជិកក្នុងរយៈពេលសមស្របនិងតាមគ្រប់មធ្យោបាយ។

រាល់មតិយោបល់និងការពិភាក្សាក្នុងកិច្ចប្រជុំត្រូវរក្សាជាការសម្ងាត់។ សមាជិកដែលទម្លាយការសម្ងាត់ ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ ប្រធាន **គ.ម.ស.** អាចអញ្ជើញអ្នកជំនាញចូលរួមប្រជុំផ្តល់យោបល់បាន។

ការសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតយកសម្លេងភាគច្រើននៃសមាជិកវត្តមាន។

ជំពូកទី៣
ប្រភេទតារាងកាលិកសុខុមាលភាពមេធាវី

ប្រការ៨ .. ប្រភេទតារាងកាលិកសុខុមាលភាពមេធាវី

តារាងកាលិកសុខុមាលភាពមេធាវីមាន ៥(ប្រាំ)ប្រភេទដូចខាងក្រោម៖

-តារាងកាលិកសម្រាប់មេធាវីវ័យចាស់

-តារាងកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាព

-តារាងកាលិកសម្រាប់មេធាវីលំហែមាតុភាព

-តារាងកាលិកសម្រាប់មេធាវីទទួលមរណភាព

-តារាងកាលិកសម្រាប់សហព័ទ្ធនិងកូនរបស់មេធាវីដែលទទួលមរណភាព។

ជំពូកទី៤
បុគ្គលដែលមានសិទ្ធិ នីតិវិធី និងលក្ខខណ្ឌ
នៃការស្នើសុំតាវកាលិកសុខុមាលភាពមេធាវី

ប្រការ៩ .. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសម្រាប់មេធាវីវ័យចាស់

មេធាវីវ័យចាស់អាចទទួលបានតាវកាលិកសម្រាប់មេធាវីវ័យចាស់ ពីមូលនិធិសុខុមាលភាពមេធាវី លុះត្រាតែបំពេញបានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក.ជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ ឬមេធាវីសុំមិនប្រកបវិជ្ជាជីវៈ ឬមេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី។

ខ.ត្រូវមានអាយុចាប់ពី ៦៥(ហុកសិបប្រាំ)ឆ្នាំឡើងទៅ។

គ.ជាមេធាវីពេញសិទ្ធិយ៉ាងតិច ១០(ដប់)ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

ឃ.បានបង់ភាគទានគ្រប់ចំនួន គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

ង.មិនត្រូវទទួលទណ្ឌកម្មវិន័យដោយការលុបឈ្មោះ ឬហាមឃាត់ការប្រកបវិជ្ជាជីវៈរយៈពេល ១(មួយ)ឆ្នាំចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

ច.សាមីខ្លួនត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរមកគណៈមេធាវី។ សហព័ទ្ធ ឬកូនជានីតិជនអាចដាក់ពាក្យស្នើសុំជំនួសបាន ក្នុងករណីសាមីខ្លួនពុំអាចធ្វើពាក្យសុំដោយខ្លួនឯង ឬតាមសំណើរបស់ប្រធាន **គ.ម.ស**.។

ឆ.តាវកាលិកសម្រាប់មេធាវីវ័យចាស់ ត្រូវផ្តល់ជូនបានតែមួយលើកប៉ុណ្ណោះ។ ករណីមេធាវីមានវ័យចាស់ផង និងទទួលរងទុព្វលភាពផង អាចស្នើសុំតាវកាលិកទាំងពីរប្រភេទបាន។

ជ.ត្រូវឆ្លងកាត់ការប្រជុំពិនិត្យនិងសម្រេចដោយ **គ.ម.ស**.។

ប្រការ១០ .. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាព

មេធាវីទទួលរងទុព្វលភាព ដែលមានសភាពផ្លូវកាយឬផ្លូវស្មារតីថមថយនិងទ្រុឌទ្រោមដោយសារជំងឺប្រចាំកាយធ្ងន់ធ្ងរ មានជាអាទិ៍ ជំងឺមហារីក ជំងឺទឹកនោមផ្អែម ជំងឺលើសឈាម ជំងឺរលាកថ្លើម ការវះកាត់ និងជំងឺផ្សេងៗទៀតដែលអាចអន្តរាយដល់អាយុជីវិត ឬពិការជាអចិន្ត្រៃយ៍មួយចំហៀងខ្លួន ឬទាំងស្រុង ឬពិការដោយសារគ្រោះថ្នាក់ផ្សេងៗ ជាហេតុបណ្តាលឱ្យមេធាវីរូបនោះមិនអាចបំពេញការងារជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ អាចទទួលបានតាវកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាពពីមូលនិធិសុខុមាលភាពមេធាវី លុះត្រាតែបំពេញបានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក.ជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ ឬមេធាវីសុំមិនប្រកបវិជ្ជាជីវៈ ឬមេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី។

ខ.ជាមេធាវីពេញសិទ្ធិយ៉ាងតិច ១០(ដប់)ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

គ. បានបង់ភាគទានគ្រប់ចំនួន គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

ឃ.មិនត្រូវទទួលទណ្ឌកម្មវិន័យដោយការលុបឈ្មោះ ឬហាមឃាត់ការប្រកបវិជ្ជាជីវៈរយៈពេល ១(មួយ)ឆ្នាំចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យសុំ។

ង.សាមីខ្លួនត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរមកគណៈមេធាវី។ សហព័ទ្ធ ឬកូនជានីតិជនអាចដាក់ពាក្យស្នើសុំជំនួសបាន ក្នុងករណីសាមីខ្លួនពុំអាចធ្វើពាក្យសុំដោយខ្លួនឯង ឬតាមសំណើរបស់ប្រធាន **គ.ម.ស**.។

ច.ត្រូវមានឯកសារដែលបញ្ជាក់ពីទុព្វលភាព ចេញដោយវេជ្ជបណ្ឌិតជំនាញ។

ឆ.តារាកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាព ត្រូវផ្តល់ជូនបានតែមួយលើកប៉ុណ្ណោះ។ ករណីមេធាវីមានវិយចាស់ផង និងទទួលរងទុព្វលភាពផង អាចស្នើសុំតារាកាលិកទាំងពីរប្រភេទបាន។

ជ.ត្រូវឆ្លងកាត់ការប្រជុំពិនិត្យ និងសម្រេចដោយ **គ.ម.ស**.។

ប្រការ១១ .. លក្ខខណ្ឌដើម្បីទទួលបានតារាកាលិកសម្រាប់មេធាវីលំហែមាតុភាព

មេធាវីស្ត្រីដែលស្ថិតនៅមុនពេល ក្នុងអំឡុងពេល ឬក្រោយពេលសម្រាលកូន អាចទទួលបានតារាកាលិកសម្រាប់មេធាវីលំហែមាតុភាពពីមូលនិធិសុខុមាលភាពមេធាវី លុះត្រាតែបំពេញបានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក.ជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ ឬមេធាវីសុំមិនប្រកបវិជ្ជាជីវៈ ឬមេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី។

ខ. សាមីខ្លួនត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរមកគណៈមេធាវី។ សហព័ទ្ធ ឬកូនជានីតិជនអាចដាក់ពាក្យស្នើសុំជំនួសបាន ក្នុងករណីសាមីខ្លួនពុំអាចធ្វើពាក្យសុំដោយខ្លួនឯង ឬតាមសំណើរបស់ប្រធាន **គ.ម.ស**.។

គ. ត្រូវភ្ជាប់មកជាមួយពាក្យសុំនូវឯកសារអេកូសាស្ត្រ ឬលិខិតបញ្ជាក់កំណើតចេញដោយមន្ទីរពេទ្យ ឬសំបុត្រកំណើតកូន។

ឃ.ត្រូវឆ្លងកាត់ការប្រជុំពិនិត្យ និងសម្រេចដោយ **គ.ម.ស**.។

ប្រការ១២ .. លក្ខខណ្ឌដើម្បីទទួលបានតារាកាលិកសម្រាប់មេធាវីទទួលមរណភាព

មេធាវីដែលបានទទួលមរណភាព អាចទទួលបានតារាកាលិកសម្រាប់មេធាវីទទួលមរណភាពពីមូលនិធិសុខុមាលភាពមេធាវី លុះត្រាតែបំពេញបានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក.ជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ ឬមេធាវីសុំមិនប្រកបវិជ្ជាជីវៈ ឬមេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី ឬមេធាវីកម្មសិក្សា។

ខ.ត្រូវមានលិខិតមរណភាព។

គ.ត្រូវដាក់ពាក្យសុំក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ គិតពីថ្ងៃទទួលមរណភាព។

ឃ.ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ មកគណៈមេធាវី ដោយសហព័ទ្ធ ឬកូនជានីតិជន ឬញាតិលោហិតរបស់មេធាវីដែលបានទទួលមរណភាព ឬតាមសំណើរបស់ប្រធាន **គ.ម.ស**.។

ង.ត្រូវឆ្លងកាត់ការសម្រេចដោយប្រធាន **គ.ម.ស**.។

ក្នុងករណីមានវិវាទទាក់ទងនឹងសិទ្ធិវន្តរបស់មេធាវីដែលបានទទួលមរណភាព **គ.ម.ស.** អាចប្រគល់តាវកាលិកសម្រាប់មេធាវីទទួលមរណភាពឱ្យទៅសហព័ទ្ធដែលមានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬកូនដែលមានអាយុច្រើនជាងគេ ឬឪពុកម្តាយ។

ប្រការ១៣ .. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសម្រាប់សហព័ទ្ធនិងកូនរបស់មេធាវីដែលទទួលមរណភាព

មេធាវីដែលមានសហព័ទ្ធឬកូនទទួលមរណភាព អាចទទួលបានតាវកាលិកសម្រាប់សហព័ទ្ធនិងកូនរបស់មេធាវីដែលទទួលមរណភាព ពីមូលនិធិសុខុមាលភាពមេធាវី លុះត្រាតែបំពេញបានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក.ជាសហព័ទ្ធឬកូនរបស់មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ ឬមេធាវីសុំមិនប្រកបវិជ្ជាជីវៈ ឬមេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី។

ខ.ត្រូវមានលិខិតមរណភាព។

គ.ត្រូវមានសំបុត្រអាពាហ៍ពិពាហ៍ក្នុងករណីសហព័ទ្ធរបស់មេធាវីទទួលមរណភាព ឬសំបុត្រកំណើតឬសំបុត្រពេទ្យដែលមានឈ្មោះឪពុកឬម្តាយជាមេធាវី ក្នុងករណីកូនរបស់មេធាវីទទួលមរណភាព ។

ឃ.ត្រូវដាក់ពាក្យសុំក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ គិតពីថ្ងៃទទួលមរណភាព។

ង.ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរមកគណៈមេធាវី ដោយមេធាវីដែលមានសហព័ទ្ធឬមានកូនទទួលមរណភាព ឬតាមសំណើរបស់ប្រធាន **គ.ម.ស.**។

ច.ត្រូវឆ្លងកាត់ការសម្រេចដោយប្រធាន **គ.ម.ស.**។

ជំពូកទី៥
តាវកាលិកដែលត្រូវទទួលបាន

ប្រការ១៤ .. តាវកាលិកសម្រាប់មេធាវីវ័យចាស់

មេធាវីវ័យចាស់ដែលបានបំពេញលក្ខខណ្ឌតាមប្រការ៩ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបានតាវកាលិកសម្រាប់មេធាវីវ័យចាស់ពីមូលនិធិសុខុមាលភាពមេធាវីចំនួន ៥.000.000(ប្រាំលាន)រៀល។

ប្រការ១៥ .. តាវកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាព

មេធាវីទទួលរងទុព្វលភាពដែលបានបំពេញលក្ខខណ្ឌតាមប្រការ១០ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបានតាវកាលិកសម្រាប់មេធាវីទទួលរងទុព្វលភាពពីមូលនិធិសុខុមាលភាពមេធាវីចំនួន ៥.000.000 (ប្រាំលាន)រៀល។

ប្រការ១៦ .. តាវកាលិកសម្រាប់មេធាវីលំហែមាតុភាព

មេធាវីលំហែមាតុភាពដែលបានបំពេញលក្ខខណ្ឌតាមប្រការ១១ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបានតាវកាលិកសម្រាប់មេធាវីលំហែមាតុភាពពីមូលនិធិសុខុមាលភាពមេធាវីចំនួន ២.000.000(ពីរលាន) រៀល។

ប្រការ១៧ .. តាវកាលិកសម្រាប់មេធាវីទទួលមរណភាព

មេធាវីទទួលមរណភាពដែលបានបំពេញលក្ខខណ្ឌតាមប្រការ១២ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបានតាវកាលិកសម្រាប់មេធាវីទទួលមរណភាពពីមូលនិធិសុខុមាលភាពមេធាវីចំនួន ៤.000.000(បួនលាន)រៀល។

ប្រការ១៨ .. តាវកាលិកសម្រាប់សហព័ទ្ធឬកូនរបស់មេធាវីដែលទទួលមរណភាព

មេធាវីដែលមានសហព័ទ្ធឬកូនទទួលមរណភាព ហើយដែលបានបំពេញលក្ខខណ្ឌតាមប្រការ ១៣ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបានតាវកាលិកសម្រាប់សហព័ទ្ធឬកូនរបស់មេធាវីដែលទទួលមរណភាពពីមូលនិធិសុខុមាលភាពមេធាវីចំនួន ២.000.000(ពីរលាន)រៀល។

ជំពូកទី៦

ការកំណត់ចំនួនមូលនិធិអប្បបរមាត្រូវបម្រុងទុក និងប្រភពមូលនិធិសុខុមាលភាពមេធាវី

ប្រការ១៩ .. ការកំណត់ចំនួនអប្បបរមានៃមូលនិធិសុខុមាលភាពមេធាវី

នៅដើមឆ្នាំសារពើពន្ធនីមួយៗ ក្រុមប្រឹក្សាគណៈមេធាវីត្រូវកំណត់ចំនួនអប្បបរមានៃមូលនិធិសុខុមាលភាពមេធាវីដែលត្រូវបម្រុងទុក ដោយពិចារណាទៅលើសក្តានុពលនៃការស្នើសុំអត្ថប្រយោជន៍នៅក្នុងឆ្នាំកន្លងមក។

ជាដំបូង ចំនួនអប្បបរមានៃមូលនិធិសុខុមាលភាពមេធាវីដែលត្រូវបម្រុងទុកមានចំនួន ៨0.000.000(ប៉ែតសិបលាន)រៀល។

ប្រការ២0 .. ប្រភពមូលនិធិសុខុមាលភាពមេធាវី

ប្រភពនៃមូលនិធិសុខុមាលភាពមេធាវីមានដូចខាងក្រោម៖

១.កាត់យកប្រាក់ជាប្រាក់រៀលស្មើនឹង $២(ពីរដុល្លារអាមេរិក)ក្នុងមួយខែពីប្រាក់បង់ភាគទានរបស់សមាជិកគណៈមេធាវីម្នាក់ៗ

២.កាត់យកប្រាក់ជាប្រាក់រៀលស្មើនឹង $១៥0(មួយរយហាសិបដុល្លារអាមេរិក)ពីប្រាក់ដែលសមាជិកគណៈមេធាវីម្នាក់ៗបានបង់សម្រាប់ចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

៣.វិភាគទានតាមការស្ម័គ្រចិត្តរបស់មេធាវីម្នាក់ៗ របស់ការិយាល័យមេធាវី របស់ក្រុមមេធាវី ឬរបស់ក្រុមហ៊ុនមេធាវី

៤.ការឧបត្ថម្ភដោយសប្បុរសជន

៥.ការរៃអង្គាសមូលនិធិនាមហាសន្និបាតប្រចាំឆ្នាំ និងពិធីផ្សេងៗ។

ជំពូកទី៧
ទណ្ឌកម្ម

ប្រការ២១ .. ទណ្ឌកម្ម

មេធាវីដែលបានផ្តល់ព័ត៌មាននិងឯកសារមិនត្រឹមត្រូវ ដើម្បីទទួលបានតារាកាលិកពីមូលនិធិសុខុមាលភាពមេធាវីដោយចេតនាទុច្ចរិត ត្រូវទទួលទណ្ឌកម្មវិន័យពីក្រុមប្រឹក្សាគណៈមេធាវី ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៨
អវសានប្បញ្ញត្តិ

ប្រការ២២ .. និរាករណ៍

សេចក្តីសម្រេចលេខ១០០/សសគម/១៧ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីគោលនយោបាយមូលនិធិសុខុមាលភាពមេធាវី និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ២៣ .. ការអនុវត្ត

សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែសីហា ឆ្នាំ២០២២

ប្រធានគណៈមេធាវី



មេធាវី លី ចំណុល

ចម្លងជូន៖
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

លេខ ៨៦១ /សសគម/២២

ប្រធានគណៈមេធាវី
មេធាវី លី ចំន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ឥណ្ណៈ
២-មេធាវី សួស សាម៉ឿន
៣-មេធាវី ទូច ចិរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម ទាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ចំន្ទសុជាតា
១០-មេធាវី លី ធិត្យបុនាមី
១១-មេធាវី ឃ្លុន ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជនៈ
១៤-មេធាវី អ៊ុំង គីរីយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា គាវ៉ា
១៩-មេធាវី អ៊ុ ធីតាពៅ
២០-មេធាវី ចួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន ទិទ្យា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុកន្ធន
២៦-មេធាវី កែ ឆជាផស្សរ
២៧-មេធាវី កេត ចំន្ទម៉ានីន
២៨-មេធាវី ខៀវ តុលា
២៩-មេធាវី ហាក់ សុគារិទ្ធ
៣០-មេធាវី សួន សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

សេចក្តីសម្រេច
ស្តីពី
គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុ នៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ចំន្ទតុលា** ជាប្រធានគណៈមេធាវី អាណត្តិទី១៣
- បានឃើញកំណត់ហេតុ នៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សា គណៈមេធាវីអាណត្តិទី១០
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះ មានគោលបំណងបង្កើតគ្រឿងកិត្តិយសរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ផ្តល់ជូនសមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងឥស្សរជន ដែលមានស្នាដៃ គុណបំណាច់ និងកក្តីកាពចំពោះគណៈមេធាវី វិជ្ជាជីវៈមេធាវី និងយុត្តិធម៌សង្គម ដើម្បីជាការថ្លែងអំណរគុណ ជំរុញលើកទឹកចិត្ត លើកកម្ពស់ និងពង្រឹងសមត្ថភាពមេធាវី ដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី។

អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរសព្ទ: ០២៣ ៦២២ ៧០៧០
Building at Corner of Street 1129 and 1930. Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / website: www.bakc.org.kh

ប្រការ២ .. គោលដៅ

សេចក្តីសម្រេចនេះ មានគោលដៅកំណត់ប្រភេទ បែបបទ និងលក្ខខណ្ឌក្នុងការផ្តល់គ្រឿងកិត្តិយសដល់សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងឥស្សរជន។

ប្រការ៣ .. វិសាលភាព

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះ មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ មេធាវីពេញសិទ្ធិសុំមិនប្រកបវិជ្ជាជីវៈ មេធាវីសុំនៅក្រៅបញ្ជីគណៈមេធាវី មេធាវីកម្មសិក្សា និងឥស្សរជន។

សេចក្តីសម្រេចនេះ អនុវត្តចំពោះមេធាវីដែលទទួលមរណភាពផងដែរ។

ប្រការ៤ .. និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងសេចក្តីសម្រេចនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

គ្រឿងកិត្តិយស សំដៅដល់ គ្រឿងកិត្តិយសគ្រប់ប្រភេទនៃសេចក្តីសម្រេចនេះ ដែលមានសណ្ឋាន ទំហំ ពណ៌ និងរចនាបថ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ។

ឥស្សរជន សំដៅដល់ ឥស្សរជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច១៥ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ដូចជា មន្ត្រីជាន់ខ្ពស់និងសមាជិកនៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ឬជាឥស្សរជនជាន់ខ្ពស់បរទេស ឬជាថ្នាក់ដឹកនាំស្ថាប័នមេធាវីបរទេស ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងវិស័យយុត្តិធម៌។

ស្នាដៃនានុវត្តន៍ សំដៅដល់ ស្នាដៃទាំងឡាយដែលបាននាំមកនូវអ្វីដែលថ្មី ឬប្រសើរជាងមុនបន្ថែមទៅលើស្នាដៃដែលមានរួចជាស្រេចណាមួយ ឬជាស្នាដៃថ្មីឯករាជ្យដាច់ដោយឡែកណាមួយ ពាក់ព័ន្ធនឹងវិស័យយុត្តិធម៌។

មនសិការវិជ្ជាជីវៈ សំដៅដល់ ការយកចិត្តទុកដាក់ ទឹកចិត្តស្រឡាញ់ និងមានឆន្ទៈចង់បំពេញការងារបស់ខ្លួនឱ្យបានល្អប្រសើរ។

អភិបាលកិច្ចល្អ សំដៅដល់ កិច្ចការដឹកនាំដែលគោរពតាមគោលការណ៍ដែលបានដាក់ចេញប្រកបដោយការយកចិត្តទុកដាក់ តម្លាភាព ការចូលរួម ការឆ្លើយតប ការដោះស្រាយ និងការគ្រប់គ្រងរដ្ឋបាល។

សភាវធម៌ សំដៅដល់ ក្រឹត្យក្រម ច្បាប់វិន័យអប់រំ ដើម្បីឱ្យមនុស្សមានដំណើរជាមនុស្សល្អប្រសើរ។ សភាវធម៌ត្រូវបានបែងចែកសាខាជាបី៖

- សុជីវធម៌៖ ការប្រព្រឹត្តកិរិយាសមសួនក្នុងការរស់នៅនិងប្រាស្រ័យទាក់ទង
- សីលធម៌៖ ការវៀរចាកអំពើបាប អំពើអាក្រក់ទាំងឡាយ
- គុណធម៌៖ ដំណើរការប្រព្រឹត្តអំពើល្អចំពោះគ្រួសារ ការងារ និងសង្គមជាតិ។

ព្រហ្មវិហារធម៌ សំដៅដល់ ចិត្តសណ្តោសប្រោសប្រណី ឬចិត្តដ៏ល្អប្រសើរ។ ព្រហ្មវិហារធម៌គឺធម៌ទាំងបួនមាន៖

- មេត្តា៖ សេចក្តីស្រឡាញ់រាប់អាន
- ករុណា៖ សេចក្តីអាណិតអាសូរ
- មុទិតា៖ សេចក្តីត្រេកអរដែលបានសុខចម្រើន
- ឧបេក្ខា៖ សេចក្តីស្មោះស្មើ ស្មោះឥតល្អៀង។

សច្ចធម៌ សំដៅដល់ សេចក្តីទៀងត្រង់ ភាពពិតប្រាកដ ជាក់ស្តែង មិនក្លែងក្លាយ។

បទវិន័យ សំដៅដល់ ទណ្ឌកម្មដែលដាក់ចំពោះមេធាវីណាម្នាក់ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ជំពូកទី២
ប្រភេទគ្រឿងកិត្តិយស

ប្រការ៥ .. ប្រភេទគ្រឿងកិត្តិយស

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់និងបែងចែកជា៥(ប្រាំ)ប្រភេទដូចខាងក្រោម៖

១.គ្រឿងកិត្តិយសឧត្តមភាព៖ គ្រឿងកិត្តិយសប្រភេទនេះ ត្រូវបានបំពាក់និងផ្តល់ជូនដល់ប្រធានគណៈមេធាវី អតីតប្រធានគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី អតីតក្រុមប្រឹក្សាគណៈមេធាវី នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី អតីតនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឬឥស្សរជន ដើម្បីថ្លែងអំណរគុណចំពោះស្នាដៃលេចធ្លោ ឬអភិបាលកិច្ចល្អដែលជាឧត្តមប្រយោជន៍ដល់មេធាវី វិជ្ជាជីវៈមេធាវី និងគណៈមេធាវី។

២. គ្រឿងកិត្តិយសកក្តីភាព៖ គ្រឿងកិត្តិយសប្រភេទនេះ ត្រូវបានបំពាក់និងផ្តល់ជូនដល់មេធាវីដែលមានសមាជិកភាពច្រើនឆ្នាំនិងមានវ័យចំណាស់ ដើម្បីផ្តល់ជាកិត្តិយសនិងការគោរពក្នុងឋានៈជាវៀមច្បងក្នុងវិជ្ជាជីវៈមេធាវី។

៣. គ្រឿងកិត្តិយសសង្គហធម៌៖ គ្រឿងកិត្តិយសប្រភេទនេះ ត្រូវបានបំពាក់និងផ្តល់ជូនដល់មេធាវីដែលបានលះបង់ពេលវេលា កម្លាំងចិត្ត កម្លាំងកាយ និងថវិកាផ្ទាល់ខ្លួនក្នុងការរួមចំណែកដើម្បីលើកស្ទួយយុត្តិធម៌សង្គមដល់ជនក្រីក្រ ជនទន់ខ្សោយ ឬជនជាតិភាគតិច។

៤. គ្រឿងកិត្តិយសគុណវុឌ្ឍិ៖ គ្រឿងកិត្តិយសប្រភេទនេះ ត្រូវបានបំពាក់និងផ្តល់ជូនដល់មេធាវីដែលបានលះបង់ពេលវេលា កម្លាំងចិត្ត កម្លាំងកាយក្នុងការបណ្តុះបណ្តាល ការស្រាវជ្រាវ ការបោះពុម្ពនិងការផ្សព្វផ្សាយ ដែលជាផលប្រយោជន៍ក្នុងវិស័យយុត្តិធម៌និងវិជ្ជាជីវៈមេធាវី ឬមេធាវីដែលបានចូលរួមបរិច្ចាគថវិកាចំពោះកិច្ចការនិងសកម្មភាពនានារបស់គណៈមេធាវី។

៥. គ្រឿងកិត្តិយសអនុស្សរណ៍៖ គ្រឿងកិត្តិយសប្រភេទនេះ ត្រូវបានបំពាក់និងផ្តល់ជូនដល់មេធាវីដែលបានទទួលមរណភាព ដើម្បីជាការរំលឹកគុណនិងចងចាំទៅដល់វីរភាពការងារ ស្នាដៃ និងគុណបំណាច់ចំពោះវិជ្ជាជីវៈមេធាវី។

ជំពូកទី៣
លក្ខខណ្ឌនៃការទទួលនិងដកហូតគ្រឿងកិត្តិយស

ប្រការ៦ .. លក្ខខណ្ឌនៃការទទួលបានគ្រឿងកិត្តិយសឧត្តមភាព

មេធាវីដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសឧត្តមភាពត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ជាប្រធានគណៈមេធាវី អតីតប្រធានគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី អតីតក្រុមប្រឹក្សាគណៈមេធាវី នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឬអតីតនាយកមជ្ឈមណ្ឌល

បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
- មានអាយុយ៉ាងតិច ៤០ ឆ្នាំ
- ជាមេធាវីដែលបានប្រកបវិជ្ជាជីវៈយ៉ាងតិច ១០ ឆ្នាំ
- មានស្នាដៃលេចធ្លោឬអភិបាលកិច្ចល្អក្នុងវិស័យយុត្តិធម៌និងវិជ្ជាជីវៈមេធាវី
- មានសភាវធម៌ មនសិការវិជ្ជាជីវៈ ប្រកាន់ខ្ជាប់ក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈមេធាវី
- ពង្រឹងសាមគ្គីភាព ការពារផលប្រយោជន៍គណៈមេធាវី និងការពារយុត្តិធម៌សង្គម
- មានទំនាក់ទំនងល្អជាមួយសហភាគា
- ពុំធ្លាប់ទទួលទណ្ឌកម្មជាបទវិន័យឬទោសព្រហ្មទណ្ឌ។

ឥស្សរជនដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសឧត្តមភាពត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖
- ជាឥស្សរជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច១៥ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ដូចជា មន្ត្រីជាន់ខ្ពស់និងសមាជិកនៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ឬជាឥស្សរជនជាន់ខ្ពស់បរទេស ឬជាថ្នាក់ដឹកនាំស្ថាប័នមេធាវីបរទេស ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងវិស័យយុត្តិធម៌
- មានស្នាដៃលេចធ្លោឬអភិបាលកិច្ចល្អក្នុងវិស័យយុត្តិធម៌
- មានសភាវធម៌ មនសិការវិជ្ជាជីវៈ ប្រកាន់ខ្ជាប់ក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន
- ចូលរួមយ៉ាងសកម្មក្នុងការការពារយុត្តិធម៌សង្គម
- ពុំធ្លាប់ទទួលទណ្ឌកម្មរដ្ឋបាលឬទោសព្រហ្មទណ្ឌ។

ប្រការ៧ .. លក្ខខណ្ឌនៃការទទួលបានគ្រឿងកិត្តិយសកក្តីភាព

មេធាវីដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសកក្តីភាពត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖
- ជាមេធាវីដែលបានប្រកបវិជ្ជាជីវៈយ៉ាងតិច ១៥ ឆ្នាំ
- មានអាយុយ៉ាងតិច ៤៥ ឆ្នាំ
- មានសភាវធម៌ មនសិការវិជ្ជាជីវៈ ប្រកាន់ខ្ជាប់ក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈមេធាវី
- មានទំនាក់ទំនងល្អជាមួយសហភាគា
- ពុំធ្លាប់ទទួលទណ្ឌកម្មជាបទវិន័យឬទោសព្រហ្មទណ្ឌ។

ប្រការ៨ .. លក្ខខណ្ឌនៃការទទួលបានគ្រឿងកិត្តិយសសង្គហធម៌

មេធាវីដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសសង្គហធម៌ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖
- ជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ
- បានបំពេញកិច្ចការស្ម័គ្រចិត្តជួយការពារជនក្រីក្រយ៉ាងតិច ៥០ សំណុំរឿង ឬបានទទួលពិគ្រោះយោបល់ជូនជនក្រីក្រយ៉ាងតិច ១០០ ករណី តាមការចាត់តាំងដោយគណៈមេធាវី

- មានមនសិការវិជ្ជាជីវៈ ប្រកាន់ខ្ជាប់ក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈមេធាវី
- ប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ សច្ចធម៌ និងសភាវធម៌ខ្ពស់
- មានទំនាក់ទំនងល្អជាមួយសហភាគា
- ពុំធ្លាប់ទទួលទណ្ឌកម្មជាបទវិន័យ ឬទោសព្រហ្មទណ្ឌ។

ប្រការ៩ .. លក្ខខណ្ឌនៃការទទួលបានគ្រឿងកិត្តិយសគុណវុឌ្ឍិ

មេធាវីដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសគុណវុឌ្ឍិត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានស្ម័គ្រចិត្តក្នុងការបណ្តុះបណ្តាល ការបោះពុម្ព និងការផ្សព្វផ្សាយ ដែលជាផលប្រយោជន៍ក្នុងវិស័យយុត្តិធម៌និងវិជ្ជាជីវៈមេធាវីយ៉ាងតិច២០(ម្តៃ)លើក ឬបានបង្កើតស្នាដៃស្រាវជ្រាវប្រកបដោយភាពច្នៃប្រឌិតឬជាស្នាដៃនវានុវត្តន៍ដែលជាផលប្រយោជន៍ក្នុងវិស័យយុត្តិធម៌ ឬបានបរិច្ចាគថវិកាសម្រាប់កិច្ចការគណៈមេធាវីសរុបយ៉ាងតិច ១០០.០០០.០០០ (មួយរយលាន)រៀល
- មានសភាវធម៌ មនសិការវិជ្ជាជីវៈ ប្រកាន់ខ្ជាប់ក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈមេធាវី
- មានទំនាក់ទំនងល្អជាមួយសហភាគា
- ពុំធ្លាប់ទទួលទណ្ឌកម្មជាបទវិន័យឬទោសព្រហ្មទណ្ឌ។

ប្រការ១០ .. លក្ខខណ្ឌនៃការទទួលបានគ្រឿងកិត្តិយសអនុស្សរណ៍

មេធាវីដែលអាចទទួលការបំពាក់និងផ្តល់គ្រឿងកិត្តិយសអនុស្សរណ៍ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ជាមេធាវីដែលទទួលមរណភាព
- ជាមេធាវីដែលមានវីរភាពការងារ ស្នាដៃ និងគុណបំណាច់ចំពោះវិជ្ជាជីវៈមេធាវី
- ពុំធ្លាប់ទទួលទណ្ឌកម្មជាបទវិន័យឬទោសព្រហ្មទណ្ឌ។

ប្រការ១១ .. ការដកហូតគ្រឿងកិត្តិយស

គ្រឿងកិត្តិយសប្រភេទណាមួយដែលបានផ្តល់ជូន អាចត្រូវបានដកហូតមកវិញក្នុងករណីបុគ្គលដែលបានទទួលគ្រឿងកិត្តិយស បានប្រើប្រាស់គ្រឿងកិត្តិយសខុសពីខ្លឹមសារនៃសេចក្តីសម្រេចនេះ និងបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់តម្លៃនៃគ្រឿងកិត្តិយសនិងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវី។

ការចាត់វិធានដកហូតគ្រឿងកិត្តិយសណាមួយអាចផ្តួចផ្តើមដោយពាក្យបណ្តឹងពីតតិយជន ឬដោយគណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី និងត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

បុគ្គលដែលត្រូវបានសម្រេចដកហូតគ្រឿងកិត្តិយសត្រូវមានកាតព្វកិច្ចប្រគល់គ្រឿងកិត្តិយសត្រឡប់មកវិញ។

ជំពូកទី៤
ការគ្រប់គ្រងគ្រឿងកិត្តិយស

ប្រការ១២ .. គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី

ត្រូវបានបង្កើតគណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី ដើម្បីសិក្សា ត្រួតពិនិត្យ វាយតម្លៃ និង

លើកសំណើក្នុងការផ្តល់និងដកហូតគ្រឿងកិត្តិយសចំពោះមេធាវីឬឥស្សរជន ទៅក្រុមប្រឹក្សាគណៈមេធាវី ដើម្បីសម្រេច។

សមាសភាពនៃគណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវីមាន ៥ រូបដូចខាងក្រោម៖

- ប្រធានគណៈមេធាវី ប្រធាន
- សមាជិកក្រុមប្រឹក្សាគណៈមេធាវី ២ រូប សមាជិក
- អគ្គលេខាធិការគណៈមេធាវី សមាជិក
- ប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលគណៈមេធាវី សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី ត្រូវតែងតាំងដោយប្រធានគណៈមេធាវី។

ប្រការ១៣ .. តួនាទីនិងភារកិច្ចរបស់គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី

គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវីមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រចាំឆ្នាំ ដើម្បីកំណត់ចំនួននៃប្រភេទគ្រឿងកិត្តិយសនីមួយៗដែលត្រូវប្រគល់
- សិក្សា ពិនិត្យ និងវាយតម្លៃលើលក្ខខណ្ឌរបស់បុគ្គលដែលត្រូវទទួលគ្រឿងកិត្តិយស
- រៀបចំរបាយការណ៍វាយតម្លៃអំពីការបំពេញលក្ខខណ្ឌ និងប្រភេទគ្រឿងកិត្តិយស ដែលត្រូវផ្តល់ ដើម្បីដាក់ជូនទៅក្រុមប្រឹក្សាគណៈមេធាវីដើម្បីពិនិត្យនិងសម្រេច
- តាមដាន សិក្សា និងវាយតម្លៃលើករណីដកហូតគ្រឿងកិត្តិយសត្រឡប់មកវិញ
- លើកសំណើជូនក្រុមប្រឹក្សាគណៈមេធាវី ដើម្បីពិនិត្យនិងសម្រេចដកហូតគ្រឿងកិត្តិយសត្រឡប់មកវិញ
- បំពេញការកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានគណៈមេធាវី។

ប្រការ១៤ .. ដំណើរការកិច្ចប្រជុំរបស់គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវី

សមាជិកគណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវីត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងរបៀបវារៈដែលកំណត់ដោយប្រធានគណៈកម្មការ។

កិច្ចប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មការ។ កិច្ចប្រជុំអាចដំណើរការបានលុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងអស់។

ប្រធានគណៈកម្មការ ត្រូវចាត់តាំងលេខាធិការកត់ត្រាមួយរូបសម្រាប់ធ្វើកំណត់ហេតុនៃរាល់កិច្ចប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំត្រូវមានចុះហត្ថលេខាដោយប្រធានគណៈកម្មការ ហើយត្រូវបញ្ជូនទៅសមាជិកក្នុងរយៈពេលសមស្របនិងតាមគ្រប់មធ្យោបាយ។

រាល់មតិយោបល់និងការពិភាក្សាក្នុងកិច្ចប្រជុំត្រូវរក្សាជាការសម្ងាត់។ សមាជិកដែលទម្លាយការសម្ងាត់ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអាចអញ្ជើញអ្នកជំនាញចូលរួមប្រជុំផ្តល់យោបល់បាន។

ការសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតយកសម្លេងភាគច្រើននៃសមាជិកវត្តមាន។

ប្រការ១៥ .. គោលការណ៍ទូទៅ

គ្រឿងកិត្តិយសពុំអាចផ្តល់ជូនមេធាវីលើសពីមួយដងទៅលើប្រភេទគ្រឿងកិត្តិយសដូចគ្នា និងពុំអាច

ទទួលគ្រឿងកិត្តិយសពីរប្រភេទផ្សេងគ្នាក្នុងមួយឆ្នាំឡើយ។

ការសម្រេចផ្តល់ជូនគ្រឿងកិត្តិយសគ្រប់ប្រភេទប្រចាំឆ្នាំ មិនអាចឱ្យលើសពីចំនួន ៥%(ប្រាំភាគរយ) នៃចំនួនសមាជិក-សមាជិកាដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានឡើយ។

គ្រឿងកិត្តិយសដែលផ្តល់ជូនពុំអាចធ្វើការដោះដូរ ទិញលក់ ប្រទានកម្ម ផ្ទេរ ឬក៏ប្រើប្រាស់ក្នុងទម្រង់ណាមួយដែលប៉ះពាល់ដល់តម្លៃនៃគ្រឿងកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវីបានឡើយ។

បុគ្គលដែលបានទទួលគ្រឿងកិត្តិយស អាចប្រើប្រាស់គ្រឿងកិត្តិយស នៅក្នុងមហាសន្និបាតគណៈមេធាវី ពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ ពិធីផ្លូវការនានា ឬតាមការជូនដំណឹងរបស់គណៈមេធាវី ស្របតាមគោលការណ៍និងខ្លឹមសារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ។

ប្រការ១៦ .. នីតិវិធីនៃការផ្តល់និងបំពាក់គ្រឿងកិត្តិយស

គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវីអាចផ្តួចផ្តើមសិក្សា ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់គ្រឿងកិត្តិយសចំពោះមេធាវីឬឥស្សរជនណាមួយដោយខ្លួនឯងឬតាមសំណើរបស់សាមីខ្លួន។

គណៈកម្មការគ្រឿងកិត្តិយសគណៈមេធាវីត្រូវរៀបចំរបាយការណ៍វាយតម្លៃអំពីការបំពេញលក្ខខណ្ឌនិងប្រភេទគ្រឿងកិត្តិយសដែលត្រូវផ្តល់ ដាក់ជូនទៅក្រុមប្រឹក្សាគណៈមេធាវីដើម្បីពិនិត្យនិងសម្រេច។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ជាសេចក្តីសម្រេចបិទផ្លូវប្តឹងតវ៉ា។

ការបំពាក់គ្រឿងកិត្តិយសដល់មេធាវីឬឥស្សរជន ត្រូវធ្វើរួមគ្នានៅក្នុងមហាសន្និបាតគណៈមេធាវីប្រចាំឆ្នាំ ឬតាមកាលបរិច្ឆេទកំណត់ដោយប្រធានគណៈមេធាវី។ ចំពោះគ្រឿងកិត្តិយសអនុស្សរណ៍ត្រូវបំពាក់ជូនតាមកាលៈទេសៈជាក់ស្តែង។

គ្រឿងកិត្តិយសអាចត្រូវបានផ្តល់កិត្តិយសបំពាក់ជូនដោយប្រធានគណៈមេធាវី និង/ឬអតីតប្រធានគណៈមេធាវី។

ប្រការ១៧ .. ការខូចខាតនិងការបាត់បង់គ្រឿងកិត្តិយស

ក្នុងករណីដែលគ្រឿងកិត្តិយសដែលបានផ្តល់ជូនមានការខូចខាតឬបាត់បង់ បុគ្គលដែលបានទទួលគ្រឿងកិត្តិយសនោះ អាចដាក់ពាក្យស្នើសុំធ្វើគ្រឿងកិត្តិយសឡើងវិញ ដោយទទួលបន្ទុកលើការចំណាយដោយខ្លួនឯង។

ជំពូកទី៥
ទណ្ឌកម្ម

ប្រការ១៨ .. ទណ្ឌកម្ម

មេធាវីដែលប្រើប្រាស់ឬអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់គ្រឿងកិត្តិយសរបស់ខ្លួន ផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទទួលរងទណ្ឌកម្មជាបទវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

មេធាវីដែលត្រូវបានសម្រេចដកហូតគ្រឿងកិត្តិយស តែពុំបានប្រគល់ត្រឡប់មកវិញដូចបានកំណត់ក្នុងប្រការ១១ នៃសេចក្តីសម្រេចនេះ ត្រូវទទួលរងទណ្ឌកម្មជាបទវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ជនណាដែលគ្មានសិទ្ធិប្រើប្រាស់ឬលែងមានសិទ្ធិប្រើប្រាស់គ្រឿងកិត្តិយសប្រភេទណាមួយដែលមាន

កំណត់នៅក្នុងប្រការ៦ នៃសេចក្តីសម្រេចនេះ ត្រូវទទួលរងទណ្ឌកម្មជាបទវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ឬត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជំពូកទី៦
អវសានប្បញ្ញត្តិ

ប្រការ១៩ .. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២០ .. ការអនុវត្ត

សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២
ប្រ ធា ន



មេធាវី លី ច័ន្ទតុលា

ចម្លងជូន:
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

នៃសេចក្តីសម្រេចលេខ ៨៦១/សសគម/២២ ចុះថ្ងៃទី៣០ ខែ ៥ ឆ្នាំ២០២២

ស្តីពីគ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


អំពីសណ្ឋាន ទំហំ ពណ៌ និងរចនាបថ នៃគ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវបានបែងចែកជាប្រភេទខ្សែក និងប្រភេទខ្សែបូ លើកលែងតែគ្រឿងកិត្តិយសអនុស្សរណ៍ដែលមានតែប្រភេទខ្សែក។ តួសម្គាល់គ្រឿងកិត្តិយសផលិតឡើងពីលោហធាតុពណ៌មាស មាននិមិត្តសញ្ញាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅចំផ្នែកណាលសម្គាល់ដោយឈ្មោះរបស់គ្រឿងកិត្តិយសនីមួយៗ នៅផ្នែកខាងក្រោមនៃផ្នែរង្វង់ខាងក្រៅនិមិត្តសញ្ញា។ តួសម្គាល់គ្រឿងកិត្តិយស ប្រភេទខ្សែក និងប្រភេទខ្សែបូត្រូវថ្ពក់ភ្ជាប់ជាមួយក្រណាត់សំពត់ មានពណ៌ពងក្រសារនៅចំកណ្តាល(ពណ៌ទង់គណៈមេធាវី) អមសងខាងដោយឆ្នូតពណ៌ខៀវនិងពណ៌ក្រហម(ពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា)។

គ្រឿងកិត្តិយសនីមួយៗមានលក្ខណៈសម្គាល់ពិសេសផ្សេងៗពីគ្នាតាមរយៈសណ្ឋាន ទំហំ ពណ៌ និងរចនាបថ ស្របទៅតាមខ្លឹមសារ និងអត្ថន័យដូចខាងក្រោម៖

ក. គ្រឿងកិត្តិយសឧត្តមភាព

តួសម្គាល់ផ្នែកខាងក្នុងមានសរសេរពាក្យ "ឧត្តមភាព" និងកងរង្វង់ពីផ្នែខាងក្រៅនិមិត្តសញ្ញាគណៈមេធាវីជាពណ៌ក្រហម រចនាតុបតែងដោយក្បាច់អង្គរ ផ្សំដោយក្បាច់ថ្នាំងអំរៅត្របកឈូក ជាប្រាំបីស្រទាប់នៅព័ទ្ធជុំវិញនិមិត្តសញ្ញាគណៈមេធាវី និងបណ្តុះដោយកូនក្បាច់ផ្កាចន្ទន៍បណ្តែតលម្អអមជាមួយ ក្នុងទម្រង់ផ្កាចន្ទន៍មើលចំពីលើ។ *(រូបភាពទី១)*



រូបភាពទី១

ខ. គ្រឿងកិត្តិយសកក្តីភាព


តួសម្គាល់ផ្នែកខាងក្នុងមានសរសេរពាក្យ "កក្តីភាព" និងកងរង្វង់ពីផ្នែខាងក្រៅនិមិត្តសញ្ញាគណៈមេធាវី ជាពណ៌បៃតង រចនាតុបតែងដោយក្បាច់ភ្ញីវល្លិ ជាបួនសន្លឹកលម្អដោយក្បាច់មន្ទីពន្ធ មានស្លឹករុក្ខជាតិ និងផ្កាភ្ញីនៅព័ទ្ធជុំវិញនិមិត្តសញ្ញាគណៈមេធាវី ក្នុងទម្រង់ផ្កាឈូកមើលចំពីលើ។ *(រូបភាពទី២)*



រូបភាពទី២

គ. គ្រឿងកិត្តិយសសង្គហធម៌

តួសម្គាល់ផ្នែកខាងក្នុងមានសរសេរពាក្យ "សង្គហធម៌" និងកងរង្វង់ពីផ្នែខាងក្រៅនិមិត្តសញ្ញាគណៈមេធាវី ជាពណ៌ខៀវ រចនាតុបតែងដោយក្បាច់ភ្ញីទឹក លម្អដោយក្បាច់ពពុះទឹកលាយរលកនៅព័ទ្ធជុំវិញនិមិត្តសញ្ញាគណៈមេធាវី ក្នុងទម្រង់ត្របកឈូក មួយស្រទាប់ផ្កាប់មុខ។ *(រូបភាពទី៣)*



រូបភាពទី៣

ឃ. គ្រឿងកិត្តិយសគុណវុឌ្ឍិ


តួសម្គាល់ផ្នែកខាងក្នុងមានសរសេរពាក្យ "គុណវុឌ្ឍិ" និងកងរង្វង់ពីផ្នែខាងក្រៅនិមិត្តសញ្ញាគណៈមេធាវី ជាពណ៌លឿង រចនាតុបតែងដោយក្បាច់ភ្ញីទេស រចនាជាក្បាច់ហៀនទេសព័ទ្ធជុំវិញនិមិត្តសញ្ញាគណៈមេធាវី ក្នុងទម្រង់ស្លឹកពោធិ៍បញ្ឈរ។ *(រូបភាពទី៤)*



រូបភាពទី៤

ង. គ្រឿងកិត្តិយសអនុស្សរណ៍

តួសម្គាល់ផ្នែកខាងក្នុងមានសរសេរពាក្យ "អនុស្សរណ៍" និងកងរង្វង់ពីផ្នែខាងក្រៅនិមិត្តសញ្ញាគណៈមេធាវី ជាពណ៌ស្វាយ រចនាតុបតែងដោយក្បាច់ភ្ញីភ្លើង លម្អដោយសន្លឹកក្បាច់អង្គរបំបែកជាភ្ញីភ្លើង រលាស់ចុងរាងអណ្តាតភ្លើងនៅព័ទ្ធជុំវិញនិមិត្តសញ្ញាគណៈមេធាវី ក្នុងទម្រង់ត្របកឈូកមួយស្រទាប់ផ្តាប់មុខ។ *(រូបភាពទី៥)*



រូបភាពទី៥

ឧបសម្ព័ន្ធទី២

នៃសេចក្តីសម្រេចលេខ /សសគម/២២ ចុះថ្ងៃទី ខែ ឆ្នាំ២០២២

ស្តីពីគ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

អំពីការប្រើប្រាស់គ្រឿងកិត្តិយស

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប្រភេទខ្សែកនិងប្រភេទខ្សែបូ ត្រូវពាក់តាមការណែនាំដូចខាងក្រោម៖

ក. គ្រឿងកិត្តិយសប្រភេទខ្សែក

គ្រឿងកិត្តិយសប្រភេទខ្សែកទាំងអស់ ត្រូវពាក់នឹងក ជាមួយអាវិជ្ជាជីវៈមេធាវី ឬអាវសម្រាប់មេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យរបស់គណៈមេធាវី ឬអាវកិត្តិយសរបស់គណៈមេធាវី ហើយក៏អាចពាក់ជាមួយអាវធំ ឬអាវហូល(បុរស) ឬអាវប្រពៃណីខ្មែរ(នារី) ដោយត្រូវពាក់ខ្សែក្រណាត់សំពត់នៅលើកអាវ ទម្លាក់សំយុងតួសម្គាល់គ្រឿងកិត្តិយសមកត្រឹមដើមទ្រូងពីលើក្រវ៉ាត់ក ឬត្រឹមឡើវអាវទីពីរ។

ការបំពាក់គ្រឿងកិត្តិយសប្រភេទខ្សែកដល់មេធាវីឬឥស្សរជន ត្រូវធ្វើនៅក្នុងមហាសន្និបាតគណៈមេធាវីប្រចាំឆ្នាំ ឬតាមកាលបរិច្ឆេទកំណត់ដោយប្រធានគណៈមេធាវី។ ចំពោះគ្រឿងកិត្តិយសអនុស្សរណ៍ ត្រូវបំពាក់ជូនតាមកាលៈទេសៈជាក់ស្តែង។

ខ. គ្រឿងកិត្តិយសប្រភេទខ្សែបូ

គ្រឿងកិត្តិយសប្រភេទខ្សែបូទាំងអស់ ត្រូវពាក់ខ្ចាស់នៅផ្នែកខាងលើនៃបូខាងឆ្វេងនៃអាវិជ្ជាជីវៈមេធាវី ឬអាវសម្រាប់មេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យរបស់គណៈមេធាវី ឬអាវកិត្តិយសរបស់គណៈមេធាវី ហើយក៏អាចពាក់ខ្ចាស់នៅលើទ្រូងខាងឆ្វេងនៃអាវធំឬអាវហូល(បុរស) និងអាវប្រពៃណីខ្មែរ(នារី)។ គ្រឿងកិត្តិយសប្រភេទខ្សែបូដែលមានចាប់ពីពីរឡើងទៅ ត្រូវខ្ចាស់ជាប់បន្តស្មើគ្នាពីស្តាំមកឆ្វេង។

គ្រឿងកិត្តិយសប្រភេទខ្សែបូទាំងអស់ អាចប្រើប្រាស់នៅក្នុងមហាសន្និបាតគណៈមេធាវី ពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ ពិធីផ្លូវការនានា ឬតាមការជូនដំណឹងរបស់គណៈមេធាវី លើកលែងតែមានការណែនាំផ្សេងពីនេះ។

(ចន្លោះទំនេរនេះត្រូវបានទុកទទេចោលដោយចេតនា)

គំរូអាវវិជ្ជាជីវៈមេធាវី(បុរសនិងស្ត្រី)ជាមួយគ្រឿងកិត្តិយស



រូបភាពទី៦



រូបភាពទី៧

គំរូអាវធំ(បុរស)ជាមួយគ្រឿងកិត្តិយស



គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែក

រូបភាពទី៨



រូបភាពទី៩

គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែបូ

គំរូអាវហូល (បុរស)ជាមួយគ្រឿងកិត្តិយស



គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែក

រូបភាពទី១០



រូបភាពទី១១


គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែបូ

គំរូអាទិប្រពៃណីខ្មែរ(នារី)ជាមួយគ្រឿងកិត្តិយស



គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែក


រូបភាពទី១២



រូបភាពទី១៣

គ្រឿងកិត្តិយសឧត្តមភាព
ប្រភេទខ្សែបូ

ក.ប្រកាសនីយបត្រនៃគ្រឿងកិត្តិយសឧត្តមភាព



ប្រកាសនីយបត្រ

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់ជូន

មេធាវី ....អត្តលេខ....

គ្រឿងកិត្តិយស ឧត្តមភាព

របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ.....ខែ.....ឆ្នាំ..... .....ស័ក ព.ស.....


រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ.....

ប្រធាន

លេខ..../សសគម/..

ចុះបញ្ជីលេខ៖...

ខ.ប្រកាសនីយបត្រនៃគ្រឿងកិត្តិយសឥតក្តីភាព



ប្រកាសនីយបត្រ

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់ជូន

មេធាវី ..... អត្តលេខ....

គ្រឿងកិត្តិយស ឥក្តីភាព

របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ.....ខែ.....ឆ្នាំ..... .....សក ព.ស.....


រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ.....

ប្រធាន

លេខ...../សសគម/..

ចុះបញ្ជីលេខ៖...

គ. ប្រកាសនីយបត្រនៃគ្រឿងកិត្តិយសសង្គហធម៌



ប្រកាសនីយបត្រ

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់ជូន

មេធាវី ..... អត្តលេខ....

គ្រឿងកិត្តិយស សង្គហធម៌

របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ.....ខែ.....ឆ្នាំ..... .....សក ព.ស.....


រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ.....

ប្រធាន

លេខ...../សសគម/..

ចុះបញ្ជីលេខ៖...

ឃ.ប្រកាសនីយបត្រនៃគ្រឿងកិត្តិយសគុណវុឌ្ឍិ



ប្រកាសនីយបត្រ

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់ជូន

មេធាវី ..... អត្តលេខ....

គ្រឿងកិត្តិយស គុណវុឌ្ឍិ

របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ.....ខែ.....ឆ្នាំ..... .....ស័ក ព.ស.....


រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ.....

ប្រធាន

លេខ...../សសគម/..

ចុះបញ្ជីលេខ៖...

១.ប្រកាសនីយបត្រនៃគ្រឿងកិត្តិយសអនុស្សរណ៍



ប្រកាសនីយបត្រ

គ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់ជូន

មេធាវី ..... អត្តលេខ....

គ្រឿងកិត្តិយស អនុស្សរណ៍

របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ.....ខែ.....ឆ្នាំ..... .....សក ព.ស.....

រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ.....

ប្រធាន

លេខ..../សសគម/..

ចុះបញ្ជីលេខ៖...

សេចក្តីសម្រេចសម្រាប់
សិស្សមេធាវីអនុវត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី ង៉ា ឡូតា

២-មេធាវី កែវ ជា

៣-មេធាវី ហាក់ សៀកលី

៤-មេធាវី ចំន្ទ ទិចិត្រ

៥-មេធាវី ចេង ប៉េងហាប់

៦-មេធាវី ជូង ជូងី

៧-មេធាវី លី ចំន្ទគុណា

៨-មេធាវី តែ ចំណាន

៩-មេធាវី ទិត សុខាចា

១០-មេធាវី ពេជ្រ សុរិយោ

១១-មេធាវី គង់ ឥលីន

១២-មេធាវី ឃុត ផានិត

១៣-មេធាវី លឹម វណ្ណា

១៤-មេធាវី សុក ស៊ីផាន់ណា

១៥-មេធាវី ស្រ៊ុ គីមឃុ

១៦-មេធាវី កុយ នាម

១៧-មេធាវី ឡុច ធីរិទ្ធ

១៨-មេធាវី គីម ទាសនា

១៩-មេធាវី សួស សាម៉ឿន

២០-មេធាវី ឡូន មករា

២១-មេធាវី លឹម អេងតេន:

២២-មេធាវី ហុង គីមសួន

២៣-មេធាវី ឯក មាលា

២៤-មេធាវី ឆួង ជារ៉ា

២៥-មេធាវី សួង ចាន់ថន

២៦-មេធាវី ស សុខាន

២៧-មេធាវី ល្បើន ចិន្តា

លេខ :២៣៦/សសគម/១៤

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៤

សេចក្តីសម្រេច

ស្តីពី

ជាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងនៃ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិក:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

ស ម្រ េ ច

ត្រូវបានដាក់ឱ្យអនុវត្ត “**បទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី**” ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.- គោលដៅ

បទបញ្ជាផ្ទៃក្នុងនេះ មានគោលដៅធានាការបណ្តុះបណ្តាលសិស្សមេធាវី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី (ហៅកាត់ថា **ម.ប.វ.ម.**) ប្រកបដោយគុណភាព សមត្ថភាព ខាងជំនាញវិជ្ជាជីវៈមេធាវី ដើម្បីចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស ។

ប្រការ ២.- គោលបំណង

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងសំខាន់ៗដូចតទៅ៖

- កំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ **ម.ប.វ.ម.** ។
- លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងវិន័យរបស់ **ម.ប.វ.ម.** ។
- កំណត់អំពីទណ្ឌកម្ម និងបទវិន័យ ព្រមទាំងបែបបទនៃការសិក្សានៅក្នុង **ម.ប.វ.ម.** ។

ប្រការ ៣.- វិសាលភាព

បទបញ្ជាផ្ទៃក្នុងនេះ មានវិសាលភាពអនុវត្តទៅលើនាយក អគ្គលេខាធិការ និងមន្ត្រីរបស់ **ម.ប.វ.ម.** ព្រមទាំងសិស្សដែលសិក្សានៅក្នុង **ម.ប.វ.ម.** ។

ជំពូកទី ២

ការរៀបចំ និងការប្រព្រឹត្តទៅនៃ ម.ប.វ.ម.

ប្រការ ៤.- ការគ្រប់គ្រង និងការទទួលខុសត្រូវ

ម.ប.វ.ម. ត្រូវស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទៃកបច្ចេកទេសដោយផ្ទាល់ពីក្រុមប្រឹក្សាគណៈមេធាវី ។

ម.ប.វ.ម. ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងារ និងសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួនជូនប្រធានគណៈមេធាវី ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែម្តង ។

ប្រការ ៥.- រចនាសម្ព័ន្ធ

ម.ប.វ.ម. ត្រូវដឹកនាំដោយនាយកមួយរូប អមដោយអគ្គលេខាធិការមួយរូប ជាជំនួយការ ដែលត្រូវតែងតាំងផ្លាស់ប្តូរ ឬបញ្ឈប់ពីមុខងារ ដោយការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី តាមសំណើរបស់ប្រធានគណៈមេធាវី ។

ប្រការ ៦.- ការិយាល័យក្រោមឱវាទ

ម.ប.វ.ម. មានការិយាល័យក្រោមឱវាទចំនួន ៤ គឺ៖

- ការិយាល័យសិក្សា
- ការិយាល័យរដ្ឋបាល
- ការិយាល័យគណនេយ្យ និង
- មណ្ឌលច្បាប់ ។

ការបង្កើត ការលុបចោល ការកែប្រែឈ្មោះ ការិយាល័យក្រោមឱវាទត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈ-មេធាវី តាមសំណើរបស់ប្រធានគណៈមេធាវី តាមការស្នើសុំរបស់នាយក **ម.ប.វ.ម.** ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងមន្ត្រីមួយចំនួនជាជំនួយការ ដែលត្រូវតែងតាំង ផ្លាស់ប្តូរ ឬបញ្ឈប់ពីមុខងារ តាមការសម្រេចរបស់ប្រធានគណៈមេធាវី តាមសំណើរបស់នាយក **ម.ប.វ.ម.** ។

ប្រការ ៧.- តួនាទី និងភារកិច្ចរបស់នាយក ម.ប.វ.ម

នាយក **ម.ប.វ.ម.** មានតួនាទី ដឹកនាំ គ្រប់គ្រង និងធានាលើការប្រព្រឹត្តទៅនៅគ្រប់ផ្នែកនៃ **ម.ប.វ.ម.** ។

នាយក **ម.ប.វ.ម.** ជាតំណាងឱ្យ **ម.ប.វ.ម.** នៅចំពោះមុខតុលាការ និងគ្រប់ស្ថាប័នពាក់ព័ន្ធ ក្នុងការការពារផលប្រយោជន៍ ដោះស្រាយរាល់វិវាទទាំងឡាយរបស់ **ម.ប.វ.ម.** តាមការសម្រេចរបស់ប្រធានគណៈមេធាវី ។

ប្រការ ៨.- តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការ ម.ប.វ.ម.

អគ្គលេខាធិការ **ម.ប.វ.ម.** ជាសេនាធិការផ្ទាល់របស់នាយក **ម.ប.វ.ម.** លើគ្រប់សកម្មភាពការងារនៃ **ម.ប.វ.ម.** ។

ក្នុងករណីអវត្តមានរបស់នាយក **ម.ប.វ.ម.** អគ្គលេខាធិការអាចតំណាងឱ្យនាយកក្នុងការដឹកនាំ គ្រប់គ្រងសកម្មភាពការងារនៃ **ម.ប.វ.ម.** តាមខ្លឹមសារនៃលិខិតផ្ទេរសិទ្ធិរបស់នាយក **ម.ប.វ.ម.** ឬតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី ។ ករណីនេះ ត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាគណៈមេធាវី ។

ប្រការ ៩.- តួនាទី និងភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

ការិយាល័យក្រោមឱវាទរបស់ **ម.ប.វ.ម.** ត្រូវបំពេញការងារតាមជំនាញរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវចំពោះមុខនាយក **ម.ប.វ.ម.** ។

ជំពូកទី ៣
ការប្រឡងជ្រើសរើសឱ្យចូលរៀនវិជ្ជាជីវៈមេធាវី

ប្រការ ១០.- ចំនួនសិស្សមេធាវី និងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី

ចំនួនសិស្សមេធាវី ត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវីតាមសំណើរបស់ប្រធានគណៈមេធាវី បន្ទាប់ពីទទួលបានយោបល់ពីនាយក **ម.ប.វ.ម.** ។

នីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវីឱ្យចូលរៀននៅ **ម.ប.វ.ម.** ត្រូវអនុម័តដោយក្រុមប្រឹក្សាគណៈ-មេធាវី តាមសំណើរបស់ប្រធានគណៈមេធាវី តាមការស្នើសុំរបស់នាយក **ម.ប.វ.ម.** ។

ប្រការ ១១.- លក្ខខណ្ឌ

អនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ និង អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០០៨ បេក្ខជនប្រឡងចូលរៀនវិជ្ជាជីវៈមេធាវីត្រូវ៖

- មានសញ្ជាតិខ្មែរ
- មានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រច្បាប់ដែលប្រកាសថាមានតម្លៃសមមូល
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬបទវិន័យ ឬជាបទរដ្ឋបាល ដូចជាការលុបឈ្មោះ ការបញ្ឈប់ពីមុខងារ ការបាត់ងារអំពីអំពើផ្តុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ
- មិនធ្លាប់ក្ស័យធនផ្ទាល់ខ្លួន ដែលប្រកាសដោយតុលាការ
- ត្រូវមានសីលធម៌ និងកាយសម្បទាគ្រប់គ្រាន់ ។

ប្រការ ១២.- គណៈមេប្រយោគសម្រាប់ប្រឡងជ្រើសរើសសិស្សមេធាវី

អនុលោមតាមមាត្រា ៨ នៃអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី គណៈ-មេប្រយោគប្រឡងជ្រើសរើសសិស្សមេធាវីមានសមាសភាព ៩ (ប្រាំបួន) រូបដូចខាងក្រោម៖

- ប្រធានគណៈមេធាវី	ប្រធាន
- តំណាងក្រសួងយុត្តិធម៌ ១ (មួយ) រូប	អនុប្រធាន
- សមាជិកក្រុមប្រឹក្សាគណៈមេធាវី ៤ (បួន) រូប	សមាជិក
- នាយក **ម.ប.វ.ម.**	សមាជិក
- តំណាងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ១ (មួយ) រូប	សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប	សមាជិក

ប្រការ ១៣.- សិស្សមេធាវី

បេក្ខជនដែលបានប្រឡងជាប់ត្រូវបានឱ្យឈ្មោះថា "សិស្សមេធាវី" តាមសេចក្តីសម្រេចរបស់ប្រធានគណៈ-មេធាវី និងជាប្រធានគណៈមេប្រយោគ ផ្អែកតាមកំណត់ហេតុនៃលទ្ធផលប្រឡង ។

សិស្សមេធាវីត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈបឋមឱ្យបានពេញលេញតាមកម្មវិធីសិក្សាដែលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងរយៈពេលបណ្តុះបណ្តាល សិស្សមេធាវី នឹងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។

ប្រការ ១៤.- ការបង់ថ្លៃបណ្តុះបណ្តាល

សិស្សមេធាវីត្រូវបង់ថ្លៃបណ្តុះបណ្តាល ដែលកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី តាមសំណើរបស់ប្រធាន គណៈមេធាវី បន្ទាប់ពីទទួលបានយោបល់ពីទទួលបានយោបល់ពីនាយក **ម.ប.វ.ម.** ។

ជំពូកទី ៤
កម្មវិធីសិក្សា និងការបណ្តុះបណ្តាល

ប្រការ ១៥.- រយៈពេលសិក្សា

ការសិក្សានៅ **ម.ប.វ.ម.** មានរយៈពេល ១ (មួយ) ឆ្នាំ ដោយត្រូវបែងចែកជា ២ (ពីរ) ផ្នែក គឺការសិក្សាផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅមណ្ឌលច្បាប់ (Legal Clinic)។

ប្រការ ១៦.- កម្មវិធីសិក្សា និងគ្រូបណ្តុះបណ្តាល

ការអនុម័ត ឬការកែប្រែកម្មវិធីសិក្សា និងការជ្រើសរើសគ្រូបណ្តុះបណ្តាលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី តាមសំណើរបស់ប្រធានគណៈមេធាវី តាមការស្នើសុំរបស់នាយក **ម.ប.វ.ម.**។

នាយក **ម.ប.វ.ម.** ត្រូវរៀបចំគម្រោងកម្មវិធីសិក្សាទៅតាមស្ថានភាពវិវឌ្ឍន៍ជាក់ស្តែង ឆ្លើយតបទៅនឹងតម្រូវការក្នុងការអនុវត្តវិជ្ជាជីវៈនៅក្នុងសង្គម។

ប្រការ ១៧.- លក្ខណៈសម្បត្តិរបស់គ្រូបណ្តុះបណ្តាល

គ្រូបណ្តុះបណ្តាលសម្រាប់បង្រៀននៅ **ម.ប.វ.ម.** ត្រូវជ្រើសរើសដោយផ្អែកលើលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ (Master) ឡើងទៅ
- ត្រូវមានបទពិសោធន៍យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យច្បាប់ ឬវិស័យពាក់ព័ន្ធ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬបទវិន័យ ឬជាបទរដ្ឋបាល ដូចជាការលុបឈ្មោះការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ និង
- មិនធ្លាប់ក្ស័យធនផ្ទាល់ខ្លួន ដែលប្រកាសដោយតុលាការ។

ជំពូកទី ៥
បទវិន័យ

ប្រការ ១៨.- បទវិន័យរបស់សិស្សមេធាវី

សិស្សមេធាវីទាំងអស់ត្រូវគោរពវិន័យឱ្យបានល្អ ដោយមានអាកប្បកិរិយា និងសីលធម៌ល្អ សុភាពរាបសារ ស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងមករៀនឱ្យទៀងទាត់តាមពេលវេលា និងកាលវិភាគ ដែលកំណត់ដោយ **ម.ប.វ.ម.**។

បទវិន័យរបស់សិស្សមេធាវីត្រូវសម្រេចដោយប្រធានគណៈមេធាវី តាមសំណើរបស់នាយក **ម.ប.វ.ម.**។

ប្រការ ១៩.- ក្រុមប្រឹក្សាវិន័យ

ក្រុមប្រឹក្សាវិន័យអាចដាក់ទណ្ឌកម្មវិន័យលើសិស្សមេធាវីរូបណា ដែលបានប្រព្រឹត្តខុសនឹងបទបញ្ជាផ្ទៃក្នុងបទវិន័យរបស់សិស្សមេធាវី និងសេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ឬសេចក្តីសម្រេចរបស់ **ម.ប.វ.ម.**។

ប្រការ ២៣.- ទណ្ឌកម្មជាបទវិន័យដែលសម្រេចដោយក្រុមប្រឹក្សាវិន័យ

សិស្សមេធាវី ដែលបំពានធ្ងន់ធ្ងរ និងមិនរាងចាលលើបទបញ្ជាផ្ទៃក្នុង ឬបទវិន័យរបស់សិស្សមេធាវី ឬសេចក្តីសម្រេចផ្សេងទៀតរបស់គណៈមេធាវី ឬសេចក្តីសម្រេចរបស់ **ម.ប.វ.ម.** អាចត្រូវទទួលទណ្ឌកម្មជាបទវិន័យពីក្រុមប្រឹក្សាវិន័យ ដូចខាងក្រោម៖

- ឱ្យរៀនត្រួតថ្នាក់
- លុបឈ្មោះចេញពីបញ្ជីសិស្សមេធាវី។

ជំពូកទី ៦
ការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី

ប្រការ ២៤.- វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី

សិស្សមេធាវីដែលបានសិក្សាចប់តាមកម្មវិធី និងប្រឡងជាប់ជាស្ថាពរ ត្រូវទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។

ប្រការ ២៥.- នីតិវិធីនៃការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី

នីតិវិធីនៃការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវីតាមសំណើរបស់ប្រធានគណៈមេធាវី តាមការស្នើសុំរបស់នាយក **ម.ប.វ.ម.** ។

ប្រការ ២៦.- គណៈមេប្រយោគសម្រាប់ការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី

បញ្ញត្តិនៃប្រការ ១២ នៃបទបញ្ជាផ្ទៃក្នុងនេះ ត្រូវយកមកអនុវត្តចំពោះសមាសភាពនៃគណៈមេប្រយោគសម្រាប់ការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។

ជំពូកទី ៧
ហិរញ្ញវត្ថុនៃ ម.ប.វ.ម.

ប្រការ ២៧.- ប្រភពធនធានហិរញ្ញវត្ថុ

ម.ប.វ.ម. មានប្រភពធនធាន និងថវិកាដែលបានមកពី៖

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- ការចុះឈ្មោះរបស់បេក្ខជនប្រឡងចូលរៀនវិជ្ជាជីវៈមេធាវី។
- ចំណូលក្នុងការសុំចុះឈ្មោះចូលរៀនរបស់សិស្សមេធាវី
- ការបង់ថ្លៃបណ្តុះបណ្តាល សុក្រឹតការវិជ្ជាជីវៈមេធាវី និងការអប់រំបន្ត។
- ការចុះឈ្មោះរបស់មេធាវីកម្មសិក្សា ដែលត្រូវធ្វើសុក្រឹតការវិជ្ជាជីវៈមេធាវី
- ជំនួយ និងប្រាក់ឧបត្ថម្ភពីស្ថាប័នជាតិ អន្តរជាតិ និងសហគមន៍នានា។

ប្រការ ២៨.- មូលនិធិនៃ ម.ប.វ.ម.

មូលនិធិនៃ **ម.ប.វ.ម.** ត្រូវស្ថិតនៅក្នុងគណនីមួយដាច់ដោយឡែក កាន់កាប់ដោយគណៈមេធាវី។

ការបញ្ជាចំណាយរបស់ **ម.ប.វ.ម.** ត្រូវសម្រេចដោយនាយក **ម.ប.វ.ម.** ទៅតាមខ្ចង់ថវិកាប្រចាំឆ្នាំ ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី។

នាយក **ម.ប.វ.ម.** ត្រូវស្នើសុំបុរេប្រទាន និងធ្វើការទូទាត់ការចំណាយរបស់ **ម.ប.វ.ម.** រៀងរាល់ត្រីមាសទៅតាមខ្ចង់ថវិកាដែលបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ ២៩.- គម្រោងចំណាយ

គម្រោងចំណាយរបស់ **ម.ប.វ.ម.** ត្រូវបែងចែកជា ២ (ពីរ) ដាច់ដោយឡែកគឺ៖

- គម្រោងចំណាយរដ្ឋបាលរបស់ **ម.ប.វ.ម.** ដែលត្រូវចាប់គិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ជារៀងរាល់ឆ្នាំ។
- គម្រោងចំណាយលើការបណ្តុះបណ្តាលសិស្សមេធាវី ដែលត្រូវរៀបចំឡើងទៅតាមការកំណត់របស់ **ម.ប.វ.ម.** ផ្អែកតាមពេលវេលានៃការប្រឡងជ្រើសរើសឱ្យចូលរៀនវិជ្ជាជីវៈមេធាវី។

ម.ប.វ.ម. ត្រូវរៀបចំគម្រោងចំណាយរបស់ខ្លួន និងដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងអនុម័តឱ្យបានយ៉ាងហោចណាស់ ១ (មួយ) ខែ មុនពេលចាប់ផ្តើមអនុវត្ត។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

ប្រការ ៣០.- និរាករណ៍

បទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៤ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣១.- ការចូលជាធរមាន

បទបញ្ជាផ្ទៃក្នុងនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ ៣២.- ការអនុវត្ត

អគ្គលេខាធិការ អគ្គហេរញ្ញិក នាយក **ម.ប.វ.ម.** ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងនេះ តាមមុខការរៀងៗខ្លួន។

ប្រធាន

ចម្លងជូន :
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
-ដូចប្រការ ៣២
-ឯកសារ-កាលប្បវត្តិ

មេធាវី.ប៊ុន ហួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី ជា ទូនគា
២-មេធាវី កែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំន្ទ វិចិត្រ
៥-មេធាវី ចេង ម៉េងហាប់
៦-មេធាវី ជុំ ជុំនី
៧-មេធាវី លី ចំន្ទគុណា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិច សុខាចា
១០-មេធាវី ពេជ្រ សុរិយោ
១១-មេធាវី គង់ ធីលីន
១២-មេធាវី ឃុន ជានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុក ស៊ីជាន់ណា
១៥-មេធាវី ស្រ៊ី គីមឃួ
១៦-មេធាវី កុយ ឆាម
១៧-មេធាវី ឡុច ធីរិទ្ធ
១៨-មេធាវី គីម ខាសនា
១៩-មេធាវី សួស សាម៉ឿន
២០-មេធាវី ទូន មករា
២១-មេធាវី លឹម អេងតេង
២២-មេធាវី ហុង គីមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឆាយ ជាក់
២៥-មេធាវី សួន ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀន ចិន្តា

លេខ : ៤៩៤ /សសគម/១៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៤

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យអនុវត្តបទឥន្ទ័យរបស់សិស្សមេធាវី
ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០អនក្រ.បក ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៧
- បានឃើញសេចក្តីសម្រេចលេខ ២៣៦/សសគម/១៤ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
- យោងតាមសំណើរបស់នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១ .- គោលដៅ

សេចក្តីសម្រេចនេះ មានគោលដៅធានាការបណ្តុះបណ្តាលសិស្សមេធាវី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ហៅកាត់ថា (ម.ប.វ.ម) ប្រកបដោយសេចក្តីថ្លៃថ្នូរ កិត្តិយស សមត្ថភាព និងជំនាញវិជ្ជាជីវៈមេធាវី ដើម្បីចូលរួមបម្រើវិស័យយុត្តិធម៌ នៅក្នុងសង្គម។

សេចក្តីសម្រេចនេះ មានគោលដៅណែនាំស្តីពី ក្រមសីលធម៌ សិទ្ធិ វិន័យ និងការទទួលខុសត្រូវរបស់សិស្សមេធាវី ដែលកំពុងសិក្សានៅ ម.ប.វ.ម ដើម្បីធានាបាននូវការអភិវឌ្ឍ និងការបណ្តុះបណ្តាលនូវចំណេះដឹង ការស្រាវជ្រាវ ប្រកបដោយប្រសិទ្ធភាព។

ប្រការ ២ .- គោលចំណង

សេចក្តីសម្រេចនេះ មានគោលបំណងផ្តោតសំខាន់ ៖

-កំណត់អំពីវិធាន ទណ្ឌកម្ម វិន័យ និងលក្ខខណ្ឌនានា ព្រមទាំងបែបបទកម្មវិធីសិក្សានៅក្នុង ម.ប.វ.ម។

-ធានាលើកកម្ពស់វិន័យ សេចក្តីថ្លៃថ្នូរ ការគោរព សុចរិតភាព និងការទទួលខុសត្រូវក្នុងការសិក្សាស្រាវជ្រាវទាំងក្នុង និងក្រៅ ម.ប.វ.ម។

-ផ្តល់ការយល់ដឹងដល់សិស្សមេធាវី អំពីក្រមសីលធម៌ និងសិទ្ធិ ក្នុងការសិក្សាស្រាវជ្រាវ ដែលជាមូលដ្ឋាននៃការធានាគុណភាព និងភាពទទួលជោគជ័យក្នុងការសិក្សា។

-បង្កើត និងជម្រុញនូវបរិយាកាសសិក្សាប្រកបដោយការលើកទឹកចិត្ត និងទទួលបាននូវសេវាអប់រំនៅក្នុង ម.ប.វ.ម។

ជំពូកទី ២
សីលធម៌សិស្សមេធាវីក្នុងពេលសិក្សា

ប្រការ ៣ .- ការប្រកាន់ភ្ជាប់សីលធម៌

សីលធម៌សិស្សមេធាវី សំដៅដល់ការការពារមិនឱ្យសិស្សមេធាវីប្រព្រឹត្តបទល្មើស ក្នុងការសិក្សា ឬក្រៅម៉ោងសិក្សា ដូចជា ការបើក ឬការលួចចម្លងក្នុងពេលប្រឡង ការយកកិច្ចការរបស់អ្នកដទៃធ្វើជារបស់ខ្លួន ការក្លែងបន្លំព័ត៌មាន ការប្រកួតប្រជែងមិនស្មោះត្រង់ ការមិនយកចិត្តទុកដាក់ក្នុងការចូលរួមបំពេញកិច្ចការជាក្រុម ការ

ប្រើប្រាស់បណ្តាញអ៊ីនធើណែតនិងឧបករណ៍ អេឡិចត្រូនិចផ្ទុយពីការសិក្សាស្រាវជ្រាវ ការប្រើប្រាស់ឥទ្ធិពល ឬការគម្រាមកំហែងដល់សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងលទ្ធផលនៃការសិក្សារបស់សិស្សផ្សេងទៀត សកម្មភាពសិក្សាដទៃផ្សេងទៀតដែលផ្ទុយនឹងគោលនយោបាយរបស់ ម.ប.វ.ម និងការសូក និងការទទួលសំណូក ដើម្បីទទួលបានផលប្រយោជន៍ទាក់ទងទៅនឹងវិស័យអប់រំនៅក្នុង ម.ប.វ.ម ។

សិស្សមេធាវី ត្រូវគោរពវិន័យ និងត្រូវមានសីលធម៌ខ្ពស់ មានឫកពាថ្លៃថ្នូរ សុភាពរាបសារ មានសុជីវធម៌ក្នុងការទាក់ទងជាមួយថ្នាក់ដឹកនាំ មន្ត្រី ម.ប.វ.ម និងសាស្ត្រាចារ្យ ។

សិស្សមេធាវី ត្រូវគោរព ឱនលំទោន និងផ្តល់តម្លៃដល់ថ្នាក់ដឹកនាំ និងមន្ត្រី ម.ប.វ.ម ព្រមទាំងសាស្ត្រាចារ្យ ។

រយៈពេលនៃការបណ្តុះបណ្តាល សិស្សមេធាវីត្រូវដាក់ឱ្យនៅក្រោមអំណាចហ៊ានុក្រមរបស់នាយក ម.ប.វ.ម ។

រាល់ការស្នើសុំ និងការឆ្លើយឆ្លងជាឯកត្តភូត ឬសមូហភាពជាមួយស្ថាប័នខាងក្រៅណាមួយ សិស្សមេធាវីត្រូវធ្វើឡើងតាមរយៈនាយក ម.ប.វ.ម ។

សិស្សមេធាវី ត្រូវផ្តល់ព័តិមានជូន ម.ប.វ.ម ក្នុងករណីមានការផ្លាស់ប្តូរ អាសយដ្ឋាន អត្រានុកូលដ្ឋាន ស្ថានភាពគ្រួសារ លេខទូរស័ព្ទ អ៊ីម៉ែល ។

សិស្សមេធាវី ត្រូវជូនដំណឹងមក ម.ប.វ.ម ក្នុងករណីបានបាត់បង់ឬសម្គាល់ ឬស្លាកឈ្មោះ ។

សិស្សមេធាវី មិនត្រូវធ្វើសកម្មភាពនយោបាយនៅក្នុងបរិវេណ ម.ប.វ.ម ឡើយ ។

ប្រការ ៤ .- ការលួចចម្លង

ការលួចចម្លងស្នាដៃ មានន័យថា ជាការប្រើប្រាស់នូវព័តិមាន ពាក្យពេជន៍ ឃ្លា គំនិតដោយគ្មានការទទួលស្គាល់នូវប្រភពព័តិមានហើយរាប់បញ្ចូលផងដែរនូវការយកស្នាដៃរបស់អ្នកនិពន្ធណាមួយធ្វើជារបស់ខ្លួន ។

ការពិភាក្សា ការបើក ឬការលួចចម្លងក្នុងពេលប្រឡង ពាក់ព័ន្ធនឹងសកម្មភាពដោយចំហរ ឬលាក់បាំងនូវការធ្វើសកម្មភាពណាមួយ ត្រូវបានហាមឃាត់ដាច់ខាត ។

រាល់ឯកសារលួចចម្លងក្នុងពេលប្រឡង ត្រូវបានហាមឃាត់ មានដូចជា សម្ភារកំណត់ត្រា វត្ថុជំនួយ ឬឧបករណ៍អេឡិចត្រូនិចណាមួយផ្សេងទៀត ដែលសម្រួលដល់ការប្រឡង ។

ការពិភាក្សា ការបើក ឬលួចចម្លង រាប់បញ្ចូលផងដែរ នូវការចម្លងកិច្ចការប្រឡងរបស់សិស្សណាម្នាក់ទៀត ការប្រគល់កិច្ចការប្រឡងក្នុងថ្នាក់ដែលមានការរៀបចំទុកជាមុន ឱ្យអ្នកដទៃប្រឡងជំនួស ឬការបំពាននីតិវិធីរដ្ឋបាលប្រលង ត្រូវចាត់ទុកជាការប្រពឹត្តល្មើសនៅក្នុងនីតិវិធីប្រឡង និងក្នុងការសិក្សាផងដែរ ។

ប្រការ ៥ .- ការងារជាក្រុម

ការធ្វើការងារជាក្រុមមិនអស់លទ្ធភាព សំដៅដល់ការមិនចូលរួម ឬចូលរួមមិនពេញលេញក្នុងកិច្ចការស្រាវជ្រាវជាក្រុម ដែលផ្ទុយទៅនឹងគោលការណ៍នៃការផ្តល់ពិន្ទុស្មើគ្នានៅក្នុងក្រុមនីមួយៗ ហើយបើមានបណ្តឹងណាមួយពីសមាជិកក្រុមចោទប្រកាន់ថាសមាជិកដទៃទៀតមិនបានធ្វើការងារជាក្រុម ត្រូវទទួលបានពិន្ទុសូន្យ ។

ជំពូកទី ៣
ឯកសណ្ឋានសិស្សមេធាវី

ប្រការ ៦ .- ឯកសណ្ឋានសិស្សមេធាវី

សិស្សមេធាវីប្រុស និងសិស្សមេធាវីស្រី ត្រូវគោរព និងប្រកាន់ភ្ជាប់ជាដាច់ខាតនូវឯកសណ្ឋាន ដូចខាងក្រោម ៖

ឯកសណ្ឋានសិស្សមេធាវីប្រុស មានដូចជា ៖

-អាវកខុប ដៃខុប ដៃវែង ពណិសលាត និងក្រវ៉ាត់កពណិផ្កាកូឡាប

-ខោជើងវែង សម្រុងត្រីមភ្លែកគោល ពណិទឹកប៊ិចក្រម៉ៅ និងខ្សែក្រវ៉ាត់ពណិខ្មៅ

-ស្បែកជើងប៊ូចងខ្សែ លាតអត់ម៉ូត ពណិខ្មៅ

-ស្រោមជើងកវែង ពណិខ្មៅ

-កាត់សក់ខ្លីសមរម្យ ។

ឯកសណ្ឋានសិស្សមេធាវីស្រី មានដូចជា ៖

-អាវកខុប ដៃខុប ដៃវែង ពណិសលាត និងបូរចងជាក្រវ៉ាត់ក ពណិផ្កាកូឡាប

-សំពត់បត់ សម្រុងក្រោមជង្គង់ ១០ស.ម ពណិទឹកប៊ិចក្រម៉ៅ

-ស្បែកជើងអេសកាប៉ាង លាតអត់ម៉ូត ពណិខ្មៅ កែងកម្ពស់ពី ២ស.ម ទៅ៤ស.ម

-ចងសក់ស្អាតសមរម្យ ។

សិស្សមេធាវី ត្រូវពាក់ស្លាកសម្គាល់ខ្លួនជាប់ជានិច្ច នៅផ្នែកខាងស្តាំ។ សិស្សមេធាវីរូបណា ដែលមិនអនុវត្តតាមខ្លឹមសារនៃប្រការខាងលើនេះទេ មិនត្រូវបានអនុញ្ញាតឱ្យចូលរៀនឡើយ ។

ជំពូកទី ៤
សិទ្ធិរបស់សិស្សមេធាវី

ប្រការ ៧ .- សិទ្ធិរបស់សិស្សមេធាវី

សិទ្ធិរបស់សិស្សមេធាវី រួមមានដូចខាងក្រោម ៖

-សិទ្ធិទទួលបានការអប់រំល្អ

-សិទ្ធិទទួលបានសេរីភាព និងស្វ័យភាពក្នុងការសិក្សា

-សិទ្ធិចូលរួមក្នុងការងារនានារបស់ ម.ប.រ.ម

-សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

-សិទ្ធិសេរីភាពរួចផុតពីការរើសអើងភេទ និងការប្រែតប្រែនផ្លូវភេទ

-សិទ្ធិសុំការអនុញ្ញាតច្បាប់

-សិទ្ធិទទួលបាននូវការការពារស្មារដៃស្រាវជ្រាវ ។

ជំពូកទី ៥
ភាតព្វកិច្ចរបស់សិស្សមេធាវី

ប្រការ ៨ .- ភាតព្វកិច្ចរបស់សិស្សមេធាវី

សិស្សមេធាវី ត្រូវមានភាតព្វកិច្ចដូចខាងក្រោម ៖

-ត្រូវគោរពតាមបទបញ្ជា និងការណែនាំរបស់ ម.ប.វ.ម

-គោរពម៉ោងពេលសិក្សាដោយអនុវត្តតាមកាលវិភាគសិក្សា

-ត្រូវមានសម្ភារសិក្សាជាចាំបាច់ពេលចូលរៀននៅក្នុងថ្នាក់រៀន

-ត្រូវចូលរួមគ្រប់សកម្មភាពសិក្សា និងស្រាវជ្រាវនៅក្នុងថ្នាក់ ដំណើរទស្សនកិច្ចសិក្សា នៅតាមស្ថាប័ននានា ព្រមទាំងការអនុវត្តជាក់ស្តែងតាមការកំណត់ដោយ ម.ប.វ.ម

-មិនត្រូវស្រែកឡូឡា ឬប្រឡែងគ្នាលេងពេលម៉ោងសិក្សា ឬម៉ោងសម្រាក នៅក្នុងបន្ទប់រៀន និងនៅក្នុងបរិវេណ ម.ប.វ.ម

-មិនត្រូវប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទ លេងកម្មវិធីបណ្តាញសង្គមនានា ព្រមទាំងលេងល្បែងនៅក្នុងឧបករណ៍អេឡិចត្រូនិចផ្សេងៗ ដែលបង្កការរំខានដល់ការសិក្សា

-មិនត្រូវបង្ក ឬធ្វើឱ្យប៉ះពាល់ និងខូចខាតដល់ទ្រព្យសម្បត្តិរបស់ ម.ប.វ.ម

-មិនត្រូវបរិភោគអាហារនៅក្នុងបន្ទប់រៀន

-ត្រូវចូលរួមថែរក្សាអនាម័យឱ្យបានស្អាតជានិច្ច

-មិនត្រូវជក់បារី បរិភោគគ្រឿងស្រវឹង ឬគ្រឿងញៀននៅក្នុងបរិវេណ ម.ប.វ.ម

-មិនត្រូវប្រពឹត្តអំពើអសីលធម៌ ដែលពាក់ព័ន្ធទៅនឹងផ្លូវភេទ នៅក្នុងថ្នាក់រៀន និងក្នុងបរិវេណ ម.ប.វ.ម

-មិនត្រូវយកអាវុធជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងបរិវេណនៃ ម.ប.វ.ម ឡើយ ។

-មិនត្រូវវាយប្រហារតាមប្រព័ន្ធបណ្តាញសង្គម លើសាស្ត្រាចារ្យ និងមន្ត្រីថ្នាក់ដឹកនាំរបស់ ម.ប.វ.ម ។

ជំពូកទី ៦
ម៉ោងសិក្សា

ប្រការ ៩ .- ម៉ោងសិក្សា

សិស្សមេធាវី ត្រូវមានវត្តមានទៀងទាត់ក្នុងម៉ោងសិក្សាតាមកាលវិភាគរបស់ ម.ប.វ.ម ។ សិស្សមេធាវីត្រូវមានវត្តមានចូលរួមគោរពទង់ជាតិជារៀងរាល់ព្រឹក នៃថ្ងៃសិក្សា ដោយគិតចាប់ពីម៉ោង ៧:២០នាទីព្រឹក ជាចាំបាច់ ។ ចំពោះការខកខាន មិនបានគោរពទង់ជាតិរបស់សិស្សមេធាវីរូបណាមួយត្រូវបានចាត់ទុកថាអវត្តមាន ។

សិស្សមេធាវី ត្រូវចូលរៀនតាមការកំណត់ដូចខាងក្រោម ៖

-ពេលព្រឹកចាប់ពីម៉ោង ៨:00នាទី ដល់ម៉ោង ១១:00នាទី

-ពេលរសៀលចាប់ពីម៉ោង ១៤:00នាទី ដល់ម៉ោង ១៧:00នាទី

ចំពោះសិស្សមេធាវីរូបណាមួយ ដែលមកយឺត ១៥ (ដប់ប្រាំ)នាទី នៃម៉ោងចូលរៀនដូចមានកំណត់ក្នុងកាលវិភាគ និងដូចដែលបានរៀបរាប់ខាងលើ ត្រូវចាត់ទុកថាបានអវត្តមានសម្រាប់ម៉ោងសិក្សានោះ។

ជំពូកទី ៧
ការឈប់សម្រាកដោយមានច្បាប់

ប្រការ ១០ .- ការឈប់សម្រាកដោយមានច្បាប់

រាល់ការឈប់សម្រាកការសិក្សា ត្រូវតែសុំច្បាប់អនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុន ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់។ បែបបទនៃការសុំច្បាប់ ត្រូវមកសុំនៅការិយាល័យរដ្ឋបាលរបស់ ម.ប.វ.ម។

ពាក្យសុំច្បាប់ ត្រូវបញ្ជូនមកការិយាល័យរដ្ឋបាលយ៉ាងហោចណាស់ឱ្យបាន២ (ពីរ)ថ្ងៃ មុនថ្ងៃឈប់។

ពាក្យសុំច្បាប់ ត្រូវតែមានការឯកភាព និងយល់ព្រមពីនាយក ម.ប.វ.ម។

រាល់ការឈប់សម្រាកការសិក្សា ដោយមានច្បាប់អនុញ្ញាត មិនត្រូវឱ្យលើសពី ២0 (ម្ភៃ)ពេល ក្នុងមួយឆ្នាំសិក្សា។

ចំពោះការឈប់លើសពី២0 (ម្ភៃ)ពេល ឡើងទៅ គឺមិនត្រូវបានអនុញ្ញាតឡើយ។

មានតែបញ្ហាគ្រោះថ្នាក់ចរាចរណ៍ បញ្ហាធំដុំធ្ងន់ធ្ងរ និងប្រធានសក្តិប៉ុណ្ណោះ ដែលសិស្សមេធាវីអាចសុំច្បាប់តាមរយៈលិខិតយុត្តិកម្ម ដោយមានលិខិតភ្ជាប់មកជាមួយជាអាទិ៍បញ្ជាក់ ពីអាជ្ញាធរមានសមត្ថកិច្ច និងលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញ។ ក្នុងករណីជួបបញ្ហាខាងលើនេះ សិស្សមេធាវី ឬឪពុកម្តាយ ឬសាច់ញាតិ ត្រូវជូនដំណឹងជាបន្ទាន់មក ម.ប.វ.ម។

ជំពូកទី ៨
ការឈប់សម្រាកពិសេស

ប្រការ ១១ .- ការឈប់សម្រាកពិសេស

ការឈប់សម្រាកពិសេស អាចអនុញ្ញាតឱ្យសុំច្បាប់ឈប់ ក្នុងករណីមានមូលហេតុដូចខាងក្រោម៖

-កំជាប់ពាក្យផ្ទាល់ខ្លួន (១ថ្ងៃ)

-អាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន (៣ថ្ងៃ)

-កំជាប់ពាក្យ ឬអាពាហ៍ពិពាហ៍លោហិតខ្សែផ្ទាល់ ឬសាខាញាតិ (១ថ្ងៃ)

-ពិធីបុណ្យផ្សេងៗ ឬបុណ្យមរណភាព នៃញាតិលោហិតខ្សែផ្ទាល់ ឬញាតិពន្ធខ្សែផ្ទាល់ ឬសាខាញាតិថ្នាក់ទី២ (៣ថ្ងៃ)

-មានជម្ងឺធ្ងន់ធ្ងរដោយមានការបញ្ជាក់ពីវេជ្ជបណ្ឌិតរបស់មន្ទីរពេទ្យ (៣ថ្ងៃ)

-ទៅព្យាបាលជម្ងឺ ឬទៅពិនិត្យសុខភាពផ្ទាល់ខ្លួនតាមការបង្គាប់បញ្ជារបស់វេជ្ជបណ្ឌិត (៣ថ្ងៃ)

-ជូនញាតិលោហិតខ្សែផ្ទាល់ ឬញាតិពន្ធខ្សែផ្ទាល់ ឬសាខាញាតិថ្នាក់ទី៣ ទៅព្យាបាលជម្ងឺ ឬពិនិត្យសុខភាព (៣ថ្ងៃ)

-បញ្ហាគ្រោះថ្នាក់ចរាចរណ៍ធ្ងន់ធ្ងរ ដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច (៣ថ្ងៃ)

-ជូនសហព័ន្ធទៅសម្រាលបុត្រ (៣ថ្ងៃ)

-ការឈប់សម្រាកលំហែមាតុភាព ត្រូវបានអនុញ្ញាតឱ្យរយៈពេល ៦០(ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃសុំច្បាប់។

ចំពោះការឈប់សម្រាកដូចដែលបានរៀបរាប់ខាងលើ ប៉ះចំថ្ងៃប្រឡងមុខវិជ្ជាណាមួយនោះ ម.ប.វ.ម ត្រូវរៀបចំការប្រឡងដោយឡែកជាក្រោយ។

ជំពូកទី ៩
ការឈប់សម្រាកដោយគ្មានច្បាប់

ប្រការ ១២ .- ការឈប់សម្រាកដោយគ្មានច្បាប់

ការឈប់សម្រាកដោយគ្មានច្បាប់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយ។ ផ្ទុយទៅវិញ ក្នុងករណីដែលសិស្សមេធាវីរូបណាមួយប្រព្រឹត្តខុសនឹងបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះ ត្រូវទទួលទណ្ឌកម្មវិន័យ។

ការឈប់ដោយគ្មានច្បាប់អនុញ្ញាតចំនួន២ (ពីរ)ពេល ត្រូវបានដក១(មួយ)ពិន្ទុ លើខ្ពង់នៃពិន្ទុវិន័យ ដោយគណនាទៅតាមពេលវេលានៃការគោរពទង់ជាតិ ការសិក្សាវេនព្រឹក ១ (មួយ)ពេល និងការសិក្សាវេនរសៀល ១ (មួយ)ពេល។

ជំពូកទី ១០
ការប្រឡង ការកំណត់ពិន្ទុប្រឡង និងនិទ្ទេស

ប្រការ ១៣ .- គោលការណ៍ នៃការប្រឡងសិស្សមេធាវី

សិស្សមេធាវី ត្រូវចូលបន្ទប់ប្រឡងតាមពេលវេលា កំណត់ដោយ ម.ប.វ.ម។ ត្រូវមានការអនុញ្ញាតពីនាយក ម.ប.វ.ម ក្នុងករណីសិស្សមេធាវីរូបណា មកក្រោយ១៥ (ដប់ប្រាំ)នាទីនៃម៉ោងប្រឡង។

ការប្រឡងលើមុខវិជ្ជានីមួយៗ គឺចាប់ផ្តើម និងបញ្ចប់ក្នុងពេលវេលាស្មើគ្នា។ សិស្សមេធាវីរូបណាប្រគល់សន្លឹកកិច្ចការប្រឡងយឺត ត្រូវទទួលទណ្ឌកម្មវិន័យពីនាយក ម.ប.វ.ម។

មុនចូលបន្ទប់ប្រឡងសិស្សមេធាវី ត្រូវបង្ហាញកាតសម្គាល់សិស្សជូនអនុរក្ស នៃ ម.ប.វ.ម។ ករណីមិនបានយកមកត្រូវសរសេរលិខិតសុំអនុញ្ញាតប្រឡងពីនាយក ម.ប.វ.ម។

ពេលប្រឡងសិស្សមេធាវី ត្រូវអង្គុយតាមលេខតុ ដែលកំណត់ដោយអនុរក្ស ម.ប.វ.ម។

ប្រការ ១៤ .- វិន័យក្នុងពេលប្រឡងសិស្សមេធាវី

ការបើកឯកសារផ្សេងៗ មើលក្នុងពេលប្រឡង ត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតដោយសាស្ត្រាចារ្យនៃមុខវិជ្ជាប្រឡងនោះ។

សិស្សមេធាវី ត្រូវមានវិន័យក្នុងពេលប្រឡង ដោយមិនត្រូវជជែកគ្នាសួរគ្នា មិនត្រូវផ្លាស់ប្តូរសន្លឹកកិច្ចការគ្នា មិនត្រូវលួចចម្លងឯកសារ មិនត្រូវផ្លាស់កន្លែងគ្នាអង្គុយ មិនត្រូវយកឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទចូលបន្ទប់ប្រឡង។

ការប្រព្រឹត្តផ្ទុយ ត្រូវដកពិន្ទុចំនួន១ (មួយ)ពិន្ទុ ពីអនុរក្សនៃម.ប.វ.ម។ ក្នុងករណីមិនរាងចាលត្រូវដក ២ (ពីរ)ពិន្ទុ។

ប្រការ ១៥ .- ការកំណត់ពិន្ទុ

ពិន្ទុលើមុខវិជ្ជានីមួយៗ ត្រូវទទួលបានពិន្ទុ២0/២0 (ម្ភៃលើម្ភៃ)។ សិស្សមេធាវីរូបណា ដែលប្រឡងមិនបានពិន្ទុមធ្យមភាគនេះទេ ត្រូវចាត់ទុកថាធ្លាក់លើមុខវិជ្ជានោះ ហើយមិនអនុញ្ញាតឱ្យប្រលងសាជាថ្មីទេ។

ដោយឡែកសិស្សមេធាវីរូបណាមួយបានប្រឡងធ្លាក់ពិន្ទុមធ្យមភាគប្រចាំឆ្នាំ ត្រូវសម្រេចឱ្យរៀនត្រួតថ្នាក់ដោយក្រុមប្រឹក្សាវិន័យ។

ចំពោះសិស្សរៀនត្រួតថ្នាក់ ត្រូវបានអនុញ្ញាតឱ្យរៀនបន្តទៅជំនាន់បន្ទាប់ទៀត បានចំនួនតែម្តងគត់ ហើយត្រូវបង់ប្រាក់ថ្លៃសិក្សាតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

លទ្ធផលពិន្ទុប្រចាំឆ្នាំ មានន័យថា ជាពិន្ទុសរុបលើគ្រប់មុខវិជ្ជាទាំងអស់ ចែកនឹងចំនួនមុខវិជ្ជានីមួយ។

លទ្ធផលពិន្ទុប្រចាំជំនាន់ មានន័យថា ជាលទ្ធផលពិន្ទុប្រចាំឆ្នាំ បូកនឹងលទ្ធផលពិន្ទុប្រឡងបញ្ចប់ ចែកនឹងពីរ។

ប្រការ ១៦ .- ពិន្ទុវិន័យ

ត្រូវបានបង្កើតឱ្យមានពិន្ទុវិន័យ ២0/២0 (ម្ភៃលើម្ភៃ) បន្ថែមលើពិន្ទុនៃមុខវិជ្ជាសិក្សា។ ពិន្ទុវិន័យត្រូវរាប់បញ្ចូលពិន្ទុវិន័យវត្តមានគោរពទង់ជាតិ ពិន្ទុវិន័យវត្តមានក្នុងថ្នាក់ និងពិន្ទុវិន័យសីលធម៌។

ក្នុងករណី បើពិន្ទុវិន័យ ២0/២0 (ម្ភៃលើម្ភៃ) ត្រូវបានដកអស់ហើយ នោះត្រូវដកពិន្ទុសរុបប្រចាំឆ្នាំបន្តទៀត។

ប្រការ ១៧ .- និទ្ទេស

និទ្ទេសនៃមធ្យមភាគប្រចាំឆ្នាំនៃ ម.ប.វ.ម ចែកចេញជានិទ្ទេសដូចខាងក្រោម ៖

-មធ្យមភាគពិន្ទុក្រោម ១០	ត្រូវរៀនត្រួតថ្នាក់
-មធ្យមភាគពិន្ទុចាប់ពី ១០ ទៅ ១២.៩៩	និទ្ទេសមធ្យម
-មធ្យមភាគពិន្ទុចាប់ពី ១៣ ទៅ ១៤.៩៩	និទ្ទេសល្អបង្គួរ
-មធ្យមភាគពិន្ទុចាប់ពី ១៥ ទៅ ១៦.៩៩	និទ្ទេសល្អ
-មធ្យមភាគពិន្ទុចាប់ពី ១៧ ទៅ ១៨.៩៩	និទ្ទេសល្អណាស់
-មធ្យមភាគពិន្ទុចាប់ពី ១៩ ទៅ ២០	និទ្ទេសល្អប្រសើរ

ជំពូកទី ១១
ក្រុមប្រឹក្សាវិន័យ

ប្រការ ១៨ .- សមាសភាពក្រុមប្រឹក្សាវិន័យ

សមាសភាពនៃក្រុមប្រឹក្សាវិន័យ ត្រូវតែងតាំងដោយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំពីនាយក ម.ប.វ.ម ដោយមានសមាសភាពដូចខាងក្រោម ៖

-ប្រធានគណៈមេធាវី	ជាប្រធាន
-នាយក ម.ប.វ.ម	ជាអនុប្រធាន
-សាស្ត្រាចារ្យ០៣ (បី)រូប ដែលមានអតីតភាពបង្រៀនយូរជាងគេនៅ ម.ប.វ.ម	ជាសមាជិក

ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍៖

-ប្រធានក្រុមប្រឹក្សាវិន័យ ត្រូវជំនួសដោយសមាជិកក្រុមប្រឹក្សាគណៈមេធាវី ដែលមានវ័យចំណាស់ជាងគេ

-អនុប្រធានក្រុមប្រឹក្សាវិន័យ ត្រូវជំនួសដោយអគ្គលខាធិការនៃ ម.ប.វ.ម

-សមាជិកក្រុមប្រឹក្សាវិន័យ ត្រូវជំនួសដោយសាស្ត្រាចារ្យផ្សេងទៀត ដែលត្រូវបានតែងតាំងដោយប្រធានគណៈមេធាវី តាមការស្នើសុំពីនាយក ម.ប.វ.ម។

ក្រុមប្រឹក្សាវិន័យ អាចប្រជុំដាក់ទណ្ឌកម្មវិន័យ បានលុះត្រាតែមានវត្តមានសមាជិកចូលរួមយ៉ាងតិច ៣(បី)រូប។ រាល់ការប្រជុំត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាវិន័យ។

ប្រធានក្រុមប្រឹក្សាវិន័យជាអ្នកកោះប្រជុំ តាមការស្នើសុំរបស់នាយក ម.ប.វ.ម។

នាយក ម.ប.វ.ម មានសិទ្ធិដាក់ទណ្ឌកម្មវិន័យលើសិស្សមេធាវីរូបណាមួយ ដែលមិនគោរពបទវិន័យរបស់ ម.ប.វ.ម។

ជំពូកទី ១២
ទណ្ឌកម្មវិន័យ

ប្រការ ១៩ .- ទណ្ឌកម្មវិន័យដាក់ដោយនាយក ម.ប.វ.ម

ប្រភេទទណ្ឌកម្មវិន័យ ដែលត្រូវបានដាក់ដោយនាយក ម.ប.វ.ម ត្រូវបានចែកចេញជា៣ (បី) ថ្នាក់ រួមមានដូចខាងក្រោម ៖

-ថ្នាក់ទី១ : ធ្វើការណែនាំ និងស្តីបន្ទោស ដោយឱ្យធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ

-ថ្នាក់ទី២ : ធ្វើការព្រមាន និងដកពិន្ទុពី ២ (ពីរ)ពិន្ទុ រហូតដល់ ៤ (បួន)ពិន្ទុ ដោយឱ្យធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ

-ថ្នាក់ទី៣: ផ្អាកការសិក្សា ១ (មួយ)ថ្ងៃ និងដក ៦ (ប្រាំមួយ)ពិន្ទុ ដោយឱ្យធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។

ប្រការ ២០ .- ទណ្ឌកម្មវិន័យដាក់ដោយក្រុមប្រឹក្សាវិន័យ

ប្រភេទទណ្ឌកម្មវិន័យ ដែលត្រូវបានដាក់ដោយក្រុមប្រឹក្សាវិន័យ ត្រូវបានចែកចេញជា ២ (ពីរ) ថ្នាក់រួមមានដូចខាងក្រោម ៖

-ថ្នាក់ទី១ : សម្រេចឱ្យរៀនត្រួតថ្នាក់

-ថ្នាក់ទី២ : លុបឈ្មោះចេញពី ម.ប.វ.ម

ប្រការ ២១ .- ភ្ជុំ

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ អាចយកជាការបាន លុះត្រាតែមានសំឡេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាវិន័យ មានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា។

ជំពូកទី ១៣
អវសានប្បញ្ញត្តិ

ប្រការ ២២ .- និរាករណ៍ និងអនុភាពនៃបទប្បញ្ញត្តិ

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៣ .- ការអនុវត្តសេចក្តីសម្រេច

នាយក អគ្គលេខាធិការ ប្រធានមណ្ឌលច្បាប់ ប្រធានការិយាល័យសិក្សា សាស្ត្រាចារ្យមណ្ឌលច្បាប់ បុគ្គលិក សិក្សាទាំងអស់នៃ ម.ប.រ.ម ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃដែលចុះហត្ថលេខានេះតទៅ ៕

ប្រធានគណៈមេធាវី



មេធាវី.ប៊ុន-ហួន

បានយកសេចក្តីគោរពជម្រាបជូនលោកប្រធានគណៈមេធាវី

ដើម្បីស្នើសុំហត្ថលេខា

នាយកម.ប.រ.ម



មេធាវី យឹម សារី

ចម្លងជូន :

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

-ដូចប្រការ ២៣

-ឯកសារ-កាលប្បវត្តិ

ក្រុមការងាររៀបចំចងក្រង
សេចក្តីសម្រេចមានលក្ខណៈបន្ទាន់របស់គណៈមេជាវី

១. ឯកឧត្តម	លី ច័ន្ទតុលា	ប្រធានគណៈមេជាវី
២. ឯកឧត្តម	លីវ សុវណ្ណា	អគ្គលេខាធិការគណៈមេជាវី
៣. លោកមេជាវី	ស្វង់ សុផល	សមាជិកក្រុមប្រឹក្សាគណៈមេជាវី
៤. លោកមេជាវី	ច៉ា ច័ន្ទតា	ជាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេជាវី
៥. លោកមេជាវី	អាន សុវឌ្ឍនា	អគ្គលេខាធិការរងគណៈមេជាវី
៦. លោកមេជាវី	ភ័ន់ ចាន់ ពៅជាភ័	អគ្គលេខាធិការនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេជាវី
៧. លោកស្រីមេជាវី	នេត បូផល	ប្រធានជាយកដ្ឋានស្រាវជ្រាវ ចោះពុម្ព និងផ្សព្វផ្សាយ
៨. លោកស្រីមេជាវី	ម៉ី ឧសភា	ប្រធានជាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល
៩. លោកមេជាវី	តឹម រ័ត្នណារ៉ុង	ប្រធានជាយកដ្ឋានការពារក្តីជូនជនក្រីក្រ
១០. លោកមេជាវី	យូ លីមហួត	ប្រធានជាយកដ្ឋានអធិការកិច្ច
១១. លោកមេជាវី	ស្រ៊ុន ជីវិទ្ធ	ប្រធានជាយកដ្ឋានចំណាក់ចំនង សាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ
១២. កញ្ញា	ស៊ូ ភ័ណី	ប្រធានជាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១៣. កញ្ញាមេជាវី	ឈុំ មុនីសុជាតា	អនុប្រធានជាយកដ្ឋានចំណាក់ចំនង សាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ
១៤. លោក	ម៉ន សំណាង	អនុប្រធានជាយកដ្ឋានស្រាវជ្រាវ ចោះពុម្ព និងផ្សព្វផ្សាយ
១៥. លោក	លី ពន្ធី	ប្រធានការិ.ព្រឹត្តបត្រ និងចោះពុម្ព
១៦. លោក	ខៀវ ជាភ័	ប្រធានការិ.ស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់
១៧. កញ្ញាមេជាវី	ឃ្វី ជាលីន	ជំនួយការនៃជាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល
១៨. កញ្ញា	ជាន សុភា	លេខាធិការព័ត៌មាននៃជាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល
១៩. កញ្ញា	ម៉ែត អ៊ាងលី	ជំនួយការអគ្គលេខាធិការដ្ឋានគណៈមេជាវីនៃព្រះរាជាណាចក្រកម្ពុជា
២០. លោក	អ៊ុន សៀងហៃ	បុគ្គលិកនៃជាយកដ្ឋានស្រាវជ្រាវ ចោះពុម្ព និងផ្សព្វផ្សាយ
២១. កញ្ញា	ញ៉ែ លីមហ័ន	បុគ្គលិកនៃជាយកដ្ឋានស្រាវជ្រាវ ចោះពុម្ព និងផ្សព្វផ្សាយ

នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

បោះពុម្ពលើកទី១ (ឆ្នាំ២០២៣)

រក្សាសិទ្ធិ © ខែកញ្ញា ឆ្នាំ២០២៣
គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា